# ធម្មឃោស





# ព្រះភិក្ខុពនេចរ

## ភាគ ទី៣

បកប្រែជាខេមរភាសាដោយដូនជី
ចំរើន ចារូន

គេហដ្ឋាន អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ
ក្រុងម៉ុងរេអាល - កេបិក - កាណាដា
ព.ស. ២៥៦០ - គ.ស. ២០១៧

ព្រះភិក្ខុ **ធម្មឃោស**, លោកជាអតីតនិស្សិតខាង «គីមីវិទ្យា» បានអាហាររូបករណ៍ទៅសិក្សានៅប្រទេសអង់គ្លេសនាទីក្រុង ឡុនដុន ( London ), ដោយលោកធ្លាប់បានឆ្លងកាត់បទពិសោធន៍មិនល្អ កាលលោកបួសមុខភ្លើងចំនួនពីរអាទិត្យនៅវត្តក្បែរផ្ទះមក លោកក៏អស់សទ្ធាទៅលើព្រះពុទ្ធសាសនារលីងពីសន្តានចិត្តរបស់លោក លែងគិត លែងខ្វល់ខ្វាយពីព្រះពុទ្ធសាសនា . . .

ថ្ងៃមួយមិត្តរបស់លោក, ចន វិល្លាម ( John William ) បានសាកសួរនូវសំណួរមួយថា ៖ **ឯងជាពុទ្ធបរិស័ទមួយរូបដែរ យើងចង់ដឹងថា តើគោលបំណងនិងសេចក្តីប្រាថ្នាខ្ពស់បំផុតក្នុងលទ្ធិសាសនារបស់ឯងគឺស្អី** ?. . .

មិនមានពេលណាក្នុងជីវិតរបស់លោកដែលលោកនឹកអៀនខ្មាស តូចចិត្តស្តាយហើយខឹងក្តៅចិត្តនឹងខ្លួនឯងស្មើនឹងពេលនោះទេ នេះហើយគឺជាចំណុចដំបូងនៃជីវិតថ្មីរបស់លោក របូតតាំងចិត្តថានឹងសូមបព្វជានៅពេលត្រឡប់មកមាតុប្រទេសវិញ . . .



ប្រែពីភាសាថៃមកជាខេមរភាសាដោយលោកយាយ **ចំរើន ចារូន** ។ សព្វថ្ងៃនេះលោកយាយរស់នៅប្រទេសបារាំង លោកមានជន្មាយុ ៨៤ ឆ្នាំហើយ ។

ក្រៅពីសមិទ្ធិផ្សេងៗ លោកយាយបានបោះពុម្ព ចម្លងសារឡើងវិញនូវសៀវភៅព្រះធម៌ ដែលជាស្នាដៃរបស់អស់លោកអ្នកប្រាជ្ញពីបុរាណ ចែកចាយជាធម្មទានជាច្រើនរយពាន់ក្បាល ។

ម្យ៉ាងវិញទៀត ដោយសេចក្តីព្យាយាមនិងវីរៈដ៏ខ្ពង់ខ្ពស់របស់លោកយាយ លោកបានបកប្រែសៀវភៅមួយចំនួនពីភាសាថៃមកជាខេមរភាសា ជាពិសេសគឺសៀវភៅដែលអស់-លោកអ្នកកំពុងតែមាននៅក្នុងដៃនេះឯង . . .

ដោយ វ. ភិរក្ស

**សម្រាប់ចែកជាធម្មទាន**

ព្រះភិក្ខុ ធម្មឃោស

# រឿង ព្រះភិក្ខុពនេចរ ភាគ ៣

* បកប្រែជាខេមរភាសាដោយ

ដូនជី សុភចម ចំរើន ចារូន (ចារុវណ្ណា)

* កម្រងកំណាព្យដោយ

មុិញ សាវ៉ាន / ហុិម ឆាន់

* ចម្លងអត្ថបទ និងរចនាដោយ

វ៉ាត តិរក្ស / ធឹម អរុណី


* ផ្សព្វផ្សាយដោយ

គេហដ្ឋាន អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ

ក្រុងម៉ុងរេអាល - កេបិក - កាណាដា

ព.ស. ២៥៦០ - គ.ស. ២០១៧


សម្រាប់ចែកជាធម្មទាន

# សៀវភៅចាស់ដែលបានចម្លងជាថ្មី ៖

១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត
២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប ( វ៉ាត ភិរក្ស ) ថ្មី
៣. ប្រស្នា គិហិប្រតិបត្តិពិស្តារ ( ឈឹម ទូច, សុង ស៊ីវ )
៤. ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )
៥. អានាបាណស្សតិកម្មដ្ឋាន វិបស្សនាបញ្ញាធម្មបរិយាយ ( គង់ ឌឹប )
៦. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, ភិក្ខុ សាន សុជា )
៧. ជីវិតកថា ( ម៉ិញ សាវ៉ាន ) ថ្មី
៨. ធម្មប្រទីប ( ប្រជុំកងធម៌ យិន វន់ )
៩. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )
១០. រឿង នគរកាយ ( ចាប ពិន )
១១. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )
១២. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )
១៣. ត្រៃកូដធម៌ ( សុង ស៊ីវ )
១៤. ឱវាទបាតិមោក្ខ ( ចាប ពិន )
១៥. កម្រងកំណាព្យ ( ហ៊ុម ឆាន់ ) ថ្មី
១៦. ឧបនីយតិសូត្រ ( ព្រះមហាវិរិយបណ្ឌិតោ ប៉ាង ខាត់ )
១៧. ធម្មទ្វេស ៤ យ៉ាង ( ម៉ិញ សាវ៉ាន ) ថ្មី
១៨. ធម៌នមស្ការសម្រាប់យុវវ័យ Khmer – Français ( វ៉ាត ភិរក្ស ) ថ្មី
១៩. ធម៌នមស្ការសម្រាប់យុវវ័យ Khmer – Anglais ( វ៉ាត ភិរក្ស ) ថ្មី
២០. លោកនីតិបករណ៍ ( ព្រះ អ៊ុក ជា វជិរញ្ញាណាភយវង្ស )
២១. អធិប្បាយមង្គលសូត្រ ( ព្រះវិន័យធរ អនុគណ ឯក ញឹម ធម្មិស្សរោ )
២២. កម្រងកំណាព្យ ភាគទី ២ ( ហ៊ុម ឆាន់ ) ថ្មី
២៣. ព្រះបាឡាត់ឃោសនាគ ហែម ចៀវ (គង់ សម្ភារ)
២៤. ចំណងដៃឆ្នាំថ្មី( ម៉ិញ សាវ៉ាន ) ថ្មី
២៥. ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាសង្ខេប (សម្តេចព្រះពោធិវង្ស ហួត តាត)
២៦. ឱវាទ ៤ «ខ» របស់លោក លៀវ ហ្វាន (បកប្រែដោយលោកយាយ ចំរើន ចារូន)
២៧. គុណមាតាបិតា ( ម៉ិញ សាវ៉ាន ) ថ្មី
២៨. ទស្សនៈសម្តេចព្រះសង្ឃរាជ ជួន ណាត (គង់ សម្ភារ )
២៩. អភិធម្មបរមត្ថសង្ខេប (ព្រះគ្រូ. យ៉ាង ផាន់ និង ព្រះមហា. អ៊ុម ប៊ុណ្ណ)
៣០. កម្រងកំណាព្យ ភាគទី ៣( ហ៊ុម ឆាន់ ) ថ្មី
៣១. រឿង ព្រះភិក្ខុពនេចរ ភាគ ២ ( ធម្មឃោស - ចំរើន ចារូន )
៣២. អ្នករូតវាំងននសង្គម ( បណ្ឌិត កែម ឡី )

# អារម្ភកថា...

ខ្ញុំសូមអភ័យទោសចំពោះធម្មមិត្តទាំងអស់ ការដែលយឺតយ៉ាវក្នុងការបោះពុម្ពសៀវភៅនេះ តែទោះបីយ៉ាងណាក៏បានសម្រេចសមដូចពាក្យថា "មកយឺត ជាជាងមិនមក" ។

ខ្ញុំត្រេកអរណាស់ដែលធម្មមិត្តខ្លះ ក្រោយពីអានភាគទី២ហើយ ដក់ចិត្តស្ថិតអារម្មណ៍ ខ្លះសួររកសំណៅ ឬជា PDF យកទៅអានសិនក៏មាន ជាពិសេសក៏គង់មិនភ្លេចនូវកំណាព្យដ៏ពីរោះរណ្ដំស្នាដៃលោកបង **មុំញ សាវ៉ាន**, **ហ៊ុម ឆាន់** និងសុភាសិតដែលបង្កប់ទៅដោយទ្រឹស្ដី ធម៌អាថ៌បន្ថែមនៅឈុតនីមួយៗទុកគ្រាន់ដាស់តឿនស្មារតីឬជាគតិ ។

នៅក្នុងភាគទី ៣ ឬភាគបញ្ចប់នេះ ក៏មិនខុសពីភាគទី ២ ទេ គឺអមទៅដោយកម្រងកំណាព្យជាមួយសាច់រឿងមួយវគ្គៗដូចគ្នា ខ្ញុំសង្ឃឹមថា ព្រះភិក្ខុពនេចរ ភាគ ៣ នេះ ក៏នឹងបានទទួលនូវការពេញចិត្តពេញថ្លើមដូចជាភាគទី២ដែរ ។

ទីបំផុត ខ្ញុំបាទសូមគោរពវន្ទាម្ដងទៀតចំពោះវីរភាពដ៏ឧត្តុង្គឧត្តមរបស់លោកយាយ **ចំរើន ចារូន** ដែលលោកបានខិតខំចំណាយពេលវេលា និងខិតខំបកប្រែរឿងនេះពីភាសាថៃមកជាខេមរភាសា ។

ហើយខ្ញុំព្រះករុណា ក៏សូមអរព្រះគុណជាពិសេសចំពោះព្រះតេជព្រះគុណ **ធឹខ ធីម** (**ចន្ទត្ថេរ**) ព្រះគ្រូចៅអធិការវត្តធម្មិការាម (ក្រុងប៉ុងពេអាល), ព្រះតេជព្រះគុណ **សុំ ប៊ុនធឿម**

(**សុវណ្ណត្ថេរោ**) *វត្តពុទ្ធសុទ្ធារាម (ក្រុងប៉ុងអេអាល) ដែល ព្រះតេជព្រះគុណ បានប្រឹងប្រែងឆ្លៀតពិនិត្យអត្ថបទ ផ្តល់យោបល់ បន្ថែមបន្ថយ ដែលធ្វើឲ្យសៀវភៅនេះចប់ដោយបរិបូរណ៍ ។*

*ហើយក៏មិនភ្លេចលោកបងទាំងពីរ* **ម៉ិញ សាវ៉ាន** *លោកបង* **ហ៊ិម ឆាន់** *ដែលលោកបានខិតខំ ស្ទៀងផ្ទាត់នូវអក្ខរាវិរុទ្ធ បន្ថែមបន្ថយពាក្យពេចន៍ និងជាពិសេសកំណាព្យអ៊ីង ខ្លី ធ្វើឲ្យសៀវភៅនេះរឹងរឹតតែមានលក្ខណៈប្រសើរជាពិសេសទៅទៀត និងអ្នកស្រី* **ធឹម អរុណី** *ដែលបានចំណាយពេលវេលាសរសេរចម្លងសៀវភៅនេះជាមួយនឹងខ្ញុំ ។*

*ដំឡូវសៀវភៅព្រះកិត្តុពនេចរភាគបញ្ចប់បានធ្លាក់ដល់ដៃធម្មមិត្តទាំងអស់ហើយ ខ្ញុំមានសេចក្តីរីករាយតតឧបមា ព្រោះកិច្ចការបានសម្រេចចប់សព្វគ្រប់ ។*

*ដោយអំណាចផលានិសង្ស ដែលបានកើតឡើងអំពីការព្យាយាម និងការជ្រះថ្លារបស់ពុទ្ធសាសនិកក្នុងការធ្វើសៀវភៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទសូមឧទ្ទិសប្រគេន ជូនចំពោះមានមាតាបិតា គ្រូឧបជ្ឈាយាចារ្យ លោកអ្នកប្រាជ្ញគតីបុព្វការីជនទាំងឡាយ ព្រមទាំងញាតិកាទាំងឡាយ រួមទាំងសត្តនិកាយក្នុងសកលពិភពនេះ សូមឲ្យបានទទួលនូវភាពក្សេមក្សាន្ត សន្តិភាព ផុតចាកវិបត្តិភ័យពៀរវេរាទាំងពួង ។*

*ក្រុងប៉ុងអេអាល,ថ្ងៃសុក្រ ទី២០ ខែមករា គ.ស.២០១៧*

*អ្នកសរសេរចម្លង*

**វ៉ាត គិរត្ន**

# អារម្ភបទព្រះភិក្ខុពនេចរ ភាគ ៣

បទពាក្យ៧

រឿងព្រះភិក្ខុពនេចរ សាទរស្មោះសរផ្ទង់ហត្ថា
បន្ទន់កាយ ចិត្ត និងវាចា ដល់ត្រៃរតនាម្លប់ភពត្រៃ ។
វន្នាថេរានុថេរៈ ដោយក្ដីស្មោះស្ម័គ្រចិត្តភក្ដី
គោរពធម្មមិត្តជិតឆ្ងាយក្ដី ដោយភាពមេត្រីនិងរាប់អាន ។
ទី ២ លាទៅនៅសន្យា ពោលថាមិនយារយូរប៉ុន្មាន
ភាគ ៣ សួស្ដីបង្ហាញប្រាណ ជូនញាតិសន្ដានអានបន្ត ។
ឥឡូវសមស្របកបបំណង សូមមិត្តប្អូនបងរួមត្រេកអរ
ភាគ ៣ ភិក្ខុពនេចរ ជូនរឿងកំដរ ត សេចក្ដី ។
បើមានរឿងល្អកើតមាន ពីការស្ដាប់អានភាគទី ៣
សូមបុណ្យបានដល់បុព្វការី បណ្ឌិត គរី គ្រូ អាចារ្យ ។
ជូនបុណ្យដល់គ្រប់និករសត្វ ទាំងញាតិក្នុងវដ្ដសង្សារ
បានរំដោះទុក្ខសោកនានា ដោយធម្មនាវាយានអមតៈ ។
សូមឲ្យឱវាទព្រះជាម្ចាស់ បានជាស្គរដាស់ទូងពញ្ញាក់
ឲ្យសត្វនិករក្រោកឈរភ្ញាក់ ឆ្លងផុតអន្ទាក់មារព័ន្ធន៍[១] ៕

ដោយឧបាសក ហ៊ិម ឆាង

(១) ចំណងមារ , ចំណងកិលេស

# សមាសភាពចូលរួម

(ពិនិត្យខ្លឹមសារ, អក្ខរាវិរុទ្ធ និងរចនាផ្សេងៗ)

០១. ព្រះតេជព្រះគុណ **ធឹង ធីម** (**ចន្ទត្ថេរ**)
ព្រះចៅអធិការវត្ត **ធម្មិការាម** (ក្រុងប៉ៃលិន)

០២. ព្រះតេជព្រះគុណ **សុំ ប៊ុនធឿម** (**សុវណ្ណត្ថេរោ**)
**វត្តពុទ្ធសុទ្ធារាម**(ក្រុងប៉ៃលិន-គេបិត-ការណាដា)

០៣. ព្រះតេជព្រះគុណ **មហា ស៊ឹម ផាន់ណា**
**វត្តខ្មែរការណាដា**(ក្រុងប៉ៃលិន-គេបិត-ការណាដា)

០៤. លោកយាយ **សុភចម ចំរើន ចារុន** (**ចារុវណ្ណា**)

០៥. ឧបាសក **ម៉ិញ សាវ៉ាន**

០៦. ឧបាសក **ហ៊ិម ឆាន់**

០៧. លោក **វ៉ាត តិរត្ន**

០៨. អ្នកស្រី **ធឹម អរុណី** (Aruny Smiley)

០៩. លោក **វ៉ាត សុគន្ធ**

១០. លោក **វ៉ាត តារា** (ទីៗ)

១១. លោក **វ៉ាត ម៉ូលីវណ្ណា**

១២. កញ្ញា **វ៉ាត វារីយា**

# មាតិការឿង


០១. អារម្ភកថា .................................... III

០២. អារម្ភកថា ឧបាសក ហ៊ុម សាន់ .......... V

០២. សមាសភាពចូលរួម ............................ VI

០៣. មាតិការឿង .................................... VII

០៤. ពាក្យប្រារព្ធ (ដូនជី ចារូន) .................... IX

០៥. ធម្មកថា ដោយព្រះធម្មឃោស .......... X

០៦. កំពូលនៃសេចក្តីខ្លាច ............................ ១៣

០៧. លោក “គូ” មានពិត ............................ ២៧

០៨. ផ្ទះខ្មោចនៅ .................................... ៣៩

០៩. ផ្ទះសំណាក់លោក .............................. ៥១

១០. មានបុណ្យល្អ ជាងមានប្រាក់ .......... ៦៣

១១. សំបកក្រៅ សាច់ក្នុងព្រះសាសនា .......... ៧៥

១២. ការដឹង និង ការឃើញ នូវអរិយសច្ច ........ ៨៧

១៣. ស្បៀងជីវិត .................................... ៩៩

១៤. ពន្លឺខាងក្នុង ...................................... ១០៩

១៥. គុណសម្បត្តិរបស់សង្ឃ ...................... ១២១

១៦. បញ្ញា សីល សមាធិ .............................. ១៣៣

១៧. មនុស្សខ្លាចសាសនា .............................. ១៤៥

១៨. ចំណុចចាប់ផ្តើមជីវិតថ្មី ...................... ១៥៧

១៩. តណ្ហា ជាអ្នកធ្វើទារុណ .................... ១៧១

២០. ភិក្ខុចម្លែក ........................................ ១៨៣

២១. បន្ទប់ងងឹតទាំង ៣ ................................ ១៩៥

២២. សទ្ធម្មប្បតិរូប ព្រះធម៌បន្លំ ...................... ២០៧

២៣. ទីណាមានចំណង់ ទីនោះមានទុក្ខ ........... ២២១

២៤. កុំរត់តាមសេចក្ដីសុខ ................................ ២៣៣

២៥. ស្រែស្រូវ - ស្រែបុណ្យ ........................ ២៤៧

២៦. សេចក្ដីស្រឡាញ់ និងសេចក្ដីអាណិត .......... ២៦១

២៧. ពុទ្ធបរិស័ទមានសទ្ធា ................................ ២៧៩

២៨. ផ្សេងៗពីគេហដ្ឋាន ........................ ២៨៧




# ពាក្យប្រារព្ធ

*(ដូនជី **ចំរើន ចារូន**)*

សៀវភៅនេះ ខ្ញុំបានអានចប់ច្រើនដងហើយ ឃើញថាមានន័យ មានប្រយោជន៍ល្អណាស់ ទើបព្យាយាមបកប្រែពីភាសាថៃមកជាខេមរភាសា ដោយមានសំណូមពរអំពីលោក **ជី ចំរុង** ផង កាលគាត់នៅមានជីវិតនៅឡើយ ហើយគាត់បានប្រគល់សៀវភៅនេះមកឲ្យខ្ញុំ ដោយផ្ញើសៀវភៅនេះតាមប៉ៃ **ស៊ុន គុយអេង** យកពីប្រទេសកាណាដាមកស្រុកបារាំង ៗ បានបកប្រែចប់ហើយ ក៏ប្រគល់សំណៅទៅឲ្យក្មួយ **វ៉ាត តិរត្ន** នៅទីក្រុងម៉ុងរេអាល - កេបិក - កាណាដា សរសេរចម្លងចងក្រងជាសៀវភៅឡើងវិញ ៗ

ហេតុនេះបើមានពាក្យ ឃ្លាណាមិនសមរម្យ សូមលោកអ្នកអានទាំងឡាយ មេត្តាអភ័យទោស និងសូមជួយកែឲ្យទានផង សូមអរគុណទុកជាមុន ៗ

ប្រែចប់នៅក្រុងម៉ុងរេអាល, ខែតុលា គ.ស.២០១៣

ដោយដូនជី **ចំរើន ចារូន** គ្រួសារ **សុភចម**

ក្នុងបាលី **ចារុវណ្ណា**

# ធម្មកថា

(ដោយ **ធម្មឃោស**)

និទានដែលបន្ទាប់នូវព្រះធម៌ ពិតជាមានខ្លឹមសារយ៉ាង វិសេសវិសាល ។ មានពេលមួយ កាលអាត្មាទៅចាំវស្សា នៅវត្តនាជើងភ្នំសុថេប ស្រុកឆៀងម៉ៃ មានញោម **ចំណាន** បានបវារណាសូមធ្វើជាញោមឧបដ្ឋាក[១] ក្នុងរយៈពេលមួយ វស្សានេះ ដោយគាត់មានសេចក្តីជ្រះថ្លាក្នុងជីវិតរបស់អាត្មា នេះ ហើយគាត់បានប្រគេនយោបល់ថា បើសិនជាអាត្មាបាន សរសេររឿងរបស់អាត្មា ឲ្យជនទូទៅបានស្តាប់ នឹងអាចបាន ជាប្រយោជន៍ច្រើន ទើបគាត់បានមកអារាធនា គឺសូមនិមន្ត ឲ្យអាត្មាសរសេរអំពីជីវិតរបស់ខ្លួនជាមួយឃ្លាៗ ដើម្បីនឹង នាំយកទៅចុះក្នុងសារព័ត៌មាន «**ពុទ្ធជន**» របស់ពុទ្ធនិយម ឆៀងម៉ៃ ។

អាត្មាបានឆ្លើយទៅញោម ដែលជាអ្នកមានចេតនាល្អ នេះវិញថា៖

- អាត្មាមិនមានថ្វីដៃក្នុងការសរសេរទេ តែរឿង ដែលគេហៅថាអ្នកនិពន្ធទាំងនោះ បើឲ្យអាត្មាសរសេរ អាច សរសេរបាន ប៉ុន្តែសរសេរបែបនិពន្ធជារឿងធម្មតាប៉ុណ្ណោះ ជាពិសេសនោះ ជីវិតរបស់អាត្មា ជាជីវិតធម្មតាៗ មិនមាន

---

(១) អ្នកទំនុកបម្រុង, អ្នកផ្គត់ផ្គង់, អ្នកផ្គង់ចតុប្បច្ច័យឬផ្គង់ចង្ហាន់ ញោមឧបដ្ឋាក ឧបាសកឬទាយកជា អ្នកផ្គត់ផ្គង់បព្វជិត ។

ហេតុការណ៍អ្វីដែលគួរឲ្យភ្ញាក់ផ្អើលអ្វីផង ក្រែងតែងទៅជារឿងសោះកក្រោះ មិនជាទីពេញចិត្តរបស់អ្នកអាន ។

ញោមឆ្លើយថា៖

- មិនអីទេទាន សូមទានសាកល្បងសរសេរមើល !

នៅទីបំផុត អាត្មាក៏ចាប់ផ្ដើមសាកល្បងសរសេរមែន ដូច្នេះនៅពេលទំនេរអំពីការបដិបត្តិធម៌ ក៏ចាប់ផ្ដើមយកក្រដាសខ្មៅដៃ មកសរសេរម្ដងបន្តិចៗ លុះគ្រាបានសម្រេច ១ វគ្គក្នុង ១ ខែ រួចហើយក៏បាននាំយកអត្ថបទនេះទៅចុះផ្សាយក្នុងសារព័ត៌មាន «ពុទ្ធជន» ។

ក្រោយពេលចុះផ្សាយបានច្រើនវគ្គ ក៏ឃើញថាមានមនុស្សគេចូលចិត្តខ្លះៗ ដោយសង្កេតឃើញថា មានមនុស្សមួយចំនួនគេបានសរសេរសំបុត្រមកសរសើរ ។ មានអ្នកខ្លះសរសើរថា អ្នកដែលសរសេរនេះជាអ្នកទាន់សម័យ អាចអធិប្បាយធម៌អាថ៌របស់ព្រះសម្មាសម្ពុទ្ធ បានច្បាស់លាស់យល់បានងាយគ្រប់ជ្រុងជ្រោយ មានអ្នកខ្លះទៀតសុខចិត្តធ្វើដំណើរមកសាកសួរផ្ទាល់ នៅពេលយល់ឃើញថារឿងរបស់ខ្លួនមានប្រយោជន៍ ហើយអាត្មាក៏តាំងចិត្តសរសេរជាបន្តបន្ទាប់ ក៏ប៉ុន្តែជាការសរសេរមិនមានសាច់រឿង ឬសរសេរមុនរឿងកើត គឺសរសេរនៅពេលមានការកើតឡើង... ចំណុចដែលសំខាន់ គឺដើម្បីផ្សព្វផ្សាយព្រះធម៌ឲ្យអស់លោក-អ្នកអានកើតសម្មាទិដ្ឋិក្នុងព្រះពុទ្ធសាសនា មិន

មានប្រាថ្នាឲ្យកើតសេចក្តីសប្បាយរីករាយ អំពីសាច់រឿងដូចជាប្រលោមលោកនោះទេ ។

រឿងនេះមិនទាន់ចប់ ហើយក៏មិនអាចនឹងចប់បានដោយងាយៗនោះទេ លុះត្រាតែជីវិតរបស់អាត្មាចប់ ។ ដោយសារជីវិតរបស់អាត្មាប្រៀបដូចជាការដើរផ្លូវទៅក្នុងព្រៃ ដោយមិនមានទីដៅអ្វីមុន បានជួបប្រទះរបស់អ្វីផ្សេងៗនៅពេលដើរទៅតាមផ្លូវ ក៏នាំយកមកអធិប្បាយប្រាយប្រាប់ចែកគ្នាស្តាប់ ។

បើសិនជាមានរឿងល្អផ្សេងៗ កើតឡើងអំពីការនិទានរឿងនេះ អាត្មាភាព សូមឧទ្ទិសបុណ្យកុសលជូនដល់ញោមប្រុសដែលបានចែកឋានទៅហើយ បើសិនជាលោកបានទៅចាប់កំណើតក្នុងទុគ្គតិភព សូមឲ្យលោកបានរួចចាកទុក្ខនោះដោយឆាប់ បើសិនជាលោកបានទៅចាប់កំណើតក្នុងសុគតិភពវិញ សូមឲ្យលោកបានសោយទិព្វសុខក្នុងសុគតិភពនោះឲ្យបានយឺនយូរតរៀងទៅ ។

ដោយ **ធម្មឃោស**

# ២០. កំពូលនៃសេចក្ដីខ្លាច

ពេលបាននឹកឃើញបណ្ដាំរបស់លោកគ្រូ អាត្មាភ្ញាក់ស្មារតីឡើងវិញ ប្រញាប់ព្យាយាមសង្កត់ចិត្ត ហើយសូត្រមន្តបទរិរូបក្ខេ... ផ្សាយមេត្តាដល់ត្រកូលសត្វពស់ទាំង៤ ដោយសារអាត្មាគិតភ័យខ្លាំងពេក ទើបសូត្រត្រូវខ្លះ ខុសខ្លះចាំក្បាលភ្លេចចុង សូត្របានមួយសន្ទុះក៏លួចបើកភ្នែកឡើងមើលថាពស់ធំនោះវារទៅបាត់ ឬមិនទាន់ទៅទេ ? ស្រាប់តែពស់ធំនោះ នៅកំពុងអើតកប្រងក់ដូចដើម និងរំកិលខ្លួនចូលមកជិតអាត្មាជាងពីមុនទៅទៀត ពេលបានឃើញដូច្នេះសេចក្ដីភ័យខ្លាច បានត្រឡប់មកគោងចាប់បេះដូងរបស់អាត្មាទៀត ភ្លេចធម៌កំពុងតែសូត្រ ភ្លេចការផ្សាយមេត្តាភ្លេចគ្រប់យ៉ាង ចាំបានតែម៉្យាងគឺថារត់ចេញៗ រត់យកជីវិតឲ្យរួចសិន គឺមានតែផ្លូវមួយនេះទេ ដែលអាចរួចផុតពីចំណោមរបស់ពស់កំណាចនេះ ។ បើនៅតែប្រើមេត្តា ករុណាជាមួយឧរគសត្វនេះ ដែលមិនធ្លាប់ស្គាល់ធម៌អាថ៌អ្វីផង ច្បាស់ជាគេចមិនរួចពីវាទេ ច្បាស់ជាវារួបរឹតលេបស៊ីជាអាហារមិនខានឡើយ ។ អាត្មាក៏បានស្ទុះក្រោកឡើង លោតថយក្រោយជាច្រើនជំហាន រត់ចេញទៅតាមគុម្ពោតព្រៃស្ពោះសំដៅទៅរកក្រុនលោកគ្រូដោយមិនគិតពីជីវិតរបស់ខ្លួន ។

ពេលបានជួបលោកគ្រូ អាត្មាប្រញាប់ឱនក្រាបឱបជើងលោកដោយខ្លួនញ័ររចំប្រប់ រួចនិយាយរនិបរនុបថា៖

- ជួយខ្ញុំករុណាផងលោកគ្រូ! ជួយករុណាផងលោកគ្រូ! ពស់ធំនឹងធ្វើបាបខ្ញុំករុណាហើយ

- កុំខ្លាច! លោកគ្រូពោលដោយសម្លេងស្មើៗជាធម្មតា លោកឈប់គិតភ័យទៅ នៅទីនេះមិនមានអ្វីដែលអាចធ្វើឲ្យអន្តរាយដល់លោកបានទេ

ពាក្យអះអាងរបស់លោកគ្រូ ធ្វើឲ្យអាត្មាបានកក់ក្តៅក្នុងចិត្តឡើង យកដៃចេញពីជើងលោកគ្រូ ហើយក្រោកឡើងអង្គុយ ងាកមើលទៅកន្លែងដែលខ្លួនរត់ចេញ សង្កេតមើលថាតើពស់ធំនោះមានមកតាមដែរឬទេ? តែមិនឃើញមានអ្វីឲ្យខុសពីធម្មតា ។ លោកគ្រូសម្លឹងមើលមកអាត្មាដោយមុខញញឹមៗ ប៉ុន្តែមិនបាននិយាយអ្វីទេ ពេលឃើញអាត្មាបាត់ហត់ និងខ្លួនឈប់ញ័ររន្ធត់ៗហើយ ទើបលោកសួរឡើងថា៖

- មានស្អីកើតឡើង និយាយឲ្យករុណាស្តាប់មើល៍!

អាត្មានិយាយរឿងពស់ធំឲ្យលោកបានស្តាប់ តាំងពីដើមរហូតដល់ពេលដាច់ចិត្តរត់គេចចេញ ។

លោកគ្រូសើចហឹះៗ ហើយសួរថា៖

- តើមុនពេលដែលពស់វារចេញមក លោកឯងមិនបានចម្រើនភាវនាមេត្តាទេឬ?

- មិនបានភាវនាទេទាន! អាត្មាឆ្លើយ

- តើក្រៅអំពីមិនបានចម្រើនមេត្តាហើយ លោកឯងគិតទៅណាទៅណីខ្លះ? ខុសរឿង ខុសរាវរបស់សមណៈទៀតផង តើមែនឬទេ? លោកគ្រូសួរ

សំណួររបស់លោកគ្រូ ធ្វើឲ្យអាត្មាភ្ញាក់ផ្អើលយ៉ាងខ្លាំង ពីព្រោះមិនយល់ថា ហេតុអ្វីបានជាលោកគ្រូបានជ្រាបពីការសញ្ជឹងគិតរឿងរ៉ាវ ខុសពីសមណៈបានយ៉ាងដូចម្ដេច តែមិនហ៊ានសួរលោកគ្រូទេ បានត្រឹមតែគិតក្នុងចិត្តតែប៉ុណ្ណោះ ។ លោកគ្រូប្រហែលជាមានញាណ ដែលអាចកំណត់ដឹងនូវចិត្តរបស់នរណាម្នាក់មិនខាន ទើបបានដឹងពីចិត្តគំនិតរបស់អាត្មាដូច្នេះ ថាមិនត្រូវប្រហែលលោកគ្រូបានដឹងពីរឿងពស់ធំនោះទៀតផង បានជាគ្មានការភ្ញាក់ផ្អើលភ័យខ្លាចដូចអាត្មាសោះ ។ លោកគ្រូអង្គុយនៅស្ងៀមរួចនិយាយដោយសម្លេងធម្មតាថា៖

- ពាក្យស្លោកមួយពោលថា៖ **នៅម្នាក់ឯងឲ្យប្រយ័ត្នគំនិត នៅជាមួយមិត្តឲ្យប្រយ័ត្នសម្ដី** លោកគ្រូបានពោលតទៅទៀត, លោកមិនប្រយ័ត្ននូវការគិត ទើបកើតនូវរឿងអាក្រក់ឡើងយ៉ាងនេះ នៅក្នុងព្រៃភ្នំនេះលោកមិនបាច់ប្រយ័ត្នរឿងវាចាទេ ប៉ុន្តែត្រូវប្រយ័ត្នគំនិត កុំគិតរឿងលោកីយ៍ធ្វើអ្វី បើយើងជាសមណៈ បើនៅតែគិតរឿងនោះច្បាស់ជាសត្វសាហាវនឹងចេញមកឲ្យឃើញពុំខាន

- សត្វសាហាវ វាអាចមើលធ្លុះពីចិត្តរបស់មនុស្សបានផងឬទាន? អាត្មាសួរដោយសេចក្ដីងឿងឆ្ងល់

- មិនដឹង ប៉ុន្តែទេវតាដឹង! លោកគ្រូឆ្លើយ ប៉ុន្តែចម្លើយរបស់លោកគ្រូឆ្លើយ មិនធ្វើឲ្យអាត្មាកើតសេចក្ដីងឿងឆ្ងល់ខ្លាំងប៉ុន្មានទេ លោកគ្រូប្រហែលសង្កេតឃើញឬកពាសម្ដែងនូវសេចក្ដីងឿងឆ្ងល់របស់អាត្មា ទើបពោលបន្ត

ទៀតថា, ការដែលយើងចូលមកនៅអាណាខេត្តរបស់ទេវតា គឺស្ថិតក្នុងការគ្រប់គ្រង និងមើលការខុសត្រូវរបស់ទេវតា ។ បើសិនយើងមកក្នុងគោលបំណងល្អ ដោយចេតនាជាកុសល ដើម្បីបំពេញសេចក្ដីព្យាយាមនូវសេចក្ដីបរិសុទ្ធនោះ ទេវតាលោកក៏តែងយកចិត្តទុកដាក់ជួយតាមថែរក្សា ជួយការពារភយន្តរាយនានា និងពេលយើងភ្លេចធ្វើអំពើល្អក៏ចាំជួយដាស់តឿន ហាមប្រាមយើងមិនឲ្យធ្វើ និយាយ ឬគិតពីរឿងមិនសមរម្យ

- ចុះទេវតា ហេតុម្ដេចបានជាមិនហាមពស់ធំមួយនោះ កុំឲ្យមកធ្វើបាបខ្ញុំកូណាទៅ ? អាត្មាសួរលោកគ្រូដោយសេចក្ដីសង្ស័យ

លោកគ្រូសើចដោយអារម្មណ៍ត្រជាក់ ហើយឆ្លើយតបវិញថា ៖

- នេះមិនមែនពស់មែនទែនទេ គ្រាន់តែជាទេវតាគ្រឡាខ្លួនជាពស់មកដាស់តឿនលោកឯង ពីព្រោះលោកស្រមៃរឿងលោកីយ៍ កូណានេះក៏គេធ្លាប់មករកច្រើនដងដែរ ទាល់តែអាចគ្រប់គ្រងចិត្តបាន មិនឲ្យគិតក្នុងផ្លូវមិនសមគួរនោះបានហើយ ទើបមិនត្រូវទេវតាដាស់តឿនដោយវិធីគួរឲ្យភ័យខ្លាចដូច្នេះតទៅទៀត

- ប៉ុន្តែលោកគួរដាស់តឿនដោយវិធីល្អជាងនេះទាន ! អាត្មាពោល ជាការតវ៉ាជាមួយនឹងលោកគ្រូ, ពីព្រោះនៅនឹកស្រមៃឃើញសត្វពស់ដ៏ធំគួរឲ្យខ្លាច,ធ្វើឲ្យអាត្មាស្ទុះជិតស្លាប់បែបនេះសោះ

- ទេវតាលោកនឹងជាមនុស្ស, លោកគ្រូពោលតទៀត លោកនឹងថា ការគិតជារឿងពិបាកបំផុត មនុស្សយើងអាច គិតទៅផ្សេងៗច្រើនយ៉ាង គិតទៅផ្លូវល្អខ្លះ អាក្រក់ខ្លះ កណ្ដាលខ្លះ បើសិនជាដាស់តឿនដោយវិធីល្អ ប្រហែល ជាមិនរាងចាលទេ ដូច្នេះត្រូវដាស់តឿនដោយឆមក្ដៅ ធ្វើឲ្យ អ្នកដែលត្រូវដាស់តឿនកើតសេចក្ដីភ្ញាក់ផ្អើល និងខ្លាចជាទី បំផុត ទើបគេខ្លាច រួចចងចាំគ្មានថ្ងៃបំភ្លេចបាន ដាស់តឿន តែមួយដង អាចបំលោញបានរហូតមិនចាំបាច់ដាស់តឿន ដដែលៗទៀត

- បើខ្ញុំកូណាបានដឹងថា គឺជាការដាស់តឿនរបស់ ទេវតា ខ្ញុំកូណាក៏មិនរត់ដែរ, អាត្មាពោលឡើងល្មើយៗ ដោយអំនួតតិចៗ

លោកគ្រូសើចហើយបានពោលឡើងថា៖

- ថាមិនប្រាកដដែរ បើសិនជាជួបសត្វគាចសាហាវ ទៀតលោកនឹងប្បាស់ជារត់ទៀតហើយ ពីព្រោះលោកនឹង យកឈ្មោះខ្លួននឹងមិនទាន់បាននៅឡើយ

អាត្មានឹកទាយក្នុងចិត្តថា លោកគ្រូប្រហែលជា យល់ពីការភ័យខ្លាចចំពោះសត្វគាចសាហាវ ដែលអាត្មា ទើបនឹងសម្ដែងឲ្យលោកគ្រូឃើញអម្បាញ់មិញនេះ ប៉ុន្តែ អាត្មាទាយខុស ពីព្រោះលោកគ្រូបានពោលដូចជាដឹងពីចិត្ត របស់អាត្មា មិនមែនខ្លាចសត្វគាចសាហាវប៉ុណ្ណោះទេ តែគឺជាការខ្លាចរបស់ម៉្យាង ដែលសត្វគាចសាហាវទាំងនោះ អាចនឹងនាំមកឲ្យអាត្មា ។

- ចូរគិតមើលថា តើហេតុដូចម្ដេចទើបបានជាខ្លាចខ្លា រួចដូចម្ដេចបានជាមិនខ្លាចឆ្មា ទាំងដែលខ្លានិងឆ្មាក៏ជាសត្វប្រភេទដូចគ្នា? លោកគ្រូសួរបន្ត

- ពីព្រោះខ្លាវាខាំមនុស្ស ចំណែកឆ្មាមិនខាំមនុស្សទេ, អាត្មាឆ្លើយទៅលោកគ្រូតាមត្រង់

- ការពិតឆ្មាវាក៏ខាំមនុស្សដូចគ្នាដែរ តែថាការខាំវាខុសគ្នា លោកដឹងទេថាបើមនុស្សត្រូវខ្លាខាំ តើនឹងមានអ្វីកើតឡើង?

- មានតែស្លាប់! អាត្មាឆ្លើយតបពាក្យខ្លីៗ

- ត្រូវហើយ ! លោកគ្រូបន្ថែម, បើត្រូវខ្លាខាំមនុស្សនឹងអាចស្លាប់បាន តែបើត្រូវឆ្មាខាំវិញមិនស្លាប់ទេ ភាពខុសគ្នានៅត្រង់ស្លាប់និងមិនស្លាប់នេះឯង ដោយហេតុដូច្នេះឯង តើមនុស្សខ្លាចស្អីខ្លាំងជាងសត្វសាហាវដូចជាខ្លា ឬពស់នេះទៅទៀត ?

នៅពេលលោកគ្រូសួរ ដេញដោលត្រង់ចំណុចនេះ អាត្មាក៏យល់ឃើញភ្លាមថា មនុស្សខ្លាចសេចក្ដីស្លាប់ជាងខ្លាចសត្វសាហាវនេះទៅទៀត បើសត្វកាចសាហាវមិនអាចធ្វើឲ្យមនុស្សស្លាប់បាន មនុស្សក៏មិនខ្លាចវាទាល់តែសោះដែរ ទើបអាត្មាឆ្លើយតបទៅលោកគ្រូវិញថា៖

- មនុស្សខ្លាចសេចក្ដីស្លាប់ !

- ត្រូវហើយ! លោកគ្រូឆ្លើយ, មនុស្សខ្លាចសេចក្ដីស្លាប់ខ្លាំងជាងអ្វីៗទាំងអស់ ការដែលលោករត់គេចពីពស់មក ក៏ពីព្រោះខ្លាចសេចក្ដីស្លាប់ លោកអាចយកឈ្នះការភ័យខ្លាច

*អស្ចារ្យបានក៏ពិតមែន ប៉ុន្តែលោកនៅមិនទាន់យកឈ្នះ មរណៈភ័យបាននៅឡើយ ហេតុដែលកូណាវានាំលោកមក ទីនេះ គឺដើម្បីបង្រៀនដល់លោកឲ្យយកឈ្នះសេចក្ដីខ្លាច ស្លាប់ឲ្យបាន បើយកឈ្នះសេចក្ដីខ្លាចស្លាប់បាន លោកនឹង មិនខ្លាចរបស់ផ្សេងៗក្នុងលោកនេះទៀតទេ ហើយគ្មានអ្វីជា ឧបសគ្គរារាំងនូវការបដិបត្តិធម៌របស់លោក សេចក្ដីខ្លាច ស្លាប់ជាឧបសគ្គយ៉ាងធំបំផុតក្នុងការបដិបត្តិធម៌ លោកឯង ធ្លាប់បានសិក្សាពីពុទ្ធប្រវត្តិមកហើយ គង់ចងចាំបានខ្លះៗថា ព្រះបរមសាស្ដានៃយើងក្នុងថ្ងៃត្រាស់ដឹង ក្រោយពីឡើង គង់ប្រថាប់លើបល្ល័ង្គ ក្រោមដើមពោធិ៍ព្រឹក្ស ព្រះអង្គទ្រង់ បានអធិដ្ឋានថា ៖* ***សាច់ និងឈាមក្នុងកាយយើង ចូរស្ងួត ស្វិតទៅចុះ ទោះបីសល់តែស្បែកនិងស្ពាយឆ្អឹងក៏ដោយក្ដី ខណៈពេលនៅមិនទាន់បានសម្រេចក្ដីប្រាថ្នា ក៏អាត្មាអញ នឹងមិនងើបក្រោកឡើងពីអាសនៈនេះជាដាច់ខាត*** *។ នេះ បញ្ជាក់ឲ្យឃើញថា មុនពេលនេះ ព្រះបរមសាស្ដានៃយើង ទ្រង់នៅស្ពាយអាឡោះអាល័យ ជីវិតរាងកាយរបស់ព្រះអង្គ នៅឡើយ និយាយឲ្យស្រួលស្ដាប់ គឺថានៅខ្លាចសេចក្ដីស្លាប់ នៅឡើយ ទើបមិនបានត្រាស់ដឹង ។ របស់ផ្សេងៗព្រះអង្គ លះបង់ចោលអស់ហើយ នៅសល់ត្រឹមតែសេចក្ដីស្រឡាញ់ ក្នុងជីវិតតែប៉ុណ្ណោះ ។ ទើបក្នុងថ្ងៃត្រាស់ដឹងនោះ ព្រះអង្គ អាចយកឈ្នះសេចក្ដីខ្លាចបានជាគ្រាដំបូង ទើបទ្រង់ធ្វើ អធិដ្ឋានចិត្តដូច្នោះឯង ទីបំផុតព្រះអង្គក៏បានត្រាស់ដឹងនូវ ព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ ។*

*យើងជាពុទ្ធសាវិករបស់ព្រះអង្គក៏ប្រាថ្នា និងដើរតាមព្រះយុគលបាទ ក៏ត្រូវកាត់ចោល គឺសេចក្ដីស្រឡាញ់ជីវិត សេចក្ដីខ្លាចស្លាប់នេះជាមុនសិន, លោកគ្រូឈប់មានដីការួច ងាកទៅយកបំពង់មកចាក់ទឹកពីកំសៀវឲ្យអាត្មាឆាន់ អាត្មាឆ្លៀតយកឱកាសនេះតបសួរលោកថា៖*

- *ធ្វើយ៉ាងណាទាន! ទើបខ្ញុំកូណាឈប់ខ្លាចស្លាប់បាន?*
- *មុននឹងសួរនូវបញ្ហានេះលោកគួរដឹងជាមុនថា ហេតុម្ដេចទើបបានជាមនុស្សខ្លាចស្លាប់ តាមពិតបញ្ហានេះព្រះបរមគ្រូនៃយើង ទ្រង់បានឆ្លើយរួចហើយក្នុង មរណភយាភយសូត្រ គម្ពីរអង្គុត្តរនិកាយថា មនុស្សខ្លាចសេចក្ដីស្លាប់ពីព្រោះហេតុ ៤ ប្រការ គឺមនុស្សខ្លះមានសេចក្ដីជាប់ជំពាក់ ត្រេកត្រអាលពេញចិត្ត ស្រឡាញ់ ចំណង់ អន្ទះសារចង់បានក្នុងកាមទាំងឡាយ នឹងភ័យខ្លាចសេចក្ដីស្លាប់ ក៏ពីព្រោះខ្លាចការព្រាត់ប្រាសពីកាមដែលគួរស្រឡាញ់ពេញចិត្តទាំងនោះ ។ មានមនុស្សខ្លះ មានសេចក្ដីជាប់នូវការត្រេកអរពេញចិត្ត ស្រឡាញ់ក្នុងជីវិតរាងកាយរបស់ខ្លួន គេខ្លាចសេចក្ដីស្លាប់ពីព្រោះខ្លាចថា ខ្លួននឹងព្រាត់ប្រាសពីជីវិតរាងកាយ ហើយជីវិតរាងកាយ និងព្រាត់ប្រាសពីខ្លួន ។ មានអ្នកខ្លះធ្វើតែអំពើអាក្រក់ មិនបានប្រព្រឹត្តិអំពើល្អទុកមកសោះ គេព្រួយថា នៅពេលកាយបែកធ្លាយទៅ នឹងទៅទុគ្គតិ ទើបភ័យខ្លាចក្នុងសេចក្ដីស្លាប់ ។ មនុស្សខ្លះនៅមានការសង្ស័យក្នុងចិត្ត ព្រះធម៌គឺជាសេចក្ដីពិត ទាក់ទងនឹងជីវិតជាមួយនឹងអនាគត ហើយនៅទីបំផុតនៃជីវិត គេខ្លាចសេចក្ដីស្លាប់*

ពីព្រោះមិនដឹងថា ពេលស្លាប់ហើយ តើគេមានអ្វីនឹងកើតឡើង ៗ សរុបសេចក្ដីមក មនុស្សដែលខ្លាចស្លាប់ ព្រោះហេតុ ៤ យ៉ាងគឺ៖ **ទី ១ សេចក្ដីស្រឡាញ់ក្នុងកាម, ទី ២ សេចក្ដីស្រឡាញ់ក្នុងជីវិត, ទី ៣ ខ្លាចទុគ្គតិ និងទី ៤ មិនស្គាល់ការពិតនៃជីវិត** ៗ កូណាជឿថា លោកមិនខ្លាចស្លាប់ ពីព្រោះមិនបានស្រឡាញ់ក្នុងកាម ប្រសិនបើនៅស្រឡាញ់ក្នុងកាមមែននោះ លោកក៏គង់មិនទាន់លះបង់ផ្លូវលោកចេញមកបួសដែរ ប្រហែលមិនខ្លាចស្លាប់ទៅកាន់ទុគ្គតិទេ ព្រោះមិនបានប្រព្រឹត្តិបាបកម្មអ្វីដែរ ក៏ប៉ុន្តែលោកខ្លាចស្លាប់ ពីព្រោះស្រឡាញ់ជីវិតតែម៉្យាង ដោយហេតុមិនស្គាល់នូវការពិតនៃជីវិត ៗ បើសិនជាអាចលះនូវសេចក្ដីខ្លាចស្លាប់បាន លោកអាចលះបង់សេចក្ដីស្រឡាញ់ និងសេចក្ដីវង្វេងក្នុងជីវិត ដោយសេចក្ដីពិតនៃសេចក្ដីស្លាប់ជាមុន ៗ

- តើធ្វើយ៉ាងណាទៅ ទើបខ្ញុំកូណាអាចឈប់អាល័យស្រឡាញ់ជីវិតបានទាន? អាត្មាសួរ

ពេលនោះលោកគ្រូត្រឡប់មកសួរអាត្មាវិញថា៖

- ការដែលលោកលះបង់ផ្ទះសម្បែង ការងារ និងសេចក្ដីសុខក្នុងផ្លូវលោក ចេញមកសាងផ្នួសជាភិក្ខុក្នុងព្រះពុទ្ធសាសនានេះ តើលោកប្រាថ្នាអ្វី?
- ខ្ញុំម្ចាស់ប្រាថ្នានូវសេចក្ដីរំលត់កិលេស និងសេចក្ដីទុក្ខដើម្បីសម្រេចព្រះនិព្វាន
- បើដូច្នេះព្រះនិព្វាន និងជីវិត មួយណាប្រសើរជាង?
- ព្រះនិព្វានប្រសើរជាង! អាត្មាឆ្លើយ

- លោកនឹងយកព្រះនិព្វានដ៏ប្រសើរ ឬយកជីវិតរាងកាយដែលមិនប្រសើរ ? លោកគ្រូសួរ

- យកព្រះនិព្វាន ! អាត្មាឆ្លើយ

- ត្រូវជ្រើសរើសយកតែមួយ មិនអាចយកទាំងពីរបានទេ បើជ្រើសយកព្រះនិព្វាន ត្រូវលះបង់ជីវិតរាងកាយ បើជ្រើសយកជីវិតរាងកាយ ត្រូវលះបង់ព្រះនិព្វាន ។ នៅពេលដែលលោកឯងគាត់ចិត្ត ជ្រើសរើសយកព្រះនិព្វានហើយ លោកក៏ត្រូវលះបង់ជីវិតរាងកាយ លះបង់សេចក្ដីស្រឡាញ់ជីវិតរាងកាយ ទម្លាក់របស់ដ៏ធ្ងន់នេះ គឺជីវិតរាងកាយចុះ ហើយរកបែរមករកជណ្ដើរ ៣ ជាន់ នាំលោកដើម្បីឈានទៅដល់ព្រះនិព្វាន គឺសីល សមាធិ បញ្ញា ជាមាគ៌ាយ៉ាងល្អិត ។ បើជនណាម្នាក់ជាប់ទូលភារៈដ៏ធ្ងន់គឺ ខន្ធ ៥ ហើយព្រមទម្លាក់ចោលនូវអង្រែកដ៏ធ្ងន់នេះចុះ ពួកគេនឹងស្រាលខ្លួន និងបោះជំហានឡើងជណ្ដើរទៅកាន់ព្រះនិព្វានបានដោយស្រួល ។

លោកគ្រូឈប់សម្រាកមួយសន្ទុះ ហើយពោលតទៅទៀតថា ៖

- ការពិតជីវិតរាងកាយ មិនមែនជារបស់ដែលគួរឲ្យភ័យបារម្ភណាស់ណាទេ ព្រះពុទ្ធអង្គមានពុទ្ធដីកាថា **ភារា ហវេ បញ្ចក្ខន្ធា** ខន្ធទាំង ៥ ជាភារៈដ៏ធ្ងន់ដើម្បីថែរក្សាចិញ្ចឹមរែកទូលនិងថ្នាក់ថ្នម ទាំងអស់នេះគឺពោរពេញទៅដោយសេចក្ដីទុក្ខ ។ ជីវិតជាក្ដីទុក្ខ តាំងពីកើតរហូតដល់ស្លាប់ បើដូច្នេះហើយ លោកនៅអាល័យស្រឡាញ់ការពារថង់ឈាម

ចង់សាច់ឈឺចូន់នេះ ដល់ពេលណាទៀត ?

អាត្មាពិចារណានូវពាក្យប្រៀនប្រដៅ របស់លោកគ្រូ ក៏យល់ឃើញភ្លាមថា ជីវិតរាងកាយមិនមែនជារបស់គួរ ឲ្យស្រឡាញ់ គួរឲ្យហួងហែងអ្វីទេ តែបែរជាចង់ឈឺចូន់ និង គួរតែដាក់ចុះភ្លាមៗ ។ លោកគ្រូបាននិយាយបន្តទៅទៀត ហាក់បីដូចជាដឹងនូវចិត្តរបស់អាត្មាថា៖

- បើបានដឹងដូច្នេះ លោកក៏នឹងសម្រាលនូវសេចក្តី ខ្លាចស្លាប់បានហើយ តែមានរបស់មួយទៀតដែលគួរនឹង ដឹងនោះ គឺសេចក្តីស្លាប់ បើលោកដឹងថាស្លាប់គឺជាអ្វី នឹង មិនខ្លាចស្លាប់ដោយសេចក្តីពិត លោកអាចនឹងស្លាប់គ្រប់ ពេលតាមផ្លូវរូបក្ខន្ធផ្សេងៗ រួមផ្សំជាមួយនឹងរាងកាយស្លាប់ កើតៗ គតៗគ្នាជានិច្ច កោសិកាចាស់ស្លាប់ទៅ បញ្ចេញមក វិញជាលាមក និងញើសតាមស្បែក ហើយកោសិកាថ្មីកើត ឡើងមកជំនួស កោសិកាដំបូងដែលមាននៅក្នុងផលាកើត នូវផលានេះបានស្លាប់ទៅអស់ហើយ មិនមាននៅសល់ សោះឡើយ កោសិកាដែលលោកមាននៅពេលនេះ ជា ជំនាន់ថ្មីទាំងអស់ ដូច្នេះរាងកាយរបស់លោកនៅផលានេះ និងរាងកាយរបស់លោកកាលពីនៅក្មេង ទើបមិនមែនជា រាងកាយជាមួយគ្នានោះទេ កោសិកាដែលលោកមាន នៅផលានេះ ប្រហែលជាដប់ឆ្នាំខាងមុខក៏នឹងត្រូវស្លាប់អស់ តែលោកនឹងនៅតែរក្សារូបរាងដើមទុកបាន ពីព្រោះវាមិន បានស្លាប់ទៅព្រមគ្នានោះទេ មិនបានកើតព្រមគ្នាបាន ឡើយ ប្រៀបដូចប្រជាជននៃស្រុកថៃពលរដ្ឋដែលកើត

កាលពីប្រហែល ១៤០ ឆ្នាំមុន ពេលនេះមិនមាននៅសល់សោះឡើយ គឺបានស្លាប់អស់ហើយ សូម្បីតែប្រជាពលរដ្ឋដែលរស់នៅពេលនេះមានចំនួនប្រហែល ១៥០ នៅឆ្នាំខាងមុខទៀត ក៏នឹងស្លាប់អស់ដូចគ្នាដែរ តែជាតិថៃ ប្រទេសថៃក៏នឹងនៅមានបន្តទៀត ពីព្រោះមនុស្សមិនបានកើតព្រមគ្នាស្លាប់ព្រមគ្នា តែស្លាប់កើតៗជំនួសគ្នាទៅរឿយៗ មិនដែលដាច់នេះហើយ គឺជាដំណើរនៃរូបក្ខន្ធ ។

ចំណែកខាងផ្លូវនាមខន្ធឬផ្លូវចិត្ត ក៏ស្លាប់កើតរហូតគ្រប់ពេលវេលា ហើយស្លាប់បានរហ័សជាងកាយទៅទៀត នៅពេលចិត្តមួយរលត់ទៅ មានចិត្តមួយទៀតកើតឡើងផ្លាស់ប្តូរគ្នាទៅជានិច្ច មិនដែលដាច់ ដូចជាភាពយន្តដែលយើងបានឃើញនៅលើផ្ទាំងសំពត់ រូបភាពដែលយើងឃើញ ជាភាពតែមួយដូចគ្នា យូរៗទៅនោះក៏ឃើញនូវការពិតថ្មីដោយភាពរាប់ចំនួនមិនអស់ ដោយមានរូបភាពមួយខាងមុខ និងគ្រឿងបញ្ចាំងទៅរូបមួយទៀតចូលមកជំនួសក្នុងរយៈពេលយ៉ាងខ្លី ហើយក៏ហួសទៅ តែជាការកើតរលត់គ្នាទៅយ៉ាងរហ័ស ទើបយើងឃើញថាជារូបតែមួយនៅក្នុងចិត្តរបស់យើង ក៏កើតរលត់តៗគ្នា ក្នុងរបៀបដូចគ្នា ដូច្នេះហើយទើបបានជាយើងស្លាប់កើតជានិច្ចគ្រប់ពេលវេលា ក្នុងពេលស្លាប់មែនៗ ដល់បញ្ចក្ខន្ធរលត់បដិសន្ធិវិញ្ញាណក៏កើតឡើង នៅពេលបដិសន្ធិវិញ្ញាណរលត់ នាមរូបដែលកើតពីកម្លាំងនៃកម្មក៏កើតឡើងតពីនោះក៏បានភពកើតជាតិថ្មីតទៅ បើនឹងប្រៀបធៀបឲ្យឃើញ

ច្បាស់ថា ជាតិនីមួយៗក៏ដូចជា ភាពយន្តមួយវគ្គៗ ក្នុងហ្វីលកុន ដែលជាំងឆ្ងាយប៉ុណ្ណោះឯង ជាតិមួយរលត់ទៅជាតិថ្មីក៏កើតឡើង សេចក្តីស្លាប់គ្រាន់តែជាចន្លោះទំនេរមួយខណៈចិត្ត ខាងក្នុងរវាងរូបទាំងពីរឬជាតិទាំងពីរតែប៉ុណ្ណោះ

លោកគ្រូឈប់និទាន ហើយសម្លឹងមកអាត្មាដូចជានឹងចង់សួរថា៖ តើយល់ឬទេ?

នៅពេលមិនឃើញអាត្មាឆ្លើយ លោកក៏បានបន្តអធិប្បាយតទៅទៀតថា៖

- លោកនឹងឃើញហើយថា សេចក្តីស្លាប់មិនមែនជារបស់ដែលគួរឲ្យខ្លាចអ្វីសោះ ហើយវានឹងត្រឡប់មកជាឱកាសដ៏ល្អសម្រាប់លោក ដើម្បីបានប្តូរភព ប្តូរជាតិម្តង បើបានធ្វើតែអំពើល្អក្នុងជាតិនេះ នៅពេលស្លាប់ទៅ លោកនឹងមានសង្ឃឹមទៅឯសុគតិ ដូចជាដេកលក់ទៅមួយសន្ទុះ ហើយក៏ភ្ញាក់ឡើងមកក្នុងលោកថ្មីដែលស្រស់ថ្លា ប្រការមួយទៀត សេចក្តីស្លាប់ជារបស់ដែលមិនអាចជៀសវាងបានឡើយ មនុស្សគ្រប់គ្នាដែលបានកើតមកហើយ តែងតែត្រូវស្លាប់ក្នុងថ្ងៃណាមួយ មិនយូរមិនឆាប់ បើមិនស្លាប់ល្អក៏ស្លាប់អាក្រក់ ជារបស់ដែលរត់គេចមិនផុតយើងក៏គួរប្រឈមមុខជាមួយនឹងវាដោយចិត្តថ្លើមរឹងប៉ឹង ដោយចិត្តជាកុសល ដោយអារម្មណ៍យ៉ាងល្អ ស្លាប់ទៅហើយនឹងបានទៅឯសុគតិ បើខ្លាចសេចក្តីស្លាប់ ដល់ពេលស្លាប់ទៅ ចិត្តនៅមានសេចក្តីវង្វេង ភ្លេចសតិ ស្លាប់ដោយចិត្តសៅហ្មងគឺច្បាស់ជាទៅកាន់ទុគ្គតិ ដូច្នោះមិនត្រូវខ្លាចនូវសេចក្តីស្លាប់

នោះឡើយ ៗ

គ្រោយពីបានស្តាប់ពាក្យពោលបរិយាយ របស់លោកគ្រូលុះត្រាបានយល់ហើយ ក៏ចូលចិត្តនូវធម្មជាតិនៃសេចក្តីស្លាប់ពិតប្រាកដ ហើយអាត្មាក៏ឈប់ខ្លាចនូវសេចក្តីស្លាប់ តាំងតែពីពេលនោះមក រហូតមកដល់បច្ចុប្បន្ននេះ ៗ

# មរណភ័យ

បទពាក្យ៩

| | | |
|---|---|---|
| ការតក់ស្លុត | ភ័យរន្ធត់ | ប្រាកដមាន |
| គ្រប់កាយប្រាណ | គេចមិនបាន | សោះឡើយណា |
| ទោះឥន្ទ្រព្រហ្ម | យមយក្សមនុស្ស | ឬទេវតា |
| ឥតសត្វណា | មានវាសនា | គេចភ័យបាន ។ |
| ភ័យក្នុងលោក | ច្រើនគគោក | រាប់មិនអស់ |
| តែភ័យនោះ | អាចស្រាយដោះ | តាមហេតុមាន |
| ឲ្យរសោះ | អស់រសាយ | កាយចិត្តប្រាណ |
| ខ្លះៗបាន | តាមវេលា | ជាធម្មតា ។ |
| តែភ័យមួយ | នាំទុក្ខព្រួយ | ដល់សព្វសត្វ |
| ពុំអាចកាត់ | ដោះវិបត្តិ | កែបញ្ហា |
| ព្រោះជីវិត | ពិតត្រូវជួប | ក្តីមរណា |
| គ្មានសត្វណា | អាចគេចផុត | រត់រួចបាន ។ |
| ត្រូវរៀនយល់ | ទទួលស្គាល់ | តាមហេតុការណ៍ |
| ដោយបញ្ញា | ស្រាយបញ្ហា | ប្រាកដមាន |
| ត្រៀមទុកមុន | កុំឲ្យស៊ុន | គ្រប់រូបប្រាណ |
| ជីវិតបាន | ក្សាន្តមិនស្លុត | រន្ធត់ភ័យ ៕ |

ដោយឧបាសក ម៉ិញ សារ៉ាង

# ២១. លោក "គ្រូ" មានពិត

ទីបំផុតសេចក្តីងងឹត ដែលគួរឲ្យខ្លាចសម្រាប់អ្នកដែលនៅមានសេចក្តីខ្លាចក៏បានចូលមក របស់ដែលមកព្រមៗជាមួយសេចក្តីងងឹត គឺសេចក្តីស្ងាត់ប្រៀបដូចជាជីវិតទាំងអស់នៅក្នុងលោកបានដល់ទីអវសានហើយ ។ អាត្មានឹកចូលចិត្តធាតុអាកាសដូច្នេះ ពីព្រោះជារាត្រីសមស្រួលនឹងការបំពេញព្យាយាមផ្លូវចិត្ត សេចក្តីងងឹតជាវាំងននធម្មជាតិជួយបាំងរូប ដែលជាសត្រូវមិនឲ្យមករំខានភ្នែកចិត្ត សេចក្តីស្ងប់ស្ងាត់ជាទ្វារធម្មជាតិ បិទនូវសម្លេងដែលជាសត្រូវ មិនឲ្យមករំខានត្រចៀក នៅពេលមិនមានអារម្មណ៍រំខាននូវភ្នែកត្រចៀក ចិត្ត អាចឈានចុះទៅក្នុងសមាធិបានងាយងាយ ។

អាត្មាមានការហត់ហេវល្ហើយយ៉ាងខ្លាំង ចង់សម្រាកបានបន្តិច អាត្មាបានប្រាប់ទៅកំលោះផែកសំបុត្ររថយន្តឈ្នួលនេះថា៖

- សូមឲ្យអ្នកឯងអង្គុយនៅស្ងៀមៗបានហើយ
- ព្រះអង្គនឹងសឹងឬ? ក្មេងកំលោះសួរឡើងសម្តែងនូវការមិនសប្បាយចិត្ត
- អត់ទេ! តែនឹងអង្គុយធ្វើសមាធិមួយភ្លែត
- លោកគ្រូកុំទុកចោលឲ្យខ្ញុំនៅម្នាក់ឯង! ខ្ញុំខ្លាចណាស់
- អាត្មាមិនទុកចោលទេ គឺអាត្មានឹងអង្គុយនៅជាមួយ

អ្នកនៅទីនេះ កុំខ្លាចអីមិនមានស្អីគួរឲ្យខ្លាចទេ បើមានអ្វីកើតឡើងសុំឲ្យអ្នកចាប់ដៃអាត្មា បើអាត្មានៅមិនទាន់នឹងខ្លួនអ្នកអាចនឹងអង្រួនតិចៗ លុះត្រាអាត្មាបាននឹងខ្លួនឡើង

- កូណាទាន! ក្មេងកំលោះទទួលពាក្យអាត្មា មើលទៅជុំវិញខ្លួនរាងភ្លើលៗ ហើយខិតចូលមកអង្គុយជិតអាត្មា, អាត្មាអង្គុយតាំងសមាធិបង្អោនចិត្ត ទៅរកដល់គុណព្រះរតនត្រ័យនិងលោកគ្រូ ហើយក៏ចាប់ផ្ដើមចម្រើននូវ អានាបាណស្សតិ កំណត់ខ្យល់ដកដង្ហើមចេញ-ចូល ។ នៅពេលមិនយូរ **នីវរណធម៌** ដែលជាមន្ទិលទាំង ៥ នៃចិត្ត គឺ **សេចក្ដីពេញចិត្ត សេចក្ដីអាក្រក់ សេចក្ដីងុយងក់ សេចក្ដីសង្ស័យ និងសេចក្ដីរាយមាយ** ក្នុងចិត្តក៏រលត់ទៅ គឺស្ងប់ទៅៗ នៅសល់តែ **ឯកគ្គតាចិត្ត** ដ៏ផូរផង់ស្អាត ឆ្អែតដោយបីតិ និងសេចក្ដីសុខយ៉ាងល្អិតក្រៃលែងលោកិយ៍ សុខទាំងឡាយបញ្ចាំងពន្លឺពេញដោយបញ្ញា អាត្មាសម្រាកនៅក្នុងសមាធិចិត្តថ្នាក់នេះអស់ពេលជាយូរសមគួរ ហើយទើបចាប់ផ្ដើមរំលត់នូវសេចក្ដីគិតចំណង់របស់ចិត្តបាន ដើម្បីចូលដល់សមាធិចិត្តថ្នាក់ខ្ពស់ឡើងទៅ ប៉ុន្តែអាត្មាក៏ចាំបាច់ត្រូវគិតពីសមាធិចិត្ត ដោយសេចក្ដីប្រុងប្រយ័ត្ន ពីព្រោះហាក់បីដូចជាមានអ្វីម៉្យាងលោតមកសង្កត់ខ្លួន ហើយឱបជាប់យ៉ាងណែនចិត្តក៏បានចេញមកទទួលនូវអារម្មណ៍ខាងក្រៅ ដោយចិត្តមន្ទិលទាំង ៥ ខាងលើ ទើបបាននឹងការពិតថា ក្មេងប្រុសដែកសំបុត្រឡានកំពុងឱបអាត្មា ដោយខ្លួនពោរពេញដោយសេចក្ដីភ័យខ្លាច ។

- មានស្អីកើតឡើង? អាត្មាសួរដោយសម្លេងធម្មតា

- ខ្ញះ..ខ្ញះ..មោ..មោ..ខ្មោចៗ!!! គេបន្លឺសម្លេងឆ្លើយមកអាត្មា ដោយអាការៈលស់ព្រលឹង

- ឯណាខ្មោច នៅឯណា? អាត្មាសួរ ប៉ុន្តែក្មេងប្រុសមិនឆ្លើយគ្រាន់តែចង្អុលដៃទៅខាងមុខ អាត្មាសម្លឹងមើលទៅទីងងឹតស្លុងតាមដៃរបស់គេចង្អុល ហើយក៏បានជួបនូវការនឹកស្មានមិនដល់ ដោយបានឃើញនូវរូបរាងមនុស្សអង្គុយនៅស្ងៀមក្នុងទីងងឹតនោះ ក្រោមដើមឈើត្រង់កន្លែងដាក់សាកសពរបស់ក្មេងយកប្រាក់ម្នាក់ទៀតនោះ នៅពេលដែលកំពុងសម្លឹងមើលនោះឯង រាងនោះក៏បែរដារទ្រូងទៅខាងក្រោយម្តងទៀត ព្រមទាំងមានសម្លេងស្រែកមកដាម្មួយផង

- ប្រហែលជាមានស្អីខុសធម្មតាប្រាកដហើយ! អាត្មាពោលព្រមទាំងកំពុងគិតនឹងក្រោក តែត្រូវក្មេងកំលោះឱបយ៉ាងណែន

- លោកគ្រូចង់ទុកខ្ញុំកូណាចោលឬ? គេពោលដោយដោយរងីបរងុបហើយឱបគាន់តែណែនខ្លាំងថែមទៀត

- លែងអាត្មាសិន! អាត្មានឹងដើរទៅមើលឲ្យដឹងច្បាស់ថាតើវាជាស្អីឲ្យប្រាកដ កុំខ្លាច!

ក្មេងប្រុសនោះបានដកដៃចេញ តែនៅចាប់ដៃទុកយ៉ាងណែន ដើរតាមអាត្មាទៅ ៗ

អាត្មាអង្គុយចុះជិតសាកសពរបស់ក្មេងកម្លោះ ហើយឈ្ងោកមើលមុខរបស់គេមួយសន្ទុះ ក៏ឃើញថាគេកំពុង

ដេកបើកភ្នែកនៅស្ងៀម នៅពេលយកដៃទៅស្ទាបរាងកាយ និងផ្ទៃមុខរបស់គេ គឺមានកម្ដៅក្ដៅឧណ្ហៗ មានន័យថាគេនៅរស់ទេ

- នឹងខ្លួនហើយ! អាត្មាភ្លេចខ្លួនស្រែកចេញមកដោយសេចក្ដីត្រេកអរជាពន់ពេក ធ្វើឲ្យក្មេងប្រុសកម្លោះមិត្តរបស់គេមានសេចក្ដីក្លាហានមួយរំពេច ប្រញាប់ស៊ែងដៃពីអាត្មា ហើយទៅអង្គុយជិតមិត្តរបស់គេ ដែលគេនឹកស្មានតែជាខ្មោចលង គេយកដៃទៅចាប់ស្មាអង្រួន ហើយសួរថា៖

- ចង! ចង! ឯងមិនទាន់ស្លាប់ទេឬ?

- ឯងឬ? មិត្តរបស់គេនិយាយចេញមកដោយសម្លេងខ្សាវៗ

- មែនហើយគ្នាឃើង! ក្មេងប្រុសដែលខ្លាចនោះឆ្លើយដោយសម្លេងខ្លាំង ជាសម្លេងនូវសេចក្ដីភ្ញាក់ផ្អើលត្រេកអរយ៉ាងខ្លាំងដោយឃើញយ៉ាងច្បាស់

- សុំទឹកផឹកបន្តិច ស្រេកទឹកណាស់! នាយចងពោលឡើង

អាត្មាក៏ប្រញាប់ទៅយកទឹកចាក់ពីកំសៀវ ដាក់ពែងយកមកឲ្យនាយចង៖

- ឯងលើកក្បាលគេឡើង! នាយចងប្រញាប់ផឹកទឹកដោយសេចក្ដីស្រេក ហើយក៏ផ្ទួលខ្លួនដេកទៅវិញ គេបិទភ្នែកត្រឹមមួយសន្ទុះ ហើយសួរឡើងថា៖

- នេះយើងនៅឯណា? ម៉េចបានជាងងឹតយ៉ាងនេះ?

- យើងនៅក្នុងព្រៃ ត្រង់ដែលឡានក្រឡាប់នោះអីឯង

ចាំមិនបានទេឬ?

- អ្ហ៎! ខ្ញុំចាំបានហើយៗ ជីដូនមួយ...ជីដូនមួយ... គេនិយាយដោយសម្លេងខ្សាវៗ ហើយគេបញ្ចេញសម្លេងដូចជាយំខ្សឹកខ្សួល

- តើឯងនៅម្នាក់ឯងឬ? គេសួរក្រោយពីស្ងាត់មួយសន្ទុះមក

- គ្នានៅជាមួយព្រះអង្គ, នាយអាយឆ្លើយ

- ឯងចាំបានទេ? ព្រះសង្ឃដែលយើងជួបនៅតាមផ្លូវព្រឹកមិញនោះអី លោកបានមកដល់ទាន់យើងល្មម ចំណែកអ្នកឯទៀតៗ គេទៅអស់ហើយ គឺលោកបានគង់ចាំនៅជាមួយយើងនេះឯង, នាយចិនផ្ទៀងក្បាលមកមើលអាត្មា យកដៃស្រវាស្រវាចាប់ដៃអាត្មា ទៅប្រណម្យដាក់លើក្បាលរបស់គេ ហើយពោលចេញមកខ្សាវៗថា៖

- **សង្ឃំ សរណំ គច្ឆាមិ**! ហើយក៏ស្រែកយំទួញគួរឲ្យស្រណោះ

អាត្មាគិតថា ប្រហែលគេខ្វួចចិត្តស្ដាយដែលបានធ្វើខុសមកលើអាត្មានៅថ្ងៃមុននោះ ។

- ព្រះអង្គ! គេពោលឡើងដោយសម្លេងញ័រៗ, លើកលែងទោសឲ្យខ្ញុំកូណាផងទាន, ខ្ញុំកូណាធ្វើទៅគឺដោយសេចក្ដីល្ងង់ខ្លៅ ខ្ញុំកូណាស្ដាយក្រោយណាស់ទាន ពេលនេះខ្ញុំកូណាបានដឹងនូវការពិតហើយ ខ្ញុំកូណាពិតជាមានការសោកស្ដាយណាស់ ! ពោលហើយ គេក៏ស្រែកយំដូចកូនក្មេង

- កុំខូចចិត្តស្តាយអីញោមអើយ ! អាត្មាពោលជួយលួងលោម, អាត្មាមិនយកទោសខឹងសម្បារនឹងអ្នកទេ អាត្មាដឹងច្បាស់ថា លោកធ្វើដោយមោហៈ នៅពេលលោកដឹងខ្លួនថាបានធ្វើខុសគឺជាការប្រសើរណាស់ហើយ តទៅកុំធ្វើទៀត

- ខ្ញុំកូណាសូមទទួលថា ខ្ញុំកូណានឹងមិនធ្វើនូវអំពើអាក្រក់ផ្សេងៗទៀតទេទាន ពីព្រោះខ្ញុំកូណាបានដឹងនូវការពិតអស់ហើយ ខ្ញុំម្ចាស់បានឃើញមកផ្ទាល់ភ្នែកហើយ គួរខ្លាចខ្លាំងណាស់លោកម្ចាស់ ពិតជាគួរឲ្យខ្លាចមែនៗ

អាត្មាមិនយល់នូវន័យ ដែលគេកំពុងពោលមកនេះទេពាក្យសំដីចុងក្រោយរបស់គេ ធ្វើឲ្យអាត្មារឹងរឹតតែមានចម្ងល់ ទើបសួរឡើងថា៖

- លោកបានឃើញស្អីខ្លះ ?

- ខ្ញុំម្ចាស់ជឿច្បាស់ថា មាននរកប្រាកដមែនណាំទាន លោកម្ចាស់ ! ពេលមុនខ្ញុំម្ចាស់ធ្លាប់បានឮតែលោកទេសនា ខ្ញុំគិតថាមិនមានទេ មិនព្រមជឿលោកទេ ទើបខ្ញុំមិនសូវជឿនិងខ្លាចបាប ខ្លាចកម្មពៀរ នៅពេលនេះខ្ញុំបានដឹង បានឃើញច្បាស់ហើយ តទៅនេះខ្ញុំកូណានឹងមិនធ្វើនូវអំពើអាក្រក់ទៀតជាដាច់ខាត គួរឲ្យខ្លាចខ្លាំងណាស់

- លោកបានជួបបានឃើញស្អីមកខ្លះ និយាយប្រាប់ឲ្យអាត្មាបានស្តាប់ខ្លះមើល៍ !

ក្មេងកំលោះដែលឈ្មោះចឹង ស្មេចភ្នែកព្រឹមៗដូចជាកំពុងគិតនូវសេចក្តីចងចាំ ហើយនិយាយថា៖

- ពេលឡានបានជួបនូវគ្រោះថ្នាក់ ភ្លាមៗនោះសេចក្តីដឹងខ្លួននោះស្រាប់តែរលត់រូបទៅ ដូចជានៅស្រួលៗស្រាប់តែដូចកើតខ្យល់ចាប់ដួលគ្រឹបទៅ តែមិនយូរប៉ុន្មានខ្ញុំម្ចាស់ក៏ភ្ញាក់ខ្លួនឡើងពិនិត្យមើលមកខ្លួនឯង ជាធម្មតានៅពេលកំពុងឈរឆ្ងល់នោះ មានមនុស្សបួននាក់ សុទ្ធតែមានរាងកាយធំៗ ហើយមានសាច់ដុំសម្បុរខ្មៅរលោងចេញប្រេងស្លៀកពាក់ខោអាវពណ៌ក្រហម ចូលមករោមចាប់ខ្លួនខ្ញុំកូណា និងបាននាំដើរទៅយ៉ាងលឿន បើថាដើរដូចជាមិនមែន បើថារត់ក៏មិនមែន ហើយបើថាជាហោះក៏មិនមែន ប៉ុន្តែគឺរំកិលបានយ៉ាងលឿន រំលងព្រៃស្ពុក វាលស្រែ ភ្នំស្ទឹង បឹងបួរ លុះគ្រាខ្ញុំកូណាចាំមិនបានថាជាទីណាកន្លែងណានោះទេ ។ មួយសន្ទុះក្រោយមក ខ្ញុំកូណាក៏ត្រូវគេនាំខ្លួនទៅកន្លែងមួយដែលជាបន្ទប់ធំស្រឡះ ពេញទៅដោយមនុស្សគ្រប់ប្រភេទអង្គុយ ឈរ ដើរពាសពេញទីកន្លែងនោះទាំងមូល ។ ខ្ញុំកូណាក៏ត្រូវគេនាំខ្លួនបង្ហួសទៅឯតុធំមួយដែលមានបុរសរូបរាងគួរឲ្យខ្លាចម្នាក់អង្គុយ ។ នៅពេលដែលទៅដល់ ខ្ញុំកូណាមានសេចក្តីតក់ស្លុតចង់សន្លប់ ខណៈពេលនោះខ្ញុំកូណាបានឃើញ បងប្អូនជីដូនមួយរបស់ខ្ញុំកូណា អង្គុយនៅតុមួយផ្សេងទៀតឆ្ងាយ បន្តិចទៅគេត្រូវមនុស្សបួននាក់ ឃុំខ្លួនទុកយ៉ាងហ្មត់ចត់ដូចគ្នានឹងខ្ញុំកូណាដែរ ខ្ញុំមានអារម្មណ៍សប្បាយចិត្តដោយបានឃើញបងប្អូនជីដូនមួយ ប៉ុន្តែមានសេចក្តីកើតទុក្ខលាយឡំដោយបានឃើញគេនៅក្នុងសភាពដូច្នេះ ។ យើងឃើញគ្នានៅក្នុង

ព្រោះចម្ងាយឆ្ងាយគួរសម ទើបមិនអាចនិយាយគ្នាបានគ្រាន់តែសម្លឹងមើលគ្នាតែប៉ុណ្ណោះ ហើយក៏ត្រូវបុរសទាំងបួននាក់នោះ ទាញកញ្ឆក់បាត់ទៅក្នុងកណ្ដាលហ្វូងមនុស្សបាត់ទៅ មិនដឹងថាតើគេនាំគាត់យកទៅឯណាទេ ។

បុរសដែលអង្គុយនៅតុសម្លឹងមើលមកខ្ញុំ ដោយយកចិត្តទុកដាក់ ហើយពោលឡើងថា ៖

- ខ្មៅណាស់ៗ ! ដែលខ្ញុំមិនយល់ថា តើគេចង់មានន័យយ៉ាងណានោះទេ គេឱនចុះមើលសៀវភៅមួយយ៉ាងគ្រាស់ ដែលដាក់នៅលើតុ ហើយមើលមកមុខខ្ញុំចុះឡើងមួយសន្ទុះទើបគេ និយាយឡើងដោយមិនពេញចិត្តថា ៖

- សង្ស័យយកមនុស្សមកខុសហើយ ! និយាយហើយគេក៏សម្លឹងមើលមកខ្ញុំ ដោយពិនិត្យពិច័យម្ដងទៀត , យកមនុស្សមកខុសមែនហើយ, គេនិយាយយ៉ាងច្បាស់ក្នុងចិត្តឈ្មោះនាយចង់មួយនេះមិនទាន់ដល់ពេលនោះទេ នាយចង់ដែលយើងត្រូវការ នៅផ្ទះជិតៗគ្នានឹងនាយចង់ម្នាក់នេះដែរ តែអាយុចាស់ជាងម្នាក់នេះ ១ ឆ្នាំ រួចក៏បានងាកមើលទៅបុរសទាំងបួននាក់ ហើយក៏បញ្ជាដោយសម្លេងខ្លាំងឡើងថា ពួកឯងនាំគេទៅវិញ ហើយទៅយកនាយចង់ដែងម្នាក់នោះមក ។

នៅទីបំផុត ខ្ញុំក៏ត្រូវនាំខ្លួនពីបន្ទប់ធំនោះ ទៅបន្ទប់ធំមួយទៀត ដែលមានធាតុអាកាសក្ដៅ ពោរពេញទៅដោយផ្សែងភ្លើង ខ្ញុំគិតសង្ស័យយ៉ាងខ្លាំង ទើបសួរមនុស្សទាំងបួននាក់នោះថា ៖

- ទីនេះជាកន្លែងស្អីឲ្យប្រាកដ ប្រាប់ខ្ញុំផងបានទេ?
- ឯងមិនចាំបាច់ដឹងអ្វីទេ! បុរសម្នាក់និយាយឡើង ដោយសម្លេងកំហែង, បន្តិចទៀតឯងនឹងដឹងហើយ

ពោលរួចហើយ គេក៏នាំខ្ញុំដើរទៅយ៉ាងលឿន ៗ នៅពេលមកដល់កន្លែងមួយ ខ្ញុំរឹតតែមានការភ័យខ្លាចជិតសន្លប់ នៅពេលឃើញមនុស្សជាច្រើនត្រូវពួកក្រុមពាក់អាវក្រហម ចាប់សន្ធឹងនៅលើថ្មរាងជែងកន្លៅ គេយកដែកគោលដោតជាប់នឹងដៃទាំងពីរ និងជើងទាំងពីរខាង ហើយនៅលើដើមទ្រូងដាប់នឹងស៊ែនដែក ពួកទាំងនោះខំពើបម្រាស់ ពត់ពែនខ្លួន និងស្រែកដោយសម្លេងថ្ងូរឃំទ្រហឹងអឺងកង ៗ ខ្ញុំគេចមុខចេញពីភាពសាហាវទារុណនោះ ហើយដើរតាមមនុស្សទាំងបួននាក់ទៅ ដោយសេចក្តីរន្ធត់ស្លុតចិត្ត ៗ

យើងក៏បានមកដល់ទីកន្លែងមួយផ្សេងទៀត ទីនេះមានបរិយាកាសល្អជាងមុន មានគុម្ពឫស្សីដុះឡើងជាម្លប់ត្រជាក់គ្រប់ទីកន្លែង តាមក្រោមម្លប់ឫស្សីមានមនុស្សឈរដើរអង្គុយ ជេកជាច្រើនហូរហែ ៗ មួយសន្ទុះក្រោយមកដូចជាមានខ្យល់បក់ឆក់មកយ៉ាងខ្លាំង ធ្វើឲ្យព្រៃឫស្សីកើតសម្លេងយ៉ាងខ្លាំងអឺៗ សន្លឹកឫស្សីក៏ចាប់ផ្តើមជ្រុះមកលើដីជាជួរៗ ប៉ុន្តែព្រះអង្គអើយ ! ស្លឹកឫស្សីទាំងនោះបានក្លាយទៅជាលំពែង ដាវ យ៉ាងមុតស្រួច ធ្លាក់មកត្រូវចាក់ដោតទៅលើអ្នកទាំងអស់នោះ ពួកគេម្នាក់ៗស្រែកយំរត់ពេញទីនោះ ដើម្បីគេចពីលំពែង ដាវទាំងនោះ ៗ ប៉ុន្តែគ្មាននរណាអាចគេចផុតរួចសោះឡើយ ពីព្រោះស្លឹកដាវ លំពែង

ធ្លាក់មកគ្រប់ទិសទី, ខ្ញុំម្ចាស់គេចមុខចេញពីភាពអ័ព្ទគួរឲ្យអាណិតអាសូរនោះ ហើយក៏ដើរតាមអ្នកទាំងបួននាក់នោះទៅ ។

មួយកន្លែងទៀត ខ្ញុំម្ចាស់បានឃើញក្រុមពួកអារក្សក្រហម ចាប់មនុស្សជាច្រើននាក់ ចងជើងព្យួរទៅលើដើមឈើ យកក្បាលសំយ៉ុងចុះក្រោមដូចជា សត្វប្រចៀវ ហើយត្រូវពួកគេយកកាំបិតយ៉ាងធំចៀរតាមជើង និងរាងកាយដូចជាចៀរដើមឈើ សាច់ដុំដែលចៀរបាន ធ្លាក់មកជាគំនរគរទុកនៅលើដីជាបន្ទុះៗ មានឈាមហូរស្រោចចេញមកពេញរាងកាយ មនុស្សដែលទទួលរងគ្រោះកាចទាំងនោះនាំគ្នាស្រែកទ្រហោរយំដោយសេចក្ដីឈឺចាប់ ព្រួសព្រូងរងំអឺងកង ខ្ញុំម្ចាស់ក៏ធ្មេចភ្នែកបិទចេញពីភាពយ៉ាងទារុណកាចសាហាវនោះ ហើយក៏ដើរតាមអ្នកទាំងបួននោះទៅ ។

- លោកមេត្តានាំខ្ញុំចេញទៅឲ្យឆ្ងាយពីទីនេះឲ្យឆាប់ៗទៅ ខ្ញុំទ្រាំតទៅទៀតមិនបានឡើយ! ហើយខ្ញុំម្ចាស់ប្រាប់ពួកគេដោយសេចក្ដីតក់ស្លុត និងភិតភ័យយ៉ាងខ្លាំង

- ខំអត់សិនទៅ! បុរសដើរមុខប្រាប់ដោយសម្លេងដាច់ខាត, ឯងនឹងត្រូវមើលកន្លែងមួយ ឬពីរទៀតសិន ទើបអាចទៅបាន

ក្នុងទីកន្លែងមួយទៀត ខ្ញុំម្ចាស់ឃើញមនុស្សដ៏គួរឲ្យអាណិតជាច្រើនត្រូវចាប់ឲ្យទឹមចូលក្នុងរទេះ ហើយត្រូវបញ្ជាឲ្យអូសរទេះរត់ ទៅលើផ្លូវដែកដែលកំពុងតែក្ដៅទាំងអស់គ្នាលោតកញ្ជ្រោល ហើយស្រែកដោយទុក្ខ

ផ្ទៃនាសែនខ្លោចផ្សា, មានប្រុសម្នាក់រូបសរទេះរត់មកជិតៗ ខ្ញុំកូណា នៅពេលខ្ញុំកូណាសម្លឹងមើលទៅគាត់ គឺចាំបាន យ៉ាងច្បាស់ថា គឺជាបងជីដូនមួយនោះឯង ខ្ញុំកូណាភ្លេចខ្លួន ក៏បានស្រែកចេញមកយ៉ាងអស់សម្លេងថា៖

- បងៗ!

ហើយក៏កើតខ្យល់ចាប់ សែងដឹងខ្លួនក្នុងពេលនោះ ទៅ ៗ នៅពេលខ្ញុំកូណាដឹងខ្លួនឡើងម្តងទៀត ទើបបាន ដឹងថា ខ្លួនបានដេកសន្លប់នៅលើដីកណ្តាលមេឃងងឹតដូច ដែលលោកម្ចាស់បានឃើញនេះឯង, ក្មេងប្រុសនេះដេក ដកដង្ហើមធំ ហើយក៏បិទភ្នែក ៗ

មួយសន្ទុះក្រោយមក យើងក៏បានឮសម្លេងរថយន្ត និងពន្លឺភ្លើង ៗ មុខរថយន្តចោលមកពីផ្លូវទិសខាងត្បូង នាយអាយ ប្រញាប់ក្រោកស្ទុះចេញទៅឈរនៅកណ្តាល ថ្នល់បក់ដៃឲ្យរថយន្តឈប់ ៗ នៅពេលរថយន្តមកដល់ ហើយឈប់ យើងមានសេចក្តីត្រេកអរជាពន់ពេក ដោយ រថយន្តទាំងពីរគ្រឿងនេះ ជារថយន្តរបស់លោកចំណាន មួយ និងជារថយន្តរបស់ភ្នាក់ងារនគរបាលមួយ ៗ ភ្នាក់ងារ នគរបាល បានដើរត្រួតពិនិត្យមើលទីកន្លែងកើតហេតុ ហើយក៏នាំគ្នាជួយលើកសពដែលនៅសល់ ហើយលើក នាយចិង ឡើងរថយន្តដើម្បីត្រឡប់ទៅវិញដែរ, ទាំងអស់ គ្នាមានការប្លែកឆ្ងល់ក្នុងចិត្ត នៅពេលបានដឹងថានាយចិង ស្លាប់ទៅហើយ តែបែរជាបានរស់ទៅវិញ ៗ អាត្មាបាន លោកចំណាន សូមឲ្យនិមន្តត្រឡប់ទៅស្ទៀងម៉ែម្តងទៀត

សិន ទើបអាត្មាគាត់ចិត្តឡើងរថយន្តត្រឡប់ទៅតាមគេ ។ នៅយប់នោះឯង ក៏បានទទួលដំណឹងដោយសេចក្តីតក់ស្លុតចិត្តថា នាយចិនដែលជាអ្នកជិតខាងរបស់នាយចិនក្មេងប្រុសដែកសំបុត្រលើឡាននោះ ត្រូវបានស្លាប់ដោយរោគខ្យល់គ គឺនៅពេលល្ងាចថ្ងៃដដែលជាមួយគ្នា ...

# នរក សួគ៌

បទពាក្យ៧

នរកសួគ៌មានពិតក្នុងចិត្តមនុស្ស ផលបាបបុណ្យនោះសាងសួគ៌នរក
ពេលចិត្តសៅហ្មងកករល្អក់ សាងកម្មលាមកកាយវាចា ។
បានផលអាក្រក់តាមមកពិត ធ្វើឲ្យកាយចិត្តពិតទុក្ខា
នៅក្នុងបច្ចុប្បន្នដឹងគ្រប់គ្នា ចាំឆ្លងដល់ណាស្ថាននរកសួគ៌ ។
ពេលណាទឹកចិត្តបរិសុទ្ធថ្លា ប្រកបកម្មាល្អគាប់គួរ
កាយវាចាចិត្តពិតបវរ សុខសាន្តមានមកគ្រប់វេលា ។
នេះជានរកសួគ៌ក្នុងចិត្តមនុស្ស បញ្ជាក់បានអស់ឃើញគ្រប់គ្នា
ចំណែកនរកសួគ៌បរលោកា កើតដោយផលាកម្មបច្ចុប្បន្ន ។
ត្រូវខំព្យាយាមត្រៀមរៀនយល់ បំបាត់ចម្ងល់រឿងបាបបុណ្យ
បំពេញកម្មល្អជាដើមទុន ការពារទុកមុនមិនសោកា ។
ឥតព្រួយតក់ស្លុតរន្ធត់ភ័យ លែងខ្វល់សង្ស័យនរកសួគ៌ា
សុខក្នុងបច្ចុប្បន្នបរលោកា ព្រោះមានផលាអានិសង្សបុណ្យ ៕

ដោយឧបាសក ម៉ិញ សាវ៉ាង

# ២២. ផ្ទះខ្មោចនៅ

ពេលយើងត្រឡប់មកដល់ផ្ទះលោកចំណាននិញ ម៉ោងប្រហែលជាង ១០ យប់ទៅហើយ ទម្រាំមុជទឹកលាង ខ្លួនប្រាណរួច ក៏ជិតដល់ម៉ោង ១១ យប់ ។ នៅពេលដែល អាត្មាកំពុងគិតថា នឹងទៅឈប់សម្រាកនៅឯណាល្អ លោក ចំណានបានពោលឡើងដូចជានឹងចិត្តថា៖

- យប់នេះ សូមនិមន្តលោកម្ចាស់ឈប់សម្រាកនៅផ្ទះ របស់ខ្ញុំកូណានេះហើយ ខ្ញុំកូណាបានឲ្យគេរៀបចំបន្ទប់ ប្រគេនរៀបរយអស់ហើយ

- តាមធម្មតា អាត្មាមិនដែលសម្រាកនៅពេលយប់ នៅផ្ទះឧបាសក ឬឧបាសិកាណាទេ ពីព្រោះបានអធិដ្ឋានជា ធុតង្គវត្តមកតាំងតែពីថ្ងៃចូលបួសដំបូងមកម្ល៉េះ និងសម្រាក ក្នុងពេលយប់តែនៅក្រោមដើមឈើ ក្រោមសំយាបថ្មក្នុង ល្អាង ក្នុងទីវាល ក្នុងកុដិរបស់ព្រះសង្ឃ ឬក្នុងផ្ទះទំនេរដែល មិនមានមនុស្សនៅអាស្រ័យនោះទេ

លោកចំណានអង្គុយឈ្ងោកមុខ គិតមួយសន្ទុះ រួចឆ្លើយឡើងថា៖

- បើនឹងទៅសុំសម្រាកនៅឯវត្ត លោកនេនប្រហែល សឹងអស់ហើយ គឺជាការរំខានដល់លោក, ខ្ញុំកូណាចង់ឲ្យ លោកម្ចាស់សម្រាកនៅផ្ទះនេះដើម្បីជាសិរីមង្គល តើខ្ញុំកូណា គិតរបៀបណាឲ្យស្រួលទៅបាន?

- អាត្មា ដាក់ក្អួតសម្រាកនៅក្រោមដើមឈើណាមួយ ស្ថិតក្នុងបរិវេណជិតៗផ្ទះនេះក៏បាន

លោកចំណាននព្រមទាំងភរិយា ហើយអ្នកនៅក្នុងផ្ទះ មិនព្រមឲ្យអាត្មាធ្វើដូច្នោះទេ លើកយកហេតុផលផ្សេងៗ ហេតុផលដ៏សំខាន់ គឺខ្លាចក្រែងភ្លៀងធ្លាក់ ពីព្រោះធាតុអាកាសកំពុងក្តៅស្ទះ ហើយមានសម្លេងផ្គរលាន់ឮសូរគ្រឹមៗមកពីឆ្ងាយផង ។

- ការពិតខ្ញុំម្ចាស់មានផ្ទះមួយខ្នង នៅផ្លូវចូលទៅជ្រៅក្នុងសួនខាងក្រោយផ្ទះតែ.......

លោកចំណានឈប់និយាយតែត្រឹមនោះ ហើយក៏ងាកទៅមើលមុខភរិយា និងប្អូនស្រីគ្រមុំ ដូចជាមានន័យ ។

- មិនសមទេបង ! ភរិយារបស់គាត់ប្រញាប់បដិសេធ, កុំឲ្យលោកម្ចាស់ទៅសម្រាកឲ្យសោះ !

- វាជាផ្ទះតាំងពីបុរាណ ដែលចាស់ទ្រុឌទ្រោម, លោកចំណានអធិប្បាយ, ហើយមិនមាននរណាមករស់នៅអស់រយៈពេលយូរណាស់មកហើយ ប្រហែលជាមិនស្អាត និងមានសំរាមពាសពេញ

- កខ្វក់ក៏មិនជាការអ្វីដែរ អាត្មាត្រូវការកន្លែងតូចមួយសម្រាប់ដាក់ខ្លួនសិនប៉ុណ្ណោះ !

គ្រប់ៗគ្នាសម្លឹងកិរិយា អាការៈស្ងាក់ស្ទើរចិត្តមួយសន្ទុះ ហើយប្អូនស្រីគ្រមុំរបស់លោកចំណានដែលឈ្មោះថាដួងកែវ ក៏ពោលឡើងថា៖

- បើលោកម្ចាស់ពេញចិត្តចង់ទៅសម្រាកនៅទីនោះ

ហើយ ក៏ឲ្យលោកសម្រាកទៅចុះមានស្អី ! លោកជាព្រះសង្ឃ ចុតន្តមានសីល មានធម៌ គង់លោកមិនខ្លាចអីទេនឹង !

ពាក្យពោលអឺមានន័យរបស់នាងស្រីដួងកែវ ទើបតែរៀនចប់ បានសញ្ញាប័ត្រខាងវិទ្យាសាស្ត្រមកពីបាងកក ធ្វើឲ្យអាត្មាយល់បានភ្លាមថា ផ្ទះមួយនោះគង់នឹងមានស្អីម៉្យាងជាក់ជាមិនខានដែលគួរឲ្យខ្លាចជាប្រាកដ ទើបអាត្មាឆ្លើយថា៖

- មនុស្សក្នុងលោកនេះ ខ្លាចសេចក្ដីស្លាប់ជាងរបស់អ្វីទាំងអស់ បើមិនខ្លាចស្លាប់តែម៉្យាងក៏មិនមានអ្វីក្នុងលោកដែលនឹងធ្វើឲ្យគេខ្លាចបានដែរ

- តើលោកម្ចាស់ខ្លាចសេចក្ដីស្លាប់ដែរឬទេ ? ដួងកែវសួរឡើងភ្លាមៗ ព្រមទាំងឫកពា វាចា និងកិរិយារបស់នាងបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា នាងជាមនុស្សក្លាហាន និងឆ្លាត ហើយអាចនិងមិនសូវមានសេចក្ដីជ្រះថ្លាក្នុងពាក្យប្រៀនប្រដៅខាងសាសនាផង

- ដួងកែវនេះសួរស្អីក៏មិនដឹងទេ ! លោកចំណាននាគទៅនិយាយជាមួយប្អូនស្រីគ្រមុំដូចជាទំនងបន្ទ្រាប

- សេចក្ដីស្លាប់អាត្មាមិនខ្លាចទេ ខ្លាចតែសេចក្ដីកើត, អាត្មាឆ្លើយជាពាក្យរាងនិយាយលេងបន្តិច ដើម្បីឲ្យដួងកែវឆ្ងល់ ហើយដើម្បីពញ្ញាក់ឲ្យគេគិតក្នុងបញ្ហាដ៏ជ្រៅ ទៅក្នុងផ្លូវប្រាជ្ញាខ្លះផង នាងស្រីគេសម្លឹងមកអាត្មាលើបឆ្ងល់មួយសន្ទុះហើយនិយាយឡើងថា៖

- បើសិនជាលោកមិនខ្លាចនូវសេចក្ដីស្លាប់ទេ គឺជាការល្អហើយយើងនឹងបានធ្វើការពិសោធន៍គ្នាម្ដងមើល ខ្ញុំម្ចាស់

ជាអ្នកវិទ្យាសាស្ត្រ ចូលចិត្តនូវការពិសោធន៍

- ន្លងកែវ! លោកចំណាននហៅឈ្មោះប្អូនស្រីគ្រប់បែប បន្ទូសនូវសម្លេង, និយាយជាមួយព្រះសង្ឃត្រូវចេះរៀបរយ ពាក្យសម្តីបន្តិចមើល៍ ស្អីនេះគ្រាន់តែជួបលោកមួយភ្លែត ស្រាប់តែចាប់ផ្តើមតវ៉ា ប្រកែកជាមួយលោកទៅហើយ!

- មិនអីទេញោម! អាត្មានិយាយដោយញញឹមៗដើម្បី រក្សាបរិយាកាសឲ្យត្រជាក់ៗ, ការប្រកែកគ្នាដោយសតិបញ្ញា ដើម្បីសេចក្តីចេះដឹងគឺជាអ្វីដែលអាត្មាចូលចិត្ត អាត្មាមិនបាន ប្រកែកជាមួយនរណាមកយូរហើយ ថ្ងៃនេះគិតថាសំណាង ល្អពីរដាន់ដែលបានជួបនឹងបណ្ឌិត អ្នកមានការចេះដឹង ហើយក៏អាចពិសោធន៍ផ្ទុះ ដែលគួរឲ្យខ្លាចមួយខ្ទង់នោះផង មានន័យថា យប់នេះអាត្មានឹងសុំទៅសម្រាកនៅផ្ទះមួយ ខ្ទង់នោះហើយណា៎!

- លោកម្ចាស់! លោកចំណាននពោលបន្លឺឡើងដោយ អាការៈខ្វាយខ្វល់ក្នុងចិត្ត, កុំអីល្អជាងទាន! បើលោកម្ចាស់ មេត្តាអនុគ្រោះខ្ញុំកូណា សូមនិមន្តទៅដាក់ក្លុតនៅតាម ដើមឈើក្នុងបរិវេណផ្ទះខ្ញុំកូណានេះវិញចុះ ពីព្រោះលោក ម្ចាស់នៅក្នុងសេចក្តីទទួលខុសត្រូវរបស់ខ្ញុំកូណា បើសិន មានការអ្វីកើតឡើង ខ្ញុំកូណាជាអ្នកទទួលខុសត្រូវទាន

ពាក្យពោលរបស់លោកចំណានន ធ្វើឲ្យអាត្មាកើត សេចក្តីសង្ស័យខ្លាំងឡើងៗ ទើបសួរថា ៖

- ផ្ទះមួយនោះមានស្អីខុសចម្លែកឬ? ចូរប្រាប់នូវការ ពិតឲ្យអាត្មាបានដឹងផង កុំនៅអឹមអៀនទៀតអី!

- គឺជាផ្ទះខ្មោចនៅណាលោកម្ចាស់! ដូនតែវងងក្ដោមឆ្លើយឡើងមុន ធ្វើឲ្យទាំងអស់គ្នាភ្ញាក់ងាកទៅមើលគេដោយខ្សែភ្នែកសម្លឹង នូវសេចក្ដីមិនពេញចិត្ត, រឿងការពិតមិនចាំបាច់បិទបាំងធ្វើអ្វី

- អរគុណច្រើន! ដែលបានប្រាប់នូវការពិតឲ្យអាត្មាបានដឹង តែអាត្មាចង់ដឹងថាតើផ្ទះខ្មោចនោះវាសម្លឹងយ៉ាងណាខ្លះ ទើបបានដឹងថាមានខ្មោចនៅទីកន្លែងនោះ?

លោកចំណាស់បានរៀបរាប់ឲ្យស្ដាប់ថា៖ ផ្ទះនោះគឺជាផ្ទះបែបបុរាណ ដែលកសាងពីឈើទាំងអស់ ហើយក៏ជាកេរមរតកបែកតៗគ្នាមក ពីជីដូនជីតាជំនាន់ដើមតែមិនមាននរណាហ៊ានទៅនៅទីនោះទេ ពីព្រោះត្រូវខ្មោចលង ហើយក៏ធ្លាប់មានមនុស្សមកជួលនៅច្រើនគ្នាហើយ តែភាគច្រើននៅបានប្រហែលមួយយប់ក៏រត់បាត់ទៅ មានអ្នកខ្លះទៀតដែលមិនសូវជឿពីរឿងខ្មោច ទ្រាំនៅបានច្រើនថ្ងៃ តែនៅទីបំផុតក៏ឈឺហើយ ក៏រត់ឈប់នៅ រីឯអ្នកខ្លះទៀតឈឺរហូតដល់ស្លាប់ក៏មាន, អ្នកនៅចុងក្រោយនោះគឺជនជាតិបារាំងធ្វើការនៅបរិសុទ្ធឈើជាមួយកូន និងប្អូន ដែលមិនជឿរឿងខ្មោច បារាំងមួយនោះជួលនៅបានតែបីថ្ងៃ ក៏ទៅជាឆ្កួតបងប្អូនត្រូវប្រញាប់នាំទៅព្យាបាលនៅឯបាងកក ។ តាំងពីពេលនោះមក គ្មាននរណាហ៊ានមកជួលនៅទៀតទេ ប្រហែលជាដប់ឆ្នាំជាងមកហើយ ពីព្រោះរឿងនេះឯង ទើបខ្ញុំកូណា មិនហ៊ានឲ្យលោកម្ចាស់ទៅសម្រាកនៅទីនោះ ។ លោកចំណាស់ក៏ពោលសរុបសេចក្ដីនៅទីបំផុត ។

- ញោមដួងកែវជឿឬទេថាមានខ្មោច? អាត្មាងាកទៅសួរបណ្ឌិតក្រមុំ

- នៅមិនទាន់ជឿទេ! គេឆ្លើយយ៉ាងដាច់ខាត

- ដូចម្ដេចក៏មិនពិសោធមើល? អាត្មាសួរ

- មិនសូវជឿ តែក៏មិនហ៊ាន! គេឆ្លើយសម្លេងតិចៗ ញញឹមស្ងួតៗដោយបង្ហាញនូវស្ដីគេទចេញមកឲ្យឃើញ

- ល្អហើយចុះ! អាត្មានឹងសាកល្បងមើល, អាត្មាពោលឡើងធ្វើឲ្យលោកចំណាស់ភ័យបើកភ្នែកធំៗ

- ញោមកុំភ័យ អាត្មាធ្លាប់ជួបរឿងយ៉ាងនេះច្រើនមកហើយ បើអាត្មាកើតស្អីក្នុងពេលនេះញោមមិនបាច់ទទួលខុសត្រូវស្អីទាំងអស់ ពីព្រោះជាការស្ម័គ្រចិត្តរបស់អាត្មាខ្លួនឯង ទាំងអស់គ្នានៅក្នុងផ្ទះនេះជាសាក្សីឲ្យលោកបាន

ក្រោយពីបានចរចាគ្នាអស់ពេលយូរ លោកចំណាស់ក៏យល់ព្រម ហើយបាននាំអាត្មាដើរកាត់តាមទីងងឹតនៃដើមមៀនទៅផ្ទះមានខ្មោចនៅ ដែលសង់នៅពាក់កណ្ដាលចំការមៀនយ៉ាងស្ងាត់ច្រៀប ឆ្ងាយទៅបន្តិចមានដើមកៅស៊ូធំៗបីបួនដើម អាចបង្ហាញឲ្យឃើញនូវសេចក្ដីទ្រុឌទ្រោមនៃទីកន្លែងនោះ ។ លោកចំណាស់ផ្ទុះភ្លើងពិល ដើរនាំមុខអាត្មាឡើងជណ្ដើរដែលធំទូលាយ ទៅបើកទ្វារបន្ទប់ខាងមុខឲ្យអាត្មា៖

- លោកម្ចាស់ត្រូវការបន្ទប់ណា និមន្តរើសយកតាមព្រះទ័យ គ្រប់បន្ទប់អាចបើកភ្លើងបានទាំងអស់, គេបើកភ្លើងបន្ទប់នីមួយៗឲ្យអាត្មា រួចចង្អុលប្រាប់ផ្លូវទៅបន្ទប់ទឹក

ហើយក៏លាទៅវិញ ដោយទឹកមុខបង្ហាញនូវសេចក្ដីភ័យ ព្រួយជាខ្លាំង ។

អាត្មារៀបចំតម្លើងក្រុតដាក់មុន គ្រាលសំពត់ ដាក់បរិក្ខារស្រួលបួលហើយ ក៏បិទភ្លើងចូលក្នុងក្រុត ថ្វាយបង្គំព្រះ សូត្រមន្ត ផ្សាយមេត្តាដល់ទេវតា និងលោកអ្នកថែរក្សាទីកន្លែងនិងសព្វសត្វ ហើយក៏ផ្ដេកខ្លួនសឹង ដោយសេចក្ដីហត់នឿយ ។ នៅពេលកំពុងជិតនឹងលង់លក់នោះឯង អាត្មាត្រូវភ្ញាក់ព្រើត ដោយបានឮសម្លេងជើងមនុស្សដើរគឹកៗនៅក្នុងបន្ទប់ខាងស្ដាំដៃ នៅពេលអាត្មាផ្ទៀងត្រចៀកតាំងចិត្តស្ដាប់សម្លេងជើង ក៏ត្រឡប់ទៅឮនៅក្នុងបន្ទប់ខាងឆ្វេងដៃវិញ បន្តិចឮនៅចុងជើង ហើយក៏វិលទៅខាងបន្ទប់ខាងស្ដាំទៀត ។ អាត្មាដេកបើកភ្នែកឡើងនៅក្នុងភាពងងឹតតាំងសតិឲ្យមាំ តាំងចិត្តស្ដាប់នូវសម្លេងជើងមនុស្សដើរដោយយកចិត្តទុកដាក់ ។

មួយសន្ទុះធំកន្លងទៅ សម្លេងជើងដើរក៏ស្ងប់ តែមានសម្លេងផ្សេងទៀតម្ដង នៅពេលនោះជាសម្លេងអម្បោសប៉ះនឹងក្ដារបន្ទប់ មានសម្លេងខ្លាំងដូចជាមនុស្សកំពុងបោសផ្ទះប្រហែលគ្នា នឹងសម្លេងជើងមនុស្សដើរ សម្លេងបោសផ្ទះឮពីបន្ទប់នោះមកដល់បន្ទប់នេះ រហូតដល់ស្វាត់ទៅវិញ ។ អាត្មាមិនបានភ្ញាក់ផ្អើលភ័យខ្លាចអ្វីទេ ផ្ទុយទៅវិញត្រឡប់ជានឹកសរសើរការឧស្សាហ៍ ខ្នះខ្នែង យកចិត្តទុកដាក់ក្នុងការមើលខុសត្រូវថែរក្សាផ្ទះរបស់ភូតបិសាចម្នាក់នោះ ។ អាត្មាភ្ញាក់ផ្អើលម្ដងទៀត នៅពេលដែលភ្លើងក្នុងបន្ទប់ឆេះឡើង

ដោយគ្មានមូលហេតុ ៗ មួយរំពេចនោះ អាត្មាក៏ក្រឡេកមើលពីក្នុងមុងទៅឃើញកន្លែងបើកភ្លើង, តែមិនឃើញមានអ្នកណានៅជិតទីនោះទេ ក្រោកអង្គុយញីភ្នែកសម្លឹងមើលជុំវិញបន្ទប់ ក៏មិនមាននរណាម្នាក់ទាល់តែសោះ សេចក្តីងឿងឆ្ងល់ក្នុងចិត្ត ដែលធ្វើឲ្យរំខាននៅពេលអង្គុយសម្រាក ចាប់ផ្តើមខ្វល់ក្នុងចិត្ត តែនៅពេលមានស្មារតីឡើង អាត្មាប្រញាប់រម្ងាប់ចិត្តនោះចេញ ៗ

នៅពេលអាត្មាកំពុងនឹងបើកមុង រៀបនឹងទៅបិទភ្លើងនោះឯង ក៏បានឮសម្លេងបិទភ្លើងគ្រឹបទៅដោយខ្លួនឯងវិញ ដោយមិនមាននរណាបិទសោះ អាត្មាអង្គុយឆ្ងល់នៅក្នុងសេចក្តីងងឹតមួយសន្ទុះ ហើយត្រៀមខ្លួននឹងសឹងតទៅទៀត ប៉ុន្តែត្រូវឈប់វិញ ពីព្រោះភ្លើងត្រូវបានបើកឡើងវិញ លើកនេះសេចក្តីបួប៉ោកើតឡើងច្រើនជាងមុន ប៉ុន្តែអាត្មាព្យាយាមរម្ងាប់វិញ ព្រមទាំងបានដឹងថារម្ងាប់វាបានដោយពិបាក នៅដែលកំពុងតស៊ូជាមួយសេចក្តីដឹងខ្លួនឯង ៗ ក្នុងពេលនោះត្រចៀកបានឮសម្លេងមនុស្សសើចដូចជាអ្នកមានកម្លាំងបានឈ្នះ ឮសូរចេញមកពីបន្ទប់នៅជិតហ្នឹងឯង ៗ សម្លេងសើចក្នុងបំពង់ក ជាចង្វាក់យឺតៗនោះធ្វើឲ្យអាត្មាចាប់អារម្មណ៍ គិតទៅដល់ពាក្យប្រៀនប្រដៅរបស់លោកគ្រូ ដែលលោកថា ការតស៊ូជាមួយនឹងស្ពឺក៏ដោយមិនថានឹងតស៊ូជាមួយមនុស្សឬខ្មោចកុំបណ្តោយឲ្យអារម្មណ៍ខ្លាច ឬខឹងចូលសង្កត់ចិត្តជាដាច់ខាត ពីព្រោះចិត្តដែលត្រូវអារម្មណ៍គ្របសង្កត់ហើយ តែងខ្សោយទៅ-

អោយភ័យខ្លាច ខ្វះនូវកម្លាំង ជាការធ្វើឲ្យភ័ន្តភាំងខ្សោយស្លេចខ្លួន អាចធ្វើឲ្យសត្រូវឃើញ និងមានផ្លូវចាញ់គេបានយ៉ាងងាយ ទើបអាត្មាប្រមូលកម្លាំងចិត្តកំចាត់នូវបដិឃៈ(១) នោះ ពេលដែលបដិឃៈបាត់ទៅពីចិត្ត សម្លេងចម្លែកសើចនោះក៏បាត់ទៅដែរ ។

អាត្មាបានកាត់ចិត្តថា មិនក្រោកទៅបិទភ្លើងទេ ពីព្រោះខ្លាចថា នឹងត្រូវគេដណ្ដើមបិទជាមុន ហើយបដិឃៈចិត្តក៏កើតឡើងទៀត ទើបអង្គុយនៅស្ងៀម ចាំមើលហេតុការណ៍តទៅទៀត ។ មួយសន្ទុះធំក៏កន្លងផុតទៅ ក៏មិនទាន់ឃើញមានហេតុការណ៍អ្វីទៀតកើតឡើង ភ្លើងនៅតែបើកភ្លឺដដែល ផ្ទះទាំងមូលនៅក្នុងសភាពស្ងាត់ជ្រងំ ។ អាត្មាបានយល់ថា បើជាបិសាចមែន បិសាចនោះប្រហែលកំពុងគិតងាក់ងើនការថា តើនឹងគិតធ្វើយ៉ាងណាជាមួយអាត្មាតទៅទៀត ពីព្រោះអ្វីៗដែលបានធ្វើមកហើយនោះ មិនបានលទ្ធផលអ្វីសោះ ពីព្រោះមិនបានធ្វើឲ្យអាត្មាភ័យខ្លាចអ្វីសោះក្រៅពីភ្ញាក់តែនៅពេលដំបូងប៉ុណ្ណោះ ។ សេចក្ដីក្លាហានខុសអំពីពេលមុនៗរបស់អាត្មា ប្រហែលឲ្យបិសាចត្រូវប្រើសេចក្ដីគិតគូរយ៉ាងច្រើនដូចគ្នា ។

អាត្មាចាប់ងងុយសឹង ទើបតែផ្ដេកខ្លួនដេកដោយមិនបានបិទភ្លើង ។ នៅពេលហៀបនឹងលក់ស្រើវៗ អាត្មាត្រូវ

---

(១) បដិឃៈ ប៉ៈ- បា.; សំ. ( ន. ) (បដិឃ; ប្រតិឃ) សេចក្ដីចង្អៀតចិត្ត, សេចក្ដីក្ដាញ់, ដំណើរប៉ះទង្គុកចិត្តដោយសេចក្ដីក្រោធ : កើតមានបដិឃៈ, រំងាប់បដិឃៈ ។ រ. ស. កិ. ទ្រង់ព្រះបដិឃៈ គឺទ្រង់ក្ដាញ់ ។ បដិឃចិត្ត ចិត្តដែលមានបដិឃៈ, ចិត្តក្ដាញ់ ។

ម្នាក់ម្តងទៀត ពីព្រោះបិសាចបានបញ្ចេញឥទ្ធិពលថ្មីទៀតមកលើអាត្មា ។ ពេលនេះវាធ្វើដូចជាខ្លាំងជាងមុន គឺទាញទ្វារបន្ទប់ដែលនៅខាងចុងជើងរបស់អាត្មា ឲ្យបើកឡើងយ៉ាងលឿន ហើយឮសូរសម្លេងខ្ទុំរខ្លាំង ធ្វើផ្ទះទាំងមូលកម្រើកញ័រ ។ អាត្មាស្ទុះក្រោកអង្គុយ សម្លឹងទៅខាងទ្វារតែមិនបានប្រទះឃើញអ្វីបន្តិចសោះ ។ នៅពេលអាត្មាកំពុងអង្គុយសម្លឹងមើលទៅទ្វារនោះ ក៏បានឮសម្លេងជើងមនុស្សដើររសើបៗ នៅក្នុងបន្ទប់ខាងឆ្វេងដៃ ហើយឮសម្លេងក្តុងក្តាំង ដូចជាសម្លេងដែកប៉ះទង្គិចគ្នា ។ សម្លេងជើងដើរស្រើបៗ ទៅផ្លូវបន្ទប់ខាងមុខអាត្មាហើយក៏ឈប់ ។ នៅពេលមើលទៅខាងទ្វារម្តងទៀត អាត្មាបានជួបប្រទះនូវរូបភាពចម្លែកមួយ ពោលគឺមានដាវព្យួរនូវនឹងស្មារឈរនៅលើអាកាស រវាងទ្វារនិងដំបូលផ្ទះខាងលើ ខ្លួនទទេពាក់ឆៀងសំយ៉ុងទៅក្រោម លក្ខណៈរបស់ដាវរបស់បុរាណស្រោមដាវរុំពីទ្ធជុំវិញដោយប្រាក់ពណ៌ស រលោងនៅពេលចាំងត្រូវពន្លឺភ្លើង ។

នៅពេលឃើញអាវុធដូច្នោះ អាត្មាបានដឹងភ្លាមថាបិសាចមួយនេះមានចេតនាអាក្រក់មកលើអាត្មាហើយ បើតស៊ូជាមួយនឹងវាក្នុងឋានៈជាមនុស្ស អាត្មាច្បាស់ជាត្រូវទទួលក្តីអន្តរាយជាមិនខាន ទើបសម្រេចចិត្តតស៊ូជាមួយគេក្នុងឋានៈជាអមនុស្សវិញ ។ អាត្មាប្រញាប់ចូលដែនកំណាត់ចិត្តធ្វើសមាធិភ្លាម ពេលចិត្តស្ងប់ត្រជាក់ជាអប្បនាសមាធិនិវរណធម៌ទាំង ៥ ក៏រលត់, ពន្លឺក៏កើតឡើងក្នុងចិត្ត ធ្វើឲ្យ

អាត្មាអាចមើលឃើញផ្ទះនោះយ៉ាងច្បាស់ដូចពេលថ្ងៃ ។ ត្រង់ទ្វារខាងមុខនោះ មានប្រុសចាស់ម្នាក់ឈរស្ពាយដាវថ្មីង សម្លឹងថ្មើមើលមកអាត្មាដោយខ្សែភ្នែកខឹងសម្បារ ។ ទាយមើលទៅអាយុគាត់ប្រហែលជាក្នុងរវាង ៦០ ឆ្នាំ តែងខ្លួនបែបទាហានជំនាន់បុរាណ មានមាឌធំខ្ពស់ កម្លាំងខ្លាំងក្បាលសស្កុះ ។

- លោកជានរណា? មកធ្វើអ្វីនៅទីនេះ? អាត្មាសួរដោយចិត្ត

បុរសចម្លែកញញឹម ហើយឆ្លើយដោយសម្តីតាមសំនៀងភាសាអ្នកខាងត្បូងរដឺនៗ ថា៖

- ខ្ញុំករុណា គួរតែជាអ្នកសួរលោកថា លោកជានរណា មកធ្វើអ្វីនៅទីនេះ តែបើព្រះអង្គបានសួរហើយ ខ្ញុំករុណាក៏ត្រូវតែប្រាប់... ខ្ញុំករុណាគឺម៉ឺន សែនហ្វា ជាទាហានឯករបស់ព្រះចៅសែន មឿង ហើយជាម្ចាស់ផ្ទះ ម្ចាស់ទីកន្លែងនៅទីនេះ, តើលោកជានរណា មកពីណា?

- អាត្មាជាព្រះសង្ឃ បួសឧទ្ទិសជីវិតឆ្ពោះទៅព្រះបរមសាស្តាសម្មាសម្ពុទ្ធ ដើរទៅរហូត ដើម្បីបំពេញព្យាយាមដុសខាត់នូវកិលេសជាដំបូង ដើម្បីសេចក្តីបរិសុទ្ធផុតអំពីការកើតស្លាប់ក្នុងវាលវដ្តសង្សារ អាត្មាមកសូមសម្រាកអាស្រ័យក្នុងផ្ទះរបស់លោកតែមួយយប់ប៉ុណ្ណោះ ថ្ងៃស្អែកក៏នឹងចេញទៅវិញ

អស្សុរកាយ ម៉ឺន សែនហ្វា សម្លឹងមើលមកអាត្មាដោយសេចក្តីសង្ស័យ ហើយក៏សួរឡើងដោយសម្លេង

ខ្លាំងៗថា៖

- លោកមកពីស្រុកខាងលិចមែនទេ?
- មែន! អាត្មាឆ្លើយ,

ទឹកមុខរបស់គេធ្មឹង មាំខ្លាំងឡើង ហើយស្រែកនិង មើលមកអាត្មាដូចជាចង់អាឃាតព្យាបាទហើយសួរថា៖

- លោកមានអាគមគាថាមកជាមួយមែនទេ? លោកតាមមកយកទ្រព្យសម្បត្តិរបស់យើង តាមធ្វើបាបដូចព្រះសង្ឃស្រុកក្រោមអន្លុងមុនៗមែនទេ?

# មិនទៀង...

បទពាក្យ៧

**អ្នកមានពុំបានបីតំណ អ្នកក្រពុំដែលបីជំនាន់**
**ជីវិតដូចទឹកស្រកជោរជន់ ដោយផលបាបបុណ្យប្តូរវេនគ្នា ។**
**ដូច្នេះត្រូវខំព្យាយាមហាត់ កុំឆ្មេសប្រយ័ត្ននឹងកម្មពៀរ**
**ជីវិតប្តូរផ្លាស់តាមវេលា កុំមើលងាយគ្នានាំសោកសៅ ៕**

ដោយឧបាសក មុិញ សារ៉ាង

# ២៣. ផ្ទះសំណាក់លោក

មុននឹងអាត្មាបានឆ្លើយឆ្លង អស្សុរគាយ ម៉ីនសែនហ្វា ក៏ទាញយកដាវចេញពីស្រោមយ៉ាងឆាប់រហ័ស គាន់ដាវយ៉ាងមុតខ្មៅក្រិបរលោងដូចឈាបប្រេងនៅនៃ ដើរចូលមកជិតអាត្មា ហើយពោលពាក្យយ៉ាងក្តៅក្រហាយថា៖

- លោកឯងត្រូវតែស្លាប់ដូចអ្នកឯទៀតៗ ដែលចង់មកលួចរឹមយកទ្រព្យសម្បត្តិរបស់យើង

អាត្មាមិនបាននឹកខ្លាចនូវសេចក្តីស្លាប់ដែលនៅចំពោះមុខសូម្បីតែបន្តិចសោះ គ្រាន់តែព្រួយបារម្ភថា បើអស្សុរគាយ ម៉ីនសែនហ្វា បានប្រទូសរ៉ាយជាមួយអាត្មា ដែលជាអ្នកមានសីល មានធម៌ហើយមិនដែលគិតនឹងប្រទូសរ៉ាយដល់អ្នកណាផង អកុសលកម្មដែលគេបានធ្វើនេះនឹងនាំសេចក្តីទុក្ខមកឲ្យគេអស់កាលដ៏វែងឆ្ងាយ គឺជាការបន្ថែមបាបកម្មដ៏អាក្រក់ដែលគេបានធ្វើមកហើយ ថែមគាន់តែច្រើនឡើងទៀតដោយមិនចាំបាច់ ។

គិតដូច្នេះហើយ ទើបអាត្មាអធិដ្ឋានដោយសមាធិចិត្តដែលមានផលខ្ពស់ក្នុងខណៈនោះថា៖

- ខ្ញុំម្ចាស់លះវិស័យលោកីយ៍ចេញបួស គឺដើម្បីធ្វើដំណើរតាមអរិយមគ្គទៅដល់អរិយផល មិនមានចេតនាអ្វីផ្សេងៗ នេះជាពាក្យសច្ចៈប្រការ ១, ខ្ញុំម្ចាស់មកសម្រាកនៅផ្ទះទំនេរនេះ ដោយចេតនាបរិសុទ្ធ មិនបានគិតប្រទូសរ៉ាយ

ជាម្ចាស់អ្នកណា ឬទ្រព្យសម្បត្តិរបស់អ្នកណា នេះជាសច្ចៈ ប្រការ ២, ដោយអំណាចនៃសច្ចៈវាចានេះ សូមឲ្យខ្ញុំម្ចាស់ បានរួចរំដោះភ័យវិបត្តិនៅពេលនេះផង

នៅពេលអាត្មាអធិដ្ឋានរួច ម៉ឺនសែនហ្វា ក៏មកឈរ ថ្មឹងនៅចំពោះមុខអាត្មា ក្នុងចម្ងាយឃ្លាតគ្នាតែ ៣ ជំហានតែ ប៉ុណ្ណោះ ។ ភ្នែករបស់គេក្រហមមុតដោយសេចក្តីចង អាឃាតយ៉ាងសាហាវ ខ្លួនញ័ររំចំប្រប់ដូចមនុស្សគ្រុនចាញ់ គេលើកដាវដោយដៃទាំងគូផុតស្មា ត្រៀមបម្រុងនឹងទំលាក់ លើក្បាលអាត្មាឲ្យអស់ទំហឹង ។

ខណៈនោះឯង ក៏ស្រាប់តែកើតមានពន្លឺភ្លឺចាំងឡើង ពាសពេញក្នុងបន្ទប់ ។ លុះអាត្មាបើកភ្នែកឡើង ក៏បាន ឃើញរូបរាងយ៉ាងធំរបស់ ម៉ឺនសែនហ្វា កំពុងតែរួញតូច ទៅៗ លុះគ្រាទៅអង្គុយលុតជង្គង់នៅលើក្តារ ដាក់ដាវចុះ ទៅម្ខាង ហើយលើកដៃទាំងពីរប្រណមនៅលើដើមទ្រូង ខ្លួនញ័រដូចកូនសត្វ តែមុខមាត់ឫកពាររបស់គាត់បង្ហាញឲ្យ ឃើញថានៅញ័រដោយសេចក្តីខ្លាចច្រើនជាងខឹង ។ ដំបូង អាត្មាយល់ថា គេស្រុតចុះលុតជង្គង់សំពះអាត្មាដោយ អំណាចបាដិហារិយ៍ ដែលកើតអំពីអំណាចអធិដ្ឋានរបស់ អាត្មា នៅពេលបានឮសម្លេងនិយាយចេញមកពីខាង ក្រោយ ហើយងាកមើលទៅ ទើបនឹងថាស្អីជាស្អី

- ព្រះភិក្ខុសង្ឃរូបនេះ ជាព្រះសង្ឃបរិសុទ្ធ! សម្លេង នោះខ្លាំងឡើងៗ មួយៗច្បាស់ៗ ដូចជាសម្លេងនៃអ្នកមាន ឫទ្ធិអំណាច, ជាអ្នកធ្វើតាមបដិបទានៃព្រះសាស្តាយ៉ាងពិត

ប្រាកដ ព្រះសង្ឃដូចជាព្រះអង្គឃើញគេបានដោយកម្រ ចូរ ឯងកុំគិតធ្វើអន្តរាយដល់លោកជាដាច់ខាត!

ម្ចាស់សម្លេងដែលអាត្មាបានឮ ឈរយ៉ាងសង្ហារនៅ កណ្ដាលអាកាស ច្បាស់ជាទេវបុត្រ អ្នកមានសក្ដានុភាព យ៉ាងពិតប្រាកដ រូបរាងរបស់គេល្អស្អាតជាងរូបចម្លាក់ រូប គំនូរ ឬរូបឆ្លាក់ដែលអាត្មាធ្លាប់បានឃើញមក មុខមាត់ ឬកពានិងសាច់ឈាមល្អស្អាត ដែលអាត្មាអធិប្បាយមិនត្រូវ សូម្បីនឹងពិសេសគេពាក្យ ដែលល្អិតទន់ជាទីបំផុតក្នុងភាសាថៃ មកពោលបរិយាយគង់មិនបាន សូម្បីមួយចំណិតកូនដៃ របស់ភាពពិតដែលអាត្មាបានឃើញ មានប្រយោគតែមួយ ដែលអាចមានចំណែកជិតដូចខ្លះ ឃើញដូចជាប្រយោគ ដែលថា ដូចព្រះចន្ទនូវថ្ងៃពេញបូណ៌មីក្នុងផ្ទៃមេឃដែល ប្រាសចាកពពកនានិទាឃរដូវ ។

- សែនប្បាអើយ! ទេវបុត្រលោកទ្រង់សក្ដាយស ពោលឡើងទៀត, ការដែលឯងត្រូវមកស៊ូទ្រាំទុក្ខវេទនានៅ ក្នុងភូមិអសុរកាយ ដែលជាទុគ្គតិនេះ ក៏ព្រោះតែបាបកម្ម អាក្រក់ដែលឯងធ្វើទុកនៅពេលជាមនុស្ស ហើយពីព្រោះ សេចក្ដីហួងហែងក្នុងទ្រព្យសម្បត្តិចាស់ដែលឯងកប់ទុក ។ សេចក្ដីទុក្ខធរមានដែលឯងបានទទួលមកជិត ៥០០ ឆ្នាំនេះ គួរនឹងសមល្មមហើយសម្រាប់ឯង បើឯងនៅតែធ្វើនូវ អកុសលកម្មតទៅ ដោយការធ្វើបាបព្រះភិក្ខុអ្នកទ្រង់សីល រូបនេះ ឯងនឹងធ្លាក់ចុះទៅដល់អវិចីមហានរកដូចគេទម្លាក់ ដុំថ្មមួយរំពេច ចូរឯងឲ្យសន្យាដល់ឃើញថា នឹងមិនធ្វើបាបព្រះ

ភិក្ខុសង្ឃអង្គនេះតទៅមុខទៀត

មុីនសែនហ្វា យកដៃទាំងពីរដាក់លើក្បាលយ៉ាងទន់ភ្លន់ ហើយពោលឡើងដោយសម្លេងខ្សាវៗថា៖

- ខ្ញុំម្ចាស់សូមសន្យា!

នៅពេលអស្សុរគាយ មុីនសែនហ្វា និយាយចប់ ស្រីដែលមានពន្លឺភ្លឺចែងចាំងនោះក៏រលត់បាត់ទៅ ព្រមជាមួយរូបរបស់ទេវបុត្រអង្គនោះ ធ្វើឲ្យអាត្មាកើតសេចក្ដីសោកស្ដាយដែលមិនមានឱកាសសន្ទនាជាមួយនឹងគេ ។ អស្សុរ-គាយ មុីនសែនហ្វា ដាក់ដាវចុះទៅលើភ្លៅ ហើយនៅអង្គុយស្ងៀមពីមុខអាត្មា គេសម្លឹងមើលមកអាត្មាដោយក្រសែភ្នែក សម្ដែងនូវសេចក្ដីជាមិត្ត រួចហើយពោលថា៖

- ខ្ញុំករុណាត្រូវសូមទោសព្រះអង្គ ដែលបានធ្វើហួសទៅលើព្រះអង្គ ដោយសេចក្ដីវង្វេង

- អាត្មាលើកទោសឲ្យ! អាត្មាឆ្លើយ, តែចិត្តនៅគិតដល់ទេវបុត្រអង្គនោះ ទើបសួរទៅមុីនសែនហ្វាថា៖

- ទេវបុត្រ ដែលប្រាកដខ្លួនមកហាមលោកនៅពេលមុននេះអម្បាញ់មិញ តើគេជាអ្នកណា?

- នោះគឺ តិន្ដទេពបុត្រ ជាអ្នកទទួលថ្វាយអំពីស្ដេចផិស្សនីណោ ដែលជាទេវបុត្រមួយអង្គក្នុងបណ្ដាស្ដេចចតុ-លោកបាលទាំងបួន ឲ្យជាទេព្ដានៅរក្សាមើលការខុសត្រូវនៅនគរឆៀងម៉ៃ ហើយធំលើទេវតានិងអមនុស្សទាំងពួងក្នុងអាណាចក្រឡានណាច័យ

- លោកបាននឹងដូចស្ដេចថា លោកកំពុងប្រទូសរ៉ាយ

នឹងអាត្មា ហើយមកឃាមឃាត់បានទាន់ពេល ? អាត្មាសួរដោយការចង់ដឹង

- តាមធម្មតា បើបុគ្គលណាតាំងនៅក្នុងសីល ក្នុងធម៌យ៉ាងពិតប្រាកដ តាំងសច្ចាអធិដ្ឋានដោយសច្ចៈយ៉ាងណានីមួយៗ កម្លាំងនៃសច្ចាអធិដ្ឋាននោះនឹងកម្រើកដល់វិមានរបស់លោក ហើយលោកក៏ជ្រាបបានភ្លាមដោយទិព្វចក្ខុ ហើយក៏ប្រញាប់មកជួយ

ចម្លើយរបស់ ម៉ឺន សែនហ្វា ធ្វើឲ្យអាត្មាយកមកគិតយ៉ាងខ្លាំង ពីព្រោះខ្លួនឯងធ្លាប់យល់ថា រឿងដែលទាក់ទងជាមួយនឹងស្ដេចចតុលោកបាលក៏ដោយ រឿងការតាំងសច្ចាអធិដ្ឋានរបស់មនុស្សក្នុងអតីត ហើយក៏កើតហេតុការណ៍ដ៏បដិហារិយ៍ឡើង តាមដែលមាននិទានទុកមកក្នុងគម្ពីរបិដកផ្សេងៗនោះក៏ដោយ គ្រាន់តែជារឿងដែលមនុស្សបូរាណគិតតែងឡើងដើម្បីបង្រៀនមនុស្សប៉ុណ្ណោះ មិនមែនជាការពិតទេ ប៉ុន្តែនៅពេលបានជួបប្រទះហេតុការណ៍នៅពេលនេះដោយផ្ទាល់ខ្លួនឯង ទើបឃើញថារឿងរ៉ាវទាំងអស់នោះគឺជាសេចក្ដីពិត ។ ទើបអាត្មាសួរ ម៉ឺន សែនហ្វា តទៅទៀតថា៖

- បើដូច្នោះ ភិក្ខុទេពបុត្រ ប្រហែលមិនមានពេលទំនេរច្រើនទេ ពីព្រោះនៅក្នុងខេត្តឡានណាច័យនេះ មានប្រជាជននៅមានចំនួនច្រើន ហើយមានមនុស្សមិនតិចទេដែលធ្លាក់ទៅក្នុងសេចក្ដីអន្តរាយ ដែលបានតាំងចិត្តសច្ចាអធិដ្ឋានសូមឲ្យទេវតាជួយ

- ប្រាកដដូចពាក្យព្រះអង្គមានដីកាមែន, ម៉ឺន សែនហ្វា ឆ្លើយ, មានមនុស្សជាច្រើនដែលគ្រាបសំពះអង្វរទេវតាឲ្យជួយខ្លួន តែពាក្យអង្វររបស់គេមិនមានកម្លាំងខ្ពុំរខ្ពារទៅដល់តិន្តទេពបុត្រ នោះទេ ពីព្រោះមនុស្សទាំងនោះ ភាគច្រើនជាមនុស្សបាប អាក្រក់ ធ្វើតែបាបកម្មតាមផ្លូវកាយ វាចា ចិត្ត ជានិច្ច នៅពេលខ្លួនធ្លាក់ចុះទៅក្នុងការចង្អៀតចង្អល់ក៏ប្រញាប់ស្វែងរកទីពឹងផ្សេងៗ ដូចជាការគ្រាបសំពះអង្វរទេវតាសូមឲ្យលោកជួយខ្លួនជាដើម ។ ទង្វើរបស់គេធ្វើទៅដោយសេចក្តីឃើញតែប្រយោជន៍ផ្ទាល់ខ្លួនពិតៗ ទើបមិនមានកម្លាំងខ្ពុំរខ្ពារ ទៅដល់វិមានរបស់តិន្តទេពបុត្រសោះឡើយ ។ ចំណែកមនុស្សដែលវៀរចាកបាបអកុសលតាមផ្លូវកាយ វាចា ចិត្ត ជាមនុស្សស្អាតបរិសុទ្ធតាមផ្លូវធម៌យ៉ាងពិតប្រាកដរកបានដោយកម្រ មនុស្សប្រភេទនេះ មិនសូវធ្លាក់ចុះនៅក្នុងភ័យវិបត្តិផ្សេងៗទេ យូរៗទើបមានការតាំងសច្ចាអធិដ្ឋានម្តង ហើយមនុស្សប្រភេទនេះ បើតាំងសច្ចាអធិដ្ឋានដើម្បីប្រយោជន៍អ្នកដទៃតែប៉ុណ្ណោះ មិនមែនដើម្បីប្រយោជន៍ផ្ទាល់ខ្លួនទេ ដូច្នេះកម្លាំងអធិដ្ឋានរបស់គេទើបព្ញខ្ពុំរខ្ពារដល់វិមានរបស់តិន្តទេពបុត្រ ដោយអត្តនោម័តិ ហើយតិន្តទេពបុត្រ លោកពេញចិត្តយ៉ាងខ្លាំងគ្រប់ពេលដែលបានជ្រាបនូវហេតុការណ៍អាក្រក់ផ្សេងៗ ពីព្រោះយ៉ាងហោចណាស់ក៏បានជ្រាបថា នៅមានមនុស្សល្អពិតៗរស់នៅក្នុងលោកនេះខ្លះ

- ហើយលោកឯងនេះ ? លោកមិនជ្រាបទេឬថា អាត្មា

ជាព្រះសង្ឃដែលបរិសុទ្ធ? អាត្មាសួរ

- មិនបានដឹងទេទាន លុះត្រាតែ តិន្តទេពបុត្រ បង្ហាញខ្លួនឡើង ទើបខ្ញុំកូណាបានដឹងពីព្រោះលោកមកឲ្យឃើញដើម្បីមកជួយ នៅពេលមានប្រទូសរ៉ាយដល់អ្នកល្អពិតៗ ប៉ុណ្ណោះ ដែលលោកបញ្ចេញខ្លួនឲ្យឃើញ ខ្ញុំកូណាទើបបានយល់ភ្លាមថា លោកម្ចាស់ជាព្រះសង្ឃដែលបរិសុទ្ធពិតៗ ខ្ញុំកូណាសូមក្រាបខមាទោសព្រះអង្គម្តងទៀត សូមកុំឲ្យខ្ញុំកូណាមានបាបកម្មទាន

- អាត្មាពេញចិត្តលើកទោសឲ្យដល់លោកគ្រប់យ៉ាង សូមលោកកុំព្រួយបារម្ភឡើយ,

អសុរកាយ ម៉ឺនសែនហ្វា បានលើកដៃសំពះអាត្មាជាលើកដំបូង គេសម្លឹងមើលទៅជុំវិញខ្លួន រួចដកដង្ហើមយ៉ាងវែង ហើយក៏អង្គុយនៅស្ងៀមដូចដើម ។ អាត្មាសង្កេតឃើញដោយសេចក្តីប្លែកក្នុងចិត្តថា ខ្លួនប្រាណរបស់គេញ័ររហូត មិនដឹងថាបណ្តាលមកពីហេតុអ្វី អាត្មាបានសួរគេអំពីសាហេតុរបស់រឿងនេះ ហើយ ម៉ឺន សែនហ្វា បានឆ្លើយថា៖

- ព្រះអង្គបានស្តាប់ឮពីទេវតា តិន្តទេពបុត្រ ហើយមែនទេទាន ! ថាខ្ញុំម្ចាស់នៅក្នុងភូមិអសុរកាយ ដែលជាទុគ្គតិ ព្រោះដូច្នោះហើយខ្ញុំម្ចាស់ទើបមិនដែលមានសេចក្តីសុខស្ងប់ក្នុងចិត្តសូម្បីតែមួយខណៈ ចិត្តក្តៅក្រវល់ក្រវាយភ័យព្រួយ ខ្លាច ជានិច្ចគ្រប់ពេល តែងព្រួយខ្វែងខ្លាចមានមនុស្សមកដណ្តើមទ្រព្យសម្បត្តិរបស់ខ្លួន ។ នៅពេលចិត្ត

ភ្លៅក្រវិលក្រវាយ ហើយគាយក៏ញ័រញាក់ទៅជាមួយ ខ្ញុំគូណា ដូចជាមានភ្លើងមួយដុំធំ មកដុតនៅក្នុងដើមទ្រូងទាំងថ្ងៃទាំងយប់អស់ពេលជិត ៥០០ ឆ្នាំមកហើយ

នៅពេលបានឮពាក្យអស់គាយ ម៉ឺន សែនហ្សា អាត្មាកើតសេចក្តីអាណិតគេយ៉ាងខ្លាំង ចង់ជួយគេឲ្យផុតអំពីសេចក្តីទុក្ខនេះ ទើបចាប់ផ្តើមបង្រៀនគេជាពាក្យសន្ទនា ដូចតទៅ៖

- ឧបាសកអើយ ! មនុស្សយើងកើតមកក្នុងភពណាក៏ដោយ មិនថាជាតិណា វណ្ណៈណា តែងតែមានបំណងតែមួយដូចគ្នាគឺ គ្រប់គ្នាប្រាថ្នានូវសេចក្តីសុខ ការដែលមនុស្សចង់បានទ្រព្យសម្បត្តិ ធ្វើការរកស៊ីបែកញើសទៅជាទឹក ពីព្រោះចង់បានទ្រព្យ ពីព្រោះជឿថាទ្រព្យនេះនឹងផ្តល់នូវសេចក្តីសុខដល់ខ្លួន តែតាមការពិតទ្រព្យសម្បត្តិក៏អាចឲ្យនូវសេចក្តីសុខដល់ខ្លួនបានខ្លះ ទើបមនុស្សនៅត្រូវការទ្រព្យសម្បត្តិតទៅ បើទ្រព្យសម្បត្តិដែលមាននៅ មិនអាចនឹងឲ្យសេចក្តីសុខដល់ម្ចាស់សោះ សូម្បីតែបន្តិច ផ្ទុយទៅវិញឲ្យតែសេចក្តីទុក្ខព្រួយ វេទនា មនុស្សប្រហែលជាមិនត្រូវការទ្រព្យសម្បត្តិនោះទេ ពីព្រោះវាមិនមានប្រយោជន៍អ្វីសោះ មានតែទោស ដូចមនុស្សកាន់គប់ភ្លើងទុក ហើយយកភ្លើងគប់នោះមកដុតខ្លួនឯង ក្នុងរឿងរបស់លោក អាត្មាយល់ថាលោកមិនបានទទួលសេចក្តីសុខ អំពីទ្រព្យសម្បត្តិរបស់លោកសោះ សូម្បីតែបន្តិច បានទទួលនូវសេចក្តីទុក្ខវេទនារហូត បើដូច្នេះ លោកនៅតែហួងហែងនូវទ្រព្យសម្បត្តិ

របស់លោកនេះតទៅទៀតឬយ៉ាងណា ?

អស្សរគាយ ម៉ឺន សែនហ្វា អន្តុយឈ្ងោកមុខគិតមួយសន្ទុះ ហើយឆ្លើយថា៖

- ព្រះអង្គមានឱការនេះត្រូវតែម្តង ខ្ញុំម្ចាស់មិនដែលបានទទួលសេចក្តីសុខអំពីទ្រព្យសម្បត្តិមហាសាល របស់ខ្លួនសោះ នឹងប្រើងដោយខ្លួនឯងក៏មិនបាន ពីព្រោះខ្លួនជាអមនុស្ស បើនឹងឲ្យទៅអ្នកឯទៀតក៏នឹកស្តាយ ទើបទ្រាំថែរក្សាទុកទាំងទុក្ខវេទនា ៗ នៅពេលខ្លះ ខ្ញុំម្ចាស់ក៏ធ្លាប់បានគិតថានឹងលើកឲ្យកូនចៅទៅចុះ តែមិនអាចយកឈ្នះសេចក្តីកំណាញ់ ហួងហែងស្តាយបានឡើយ តើខ្ញុំកូណាគួរធ្វើយ៉ាងណាឲ្យបានស្រួលទៅទាន ?

- ឧបាសក! ខ្លួនលោកនៅវេលានេះប្រៀបបីដូចជាមនុស្សអស់ស្បៀង ហើយកំពុងតែស្ពាយថង់ប្រាក់ដើរឆ្លងកាត់ទន្លេខ្សាច់ដ៏ធំធេង អត់ឃ្លាន ស្រេក ហើយបានទទួលនូវទុក្ខវេទនាយ៉ាងខ្លាំង នឹងដឹកប្រាក់ដឹន្នូសទឹក ឬនឹងហូបប្រាក់ជំនួសអាហារក៏មិនបាន ព្រមទាំងមិនមានសង្ឃឹមថានឹងឆ្លងឲ្យរួចអំពីសមុទ្រខ្សាច់នេះ នៅពេលណាផង លោកខំព្យាយាមលីទូលនូវថង់ប្រាក់ ថង់មាសនោះដោយសេចក្តីលំបាក ក៏ព្រោះសេចក្តីចង់បាន សេចក្តីស្រឡាញ់ សេចក្តីហួងហែងក្នុងមាស ប្រាក់នោះឯង ៗ នៅពេលនេះទ្រព្យសម្បត្តិនេះ មិនមានប្រយោជន៍អ្វីដល់លោកសោះឡើយ បើសិនលោកជាមនុស្ស ទ្រព្យសម្បត្តិនេះអាចជាប្រយោជន៍ដល់លោកបានខ្លះ ពីព្រោះលោកអាចនាំយកទៅលក់ ឬដូរ

*យកបច្ច័យ ៤ មកចិញ្ចឹមជីវិតបានខ្លះ តែនៅពេលនេះលោក នៅក្នុងកំណើតអសុរកាយ មិនមានការចាំបាច់ដែលនឹង ត្រូវប្រើនូវបច្ច័យ ៤ គឺអាហារ សំពត់ ខោអាវ សេនាសនៈ និងគិលានភេសជ្ជៈរបស់មនុស្ស ៗ បើនឹងប្រៀបធៀប ម្យ៉ាងទៀត ខ្លួនលោកប្រៀបបាននឹងស្រមោចក្រហមដែល នៅចាំផ្លែស្វាយឲ្យអ្នកដទៃគេបរិភោគ បើដូច្នេះហើយតើ លោកនៅហួងហែងទ្រព្យសម្បត្តិទុកធ្វើអ្វីទៀត?*

*អសុរកាយ ម៉ីន សែនហ្វា អង្គុយឈ្ងោកមុខស្ងៀម ដដែល សម្តែងឲ្យឃើញបានថា គេកំពុងគិតរកហេតុផល យ៉ាងពិនិត្យពិច័យ ៗ ទើបអាត្មាពន្យល់គេតទៅទៀតថា៖*

*- ឧបាសកអើយ! ហេតុដែលលោកនៅវង្វេងទុកនូវ ទ្រព្យសម្បត្តិរបស់លោកនេះ ក៏ពីព្រោះលោកយល់ខុសគិត ថាវាជារបស់លោក ប៉ុន្តែការពិតនោះមាស ប្រាក់ ពេជ្រ ត្បូងទាំងអស់នោះគឺជាធាតុដី កើតមកអំពីដី យើងកើតមក ក្នុងផែនដីនេះ យើងបានខ្ចីអំពីផែនដីមកប្រើមួយរយៈ នៅ ពេលយើងស្លាប់ទៅ ធាតុដីទាំងនោះក៏ធ្លាក់ទៅជារបស់អ្នក ដទៃ យើងមិនអាចនាំយកទៅជាមួយសូម្បីបន្តិចបន្តួច គឺ ត្រូវទុកឲ្យកូនចៅប្រើតទៅ ប្រៀបដូចមនុស្សក្នុងលោកនេះ ស្លាប់ទៅព្រមគ្នាទាំងអស់ មិនមាននរណានៅរស់ឡើយ ទ្រព្យសម្បត្តិទាំងនោះបានគរនៅលើផែនដី ក្លាយទៅជា ទ្រព្យសម្បត្តិរបស់ផែនដីដូចដើម កុំថាឡើយតែទ្រព្យ សម្បត្តិខាងក្រៅ សូម្បីតែសរីរាង្គកាយរបស់យើង នៅទី បំផុតក៏ត្រូវសងឲ្យផែនដីវិញដែរ ដែលជាម្ចាស់ដើមដូចគ្នា*

ព្រោះហេតុនេះ ទ្រព្យសម្បត្តិរបស់យើងពិតប្រាកដមិនមានទេ គ្រប់ៗគ្នាមកនៅលើផែនដីនេះខ្លួនទទេ ហើយនឹងចេញទៅវិញក៏ខ្លួនទទេដូចគ្នា ។ មនុស្សយើងគ្រប់ៗគ្នា ប្រៀបបីដូចបុរសអ្នកដើរផ្លូវឆ្ងាយ មកសម្រាកនៅពេលយប់ក្នុងផ្ទះសំណាក់ពិភពលោក តែងមានសិទ្ធប្រើប្រាស់នូវរបស់ផ្សេងៗដែលនៅក្នុងបន្ទប់របស់យើងបានយ៉ាងស្រួល ប៉ុន្តែដល់ពេលវេលាដែលយើងនឹងចាកចេញទៅ មិនត្រូវពីយករបស់គេទៅជាមួយ ដោយយល់ខុសគិតថាជារបស់ខ្លួន តែការពិតគឺដូចនេះ តើគួរឬទេដែលលោកវង្វេងប្រកាន់យកធាតុដី ដែលជាសម្បត្តិរបស់ផែនដីទុកដោយសេចក្ដីលំបាក ? តើគួរដែរឬទេដែលលោកធ្វើនូវសេចក្ដីអាក្រក់ ស្វែងរកទុក្ខមកដាក់ខ្លួន ព្រោះតែដុំថ្ម ដុំដី ដែលជាសម្បត្តិរបស់ផែនដី ?

នៅពេលអាត្មាពោលមកដល់ឃ្លានេះ អសុរកាយម៉ឺន សែនហ្វា ឱនក្រាបអាត្មា ហើយក្រោកឡើងអង្គុយដូចដើម ពោលចេញមកដោយវិចាទុក្ខព្រួយថា ៖

- លោកម្ចាស់ដ៏ចម្រើន ! ខ្ញុំម្ចាស់វង្វេងសម្គាល់ ប្រកាន់យក ហួងហែងនូវធាតុដីដែលឥតមានតម្លៃទុកអស់ពេលវេលារាប់រយឆ្នាំ ពីព្រោះសេចក្ដីល្ងង់ខ្លៅពិតៗ ខ្ញុំម្ចាស់ទើបតែបានទទួលនូវពន្លឺ យល់នូវការពិតអំពីលោកម្ចាស់នៅក្នុងថ្ងៃនេះ គួរឲ្យស្ដាយនូវពេលវេលា ដែលបានកន្លងហួសទៅ ពេលនេះខ្ញុំម្ចាស់បានសម្រេចចិត្តហើយថា និងលះបង់នូវទ្រព្យសម្បត្តិមហាសាលទុកពេលក្រោយ តែមិនដឹងថា

*នឹងលើកឲ្យទៅអ្នកណាល្អ សូមព្រះករុណាជួយពន្យល់ខ្ញុំម្ចាស់ផងទាន!*

*អាត្មាពន្យល់គាត់ថា គួរឲ្យគាត់យកទ្រព្យសម្បត្តិទាំងអស់ប្រគល់ឲ្យលោកចំណាន ដែលត្រូវជាសាច់ញាតិសាលោហិតរបស់គេស្រាប់ ដោយអាត្មាទទួលថានឹងធ្វើឲ្យលោកចំណាននាំយកទ្រព្យទាំងអស់នោះ យកទៅធ្វើបុណ្យឧទ្ទិសចំណែកកុសលឲ្យ ៗ អស់រយៈយ ម៉ឺន សែនហ្វា ចង្អុលបង្ហាញអាត្មា នូវកន្លែងទុកទ្រព្យសម្បត្តិដ៏ច្រើនមហិមា ដែលកប់ទុកនៅអណ្តូងរីងនៅជិតដើមគោស្វ ហើយគេក៏បាត់ខ្លួនទៅ...*

# ព្រមលះ

*បទពាក្យ៧*

ត្រូវព្រមទទួលស្គាល់តាមហេតុ ព្យាយាមសង្កេតទៅរកផល
ពិនិត្យរិះគិតពិតដឹងយល់ បំបាត់ចម្ងល់ពីចិន្តា ។
អ្វីកើតមានហើយតែងរលត់ ទៅតាមបែបបទនៃសង្ខារ
ពីមានទៅអត់ជាធម្មតា នេះគឺតម្រាច្បាប់ធម្មជាតិ ។
ទោះជាសម្បត្តិផងទាំងឡាយ បងប្អូនតាយាយមិត្តផៅញាតិ
មាតាបិតាបុត្រត្រូវឃ្លាត ខ្លួនឯងសោតទៀតហាមមិនបាន ។
គ្មានបុគ្គលណាជាកម្មសិទ្ធ ការពារជីវិតចិត្តកាយប្រាណ
ព្រមទាំងញាតិមិត្តសម្បត្តិមាន ត្រូវតែចាកឋានលះលោកីយ៍ ។
គ្មានរបស់អ្វីឲ្យសល់នៅ ទីបំផុតទៅក្លាយជាដី
ជាម្ចាស់ដើមពិតឥតសង្ស័យ លះលែងអាល័យទើបផុតទុក្ខ ។

# ២៨. មានបុណ្យល្អជាងមានប្រាក់

នៅពេលព្រឹកឡើង អាត្មាចេញទៅបិណ្ឌបាតតាំងពីព្រលឹម ។ ភាពដំបូងដែលអាត្មាបានឃើញនោះគឺជាសាកសពឆ្កែពណ៌ខ្មៅមួយដេកស្លាប់នៅកណ្ដាលថ្នល់ គិតថាប្រហែលត្រូវរថយន្តបុកស្លាប់ តាំងតែពីពេលកណ្ដាលអធ្រាត្រ ឬនៅពេលព្រឹកព្រលឹមស្រាងៗថ្ងៃនេះឯង ពីព្រោះមានឈាមហូរចេញពីមាត់នៅលើផ្លូវថ្នល់ ។ អ្នកដែលដើរហួសទៅ ក្រឡេកមើលក្រោយមួយភ្លែត ដោយសេចក្ដីខ្ពើមរអើម បង្ហាញឲ្យឃើញនៅលើទឹកមុខ ហើយក៏ដើរបង្ហួសទៅ សូម្បីតែឆ្កែដូចគ្នាក៏រត់ហួសទៅមក មិនមាននរណាមួយយកចិត្តទុកដាក់សោះ ។ អាត្មារំពឹងក្នុងចិត្តថា "នេះហើយជាទោស នៃការដែលកើតក្នុងកំណើតសត្វតិរច្ឆាន ដែលមានតម្លៃទាបថោក" ប៉ុន្តែមនុស្សខ្លះក៏បញ្ចុះតម្លៃរបស់ខ្លួនឯងឲ្យទាបប្រហែលនឹងសត្វដែរ ត្រូវភ្នាក់ងារនគរបាលកាន់កាំភ្លើង ដេញបាញ់ ដេញតាមសម្លាប់ដូចព្រានប្រមាញ់សត្វ ។ បើសិនជាត្រូវចាប់បាន ក៏នាំយកទៅឃុំឃាំងក្នុងទ្រុង ដូចជាឃាំងខ្លានៅក្នុងសួនសត្វ ។ តែមនុស្សខ្លះ គេបំពេញតម្លៃឲ្យដល់ខ្លួនគេ លុះត្រាក្លាយទៅជាទីគោរពរាប់អានរបស់ជនទាំងភូមិ ទាំងស្រុក ទាំងប្រទេស ទាំងផែនដី ដូចជាព្រះបរមសាស្ដាសម្មាសម្ពុទ្ធ សូម្បីព្រះអង្គជាជនជាតិឥណ្ឌា បរិនិព្វានជាយូរមកហើយតាំងពីជាងពីរ

ពាន់ប្រាំរយឆ្នាំដែរ តែមនុស្សលោកនៅតែគោរពសំពះបូជាដូចជាព្រះអង្គគង់នៅមានព្រះជន្មនៅឡើយ ។ តើអ្វីទៅដែលធ្វើឲ្យមនុស្សយើងប្លែកខុសគ្នាដូចជាមេឃនិងដីដូច្នេះ មិនមានអ្វីទេ ក្រៅតែពីកម្មរបស់មនុស្សម្នាក់ៗនោះឯង ។ កម្មល្អបន្ថែមតម្លៃឲ្យអ្នកនោះ កម្មអាក្រក់បញ្ចុះតម្លៃដល់អ្នកនោះ បើសេចក្តីពិតមាននៅដូច្នេះ តើដូចម្តេចបានជាមនុស្សយើងមិនខំធ្វើអំពើល្អឡើង ពីព្រោះមារទាំង ៣ គឺ លោភៈទីងទ្វេងនេះហើយ នៅចាំស្កាត់ទុក លើសពីនេះទៅទៀតមារគឺមោហៈ សំខាន់បំផុតមានអ្នកខ្លះចង់ធ្វើនូវអំពើល្អដែរ តែមោហៈធ្វើឲ្យគេយល់ខុសថា ការធ្វើល្អគឺការកសាងព្រះវិហារមានតម្លៃរាប់លាន ការធ្វើកឋិនមានមនុស្សចូលរួមរាប់ពាន់នាក់ ។ ការកសាងអាគារមន្ទីរពេទ្យមានតម្លៃរាប់សែន នៅពេលគេយល់ថានេះគឺអំពើល្អ ប៉ុន្តែនៅពេលឋានៈរបស់ខ្លួននៅមិនទាន់ជំនួយ គេនៅរង់ចាំដេកចាំឲ្យខ្លួនឯងទៅជាអ្នកមានសិន ទើបនឹងទៅធ្វើនូវអំពើល្អដូច្នោះ តែមុនដែលគេនឹងមានបាន មច្ចុរាជបានមកឆក់យកជីវិតរបស់គាត់ទៅមុនបាត់ នៅទីបំផុតត្រូវស្លាប់ដោយបាបអកុសលហើយក៏ទៅកើតឯទុគ្គតិ ។ មនុស្សឆ្លាតតែងមិនឲ្យថ្ងៃ ពេលវេលាក្នុងការធ្វើនូវអំពើល្អ ហើយមិនមើលងាយនូវសេចក្តីល្អបន្តិចបន្តួច គេធ្វើនូវអំពើល្អបានរាល់ថ្ងៃ រាល់ឱកាសដែលអាចធ្វើទៅបាន បើធ្វើមិនបានដោយទ្រព្យ គេធ្វើដោយកាយ បើមិនបានធ្វើដោយកាយ គេធ្វើដោយវាចា បើធ្វើមិនបានដោយវាចា គេធ្វើដោយចិត្ត នៅទីបំផុតគេក៏

ក្លាយទៅជាមនុស្សអ្នកមានបុណ្យ ។ អ្នកមានបុណ្យប្រសើរជាងអ្នកមានទ្រព្យសម្បត្តិ ពីព្រោះសម្បត្តិអាចសាបសូន្យទៅបានដោយភ័យវិបត្តិផ្សេងៗ ប៉ុន្តែភ័យផ្សេងៗមិនអាចបំផ្លាញបុណ្យបានទេ ។ សម្បត្តិទ្រព្យឲ្យប្រយោជន៍ចំពោះតែជាតិនេះ នៅពេលស្លាប់ទៅ ក៏ទុកចោលនៅខាងក្រោយ តែបុណ្យនៅជាប់តាមទៅឲ្យប្រយោជន៍ បានសូម្បីទៅក្នុងជាតិខាងមុខ ។

នៅពេលដែលអាត្មាកំពុងរំពឹងគិត មានមនុស្សប្រុសម្នាក់អាយុប្រហែលកណ្តាលមនុស្ស ដើរតម្រង់មករកអាត្មាហើយសួរថា៖

- ព្រះគុណម្ចាស់ឈរនៅទីនេះធ្វើអ្វីទាន ?
- អាត្មានឹកកំពុងតែចង់ធ្វើបុណ្យអ្វីម៉្យាង ថ្ងៃមួយនេះ ការពិតទៅវាជាមិត្តដែលរួមលោកនិងយើង កើតមកតស៊ូជាមួយសេចក្តីទុក្ខនៃជីវិតដូចជាយើងដែរ តែវាមានគ្រោះកាចជាងយើងទោះបីត្រូវឡានបុកស្លាប់ ដេកនៅកណ្តាលថ្នល់នេះ ។ មនុស្សដើរទៅហួសមកហួសដោយមិនមានអ្នកណាយកចិត្តទុកដាក់សោះ ។ បើវាជាមនុស្សប្រហែលនឹងមានគេយកចិត្តទុកដាក់ជាងនេះ តែនេះវាមានកម្មកើតមកជាសត្វ ទើបមនុស្សមិនរវល់ ។ អាត្មានឹកអាណិតវាណាស់ កំពុងតែគិតយកសពឆ្កែនេះទៅដាក់នៅកៀនៗថ្នល់ មើលទៅដូចជាមិនសូវទាស់ភ្នែក ដល់អ្នកដើរទៅមកហើយនិងមិនមានអន្តរាយដល់ការបើកបរផ្សេងៗទៀតផង

បុរសនោះសម្លឹងមើលមុខអាត្មាមួយសន្ទុះ ក្រោយ

មកក៏ដើរទៅរុសដើមសាគសពស្ដែនោះ ទៅដាក់នៅគៀនថ្មល់

- ញោមធ្វើសេចក្ដីល្អបានមួយហើយ! អាត្មាសូមអនុមោទនា

- តើព្រះអង្គឲ្យខ្ញុំកូណាធ្វើអ្វីទៀតទាន? គេសួរអាត្មាបណ្ដើរដូតនិងគេបណ្ដើរ

- បើសិនជាញោមចោលវានៅគៀនថ្នល់ អ្នកជិតខាងដែលនៅក្បែរៗនោះ, មិនយូរប៉ុន្មានសាគសពស្ដែនេះវាអាចហើមប៉ោងស្អុយរលួយ ធុំក្លិនពេញក្នុងបរិវេណនេះ ពេលមនុស្សដែលនៅជិតៗនេះ កើតសេចក្ដីមិនពេញចិត្តគេកើតមានចិត្តជាអកុសល អ្នកខ្លះអាចយកចបមកជីកកប់ស្ដែនេះតែនឹងជីករណ្ដៅផងដើរផងទៅជាមួយគ្នា បើសិនជាញោមជីករណ្ដៅហើយកប់វាទៅនៅពេលនេះ គឺជាសេចក្ដីល្អយ៉ាងខ្ពង់ខ្ពស់ ជាការជួយមិនឲ្យអ្នកដទៃក្ដៅក្រហាយ

នៅពេលអាត្មាពោលចប់ បុរសនោះដើរសំដៅទៅផ្ទះមួយខ្នង ពេលត្រឡប់មកវិញមានកាន់ចបជីកមួយផង ។ គេក៏ចាប់ជីករណ្ដៅតូចមួយនៅជិតខាងថ្នល់ ហើយក៏យកសាគសពស្ដែនោះទៅកប់ក្នុងរណ្ដៅ បង្ហាប់ដីណែនហើយគេក៏ដើរមករកអាត្មា

- ល្អហើយ! ថ្ងៃនេះញោមបានធ្វើបុណ្យតាំងតែពីព្រលឹម ញោមនឹងសប្បាយចិត្តរហូតមួយថ្ងៃ, អាត្មាពោលហើយក៏ដើរចេញទៅបិណ្ឌបាតជាបន្ត

- លោកគ្រូទាន! សម្លេងបុរសនោះសួរមកអាត្មា,

លោកម្ចាស់មិនករុណាឲ្យដោត លោតដល់ខ្ញុំករុណាម្ចាស់ខ្លះ ឬទេទាន?

- បុណ្យនេះហើយ គឺជាលោតដ៏ប្រសើរ អាត្មាសាកទៅប្រាប់គេហើយក៏ដើរចេញទៅ

នៅពេលបានអាហារល្មមគ្រប់គ្រាន់ និងការរស់នៅក្នុងមួយថ្ងៃហើយ អាត្មាក៏ត្រឡប់ទៅផ្ទះសំណាក់ តាំងចិត្តថា នៅពេលឆាន់រួចហើយ នឹងឲ្យដំណឹងខ្លះដល់ម្ចាស់ផ្ទះរួចហើយក៏នឹងចេញដំណើរតាមផ្លូវតទៅទៀត តាមការតាំងចិត្តពីដើមទុកមក ។

ពេលមកដល់ផ្ទះសំណាក់ អាត្មាបានជួបលោកចំណាស់ព្រមទាំងក្រុមគ្រួសារ ៦ ឬ ៧ នាក់ទៀតកំពុងតែនៅរង់ចាំអាត្មា ។ លោកចំណាស់សម្លឹងមើលមកអាត្មាដោយឫកពាភ្ញាក់ផ្អើល ហើយពោលដោយភ្ញាក់សម្លេងខ្លាំងថា៖

- ខ្ញុំនឹកថា លោកម្ចាស់កើតអីទៅហើយ! ពេលភ្ញាក់ឡើងក៏ប្រញាប់បបួលភរិយាមកមើល នៅពេលមិនឃើញព្រះអង្គ ឃើញតែរបស់ពីរ-បីបន្ទះទុកនៅ ខ្ញុំករុណាភិតភ័យយ៉ាងខ្លាំង ហៅអ្នកជិតខាងមកជួយរក ។ សប្បាយចិត្តណាស់ដែលបានឃើញព្រះអង្គនៅជាធម្មតា ព្រះអង្គលោកសុខសប្បាយជាទេ មែនទេទាន?

- ធម្មតាគ្រប់យ៉ាង! អាត្មាឆ្លើយ

- មិនមានអ្វីកើតឡើងសោះឡើយទាន? គេសួរដោយសេចក្ដីសប្បាយចិត្ត

- មានខ្លះដូចគ្នាដែរ!

គ្រប់ៗគ្នាសំគមមកមើលមុខអាត្មាដែរ ហៀបគ្នាក់ឆ្លើយ ហើយប្អូនស្រីរបស់លោក ចំណាន ពោលឡើងថា៖

- សូមព្រះករុណា និយាយឲ្យស្តាប់បន្តិចបានទេទាន?

- មិនមានប្រយោជន៍ទេ បើអាត្មានិយាយប្រាប់ ញោម អាចនឹងមិនជឿ អាត្មាក៏គ្មានអ្វីនឹងពិសោធឲ្យញោមជឿបាន

ទាំងអស់គ្នាសុទ្ធតែចង់ដឹង និងចង់ស្តាប់ នៅពេល ពួកគេរុកគួនខ្លាំងពេក ទើបអាត្មាទទួលពាក្យថា នឹងនិយាយ ប្រាប់ តែសូមឆាន់ចង្ហាន់ព្រឹកឲ្យរួចសិន ។

ក្រោយមក លោកចំណានបានបញ្ជាឲ្យទៅរៀបចំ ចង្ហាន់ ព្រមទាំងទឹកយកមកប្រគេនអាត្មា ។ អាត្មាបាន ទទួលនូវការប្រគេនហើយ ដួសអាហារដាក់ចូលទៅក្នុង បាត្រតាំងចិត្តក្នុងចិត្តថានឹងឆាន់អាហារ ដូចជាឆាន់ថ្នាំកែរោគ ឃ្លានឆាន់ដើម្បីឲ្យជីវិតរស់នៅ ហើយរស់នៅដើម្បីធ្វើនូវ សេចក្តីល្អនិងមិនឆាន់ដើម្បីកែរាយសប្បាយ មិនឆាន់ដើម្បី ឆ្ងាញ់ មិនឆាន់ដើម្បីធ្វើឲ្យកាយស្អាត ។ ក្រោយអំពីនោះក៏ តាំងចិត្តឧទ្ទិសចំណែកកុសលឲ្យដល់ត្រី មាន់ ជ្រូក និងអ្នក ជាម្ចាស់របស់សាច់ដែលត្រូវមនុស្សចិត្តខ្មៅ បានប្លន់ សម្លាប់ យកសាច់ស្បែករបស់គេមកជាអាហាររបស់ខ្លួន ។ រួច ហើយក៏យកមកដាក់បាត្រ សូមឲ្យម្ចាស់សាច់ទាំងនោះបាន ទទួលចំណែកកុសល ហើយទៅកើតក្នុងសុគតិភព កុំមក កើតក្នុងកំណើតតិរច្ឆានដែលជាទុគ្គតទៅទៀត ។ តាំងចិត្ត ក្នុងចិត្តល្អហើយ ក៏ចាប់ឆាន់ដោយអាការៈសង្រួម មិន និយាយមិនឆ្លើយ មិនឲ្យឮនូវសម្លេង ភ្នែកសម្លឹងមើលទៅ

ក្នុងបាត្រឆាន់ឃើតៗ មិនប្រញាប់ ទំពារអាហារគ្រប់ម៉ាត់ឲ្យល្អិត ។ នៅពេលនឹងថាឆ្អែតហើយ ក៏ឈប់ភ្លាម ឆាន់រួចហើយយកបាត្រទៅលាងដុសឲ្យអស់ក្លិន ដោយសន្លឹកឈើស្ងួត ជូតឲ្យស្ងួតដោយសំពត់ជូតទឹកភ្លៀង ហើយនាំយកទៅហាលថ្ងៃដើម្បីឲ្យស្ងួតមែនទែន ។ លុះប្រាកដច្បាស់ក្នុងចិត្តថា មិនកើតស្នឹមហើយ នាំយកមកដាក់ក្នុងថង់ទុក ។

លោក ចំណាន និងបរិវារ នាំគ្នាសម្លឹងមើលនូវការឆាន់ ការរក្សាបាត្រ និងការរៀបទុកដាក់បរិក្ខាររង់ទៀតរបស់អាត្មាដោយសេចក្តីពេញចិត្ត និងដោយទឹកមុខសម្តែងនូវសេចក្តីជ្រះថ្លា ។ កិច្ចវត្តរបស់ព្រះភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា បើធ្វើដោយអាការៈសង្រួមរើងតាមពាក្យប្រៀនប្រដៅរបស់ព្រះបរមសាស្តា អាចបានជាទីតាំងនៃសេចក្តីជ្រះថ្លារបស់ប្រជាជនទាំងពួង ។

នៅពេលឆាន់រួចស្រួលបួលហើយ អាត្មាទើបចាប់ផ្តើមនិយាយរឿងផ្សេងៗឲ្យស្តាប់ តាមសេចក្តីពិតតាំងតែពីដើមដល់ចប់ ។ លោក ចំណាននិងគ្រួសារម្នាក់ៗតាំងចិត្តស្តាប់ដោយការពេញចិត្ត សម្តែងនូវការភ្ញាក់ផ្អើល ភ័យប្លែកក្នុងចិត្តជាវគ្គៗ តែអាត្មាមិនបានប្រាប់រឿងកំនរទ្រព្យសម្បត្តិឲ្យស្តាប់ទេ តាំងចិត្តថានឹងប្រាប់ដល់លោក ចំណានតែម្នាក់ដោយចំពោះមុខនៅពេលក្រោយ ពីព្រោះខ្លាចក្រែងកើតរឿងមិនស្ងប់ឡើង

- លោកមានឌីកាដូច្នេះ គួរឲ្យល្អជឿដែរ, នាង ដួងកែវ ប្អូនស្រីរបស់លោក ចំណាន អ្នកបណ្ឌិតវិទ្យាសាស្ត្រពីទី

ក្រុងបាងកក ពោលឡើងនៅពេលអាត្មានិយាយរឿងនេះចប់ ធ្វើឲ្យលោក ចំណាននិងសមាជិកផ្សេងៗ ងាកទៅមើលគេដោយក្រសែភ្នែកមិនពេញចិត្តភ្លាម

- ញោមចង់ជឿ ឬមិនជឿ ជារឿងរបស់ញោមទេ! អាត្មាពោលឡើងដោយសម្លេងធម្មតា សូម្បីនឹងថាខ្លួនត្រូវគេជំទាស់, តែអាត្មាបាននិយាយប្រាប់ទៅតាមការពិតក្នុងឋានៈជាព្រះសង្ឃ អ្នករក្សាព្រះវិន័យនៃព្រះបរមសាស្ដា អាត្មានិយាយតែការពិតប៉ុណ្ណោះ និយាយច្រើនឬតិចលើសពីការពិតមិនបានទេ

- ពិតណាស់លោកម្ចាស់អាចនឹងឃើញ, បណ្ឌិតវិទ្យាសាស្ត្រពោលឡើង, តែមនុស្សយើងក៏អាចនឹងឃើញបានដោយវិធីច្រើនយ៉ាង ជួនកាលបានឃើញដោយភ្នែកពិតៗ ជួនកាលក៏ឃើញដោយការយល់សប្តិ ជួនកាលឃើញដោយចេតនា ក៏តែងតែឃើញអ្វីៗជាខ្មោចទាំងអស់

- ឈប់និយាយទៅណ៎ា ឆ្លូងកែវ! លោក ចំណាន ឃាត់ដោយមិនសប្បាយចិត្ត

- កុំបន្លាក់គេអីញោម! អាត្មាហាមលោក ចំណាន គេជាមនុស្សមានហេតុផល មិនព្រមជឿស្អីងាយៗនោះទេ រាប់បានថាជាពុទ្ធសាសនិកជនប្រាកដមួយរូប ដែលបដិបត្តិតាមពាក្យប្រដៅរបស់ព្រះពុទ្ធអង្គក្នុងកាឡាមសូត្រ យ៉ាងពិតប្រាកដ ពីព្រោះក្នុងកាឡាមសូត្រ ព្រះពុទ្ធទ្រង់ហាមថា កុំជឿប្រកាន់ដោយការឮតៗគ្នា, កុំជឿប្រកាន់ដោយការនិយាយតៗគ្នា,កុំជឿប្រកាន់ដោយការភ្ញាក់ផ្អើល,កុំជឿប្រកាន់ដោយ

ប្រកាន់ដោយការអានតម្រា, កុំជឿប្រកាន់ដោយសេចក្តីត្រិះរិះតាមអាការៈ, កុំជឿប្រកាន់ដោយឃើញសមនឹងយោបល់, កុំជឿប្រកាន់ចំពោះបុគ្គលដែលគួរជឿ, កុំជឿប្រកាន់ថាសមណៈជាគ្រូនៃយើង ៗ អ្នកកាន់សាសនាព្រះពុទ្ធពិត មិនឲ្យជឿអ្វីងាយៗដូចញោមដួងកែវនេះឯង

- មានន័យថារបស់ដែលព្រះអង្គបានឃើញ បានជួបយប់មិញ ព្រះអង្គទទួលថាជាភាពច្លីនភ្នែក ឬ Hallucination មែនទេ? នាងស្រីសួរអាត្មាបន្តទៅទៀត

- បើអាត្មាមិនព្រមទទួលថាជាការបញ្ឆោត ហើយប្រាប់ថាជាការពិត ញោមក៏មិនព្រមជឿដែរ ដូច្នេះអាត្មាមិនព្រមទទួលទេ តែក៏មិនបដិសេធយកយ៉ាងនេះវិញ បើជារបស់ដែលអាត្មាបានឃើញនៅយប់មិញនេះ ជាភាពច្លីនភ្នែកឬដូចជាយល់សប្តិក៏ដោយ កើតពីចិត្តរបស់អាត្មាក៏បានកើតអំពីអារម្មណ៍មិនធម្មតាក៏ដោយ កើតពីឧបាទានក៏ដោយភាពបញ្ឆោតភ្នែកទាំងនោះជារបស់មិនពិតក្នុងលោក ប៉ុន្តែបើជាភាពពិត អាចមានរបស់ពិតជាសាក្សីអាត្មា របស់ជាសាក្សីពីរយ៉ាងដើម្បីពិសោធន៍ថារបស់ដែលអាត្មាឃើញជាការពិតទី១ ចាប់ពីពេលនេះទៅផ្ទះនោះអាចឡើងទៅនៅបានដោយគ្មានភិតភ័យទៀតទេ, ទី២ អាត្មាសុបជួបជាមួយលោកចំណានតែពីរនាក់ ពីព្រោះជារឿងសំខាន់

- ព្រះអង្គត្រូវប្រាប់ខ្ញុំកូណាផង ពីព្រោះជាមនុស្សមិនជឿ បង ចំណានគាត់ជឿហើយ មិនបាច់ប្រាប់គាត់ទេ

- រឿងនេះជារឿងសំខាន់ណាស់ ត្រូវប្រាប់មេគ្រួសារ

កុំព្រួយញោមគង់តែបាននឹងទេ នៅពេលនឹងហើយ ត្រូវតែជឿ

- បើសាក្សីទី២ របស់ទានម្ចាស់មិនច្បាស់ធ្វើឲ្យខ្ញុំកូណាមិនអាចជឿបាន តើព្រះអង្គធ្វើយ៉ាងណាទាន?

- ល្អហើយចុះ! ចាំសាក្សីទី២ចេញមកសិន ទើបអាចនិយាយគ្នាទៀត អាត្មានឹងនៅទីនេះលុះត្រាបានទទួលនូវការពិសោធន៍ សាក្សីទី២

រសៀលថ្ងៃនោះ នៅពេលលោក ចំណាននបញ្ជាឲ្យក្រុមគ្រួសារចេញទៅអស់ហើយ អាត្មាបានប្រាប់លោកចំណាននថា៖

- នៅពេលបែកគ្នា អសុរកាយ ម៉ឺនសែនហ្វាដែលជាញាតិរបស់លោក បានប្រគល់ទ្រព្យសម្បត្តិទាំងអស់ដែលកប់ទុកឲ្យញោមទាំងអស់ កប់នៅបាតអណ្តូងរីងស្ងួត នៅជិតផ្ទះនេះឯង

នៅពេលបានឮតែប៉ុណ្ណោះ លោក ចំណាននភ្ញាក់ព្រញាង ហាមាត់គាំង យកដៃជុសគ្នាទៅមកៗ ។ ការភ្ញាក់ផ្អើលសប្បាយចិត្តបញ្ចេញអាការៈរីករាយយ៉ាងខ្លាំង ។

- ទប់សតិឲ្យល្អ! អាត្មាដាស់តឿនគេកុំឲ្យគេភ្ញាក់ផ្អើលខ្លាំងពេក, នៅពេលទំនេរលោកឆាប់ទៅជីកយកមកទុកឲ្យល្អ កុំឲ្យនរណាដឹងជាដាច់ខាត ពីព្រោះអាចមិនរួចអំពីភ័យសម្រាប់ខ្លួនញោម ។ នៅពេលដែលជីកបានមកសូមឲ្យញោមយកទៅធ្វើបុណ្យឲ្យធំ ហើយឧទ្ទិសកុសលឲ្យ ម៉ឺនសែនហ្វា គាត់នឹងបានទៅកើតនៅក្នុងសុគតិភពដោយ

កម្លាំងនៃកុសលនេះ

- ខ្ញុំកូណានឹងធ្វើតាមទាំងអស់ទាន! លោកចំណាន ពោលឡើងដោយសម្លេងញ័រៗ ហើយឱនក្រាបអាត្មា ដោយនែកញ័រដែរ...

# ដឹងមិនដល់ ឆ្ងល់មិនអស់

បទពាក្យ៧

អ្វីនៅឆ្ងាយប្រាណឥតបានយល់ ពុំអាចដឹងស្គាល់ឲ្យបានអស់
នឹងពោលបដិសេធឬជំទាស់ ភ្លាមមិនសមសោះត្រូវគិតលៃ ។
ស្តាប់ហើយយកមកពិចារណា បង្កើនបញ្ញាយល់អត្ថន័យ
ប្រាកដក្នុងចិត្តឥតសង្ស័យ ទៅតាមបច្ច័យនិងហេតុផល ។
ធម្មជាតិមានមកក្នុងលោកីយ៍ ក្រោមមេឃលើដីពុំអាចស្គាល់
មានច្រើនប្រការដឹងមិនដល់ គ្មានជនណាយល់ឲ្យអស់បាន ។
មានតែព្រះពុទ្ធជាអម្ចាស់ ទ្រង់ត្រាស់នូវសព្វញ្ញុតញ្ញាណ
ទើបអាចឈ្វេងយល់សព្វអស់បាន ទៅតាមព្រះញាណគ្មានចន្លោះ ។
យល់រឿងខ្មោចប្រេតអសុរកាយ នរកសត្វទាំងឡាយឥតទើសទាស់
ទាំងឈានវិស័យកម្មផលនោះ និព្វានធម៌ខ្ពស់អស់សង្ស័យ ។
ព្រះអង្គសម្តែងថ្លែងបញ្ជាក់ ទុកឲ្យសាវ័កមានស្មារតី
ពិចារណាត្រង់ត្រាប់ស្តាប់យប់ថ្ងៃ យល់ច្បាស់អត្ថន័យអស់ចម្ងល់ ។
កុំគិតលើអ្វីហួសវិស័យ ទិវារាត្រីនាំចិត្តខ្វល់
ដោះស្រាយបញ្ហាមានមកដល់ បច្ចុប្បន្នឃើញផ្ទាល់ផលសម្រេច ៕

ដោយឧបាសក មុិញ សារ៉ាង

# ទ្រព្យគឺបុណ្យ

បទពាក្យ៩

ទ្រព្យគឺបុណ្យ វិសេសលន់ ក្នុងលោកីយ៍
គ្មានទ្រព្យអ្វី ឲ្យប្រសើរ ស្មើប្រៀបបាន
ជាសម្បត្តិ ប្រពៃពិត ជាប់ជិតប្រាណ
គ្រប់ទិសឋាន ផលត្រូវបាន ក្សាន្តប្រណីត ។
រីប្រាក់មាស ពេជ្រឱភាស ផងទាំងឡាយ
ប្រដាប់កាយ ចាយសប្បាយ រីករាយចិត្ត
ក្នុងលោកីយ៍ ជនប្រុសស្រី ប្រាថ្នាពិត
ញុំាងជីវិត ចិត្តភ្លើតភ្លើន កើនតណ្ហា ។
មិនប្រសើរ ស្មើទ្រព្យបុណ្យ គុណប្រពៃ
ត្រូវជួបភ័យ ក្តីវិបត្តិ ផងនានា
មានចោរភ័យ អគ្គិភ័យ ញាតិផងគ្នា
ព្រះរាជា ប៉ងប្រាថ្នា ទាំងយប់ថ្ងៃ ។
ទឹកជំនន់ ជោរជន់លិច ឲ្យវិនាស
អ្នកជាម្ចាស់ ជួបប្រទះ ស្តាយអាល័យ
កើតសោកសៅ ក្តៅក្រហាយ ទាំងយប់ថ្ងៃ
ព្រោះអាស្រ័យ ការជំពាក់ ទាក់ជាប់ចិត្ត ។
មានតែបុណ្យ ជាទ្រព្យធន ជាប់តាមប្រាណ
នាំសុខសាន្ត បានថ្ងៃយប់ ប្រាកដពិត
ក្នុងឥធលោក[១] បរលោក មិនសោកកិត
បុណ្យជាមិត្រ ពិតជួយផ្តល់ ផលសុខា ៕

(១) ឥធលោក អ៊ិធ:-- បា.; សំ. (ន.) (ឥហ--) លោកនេះ

# ២៩. សំបកក្រៅ សាច់ក្នុងព្រះសាសនា

នៅទីបំផុត អាត្មាបានត្រឡប់មកសម្រាកនៅវត្តជើងភ្នំទៀត ដោយមិនបាននឹកនាបណ្ដាមិត្តធម៌ដែលធ្លាប់នៅក្នុងវត្តជាមួយគ្នា មកចោមរោមសួរសុខទុក្ខ ។ នៅពេលបានដឹងនូវហេតុការណ៍ផ្សេងៗដែលកើតឡើង ម្នាក់ៗឆ្ងល់ ហើយភ័យតក់ស្លុតនូវការធ្វើដំណើររបស់អាត្មា ។

នៅពេលរសៀល អាត្មាទៅអង្គុយលើគ្រែឫស្សីក្រោមដើមឈើនៅមាត់អាងដាក់ទឹកដែលធ្លាប់អង្គុយ ។ ឥឡូវនេះ មកអង្គុយម្ដងទៀត បានយល់ថាធម្មជាតិនៅជុំវិញខ្លួនដូចជាសប្បាយត្រជាក់ ដើមឈើពេញវត្តកំពុងតែបញ្ចេញសន្លឹកខៀវខ្ចី ដើមឈើខ្លះចេញសន្លឹកបៃតង ដើមឈើខ្លះពណ៌ក្រហមជាំ ដើមខ្លះមានពណ៌ប្រផេះស ដើមខ្លះពណ៌ខៀវលោង ។ នៅពេលឃើញស្លឹកឈើស្ករតៗ ធ្វើឲ្យចិត្តគិតដល់ជាតិ ការកើត ពេលគិតដល់សេចក្ដីកើត ចិត្តថ្លើមក៏ដើរតាមខ្សែតទៅដល់ជរា សេចក្ដីចាស់ ព្យាធិ សេចក្ដីឈឺ និងមរណៈ សេចក្ដីស្លាប់ ។ ស្លឹកឈើដែលកំពុងស្រស់ល្អទាំងនោះ នៅពេលដល់ខែមិនាខាងមុខ ពេលធាតុអាកាសអស់ភ្លៀង ពេលដីស្ងួតហួតហែង ក្ដៅក៏នឹងក្លាយទៅជាពណ៌លឿងព្រោះជរា ហើយក៏ជ្រុះធ្លាក់ចុះលើផែនដីដូចគ្នានឹងផ្កាសាលព្រឹក្សស្ងួតពណ៌ស្ករត្នោត នៅគរពាសពេញដីដោយគ្មានតម្លៃ ត្រូវមនុស្សដើរជាន់ទៅមក

*ដែលកាលពីមុនមានក្លិនក្រអូបសាយ រីកស្គុះស្គាយពេញលើផើងយ៉ាងស្រស់បំព្រង ទទួលវាយោ រស្មីព្រះអាទិត្យ និងពពួកមេអំបៅយ៉ាងស្រស់ត្រកាល ។*

*ចំណែកអាងដាក់ទឹកនោះ នៅពេលនេះទឹកក៏រីងស្ងួត នៅសល់បាតអាងបន្តិចបន្តួចដែរ ពីព្រោះត្រូវនឹងចំហាយព្រះអាទិត្យ មច្ឆាជាតិ ត្លាម ត្រី ដែលត្រូវលំដាប់ទឹកដេញទៅរួមគ្នានៅក្នុងបរិវេណចង្អៀតៗ ម្នាក់ៗខំតស៊ូបម្រះនឿយ ដើម្បីឲ្យរួចពីមាត់ត្រីធំៗ ដែលធ្វើឲ្យទឹកល្អក់ក្លាយទៅជាពណ៌ឈាម ។ សត្វកុក ក្រសារ និងសត្វដែលស៊ីត្រីជាអាហារផ្សេងៗទៀត ខ្លះទំតាមមែកឈើ ខ្លះឈរស្ងៀមនៅមាត់ទឹកដោយមាយា សម្លឹងមើលដោយភ្នែកមុតចាំចាប់ចឹកត្រីដែលអើតក្បាលចេញមក ឬក៏ឆ្លេចខ្លួនហែលមកជិតច្រាំង គឺត្រូវសត្វទាំងនោះដែលមានចំពុះវែងស្រួចនៅចាំចឹក បើកាលណាមិនមានភ្លៀងបង្អុរចុះមកទាន់វេលាទេ មច្ឆាទាំងនោះត្រូវវិនាសទាំងអស់យ៉ាងពិតប្រាកដ ។*

*នៅពេល បានឃើញជតាកម្មរបស់ពួកមច្ឆាក្នុងអាងតម្កល់ទឹកហើយ ក៏យកមកគិតដល់មនុស្សក្នុងលោកដែលបៀតបៀនគ្នានៅក្នុងលោក ដូចជាសម្លាប់គ្នាដណ្ដើមគ្នា ដូចជាពួកមច្ឆាកំពុងគ្រៀមស្ងួត គឺលោកនេះត្រូវទឹកស្រកនៅពេលវេលាដែលខះតិចទៅៗជានិច្ច ដេញទៅរកជរាភាព ហើយទៅដល់មាត់សត្វ ដែលមានចំពុះវែងស្រួចនៃសត្វដែលស៊ីមច្ឆាគឺមច្ចុរាជ ដែលនៅឈរចាំឆក់យកជីវិតមនុស្សនៅគ្រប់ខណៈ ។ ពេលណាខ្ញុំនិព្វានធម៌ដែលត្រជាក់ហូរ*

ធ្លាក់មកស្រោចស្រង់ នៅពេលនោះសត្វនឹងបានរួចចាកផុត អំពីវិវដ្តភ័យគឺ កើត ចាស់ ឈឺ ស្លាប់ ។

នៅពេលអាត្មា កំពុងតែអណ្តែតពិចារណាធម៌ ដោយចិត្តយ៉ាងស្ងប់នោះឯង ក៏ត្រូវធ្លាក់ព្រើតនូវពាក្យសម្តីអ្នកសួរ ដែលលេចឮមកពីខាងក្រោយថា៖

- ព្រះគុណម្ចាស់!

នៅពេលងាកទៅមើលម្ចាស់សម្លេង ក៏បានជួបនឹងបុគ្គលដែលមិននឹកស្មានថាមកជួប គឺបណ្ឌិតវិទ្យាសាស្ត្រ ក្រមុំ ដួងកែវ និងក្មេងប្រុសតូចម្នាក់ឈរនៅក្បែរដោយកិរិយាសម្តែងអាការៈក្រែងរអែងចិត្ត ។

- ខ្ញុំម្ចាស់មានបញ្ហាច្រើនយ៉ាងដែលចង់មកសួរព្រះអង្គទានម្ចាស់? ហើយគេក៏ពោលបន្តទៅទៀត, ទើបចង់តាមមកសន្ទនាជាមួយ...

អាត្មាមើលទៅជុំវិញគៀនៗ ដោយមិនសូវស្រួលក្នុងចិត្ត ពីព្រោះទីកន្លែងនេះនៅកណ្តាលវាល មិនកំបាំងភ្នែកតែឆ្ងាយពីកន្លែងឯទៀតក្នុងវិត្តអារាម ចាត់ទុកថាជាទីកំបាំងត្រចៀកបាន សូម្បីតែមានក្មេងប្រុសនៅជាមួយ ក៏មិនទុកចិត្តថា ក្មេងនេះស្តាប់យល់ពាក្យហើយឬនៅ ទើបពោលតបទៅវិញថា៖

- បើដូច្នេះ សូមញោមទៅនិយាយគ្នាជាមួយអាត្មានៅឯសាលាទទួលភ្ញៀវឯនុ៎ះ

- ខ្ញុំកូណាយល់ថា ព្រះអង្គជាព្រះសង្ឃប្លែកពីព្រះសង្ឃឯទៀតដែលធ្លាប់បានឃើញមក! នាងស្រីពោលឡើងនៅ

- ពេលអន្លុយគ្រាបអាត្មារួចហើយ នៅសាលាទទួលភ្ញៀវ, តែអាត្មាមិនបានគិតថា ខ្លួនឯងប្លែកពីព្រះសង្ឃសាវឹករបស់ព្រះបរមសាស្តាអន្លផ្សេងៗឡើយ តើញោមឃើញអាត្មាប្លែកយ៉ាងណា?

នាងនុំះសម្លែងឫកពាមិនចេញស្តីមួយសន្ទុះ ហើយឆ្លើយថា៖

- ខ្ញុំកូណាប្រាប់មិនត្រូវទេ ថាតើវាប្លែកយ៉ាងណា តែឲ្យនឹងថាលោកម្ចាស់ប្លែក ធ្វើឲ្យចង់សន្ទនាជាមួយ ជឿថាព្រះអន្ល ប្រហែលជាអាចផ្តល់នូវសេចក្តីយល់នឹងដល់ខ្ញុំកូណាជាមិនខាន តាមធម្មតាខ្ញុំកូណាជាមនុស្សមិនងាយជឿគេងាយៗទេ ចូលចិត្តប្រកែករកខុសរកត្រូវសិន លុះត្រាត្រូវបង ចំណាន និងញាតិមិត្តថាឲ្យខ្ញុំម្ចាស់ជាមនុស្សក្បាលរឹងជាមនុស្សមិនមានសាសនា, ខ្លួនខ្ញុំកូណាខ្លួនឯង ក៏មិនដឹងដូចគ្នា ថាមានសាសនាឬក៏អត់ ពីព្រោះមិនបានគោរពអ្វីឲ្យពិតប្រាកដ មិនជឿស្អីឲ្យច្បាស់លាស់ នៅពេលមានគេសួរឬនៅពេលបំពេញសំណុំរឿង ខ្ញុំកូណាតែងតែដាក់ថាជាពុទ្ធសាសនិកជនជាយ៉ាងនេះឯង មិនច្បាស់ថាខ្លួនឯងជាអ្នកកាន់សាសនាព្រះពុទ្ធឬមិនមែន សូមព្រះអន្លជួយអធិប្បាយឲ្យខ្ញុំកូណាស្តាប់បន្តិចទៅមើលបានឬទេទាន? ថាគេដែលជាអ្នកកាន់ព្រះពុទ្ធសាសនានោះ គេធ្វើយ៉ាងម៉េចខ្លះ?

ពេលស្តាប់ពាក្យនិយាយរៀបរាប់ ដូចជារំងាប់ទុក្ខរបស់ ដួងកែវ អាត្មាបានយល់ភ្លាមថា គេជាពុទ្ធជនសម័យថ្មី ដែលមានការចេះដឹងខាងផ្លូវលោកច្បាស់ តែខ្វះសេចក្តី

នឹងខាងផ្លូវចិត្ត ឃើញសាសនាតែក្នុងពិធីកម្មជាពិសេស ទើបអស់ជំនឿ អស់សទ្ធាក្នុងសាសនា ដើម្បីកែនូវសេចក្ដីសង្ស័យរបស់គេ ទើបអាត្មាពោលថា៖

- ដូច្នេះចុះបើញោមមិនជឿ មិនជ្រះថ្លាក្នុងពុទ្ធសាសនា ប្រហែលញោមជឿនូវអ្វីម្យ៉ាងជាប្រាកដ ប្រាប់អាត្មាបន្តិចបានឬទេ ថាញោមជឿស្អីច្រើនបំផុត?

នាងស្រីធ្វើដូចជាគិតមួយសន្ទុះ ទើបឆ្លើយឡើងថា៖

- ខ្ញុំម្ចាស់ជឿក្នុងគោលការរបស់វិទ្យាសាស្ត្រ!

- អាត្មាជឿថា កាលពីញោមនៅក្មេង មិនទាន់នឹងរៀនវិទ្យាសាស្ត្រ ញោមក៏មិនមានការជឿក្នុងគោលវិទ្យាសាស្ត្រដែរ ដែលអាត្មានិយាយដូច្នេះ តើមែនឬទេ?

- មែន! នាងស្រីនោះព្រមឆ្លើយទាំងមានចម្ងល់

- ក្រោយមក នៅពេលញោមបានសិក្សាវិទ្យាសាស្ត្រយ៉ាងច្បាស់ បាននឹង បានយល់អំពីគោលវិទ្យាសាស្ត្រទើបញោមកើតមានសេចក្ដីជឿពិតប្រាកដមែនឬទេ?

- មែន!

- អាត្មាសូមសួរបន្តិចថា ដូចម្ដេចទើបញោមជឿលើគោលវិទ្យាសាស្ត្រ?

- ពីព្រោះខ្ញុំកូណាដឹងថាគោលវិទ្យាសាស្ត្រ ជាគោលល្អបំផុត ត្រឹមត្រូវគួរឲ្យជឿប្រាកដ, នាងស្រីនេះឆ្លើយយ៉ាងច្បាស់

- ល្អហើយ! ញោមឆ្លើយត្រូវគ្រប់ប្រការ អាត្មាសូមសរុបក្នុងចិត្តនេះថា ញោមមានជំនឿ និងជ្រះថ្លានូវគោល

ការណ៍របស់វិទ្យាសាស្ត្រ ព្រោះមូលហេតុពីរប្រការគឺ ៖ ប្រការទីមួយ ព្រោះញោមបានសិក្សាវិទ្យាសាស្ត្រដោយពិតប្រាកដ, ប្រការទីពីរ ញោមយល់ឃើញថាគោលវិទ្យា - សាស្ត្រល្អគួរឲ្យជឿ អាត្មាសរុបយ៉ាងនេះតើត្រូវឬទេ ?

- ល្អហើយចុះ ! អាត្មាសូមសួរទៅញោមថា តើញោមបានសិក្សាគោលរបស់ព្រះពុទ្ធសាសនា យ៉ាងពិតប្រាកដដូចជាញោមបានសិក្សាគោលនៃវិទ្យាសាស្ត្រហើយឬនៅ ?

នាងស្រីសម្លឹងដូចជាមានអំណួត ហើយក៏ឆ្លើយចេញមកដោយសម្លេងតិចៗថា ៖

- នៅទេទាន !

- បើញោមមិនទាន់បានសិក្សា ញោមក៏មិនទាន់បានយល់នូវសេចក្ដីរាក់ជ្រៅ គ្រាស់ស្តើង របស់គោលព្រះពុទ្ធសាសនា នៅពេលមិនដឹងញោមក៏កុំអាលសម្រេចចិត្តថាគោលនៃព្រះពុទ្ធសាសនាល្អ ឬមិនល្អ នៅពេលសម្រេចចិត្តមិនទាន់បានញោមក៏មិនទាន់ជឿជាធម្មតា ព្រោះដូច្នោះមិនមានផ្លូវណាផ្សេងក្រៅពីនឹង សូមឲ្យញោមសិក្សាមើលសិន នៅពេលបានសិក្សាចប់ហើយ ឃើញថាមិនល្អ មិនគួរឲ្យជឿ ឈប់ជឿក៏បានដែរ ប៉ុន្តែបើមិនបានសិក្សាទេមិនទាន់ដឹងទេ ស្រាប់តែពោលថាព្រះពុទ្ធសាសនាមិនគួរជឿទេ អាត្មាយល់ថាជាការមិនឲ្យសេចក្ដីយុត្តិធម៌ដល់ព្រះពុទ្ធសាសនា

ដួងកែវឱនមុខចុះគិតមួយសន្ទុះធំ ហើយពោលឡើងដោយសម្លេងតិចៗថា ៖

- ព្រះអង្គមានតីការត្រូវទៅតាមគោលតែម្តងទាន តែថា ខ្ញុំកូណាមិនបានសិក្សាព្រះធម៌អាថី ហើយមិនមានការចេះ នឹងសោះក៏មិនត្រូវ ការពិតចេះខ្លះដែរ តែខ្ញុំកូណាមិនឃើញ មានអ្វីក្រៅតែពីការសូត្រមន្ត ធ្វើបុណ្យ ធ្វើទាន រក្សាសីល បុណ្យកឋិន បុណ្យផ្កាប្រាក់ ហែទៀនវស្សា ធ្វើតែល្អលះ អំពើអាក្រក់ សាសនាណាៗក៏ឃើញដូចគ្នា បង្រៀនឲ្យ មនុស្សជាមនុស្សល្អដូចគ្នាទាំងអស់

នៅពេលបានស្តាប់ពាក្យរបស់ដួងកែវ អាត្មាបាន យល់ភ្លាមថា គេមានការចេះនឹងផ្លូវពុទ្ធសាសនាតិចតួច ណាស់ ស្គាល់តែការធ្វើពិធីផ្សេងៗ ដូចជាអ្នកកាន់ពុទ្ធ សាសនាទូទៅ ដើម្បីទាញគេឲ្យជឿចូលដល់សម្មាទិដ្ឋិនោះ ទើបអាត្មាពោលឡើងថា៖

- មុននឹងពន្យល់ឲ្យញោមចូលចិត្ត តទៅអាត្មានឹង និទានឲ្យញោម ស្តាប់នូវរឿងមួយ តាមធម្មតាគេនិទានឲ្យ ក្មេងៗស្តាប់ ដើម្បីឲ្យក្មេងយល់ពីគតិធម៌ដ៏ជ្រៅ តែមនុស្សធំ ខ្លះគឺធំតែខ្លួនចិត្តនៅក្មេង ត្រូវនិយាយរឿងឲ្យស្តាប់ដូចគ្នា

ពាក្យពោលរបស់អាត្មា ធ្វើឲ្យនាងស្រីងើយមុខឡើង សម្លឹង មើលមកអាត្មាដោយក្រសែភ្នែកសម្តែងនូវសេចក្តី មិនពេញចិត្តភ្លាម ៗ

- ព្រះអង្គមាត់អាយខ្ញុំកូណា! គេពោលចេញមកដោយ ឫកពារសម្តែងនូវសេចក្តីក្រោធ, លោកម្ចាស់នៅមាត់អាយ អ្នកឯទេ ខ្ញុំកូណាខកបំណងខ្លាំងណាស់ទាន, ថាហើយក៏ស្ទុះ ក្រោកដើរចេញទៅ ៗ

អាត្មាប្រញាប់រម្ងាប់ចិត្ត ក៏ផ្សាយមេត្តាឲ្យស្រីក្រមុំនោះ ហើយពោលថា ៖

- អ្នកណាបានឮសម្លេងទាស់ត្រចៀក សូម្បីតែបន្តិចក៏តូចចិត្ត អ្នកនោះចិត្តនៅដូចកូនក្មេងនៅឡើយទេ !

ពាក្យពោលរបស់អាត្មា ធ្វើឲ្យនាងស្រីនោះឈរនៅស្ងៀមមួយសន្ទុះ ហើយក៏ត្រឡប់មកអង្គុយវិញ នៅខាងមុខអាត្មាដូចដើម ៗ

- លោកម្ចាស់នេះពូកែមែន ! គេនិយាយតិចៗ ហើយសម្លឹងមើលមុខអាត្មា

- ញោមអើយ ! ផែនដីនេះមិនមែនជារបស់ញោមតែម្នាក់ឯងទេ ញោមកើតមកក្នុងលោកនេះជាប់ជំពាក់នឹងលាភយស សរសើរ សុខ តែម៉្យាងមិនបានទេ ត្រូវព្រមទទួលការអស់លាភ អស់យស អស់សរសើរ និងទុក្ខផងដែរ ៗ ប្រៀបដូចជាដីវីច្បាំងក្នុងសង្គ្រាម ត្រូវអត់ធ្មត់ជាមួយព្រួញរបស់សត្រូវបាញ់មកគ្រប់ទិសទាំង ៤ ដីវីណាត្រូវព្រួញតិចតួច ស្រាលៗ ក៏រត់ចោលបាត់ ដីវីនោះមិនមែនជាដីវីចម្បាំងទេ មិនសមតាមតំណែង ជាពលដំរីរពាហនៈនោះទេ

- និមន្តលោកម្ចាស់និទានរឿងរបស់លោកម្ចាស់នោះចុះទាន

- ការដែលញោមយល់ថា សាសនាមានតែគឋិន ហែផ្កាប្រាក់ ធ្វើល្អ កុំធ្វើអាក្រក់នោះ វាជាការយល់ឃើញរាក់ៗទេ ឯរឿងដែលអាត្មានឹងនិទានឲ្យស្ដាប់គឺ ពេលមួយនោះមានបុរសបីនាក់ដើរឆ្លងកាត់ព្រៃធំៗ មានសេចក្ដីស្រេក

ឃ្លានយ៉ាងខ្លាំង ។ នៅពេលដើរមកដល់កន្លែងមួយ បានជួបដូងខ្ចីមួយគំនរធំក្រោមដើមឈើ នៅក្បែរនឹងគំនរនោះមានដាក់ផ្លាកសរសេរប្រាប់ថា អ្នកដែលស្រេកឃ្លាន សូមបរិភោគដូងនេះតាមសេចក្ដីប្រាថ្នាចុះ ។

**បុរសទី ១** ដើរមកដល់មុនបានអានផ្លាកនោះហើយក៏ចាប់យកដូងមួយមក ដោយមិនធ្លាប់បានស្គាល់ដូងពីមុនហើយមិនដឹងពីវិធីបរិភោគផ្លែដូងទៀត ទើបយកចុងកាំបិតមុតស្រួចចាក់សម្បកដូងនោះ ដោយរំពឹងគិតថា ទឹកនឹងហូរចេញមក តែលិទ្ធមើលទៅគ្រប់កន្លែងហើយ ក៏មិនឃើញមានទឹកហូរចេញមកទៀត ។ ទើបគេនិយាយដោយភាពល្ងង់ថា នៅទីបំផុតដូងគ្មានអ្វីសោះ ក្រៅពីសម្បករុំពទ្ធដែលឥតប្រយោជន៍ គេក៏បោះដូងនោះទៅកន្លែងដដែលវិញ ហើយក៏ដើរចេញទៅ ។

**បុរសទី ២** ដើរមកដល់គំនរដូង និងអានផ្លាក ហើយក៏ចាប់យកដូងមួយមក រួចយកកាំបិតចេញមកចាក់ លើកយកមកហូបដូចជាបុរសទី១ដែរ តែគេមិនឈប់ត្រឹមនឹងនោះទេ គេជឿថាច្បាស់ជាមានស្អីនៅខាងក្នុងជាក់ជាមិនខាន ។ ទើបបកសម្បកដូងចេញឲ្យអស់នៅសល់តែលលាដ៍ រួចគេយកកាំបិតចាក់លលាដ៍ដូង តែមិនឃើញមានអ្វីក្រៅពីភាពរឹងដូចថ្មសោះ ។ គេក៏នឹកអស់សង្ឃឹម ហើយក៏ដើរចេញចោលដូងនោះដែរទៅ ។

**បុរសទី ៣** យកដូងឡើងមកបកសំបកចេញ សល់តែលលាដ៍ ហើយចាប់អង្រួនមើល ពេលបានឮសូរស្អីនៅ

ខាងក្នុង គេក៏ឆ្កឹះលលាដ៍ដូងនោះចេញ ទើបឃើញសាច់ដ៏ផ្អែមឈ្ងុយ និងទឹកដ៏ផ្អែមត្រជាក់គួរជាទីពេញចិត្ត ។ គេហូបសាច់ដូង និងទឹកដូងបានឆ្អែតសប្បាយហើយ ក៏ធ្វើដំណើរបន្តទៀតបាត់ទៅ ។

ញោមអើយ សាសនារបស់ព្រះសម្មាសម្ពុទ្ធនៃយើងក៏ដូចជា ដូងនេះដែរ គឺមានទាំងសំបក ទាំងសាច់ និងទឹក ។

កម្មវិធីបុណ្យផ្សេងៗដូចជា ការថ្វាយបង្គំព្រះ សូត្រមន្ត ធ្វើបុណ្យ ដាក់បាត្រ ការបង្វិលទៀន ការហែកឋិន ហែផ្កាប្រាក់ បុណ្យចូលវស្សា ទាំងអស់នេះគ្រាន់តែជាសម្បកនិងគ្រាន់តែជាកិច្ចរបស់សាសនាព្រះពុទ្ធតែប៉ុណ្ណោះ ដោយមិនបានជ្រួតជ្រាបច្បាស់ពីព្រះពុទ្ធសាសនា អ្នកនោះក៏ដូចជាបុរសដែលឃើញត្រឹមតែសម្បកក្រៅរបស់ដូង ហើយក៏បោះដូងនោះចោលទៅ ។

អរិយធម៌ផ្សេងៗដូចជាអំពើល្អ អំពើអាក្រក់ សេចក្ដីសុខ សេចក្ដីទុក្ខ ប្រយោជន៍ ឥតប្រយោជន៍ គុណ ទោស ចម្រើន វិនាស និងការប្រាស្រ័យទាក់ទងជាមួយមនុស្សគ្រាន់តែជាសម្បកក្រៅរបស់ព្រះពុទ្ធសាសនា ។ អ្នកកាន់ព្រះពុទ្ធសាសនា គ្រាន់តែជៀវចាកអំពើអាក្រក់ ធ្វើនូវអំពើល្អអ្នកនោះបានត្រឹមកាន់ស្លឹកដូង ។ ជនណាឃើញព្រះពុទ្ធសាសនា មានតែអរិយធម៌ ហើយក៏នៅស្ងៀមមិនរវល់នឹងព្រះពុទ្ធសាសនា អ្នកនោះក៏ដូចជាបុរសដែលឃើញលលាដ៍ដូងហើយបោះដូងចោលដូចគ្នា ។

អរិយសច្ចធម៌ទាំង ៤ គឺ ទុក្ខ ហេតុឲ្យកើតទុក្ខ ការ

*រំលត់នូវទុក្ខ ផ្លូវបដិបត្តិឲ្យដល់សេចក្តីរំលត់ទុក្ខ គឺជាសាច់និងទឹកដូងរបស់ព្រះពុទ្ធសាសនា ។ ជនណាចូលទៅដល់អរិយសច្ចៈ ជននោះបានដល់នូវព្រះពុទ្ធសាសនា នឹងបានទទួលនូវផលនោះគឺ **ញាណ វិជ្ជា វិមុត្តិ និព្វាន** ដូចជា បុរសទី ៣ ដែលបានបរិភោគទឹក និងសាច់ដូងឆ្ងាញ់ហើយស្អែតយ៉ាងសុខសប្បាយនោះឯង ។*

# កុំទាន់ថា

*បទពាក្យ ៧*

*កុំធ្វើជាមនុស្សរមិលគុណ　　កុំខ្លាចខ្លួនអន់ពោលបំភ្លៃ*
*កុំរស់ជាមនុស្សឈ្មោះពួរជ្រៃ　　កុំគិតកាលខ្លីលៃកាលវែង ។*
*កុំចេះតែពោលឲ្យផុតមាត់　　អ្វីមិនប្រាកដកុំសម្តែង*
*កុំចេះតែស្តីឮក្តែងៗ　　ប្រយ័ត្នប្រយែងពាក្យសម្តី ។*
*អ្វីដឹងមិនដល់ឆ្ងល់មិនអស់　　កុំទាន់ថ្កោលទោសក្រែងខុសន័យ*
*ត្រូវខំពិនិត្យគិតលកលៃ　　បានយល់អត្ថន័យច្បាស់ក្នុងចិត្ត ។*
*ក្នុងលោកមានមកជាគូគ្នា　　មានប្រាជ្ញពាលាឆ្លាតល្ងង់ពិត*
*អាក្រក់ល្អសខ្មៅភ្លឺល្ងិត[១]　　ខុសត្រូវឆ្ងាយជិតល្អិតតូចធំ ។*
*មេឃដីស្រីប្រុសជាធម្មតា　　សប្បាយហឹុហាការសើចយំ*
*យកមកបូកសងគិតផ្សំផ្គុំ　　បានជាអារម្មណ៍ផ្តល់គំនិត ។*
*អាក្រក់លះចោលល្អកាន់យក　　បង្កើនលេខបូកបានផលពិត*
*ចម្រើនបញ្ញាថ្លាគំនិត　　កំចាត់ងងឹតអវិជ្ជាបាន ៕*

---

(១) តាមត្រូវគឺ ងងឹត តែទីនេះតម្រូវតាមពាក្យជួន ។

# កាន់ឲ្យប្រាកដ

បទពាក្យ៧

បើកាន់សាសនាថាតែមាត់ កាន់ឥតប្រាកដមិនសិក្សា
ឥតបានស្វែងយល់ខ្វល់ចាំថា សម្លឹងទោសាចាប់កំហុស ។
ធ្វើឲ្យចិន្តាកើតហ្មងសៅ ព្យាយាមពោលដៅតែខាងខុស
សម្លឹងប្រឹងមើលឃើញតែទោស កើតក្ដីប្រទូស្តអស់សទ្ធា ។
វិជ្ជាការងារសព្វសារពើ ចេះបានពីធ្វើនិងសិក្សា
ឲ្យបានដឹងយល់ន័យខ្លឹមសារ ទើបអាចកើតការប្រយោជន៍បាន ។
ពុំមែនសញ្ជឹងប្រឹងចាំថា មិនយល់គោលការណ៍ថាដៅស្មាន
ចំណេះយល់ដឹងកើតពីរៀន ប្រាជ្ញាកើតមានព្រោះស្ដាប់គិត ។
ដ្បិតអ្វីពុំទាន់ចេះស្គាល់យល់ ច្របូកច្របល់ខ្វល់គំនិត
ហាក់ដូចនេត្រខ្វាក់ត្រូវងងឹត នឹងយល់ការពិតដូចម្ដេចបាន? ។
ត្រូវព្យាយាមខំស្ដាប់វិចារណ៍ បង្កើនបញ្ញាឲ្យកើតមាន
ទុកដូចប្រទីបដាប់ជិតប្រាណ ឆ្លុះបំភ្លឺបានឃើញអ្វីៗ ។
ដែលចិត្តប្រាថ្នាចង់ដឹងយល់ បំបាត់ចម្ងល់អស់សង្ស័យ
បញ្ញាប្រចក្សជាក់អត្ថន័យ ជ្រៅរាក់ម្ដេចក្ដីប្រាកដបាន ៕

ដោយឧបាសក មុិញ សារ៉ាង

# ២៦. ការដឹង និង ការឃើញនូវអរិយសច្ច

នាងស្រីនោះអង្គុយឈ្ងោកមុខគិតមួយសន្ទុះ ហើយសួរថា៖

- លោកម្ចាស់មានន័យថា អ្នកកាន់ព្រះពុទ្ធសាសនា ត្រូវតែឆ្លងកាត់នូវសំបក និងលលាដ៍របស់ព្រះពុទ្ធសាសនា ចូលទៅដល់សាច់ និងទឹក គឺអរិយសច្ចតែម្ដង ដូច្នេះមែនឬទេទាន?

- ត្រូវហើយ! អាត្មាឆ្លើយ

- តើមិនខ្ពស់ពេកទេឬ?

- ខ្ពស់យ៉ាងម៉េច? អាត្មាសួរ

- ខ្ញុំកូណាមិនសូវយល់ដឹងពីអរិយសច្ច ការពិតជាធម៌ដ៏ប្រសើរនៃអរិយធម៌របស់ព្រះអង្គ ព្រះអរិយបុគ្គលតែប៉ុណ្ណោះទើបយល់ដឹងអរិយសច្ច ចំណែកឯមនុស្សធម្មតាៗដែលមានកិលេសក្រាស់ បញ្ញាតិច តើនឹងឃើញនូវអរិយសច្ចបានយ៉ាងណាទៅ?

- ញោមនៅយល់ខុស!

- តើខុសត្រង់ណាទាន? នាងស្រីសួរដោយឫកពាប្លែកក្នុងចិត្ត, បើសិនខ្ញុំកូណាយល់ខុស ចុះព្រះសង្ឃទ្រង់សម្ដែងធម្មទេសនា ដែលខ្ញុំកូណាធ្លាប់បានស្ដាប់ និងសៀវភៅធម៌ផ្សេងៗ ដែលខ្ញុំកូណាបានអានមក តើខុសទាំងអស់នោះដែរឬទាន? ព្រោះនរណាៗគេក៏ថា អរិយសច្ច ជា

ការឃើញពិតរបស់ព្រះអរិយបុគ្គលទាំងនោះ

- ត្រូវហើយ ! អរិយសច្ចជាសេចក្ដីពិតរបស់ព្រះអរិយបុគ្គលតែអាត្មាសុំសួរបន្ដិចចុះថា ព្រះអរិយៈលោកជាអរិយបុគ្គលតាំងពីកំណើត ឬលោកជាបុគ្គលធម្មតាមកពីមុន រួចក៏បានសម្រេចជាអរិយបុគ្គល នៅពេលខាងក្រោយមក ?

- លោកជាបុគ្គលធម្មតាពីមុន ហើយបានក្លាយជាអរិយបុគ្គល នៅពេលក្រោយ

- តើហេតុបច្ច័យអ្វី បានជាធ្វើឲ្យបុគ្គលធម្មតាក្លាយទៅជាព្រះអរិយបុគ្គលបាន ?

នៅពេលនាងស្រីមិនអាចឆ្លើយតបាន ទើបអាត្មាឆ្លើយខ្លួនឯងវិញថា ៖

- ការឃើញអរិយសច្ចនោះហើយ ដែលធ្វើឲ្យបុគ្គលធម្មតាប្រែក្លាយទៅជាអរិយបុគ្គល មិនមែនបានជាអរិយ-បុគ្គលមុន ទើបឃើញអរិយសច្ចនោះទេ ត្រូវតែឃើញនូវអរិយសច្ចជាមុនសិន ការឃើញអរិយសច្ចនេះហើយ ដែលជាហេតុបានក្លាយជាអរិយបុគ្គល ហេតុត្រូវកើតមុនផលជានិច្ច អាត្មាសូមលើកយកញោមមកធ្វើជាឧទាហរណ៍បច្ចុប្បន្នញោមជាបណ្ឌិតវិទ្យាសាស្ដ្រ អាត្មាចង់ដឹងថា ញោមជាបណ្ឌិតវិទ្យាសាស្ដ្រមុន ទើបចេះវិទ្យាសាស្ដ្រ ឬត្រូវតែរៀនឲ្យចេះមុខវិជ្ជាវិទ្យាសាស្ដ្រមុន ទើបក្លាយជាបណ្ឌិតវិទ្យាសាស្ដ្រ ?

- ត្រូវរៀនវិទ្យាសាស្ដ្រមុន !

- ការក្លាយទៅជាព្រះអរិយបុគ្គលក៏ដូចគ្នាដែរ បើមិនទាន់បានឃើញអរិយសច្ចនោះទេ ក៏មិនអាចក្លាយជាព្រះអរិយបុគ្គលបានដែរ ព្រះអរិយបុគ្គលគ្រប់ៗអង្គពីមុន ក៏ជាមនុស្សធម្មតាដូចយើងនេះឯង ៗ នៅពេលបានស្វែងយល់ឃើញអរិយសច្ច ហើយទើបក្លាយទៅជាព្រះអរិយបុគ្គល ព្រោះមនុស្សធម្មតាក៏អាចក្លាយទៅជាព្រះអរិយបុគ្គលបាន។

- លោកម្ចាស់មានដីកា ហាក់ដូចជាអរិយសច្ចបានមកដោយងាយៗ

- ជាការពិតណាស់អរិយសច្ច ឃើញបានដោយងាយមួយបែបផ្សេង ចំណែកផ្នែកវិទ្យាសាស្ត្រវិញ ដែលបានរកឃើញការពិតថាផែនដីមានរាងមូល ទម្រាំមនុស្សរកឃើញជាក់ច្បាស់បែបនេះ គឺត្រូវប្រើពេលវេលារាប់រយឆ្នាំ ហើយទម្រាំរកឃើញបាន គឺត្រូវប្រើដើមទុន ដូចជាប្តូរជីវិតដើម្បីស្រាវជ្រាវនេះឯង ៗ អ្នកវិទ្យាសាស្ត្រខ្លះរហូតដល់អស់ជីវិតទៀត ព្រោះតែការសិក្សាស្រាវជ្រាវរកការពិតខាងផ្លូវវិទ្យាសាស្ត្រ ប្រាស្រ័យទាក់ទងគ្នាជាបណ្ដាញមួយ ៗ ទម្រាំនឹងបានរកឃើញ ត្រូវប្រើប្រាស់ឧបករណ៍ ផ្សេងៗដូចជាគ្រឿងអេឡិចត្រូនិចទំនើបៗដើម្បីជាជំនួយក្នុងការសិក្សាស្រាវជ្រាវ ប៉ុន្តែការសិក្សារកនូវការពិតនៃអរិយសច្ចនោះ មិនបាច់អស់ដើមទុន ប្រើកម្លាំងធ្វើដំណើរនោះទេ ពីព្រោះអរិយសច្ចនៅក្នុងខ្លួនញោម ហើយក៏មិនចាំបាច់ប្រើឧបករណ៍អ្វីផ្សេងនោះដែរ ៗ ព្រះអរិយបុគ្គលដែលរកឃើញនូវអរិយសច្ចក៏មិនដែលឃើញថាលោកត្រូវប្តូរជីវិតធ្វើដំណើរ ដើម្បី

ដើម្បីពិសោធន៍ទីកន្លែងនានា មិនដែលឃើញលោកប្រើគ្រឿងផ្ទុះ ឬ កែវិស្វកម្មផ្សេងៗអ្វីសោះឡើយ ព្រោះហេតុដូច្នោះហើយ អ្នកណាពោលយ៉ាងណាក៏ដោយ អាត្មានៅតែយល់ឃើញថា អរិយសច្ចឃើញបានងាយដូច្នោះឯង

- លោកម្ចាស់មានដីកាប្រៀបធៀបគួរឲ្យចង់ស្តាប់មែនទាន ! នាងស្រីពោលឡើងតិចៗ, ប៉ុន្តែមានអ្វីខ្លះដែលទាក់ទងគ្នាថា បើអរិយសច្ចឃើញបានងាយដូចលោកម្ចាស់មានដីកានេះ មនុស្សក៏គួរនឹងឃើញអរិយសច្ចទៅជាព្រះអរិយបុគ្គលទូទាំងសាកលលោកអស់ហើយ តែដូច បានដឹងមកហើយថា ព្រះអរិយបុគ្គលរកបានដោយកម្រណាស់សម័យនេះដូចជាមិនមានសោះក៏សឹងថាបាន

- ជាការពិតណាស់ ពុទ្ធបរិស័ទភាគច្រើន ឬបញ្ជិតទាំងអស់ មិនបានឃើញនូវអរិយសច្ចមែន ប៉ុន្តែហេតុដែលមិនឃើញនេះ មិនមែនព្រះអរិយសច្ចឃើញដោយពិបាកនោះទេ ។ អរិយសច្ចមាននៅដូចពីដើម មិនបានបាត់ទៅណាទេ តែហេតុដែលមនុស្សមើលមិនឃើញអរិយសច្ចក៏ពីព្រោះមនុស្សមិនចង់មើល មិនចង់ដឹង មិនចង់ឃើញ នៅពេលជិតឃើញឡើងខ្លះ ក៏ធ្មេចភ្នែកវិញ ឬ ងាកមុខចេញទៅ

- ខណៈនេះខ្ញុំករុណាយល់ស្រប, នាងស្រីនោះនិយាយឡើងច្បាស់ៗ, ខ្ញុំករុណាជឿថា អ្នកណាៗក៏ចង់ដឹង ចង់ឃើញនូវអរិយសច្ចនោះដែរ ពីព្រោះការបានឃើញនូវអរិយសច្ចធ្វើឲ្យមនុស្សក្លាយទៅជាព្រះអរិយបុគ្គល ធ្វើឲ្យផុតចាកទុក្ខ

ខ្ញុំករុណាម្នាក់ឯង ដែលចង់ឃើញអារិយសច្ច!

- មិនមែនទេនឹង! អាត្មាពោលឡើង

- មែន! ដូងកែវពោលឡើងដោយសម្លេងដាច់ខាត

- ល្អហើយចុះ! បើដូច្នេះល្អហើយ មុននឹងសន្ទនាអំពីព្រះធម៌តទៅ អាត្មាសូមសួរនូវបញ្ហាផ្ទាល់ខ្លួនខ្លះ អាត្មាសួរថា បច្ចុប្បន្ននេះញោមអាយុប៉ុន្មាន?

នាងស្រីអង្គុយឈ្ងោកមុខនៅស្ងៀម មិនព្រមឆ្លើយ ពីព្រោះតាមធម្មតាស្រីក្រមុំ ដែលមានអាយុលើសពី ២៥ ឆ្នាំ មិនសូវហ៊ានប្រាប់ពីអាយុពិតរបស់ខ្លួនឲ្យអ្នកដទៃដឹងទេ ។

- ញោមអាយុប៉ុន្មាន? អាត្មាសួរម្តងទៀត

នាងស្រីនេះអឹមអៀនមួយសន្ទុះ ហើយពោលថា៖

- លោកម្ចាស់សួរធ្វើអ្វី? លោកម្ចាស់នឹងមើលហោរឲ្យខ្ញុំករុណាឬ?

- អាត្មាមិនចេះមើលហោរទេ!

- បើដូច្នេះខ្ញុំករុណាមិនទូលប្រាប់ទេ ទាន!

- មិនប្រាប់ក៏មិនអីដែរ បើសិនឲ្យអាត្មាទាយ អាត្មាគិតថាញោម អាយុប្រហែលខ្ទង់ម្ភៃឆ្នាំដែរ

នាងស្រីញញឹមចេញមកដោយពេញចិត្តភ្លាម អាត្មាបណ្តោយឲ្យគេញញឹម ដោយសេចក្តីពេញចិត្តមួយសន្ទុះ ហើយពោលទៀតថា៖

- តែញោមដូចជាចាស់ជាងអាយុ មុខមាត់ឫកពាមើលទៅដូចជាមនុស្សអាយុ ៣៥ ឆ្នាំ

អាការញញឹមរបស់ស្រីក្រមុំនេះ បាត់ទៅភ្លាមមួយ

រំពេច គេសម្លឹងមើលមកអាត្មា ដោយទឹកមុខក្នែកសម្ដែងនូវសេចក្ដីមិនពេញចិត្តយ៉ាងខ្លាំង ។

- អាត្មាសូមទោស បើសិនជាពាក្យសម្ដីរបស់អាត្មាធ្វើឲ្យញោមមិនពេញចិត្ត គ្រាន់តែអាត្មាយល់ថា ញោមក៏ដូចញាតិញោមដទៃទៀត ដែលកាន់ព្រះពុទ្ធសាសនាដែរ មិនចង់ដឹង មិនចង់ឮពីអរិយសច្ច ព្យាយាមគេចពីអរិយសច្ចគ្រប់ពេលវេលាថែមទៀត

នាងស្រីមើលមកអាត្មាដោយឆ្ងល់ហើយទូលសួរថា៖

- លោកម្ចាស់ មានន័យយ៉ាងម៉េចទាន ?

- មានន័យថា ញោមមិនចូលចិត្តភាពចាស់ នៅពេលអាត្មាសួរអាយុ ញោមមិនព្រមប្រាប់ ពីព្រោះខ្លាចក្ដូលេខច្រើននិងពេលអាត្មាប្រាប់វិញថាញោមចាស់ជាងអាយុ ញោមក៏សម្ដែងនូវសេចក្ដីមិនពេញចិត្តចេញមកភ្លាម ពីព្រោះញោមស្អប់ភាពចាស់ ។ ញោមមិនចង់ចាស់ ញោមមិនព្រមទទួលស្គាល់ថាខ្លួនញោមចាស់ទេ ។ ជរា ព្យាធិ និងមរណៈជាអរិយសច្ចមួយប្រការផងដែរគឺជាទុក្ខសច្ច នៅពេលញោមមិនចង់ជួបនូវទុក្ខសច្ចរួចព្យាយាមគេចអំពី ទុក្ខសច្ចយ៉ាងនេះ តើអាចនិយាយបានថា ខ្លួនចង់ឃើញអរិយសច្ចបានយ៉ាងណា

នាងស្រីឈ្ងោកមុខនៅស្ងៀម ដោយសេចក្ដីអៀនខ្មាស ។

- ញោមគ្មានអ្វីសេសវិសាលនោះទេ មនុស្សផ្សេងទៀតក៏ដូចគ្នាយ៉ាងនេះទាំងអស់ ពេលឃើញគ្មានភាពតស៊ូ

ជាមួយនឹងអរិយសច្ច យើងក៏មិនអាចរកផ្លូវឃើញនូវអរិយសច្ចដែរ ។ បើយើងមើលមិនឃើញអរិយសច្ច ក៏នឹងអាចក្លាយទៅជាអរិយបុគ្គលយ៉ាងណានឹងបាន រឿងរ៉ាវមានតែប៉ុណ្ណឹង

- លោកម្ចាស់មានន័យថា ក្នុងអរិយសច្ចទាំង៤នោះ យើងត្រូវស្គាល់ទុក្ខអរិយសច្ចជាមុនសិនមែនឬទេទាន?

- មែន! យើងត្រូវចាប់ផ្ដើមពីការឃើញនូវទុក្ខសច្ចជាមុនសិន បើយើងសិក្សាក្នុងពុទ្ធប្បវត្តិក៏បាន ប្រវត្តិរបស់ព្រះអរិយសាវកទាំងឡាយក៏បាន យើងនឹងបានឃើញថា ជីវិតរបស់លោកគឺចាប់ផ្ដើមដោយការបានឃើញនូវទុក្ខជាមុន ។ សម័យព្រះពុទ្ធអង្គ កាលនៅជាព្រះរាជបុត្រសិទ្ធត្ថ នៅឡើយ នំណើរជីវិតរបស់ទ្រង់ក៏ដូចជាមនុស្សធម្មតាទូទៅអញ្ចឹងដែរ មានថ្ងៃមួយខណៈពេលដែលទ្រង់យាងទតព្រះឧទ្យាន ក៏បានទតដោយព្រះនេត្រផ្ទាល់ព្រះអង្គ គឺមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់ ដែលជាសញ្ញានៃសេចក្ដីទុក្ខក្នុងជីវិត ។ ទើបកើតសេចក្ដីសង្វេគស្លុតព្រះទ័យ ទ្រង់ធុញទ្រាន់នូវសេចក្ដីទុក្ខទាំងនេះណាស់ ទើបទីបំផុតទ្រង់ក៏លះនូវភេទឃរាវាស ។ ស្ដេចទ្រង់យាងចេញបព្វជ្ជាហើយបានត្រាស់ដឹងជាព្រះពុទ្ធអង្គនៃយើង នៅពេលព្រះបរមសាស្ដាទ្រង់ក៏ចាប់ផ្ដើមឃើញនូវទុក្ខជាមុន ។ ដូច្នេះយើងដែលជាពុទ្ធសាសនិក ក៏ត្រូវចាប់ផ្ដើមពីអ្វីមុន ទើបអាចរួចផុតចាកទុក្ខបាន

- ពិតមែន! ខ្ញុំកូណាក៏គិតដូច្នេះដែរថា ជីវិតមានតែ

សេចក្ដីទុក្ខ មានជរា ព្យាធិ និងមរណៈ បើដូច្នេះគេអាចហៅបានថាឃើញអរិយសច្ចបានឬទេទាន?

- យ៉ាងនេះ ក៏នៅមិនទាន់បានឃើញអរិយសច្ចទេ គ្រាន់តែស្គាល់អរិយសច្ច ឬក៏ត្រឹមតែបានដឹងអរិយសច្ចប៉ុណ្ណោះ ពីព្រោះដោយបានមកពីការស្ដាប់ ឬការអានសៀវភៅមកតែប៉ុណ្ណោះ ។ ការចេះបែបនេះ ជាការចេះដោយបញ្ញា ជាការចេះរៀបសើៗ មិនមានផលដល់ផ្លូវចិត្តអ្វីទាំងអស់ នរណាៗដែលបានរៀនសូត្រពីព្រះពុទ្ធសាសនាក៏អាចយល់ដឹងពីអរិយសច្ចបែបនេះបានដែរ រឿងរបស់អរិយសច្ចនេះត្រូវតែឃើញ មិនមែនចេះដឹងតែប៉ុណ្ណោះទេ

- ធ្វើដូចម្ដេចទៅទើបអាចឃើញអរិយសច្ចដូចលោកម្ចាស់ទូល?

- ធម៌ គឺជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ ជា **ឱបនយិកោ** ដែលប្រែថា បង្អោនចូលមករកខ្លួន ត្រូវសម្លឹងមើលឲ្យឃើញចាក់ស្ទះខ្លួនឯង មិនមែនមើលទៅអ្នកដទៃ ឬ វត្ថុដទៃ មិនមែនមើលផ្នែកខាងក្រៅ ដូចជាក្ដីទុក្ខដោយបានឮពាក្យថា **ចាស់ ឈឺ ស្លាប់** មិនមែនឃើញតែអ្នកផ្សេងជួបនូវការចាស់ ការឈឺ ការស្លាប់ ។ ប៉ុន្តែត្រូវពិចារណាឲ្យឃើញថាតួខ្លួន របស់យើងក៏កំពុងតែចាស់ ឈឺ និងស្លាប់ គ្រប់ពេលវេលា ។ លុះកើតសេចក្ដីសង្វេគ ភ័យ តក់ស្លុតចិត្តនឿយណាយក្នុងជីវិត គិតចង់គេចចេញពីទុក្ខយ៉ាងនេះ ទើបហៅថាឃើញទុក្ខ

- ការឃើញនូវទុក្ខ ដូចលោកម្ចាស់បានពោលមកនេះ នឹងធ្វើឲ្យមនុស្សក្លាយទៅជាព្រះអរិយបុគ្គលភ្លាមៗ ឬយ៉ាងណាទាន?

- ការឃើញទុក្ខក្នុងខណៈនេះ គឺជាការឃើញដោយទិដ្ឋិ នៅមិនទាន់បានឃើញដោយញាណទេ ។ បន្ទាប់ពីបានឃើញដោយញាណហើយ ពេលនោះទើបអាចក្លាយទៅជាព្រះអរិយបុគ្គលបាន ប៉ុន្តែការឃើញដោយទិដ្ឋិនេះក៏ជាជំហានដំបូង ដែលអាចនាំទៅដល់ការឃើញដោយញាណបាន ។ ពេលមនុស្សឃើញទុក្ខដោយទិដ្ឋិពេលនោះសម្មាទិដ្ឋិ ដែលជាអង្គដំបូងរបស់**អរិយមគ្គអង្គប្រាំបី** ក៏កើតឡើងបន្តបន្ទាប់គ្នា ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា សម្មាទិដ្ឋិសំខាន់បំផុត បើមាន **សម្មាទិដ្ឋិ** ហើយ **សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ** និង**សម្មាសមាធិ** ក៏កើតឡើងតៗគ្នាតាមលំដាប់ដោយមានហេតុមានផលទាក់ទងគ្នាទៅវិញទៅមក ។ បើសិនជាប្រៀបធៀបពីសម្មាទិដ្ឋិ គឺប្រៀបដូចជាក្បាលម៉ាស៊ីនចំណែកអង្គមគ្គផ្សេងៗទៀត ប្រៀបដូចជាទូរទេះភ្លើងប្រាំពីរទូ រៀបតាមលំដាប់គ្នា នៅពេលក្បាលម៉ាស៊ីនចាប់ផ្ដើមចេញ ក៏តែងទាញយកទូទី ១ ឲ្យចេញ ។ ទូទី ១ ក៏ទាញទូទី ២, ទូទី ២ ទាញទូទី ៣, ទូទី ៣ ទាញទូទី ៤, ទូទី ៤ ទាញទូទី ៥, ទូទី ៥ ទាញទូទី ៦, ទូទី ៦ ទាញទូទី ៧, ទូទី ៧ ទាញទូទី ៨ ជាបន្តតាមលំដាប់ ។ នៅពេលទូទាំងប្រាំបីចេញទៅយ៉ាងលឿនព្រមគ្នាហើយ រទេះភ្លើងនោះក៏ចេញជាជួរៗព្រមៗគ្នាដែល

មានកម្លាំង និងល្បឿនស្របគ្នាអាចបើកបរទៅដល់ទីកន្លែងតាមប្រាថ្នាដូចបំណងបាន ។ អរិយមគ្គអង្គប្រាំបី ក៏ដូចគ្នាកាលណាសម្មាទិដ្ឋិកើតឡើងហើយ សម្មាសង្កប្បៈក៏បន្តរហូតដល់ សម្មាសមាធិកើតឡើង ពេលសម្មាសមាធិកើតឡើង ក៏បានសម្រេចសម្មាសម្ពោធិញ្ញាណ ឈានដល់សម្មាវិមុត្តិ គឺសេចក្តីផុតចាកទុក្ខក៏កើតឡើង ។ ពេលសេចក្តីផុតរំលត់ពីកិលេស និងក្តីទុក្ខនោះហើយ បុគ្គលនោះក៏ប្រែក្លាយទៅជាព្រះអរិយបុគ្គលនោះឯង ដែលអាត្មាបរិយាយមកនេះ តើញោមអាចចាប់បានខ្លះឬទេ ?

- លោមនឹងយល់ច្បាស់បានខ្លះ តែពិបាកមែនទែនពីព្រោះខ្ញុំករុណា មិនធ្លាប់មានការចេះដឹងក្នុងផ្លូវនេះពីមុនមកសោះ យល់ថាលោកម្ចាស់ សម្តែងព្រះធម៌ជាន់ខ្ពស់ពេកខ្ញុំករុណាចង់សួរលោកម្ចាស់ថា សម្រាប់អ្នកកាន់ព្រះពុទ្ធសាសនាធម្មតាៗដូចជាខ្ញុំករុណានេះ ដែលមិនមានបំណងចង់ទៅនិព្វានឬមានន័យថា នៅមិនទាន់បានជាបុគ្គលសម្មាទិដ្ឋិនៅឡើយ តើត្រូវធ្វើយ៉ាងណាទៅទាន ? បុគ្គលដែលមិនទាន់បានឃើញនូវទុក្ខសច្ច គឺនៅជាបុគ្គលមិច្ឆាទិដ្ឋិឃើញជីវិតមនុស្សលោកនេះគួរជាទីសោយសុខ បើដូច្នេះត្រូវត្រៀមខ្លួនតតាំងជាមួយវដ្តសង្សារ គឺការស្លាប់កើត ស្លាប់កើតក្នុងភពទាំង៣ ។ ប្រសិនបើចាប់មិនជាប់ទេ អាចនឹងរបូតធ្លាក់ក្នុងនរក ក្នុងកំណើតតិរច្ឆាន ត្រូវគេចាប់ចងធ្វើបាប

- កុំមកតវ៉ាជាមួយនឹងអាត្មាបានហើយ ពីព្រោះទ្វារ

អបាយភូមិ អាចបើកចំហរនិច្ចសម្រាប់បុថុជ្ជន ។ តែល្ហីយចុះ បើនៅមិនទាន់ចង់បិទទ្វារនរកទេ ព្រះពុទ្ធសាសនា ក៏នៅមានអ្វីផ្សេងទៀតទុកសម្រាប់មនុស្សគ្រប់ប្រភេទ ។ អាត្មាបានប្រៀបធៀបតាំងពីដំបូងហើយថា ព្រះពុទ្ធសាសនា ប្រៀបដូចជាដូងមានទាំងសំបក លលាដ៍ សាច់ និងទឹក ។ អ្នកដែលមិនត្រូវការទឹកដូង គេត្រូវការតែសំបក ចំណែកអ្នកដែលត្រូវការសំបក គេក៏យកទៅធ្វើជាខ្សែក៏យកទៅ ។ អ្នកដែលមិនត្រូវការលលាដ៍ គេត្រូវការ តែសាច់ និងទឹក គេក៏យកទៅហូបនិងទៅផឹកតាមការស្រេកឃ្លានក៏យកទៅ ។ កម្មជាសំបករបស់ព្រះពុទ្ធសាសនា សីលជាលលាដ៍ អរិយសច្ច ជាសាច់ ញាណ និងវិមុត្តិជាទឹក ។ អ្នកណាចង់បានអីក៏យកតាមសប្បាយ ព្រះពុទ្ធសាសនាមានគ្រប់យ៉ាងសម្រាប់មនុស្សគ្រប់រូប ...

# បុណ្យកើតពីចិត្ត

**បើសិនធ្វើបុណ្យដោយសុទ្ធចិត្ត   នឹងបានបុណ្យពិតឥតសង្ស័យ**
**ចេះអត់ចេះឱនឲ្យអភ័យ   សន្តោសប្រណីនូវទោសា ។**
**ប្រសិនធ្វើបុណ្យយកមុខមាត់   នោះពិតប្រាកដខុសតម្រា**
**ធ្លាក់ចុះក្នុងជ្រោះនៃតណ្ហា   ឥច្ឆាឫស្យាបានខាងទោស ៕**

ដោយឧបាសក ម៉ិញ សារ៉ាង

# ចំណុចសំខាន់នៃអ្នកកាន់ព្រះពុទ្ធសាសនា

បទពាក្យ៧

*គោលដៅនៃព្រះពុទ្ធសាសនា　　ចែងជាមាគ៌ាដ៏ប្រពៃ*
*គឺអរិយមគ្គអង្គប្រាំបី　　បដិបត្តិយប់ថ្ងៃដុសខាត់ចិត្ត ។*
*ជម្រះឲ្យអស់អវិជ្ជា　　បង្កើតបញ្ញាថ្លាគំនិត*
*យល់ច្បាស់អរិយសច្ចធម៌ពិត　　ជាគោលសុក្រឹតពុទ្ធសាសនា ។*
*ឃើញទុក្ខហេតុនាំឲ្យកើតទុក្ខ　　មានជាប្រមុខគឺតណ្ហា*
*ប្រតិបត្តិតាមអង្គអរិយមគ្គា　　កំចាត់តណ្ហាជាសមុទ័យ[១] ។*
*ញ៉ាំងនិរោធធម៌ឲ្យកើតមាន　　គឺព្រះនិព្វានក្សេមសុខី*
*ជាខន្ធវិមុត្តិផុតទុក្ខភ័យ　　នេះជាអត្ថន័យពុទ្ធដីកា ។*
*គឺជាបេះដូងពុទ្ធសាសន៍　　បញ្ជាក់ចែងច្បាស់ទុកវិចារណ៍*
*ឥតមានសាសនាដទៃណា　　ក្លែងពោលមុសាបន្លំបាន ។*
*ដូច្នេះចូរពុទ្ធបរិស័ទ　　សិក្សាបដិបត្តិកុំខកខាន*
*បង្កើតពន្លឺបញ្ញាញាណ　　កំចាត់ចោលបាននូវកង្ខា[២] ៕*

ដោយឧបាសក **មុិញ សារ៉ាង**

---

(១) សមុទយៈ  សៈមុ-ទៈ យៈ  សំ. បា. (ន.) (សមុទយ) ការតាំងឡើង; ការប្រមូល, រួបរួម; ការទាក់ទងរកគ្នា;
(២) កង្ខា  ក័ង-ខា  បា. (ន.) សេចក្ដីសង្ស័យ, សេចក្ដីសន្ទិះ ។

# ២៧. ផ្សងជីវិត

ពេលដែលអាត្មាកំពុងសន្ទនាព្រះធម៌ ជាមួយនឹងបណ្ឌិតវិទ្យាសាស្ត្រគ្រូម្នាក់ ខណៈពេលនោះលោកចំណាន ដែលជាបងប្រុស បានបើករថយន្តមកឈប់នៅពីមុខសាលាទទួលភ្ញៀវ ប្រញាប់ចុះពីរថយន្តឡើងមក ក្រាបថ្វាយបង្គំអាត្មា ដោយមានការប្រញាប់ ។

- លោកម្ចាស់! ខ្ញុំកូណាបានជីកសម្បត្តិពីបាតអណ្ដូងហើយទាន

គេរៀបរាប់ដោយសម្លេងតិចៗ ព្យាយាមរម្ងាប់នូវសេចក្ដីភ្ញាក់ផ្អើល ។ ដួងកែវខិតចូលជិតបងប្រុស ផ្ទៀងត្រចៀកដោយឫកពាយកចិត្តទុកដាក់ ។

- មានស្អីខ្លះ? អាត្មាសួរ ព្រមទាំងមើលទៅជុំវិញសាលាដោយការប្រុងប្រយ័ត្ន ពីព្រោះក្រែងថានឹងមានមនុស្សណាមកចាំស្ដាប់ដែរ

- មានព្រះពុទ្ធរូបខ្នាតតូចធ្វើពីមាស និងប្រាក់ប្រហែល ២០អង្គ និងមានគ្រឿងតុបតែងធ្វើពីមាស ប្រាក់ និងពេជ្រផ្សេងៗទៀតជាច្រើន ប៉ុន្តែខ្ញុំកូណាមិនបានត្រួតពិនិត្យមើលល្អិតល្អន់ថា តើមានអ្វីខ្លះទៀត ។ ក្រៅពីនេះនៅមានគ្រឿងប្រើប្រាស់ផ្សេងៗធ្វើពីមាសខ្លះ ប្រាក់ខ្លះ និងភ្លុកខ្លះ ។ លោកម្ចាស់ខ្ញុំកូណាសឹងតែមិនជឿផ្ទាល់ភ្នែកខ្លួនឯងថា បានជួបពិតៗបែបនេះសោះទាន ។ ខ្ញុំកូណាធ្លាប់តែអានសៀវភៅ

រឿងព្រេងតែពេលនេះជាការពិត ។ ខ្ញុំករុណាគាំងស្មារតី អស់រគនឹកធ្វើអ្វីមិនកើត ប្រញាប់គរគាយ ជញ្ជូនយកទៅទុកក្នុងបន្ទប់បិទចាក់សោ ហើយក៏ប្រញាប់មករកលោកម្ចាស់នេះឯង ។ តើលោកម្ចាស់ឲ្យខ្ញុំករុណាចាត់ចែងយ៉ាងម៉េចទៀតទាន ?

អាត្មានឹកអស់សំណើចពីការភ្ញាក់ផ្អើល របស់លោកចំណាន តែក៏ចង់មើលឫកពាបស់ផ្សងតែវច្រើនជាង ។ គេសម្លឹងមើលមកអាត្មា ដោយក្រសែភ្នែកហាក់បីដូចជាអាត្មានឹងជាសត្វចម្លែក ដែលគេមិនធ្លាប់បានឃើញពីមុនមកសោះក្នុងឆាកជីវិត ។

- ញោមចាត់ចែងយ៉ាងណាៗនោះស្រេចលើញោមចុះ ពីព្រោះ ទ្រព្យសម្បត្តិទាំងអស់នេះជារបស់ញោមហើយ អាត្មាសូមបិណ្ឌបាតទុកតែម្យ៉ាងទេ គឺសូមឲ្យញោមចាត់ចែងធ្វើបុណ្យឧទ្ទិសកុសលជូនដល់ម៉ឺនសែនហ្វា ជាម្ចាស់ទ្រព្យសម្បត្តិដើមប៉ុណ្ណោះ

- រឿងនេះលោកម្ចាស់កុំព្រួយបារម្ភ ខ្ញុំករុណានឹងចាត់ចែងធ្វើយ៉ាងល្អជាទីបំផុត ប៉ុន្តែវាជាសម្បត្តិមហាសាលខ្ញុំករុណានឹងត្រូវចាត់ចែងដូចម្ដេច ? បើសិនជាខ្ញុំករុណាថែរក្សាម្នាក់ឯង គឺច្បាស់ជាភារៈដ៏ធ្ងន់សម្រាប់ខ្ញុំករុណាហើយ ពីព្រោះខ្ញុំករុណាមិនសូវបាននៅផ្ទះជាប់លាប់រហូតទេ ត្រូវចេញទៅបំពេញកិច្ចការងារ ថែមពីនេះទៀតវាអាចនឹងនាំគយន្តរាយមកដល់ខ្ញុំករុណាទៀតផង ។ ខ្ញុំករុណាមិនចង់យកទៅលក់ដូរឲ្យជនបរទេស ពីព្រោះវាជាសម្បត្តិរបស់

បុព្វបុរសដូនតារបស់ខ្ញុំករុណា បើសិនជាប្រគល់ឲ្យរាជការ គេក៏គង់នឹងយកទៅតម្កល់ទុកក្នុងសារមន្ទីរជាតិ នៅទីក្រុងបាងកកដោយសារវាជាសម្បត្តិមានតម្លៃរកមិនបាន សម្បត្តិទាំងអស់នេះជារបស់ឈៀងម៉ៃ ។ ខ្ញុំករុណាចង់ទុកក្នុងខេត្តឈៀងម៉ៃនេះ មិនចង់ឲ្យធ្លាក់ទៅកន្លែងដទៃក្នុងខេត្តឆ្ងាយៗនោះទេទាន ។ សូមនិមន្តលោកម្ចាស់ ផ្តល់ជាយោបល់ដែលនាំដល់ខ្ញុំករុណាផងទាន

- ការពិតអាត្មាខុសនាទីច្រើនណាស់ហើយ កុំឲ្យអាត្មាចូលទៅទាក់ទងច្រើនជាងនេះទៀតអី គ្រាន់តែប៉ុណ្ណឹងក៏រាប់ថាច្រើនហួសពីសមណៈហើយ កាលដែលអាត្មាធ្វើទៅនោះដោយសារការអាណិតញោមម៉ឺនសែនហ្វា ដែលជាបុព្វការីជនរបស់ញោម ។ វិធីដោះស្រាយគង់តែនឹងមាន គ្រាន់តែពេលនេះញោមរកនឹកពុំទាន់ឃើញនៅឡើយ ពីព្រោះតែការភ្ញាក់ផ្អើលសប្បាយចិត្តខ្លាំងពេក ចាំឲ្យសេចក្តីភ្ញាក់ផ្អើលនេះចុះថយបន្តិចសិន ហើយសឹមគិតរកវិធីដោះស្រាយ ។ ពេលនេះទុកទ្រព្យសម្បត្តិទាំងនោះនៅក្នុងផ្ទះញោមសិនទៅរឿងសំខាន់ត្រូវតែថែរក្សាទុកយ៉ាងស្ងៀមស្ងាត់ កុំឲ្យព្រូរខ្ចាយដល់អ្នកដទៃទៅបានហើយ

លោកចំណាននអង្គុយនៅស្ងៀម ដោយគិតមួយស្របក់ ហើយលើកយកព្រះពុទ្ធរូបមាស ដែលមានកម្ពស់ប្រហែល ១០ សង្ទីម៉ែត្រចេញពីថង់ក្រដាសហុចមកឲ្យអាត្មាហើយពោលថា៖

- ខ្ញុំករុណា សូមប្រគេនព្រះពុទ្ធរូបនេះទុកជាគ្រឿងបូជា

ព្រះគុណដល់លោកម្ចាស់ទាន!

អាគ្នាប្រាប់ឲ្យគេយកព្រះពុទ្ធរូបមាស ក្នុងសម័យធៀងម៉ៃស្នួតនោះទុកវិញ ដាក់ចូលចង់ក្រដាសដូចដើម ហើយពោលថា៖

- អាគ្នា សូមអនុមោទនានូវកុសលចេតនារបស់ញោមអាគ្នាព្រមទទួលយកព្រះពុទ្ធរូបនេះ តែពេលនេះអាគ្នាសុំផ្ញើទុកជាមួយញោមសិន ។ អាគ្នាមិនអាចនាំ យកទៅជាមួយបានទេ ពីព្រោះអាគ្នាមិនគង់នៅមួយកន្លែងទេ គឺពនេចរធុតង្គរឿយៗ មិនចង់ឲ្យមានរបស់មានតម្លៃផ្សេងៗជាប់ខ្លួននោះដែរ ។ សូម្បីតែបរិក្ខារប្រាំបីរបស់ភិក្ខុជាភារៈដ៏ធ្ងន់ធ្ងរក្នុងការមើលថែរក្សាទៅហើយ បើសិនជាមានព្រះពុទ្ធរូបផ្ញើពីមាសថែមទៀត អាគ្នាប្រហែលមិនមានពេលវេលាបំពេញសមណធម៌ឡើយ ។ ដូច្នេះសូមញោមយកទុករក្សានៅផ្ទះដូចដើមបានហើយ ថ្ងៃណាមួយបើអាគ្នាមានឱកាសត្រឡប់មកធៀងម៉ៃទៀត អាគ្នានឹងមកសុំយក តែប្រសិនបើអាគ្នាមិនបានត្រឡប់មកវិញទេ នោះព្រះពុទ្ធរូបអង្គនេះនៅជារបស់ញោមដូចដើម ។ សូមញោមរក្សាទុកដូចជារបស់ញោមចុះ

- ខ្ញុំកូណានឹងធ្វើតាមដីការបស់លោកម្ចាស់, លោកចំណាននោល និងសម្លឹងមើលទៅចង់ព្រះពុទ្ធរូប ដោយភ្នែកមានសេចក្ដីទុក្ខព្រួយ អាគ្នាជួយលោមចិត្តគេ ដោយធម្មៈឲ្យបាត់នូវសេចក្ដីកង្វល់ ហើយគេក៏ក្រាបថ្វាយបង្គំលាត្រឡប់ទៅផ្ទះវិញ ។

- លោកម្ចាស់ តើគេយកស្រីញ្ញ័រទ្រព្យពីមហាសាលនេះបាន ដោយរបៀបណាទាន ? ដួងកែវសួរឡើង នៅពេលបង ប្រុសគេត្រឡប់ទៅវិញបាត់

ក្នុងខណៈដែលញោមដាអ្នកវិទ្យាសាស្ត្រ អាត្មានឹង អធិប្បាយឲ្យស្ដាប់ក្នុងផ្លូវវិទ្យាសាស្ត្រ តែដំបូងអាត្មាចង់សួរ ញោមជាមុនថា ញោមជឿ ឬទេថាមនុស្សយើងមានចិត្ត ?

- ខ្ញុំកូណាមិនទាន់ជឿច្បាស់ទេ ពីព្រោះមិនទាន់ដឹងនូវ ធម្មជាតិដែលពិតប្រាកដរបស់ចិត្ត

- តែញោមគង់បានយល់ពីដំណើរ ដែលធ្វើឲ្យទៀន ក្រមួនឆេះ ឡើងជាអណ្ដាតភ្លើង នៅពេលដែលយើងអុជ ទៀនក្រមួន ។ ញោមជួយអធិប្បាយឲ្យអាត្មាស្ដាប់បន្តិចមក មើល៍ ជួនកាលអាចធ្វើឲ្យញោមបានយល់ជ្រួតជ្រាបតាមផ្លូវ ចិត្តងាយ

- ការឆេះរបស់ទៀនក្រមួនដូចខ្ញុំកូណាធ្លាប់បានដឹង គឺ មានការផ្សំគ្នាសំខាន់មានបីយ៉ាង គឺសាច់ក្រមួនសុទ្ធ អំបោះ ប្រឆេះសម្រាប់អុជពន្លឺ និងអុកស៊ីសែរ្យនៅក្នុងអាកាស ។ នៅពេលមានការប្រកបរបស់ទាំងនេះហើយ យើងបង្កើត កំដៅឲ្យដល់អំបោះប្រឆេះដូចជាយកឈើគូសទៅអុជ ធាតុ កាបោនក្នុងទៀនក្រមួន វាក៏មានប្រតិកម្មគីមីប៉ះជាមួយធាតុ អុកស៊ីសែរ្យនក្នុងអាកាស ក៏បង្កើតឲ្យមានផ្សែងភ្លើងឡើង មានតែប៉ុណ្ណោះឯង

- ផ្សែងភ្លើងធ្វើឲ្យកើតស្អីទៀត ? មានន័យថា ផ្សែង ភ្លើងបញ្ចេញអ្វីចេញមកទៀត ?

ផើង្រផ្លើងនោះឲ្យផលសំខាន់ពីរយ៉ាងគឺឲ្យកំដៅ និងពន្លឺ

- ពន្លឺភ្លើងនោះនឹងរលត់ទៅវិញនៅពេលណា?

- នឹងរលត់ទៅវិញ ដោយសារហេតុផលបីយ៉ាងដែរ ដូចជាទៀនត្រូវឆេះអស់ ឬខ្វះអុកស៊ីហ្សែន ឬខ្វះកំដៅ

- ញោមអធិប្បាយបានច្បាស់ល្អណាស់ ម្តងនេះអាត្មានឹងអធិប្បាយអំពីជំណើរជីវិតឲ្យស្តាប់ម្តង វិញ្ញាជីវិតមានលក្ខណៈប្រហែលគ្នា នឹងផើង្រផ្លើងទៀនក្រមួននេះដែរ ។ រាងកាយប្រៀបដូចជាទៀន ខួរក្បាលប្រៀបដូចជាអំបោះប្រឆេះទៀន អារម្មណ៍ផ្សេងៗមាន **រូប សម្លេង ក្លិន រស ផោដ្ឋព្វ** និង **ធម្មារម្មណ៍** ដែលចូលមកប៉ះនឹងភ្នែក ច្រមុះ អណ្តាត កាយចិត្ត ប្រៀបដូចជា អុកស៊ីហ្សែនក្នុងអាកាស ។ កាយសម្ផស្សរវាងអារម្មណ៍ ខាងក្រៅជាមួយទ្វារទាំងប្រាំមួយ ប្រៀបដូចប្រតិកម្មគីមីរវាងអុកស៊ីហ្សែន និងការបោនវិញ្ញាណដែលកើតឡើងពីការប៉ះទង្គិចរវាងភ្នែក និងរូបជាដើម ។ ប្រៀបដូចជាកម្តៅ សេចក្តីដឹងនូវអារម្មណ៍ដែលជាលក្ខណៈសំខាន់របស់វិញ្ញាណ ប្រៀបដូចពន្លឺភ្លឺ ដែលផើង្រផ្លើងស្ទុះចេញមក យ៉ាងម៉េចញោម ល្មមនឹងមើលឃើញយល់បានខ្លះឬនៅ?

នាងស្រីឈ្មោកមុខគិតយ៉ាងខ្លាំង ងក់ក្បាលជំនួសចម្លើយ ហើយពោលពាក្យដដែលរបស់អាត្មាតិចៗថា៖

- រាងកាយ ប្រៀបដូចជា ត្ងទៀន

- ខួរក្បាល ប្រៀបដូចជា អំបោះប្រឆេះទៀន

- អុកស៊ីហ្សែន ប្រៀបដូចជា រូប សម្លេង ក្លិន រស

ផោដ្ឋព្វ និងធម្មារម្មណ៍

- ការប៉ះទង្គិចរវាងភ្នែក និងរូប ប្រៀបដូចជា ប្រតិកម្មគីមី
- សភាវៈក្តៅ ប្រៀបដូចជា វិញ្ញាណ
- ពន្លឺ ប្រៀបដូចជា ការចេះដឹង

ខ្ញុំកូណាល្មមយល់បាន ប៉ុន្តែក្នុងរឿងទៀនប្រតិកម្មគីមី ផ្តើមឲ្យមានកម្តៅកើតឡើងក្នុងរឿងមនុស្សលោក លោកប្រាប់ថា ការប៉ះទង្គិចរវាងអារម្មណ៍ខាងក្រៅជាមួយទ្វារទាំងប្រាំមួយជាហេតុឲ្យកើតវិញ្ញាណដូច្នេះមែន ឬទេ?

- ត្រូវហើយ! អាត្មានឹងអធិប្បាយតាមបែបវិទ្យាសាស្ត្រឲ្យស្តាប់គឺ នៅពេលភ្នែកប៉ះនឹងរូបមានន័យថា កម្លាំងនៃពន្លឺមួយចំនួនចូលទៅប៉ះភ្នែក ហើយនឹងកើតមានប្រតិកម្មគីមីឡើងនៅស្បែកភ្នែកនោះ ។ ប្រតិកម្មគីមីនោះនឹងប្តូរពីពន្លឺឲ្យទៅជាកម្លាំងអគ្គិសនី ភ្លើងអគ្គិសនីនោះនឹងរត់ទៅតាមខ្សែប្រសាទ ចូលទៅក្នុងខួរក្បាល ។ នៅពេលភ្លើងអគ្គិសនីនោះប៉ះនឹងកោសិកាខួរក្បាល ក៏កើតឡើងបតិកិរិយាម្តងទៀត ។ សភាពដែលភ្នែកបានឃើញនោះនឹងត្រូវចារឹកទុកក្នុងកោសិកាខួរក្បាល ហើយបតិកិរិយាខណៈពេលនោះនឹងប្តូរកម្លាំងពីភ្លើងអគ្គិសនី ក្លាយទៅជាកម្លាំងរបស់ចិត្ត ។ ចំណែកកម្លាំងចិត្តមួយចំនួន ក៏នឹងហូររួមជាមួយចិត្តកណ្តាលនៃខួរក្បាល ចិត្តកណ្តាលនោះជាប្រយោជន៍រួមរបស់ខ្សែកម្លាំងចិត្តដែលហូរមកពីទ្វារផ្សេងៗ នោះឯង ។ ចិត្តកណ្តាលប្រៀបដូចជាស្រះទឹកដែលមានចង្អូរទឹកច្រើនកន្លែង

បញ្ជូនទឹកទៅចូលរួមជានិច្ច ។ មកពីមនុស្សយើងទទួលនូវអារម្មណ៍តាមរយៈភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្តជានិច្ចគ្រប់ពេលវេលា ។ ទើបកើតជាក្រសែចិត្តហូរឡូមជាមួយចិត្តកណ្តាលគ្រប់ពេល ធ្វើឲ្យចិត្តកណ្តាលស្ថិតក្នុងសភាពនៅបាន ប្រៀបដូចជាអំពូលភ្លើងដែលបានទទួលអ៊ុកស៊ីហ្សែន គាបោន និងកម្តៅថែមជានិច្ចអាចឆេះនៅបាន

អាត្មាឈប់មួយស្របក់ ដើម្បីសង្កេតអាកប្បកិរិយារបស់នាងស្រី ថាតើអាចយល់បានឬទេ ។ គេអង្គុយឱនមុខគិតមួយរយៈធំ ហើយនិយាយឡើងថា ៖

- នៅវេលាមនុស្សដេកលក់នោះ ខ្ញុំកូណាមិនឃើញគេទទួលអារម្មណ៍នានាទេ ហើយគ្មានដឹងអ្វីទាំងអស់ មានន័យថា ក្នុងពេលនោះមនុស្សមិនមានចិត្តតើមែនឬទេទាន ?

- នៅពេលដេកលក់ មនុស្សក៏នៅមានចិត្តដូចគ្នា តែជាចិត្តដែលស្ងួតចុះ នៅសល់តិចតួចប៉ុណ្ណោះ ប្រៀបដូចជាទឹកនៅក្នុងស្រះ ដែលមិនមានទឹកហូរមកថែមទៀត ចេះតែស្រកទៅៗរីងស្ងួតទៅៗ ។ ដោយហេតុនៅសល់បន្តិចបន្តួចនៅបាតស្រះ ឬប្រៀបដូចជាអំពូលភ្លើងទៀនសុទ្ធ ដែលខ្វះបច្ច័យណាមួយ លុះនៅសល់បន្តិចបន្តួចនឹងរលត់ក៏មិនរលត់នោះឯង ចិត្តដែលនៅសល់ប្រហែលបន្តិចនោះ មិនមានសេចក្តីដឹងនឹកគិតអ្វីៗទេ លោកហៅថា **ភវង្គចិត្ត** គឺចិត្តដែលជាអង្គនៃភព ។ ភវង្គចិត្តអាច នៅបានក៏ព្រោះ **ភវតណ្ហា** និងផលកម្ម តែភវង្គចិត្តនោះកើតរលត់តគ្នាទៅ

យ៉ាងរហ័សដូចគ្នានឹងសរសៃភ្លើងដែរ លុះត្រាឈើងឈើញរួច វាសរសៃតែមួយគត់ហូតតទៅ

- ចុះនៅពេលមនុស្សយល់សប្តិនោះទាន ! តើអ្វីកើតឡើង ?

- យល់សប្តិខ្លះមកពីអារម្មណ៍ខាងក្រៅ ដោយមានកម្លាំងខ្សោយ ដូចជាបានឮនូវសម្លេងម៉្យាង កម្លាំងនៃសម្លេងនោះទៅប៉ះខ្ទប់ប្រព័ន្ធប្រសាទត្រចៀក ដែលមិនដំណើរការ ។ បដិកិរិយារបស់ប្រព័ន្ធប្រសាទត្រចៀកទើបបណ្តាលឲ្យកើតនូវកម្លាំងភ្លើងបន្តិចបន្តួច ពេលកម្លាំងភ្លើងដែលហូរចូលមកខួរក្បាល ហើយទៅប៉ះទង្គិចនឹងមនោទ្វារចាស់ ហើយក៏កើតក្រសែចិត្តហូរទៅថែមជាមួយភវង្គចិត្ត ធ្វើឲ្យភវង្គចិត្តខ្វះឡើងទទួលនូវអារម្មណ៍ ។ ដោយសារអារម្មណ៍នោះបានទទួលមនោទ្វារចាស់ ដូចជាសម្លេងផ្គរលាន់ដែលធ្លាប់បានឮនោះ ទើបយល់សប្តិទៅជាបានឮសម្លេងផ្គរលាន់គ្រាំងៗ តាមពិតវាជាសម្លេងរបស់មនុស្សស្រមុកនៅក្បែរខ្លួនសោះ ។ ប៉ុន្តែជួនកាលមនុស្សកំពុងដេកលក់មិនស៊ប់ ភវង្គចិត្តវាកណ្តាលទៅប៉ះជាមួយនឹងមនោ-ទ្វារចាស់ៗក្នុងខួរក្បាល ធ្វើឲ្យកើតនូវការយល់សប្តិឡើងផងដែរ

- លោកម្ចាស់ ! អធិប្បាយបានច្បាស់ល្អណាស់ទាន តាមផ្នែកវិទ្យាសាស្ត្រពិតៗ ខ្ញុំកូណាមិនធ្លាប់បានស្តាប់ពីមុនទេទាន ខ្ញុំកូណាចង់សួរទៀតថា នៅពេលមនុស្សស្លាប់តើអ្វីកើតឡើង ?

- ខណៈពេលមនុស្សស្លាប់ មានន័យថាជីវិតដាច់នូវបច្ច័យណាមួយ ដូចជារាងកាយខូចខាតអស់ រួចប្រើការមិនកើត ចិត្តជាកណ្ដាល នឹងថយចុះបន្តិចម្ដងៗ ក៏ប្រែក្លាយទៅជាភវង្គចិត្ត អស់សេចក្ដីដឹងដូចជាពេលដេកលក់ ។ ប៉ុន្តែស្លាប់ភវង្គចិត្តមួយភ្លែតនឹងចាកចេញពីរាងកាយចាស់ ហើយមិនគាន់បដិសន្ធិ ចិត្តនោះក៏រលត់ទៅកើតមានភវង្គចិត្ត ដួងថ្មីកើតឡើងមកជំនួស ប្រៀបដូចយើងយកឈើចាក់ឆ្កេញ ទៅដុតបន្តពីភ្លើងទៀនដែលកំពុងនឹងរលត់ ហើយនាំយកទៅអុជទៀនថ្មីមួយទៀត ។ ពេលទៀនថ្មីបានឆេះជាប់ហើយ ភ្លើងដែលឆេះពីឈើចាក់ឆ្កេញនោះក៏ រលត់ជាមួយគ្នាល្មម

- ភវង្គចិត្តដែលដឹងចេញពីរាងកាយមុននោះ នឹងត្រូវប្រើពេលយូរប៉ុន្មាន ទើបបានទៅកើតថ្មី ? នាងស្រីសួរសម្ដែងឲ្យឃើញពីភាពវៃឆ្លាតរបស់គេ

- សឹងនឹងពោលបានថា មិនមានការប្រើពេលវេលានោះទេ នៅពេលស្លាប់ភ្លាមក៏កើតភ្លាមមួយរំពេច ពីព្រោះកម្លាំងចិត្តលឿនរហ័សជាងល្បឿនរបស់ពន្លឺក្នុង១វិនាទី បានចម្ងាយជាង ៣០០,០០០ គីឡូម៉ែត្រ ហើយទីកន្លែងសមគួរសម្រាប់ឲ្យកម្លាំងចិត្តទៅគាន់បដិសន្ធិក្នុងភពទាំងបី ដោយមិនចាំបាច់ខាតពេលវេលាស្រាវជ្រាវ ...

# ២៨. ពន្លឺខាងក្នុង

- ខ្ញុំករុណាចង់ត្រឡប់ទៅសំណួរមុន! នាងស្រីពោលឡើងក្រោយពីអង្គុយស្ងៀមគិតមួយសន្ទុះអស់ពេលយ៉ាងយូរ ថាលោកម្ចាស់ឃើញសម្បត្តិដែលកប់នៅក្នុងដីនោះបានដោយរបៀបណាទាន?

- បើញោមព្រមទទួលថា មនុស្សយើងមានចិត្តគឺជាការវាយនឹងឆ្លើយ

- ក្រោយពីបានស្ដាប់លោកម្ចាស់ពន្យល់ ពីរឿងរបស់ចិត្ត ដោយធ្វើការប្រៀបធៀបជាមួយនឹងផ្សេងទៀត ខ្ញុំករុណាក៏ចាប់ផ្ដើមជឿថា មនុស្សយើងមានជីវិត ព្រោះមានហេតុផលគួរឲ្យជឿមែន តែក៏គ្រាន់តែជាការជឿតែប៉ុណ្ណោះទាន! ពីព្រោះខ្ញុំករុណាមិនទាន់សាកល្បងមើលផ្ទាល់ ដោយគ្រឿងផ្សេងៗមិនបាន ។ បើឲ្យប្រាកដថា ជាសេចក្ដីពិតត្រឹមត្រូវមួយរយភាគរយនោះមិនទាន់បានទេ

- ញោមជាអ្នកវិទ្យាសាស្ត្រ ពិតមែនមិនទាន់ព្រមទទួលរបស់ណាថាជាការពិត លុះត្រាបានទទួលនូវការពិសោធន៍ជាមុនសិន តែកុំភ្លេចថា របស់ដែលមិនអាចពិសោធន៍បាននោះ មិនមែនពិសោធន៍មិនបានរហូតនោះទេ យើងគួរពោលថា របស់ដែលពិសោធន៍មិនបាន ពីព្រោះយើងមិនចេះពីរបៀបពិសោធន៍ ឬមិនទាន់មានគ្រឿងសម្រាប់ពិសោធន៍នៅឡើយ ។ ពីបច្ចុប្បន្ននេះទៅថ្ងៃ

អនាគត នៅពេលមនុស្សចេះនឹងគាន់តែច្រើនឡើងៗ ចេះនឹងពិធីពិសោធន៍ ហើយមានគ្រឿងពិសោធន៍របស់ដែលឃើងមិនអាចពិសោធន៍បាន នៅពេលនេះក៏អាចក្លាយជារបស់ដែលពិសោធន៍បានក៏ថាបានដែរ

- លោកម្ចាស់មានដីកាត្រូវណាស់ទាន! នាងស្រីនិយាយដោយសម្លេងច្បាស់ឆ្ងន់, មានរបស់ច្រើនយ៉ាងនិងច្រើនបែបណាស់ ដែលវិទ្យាសាស្ត្របានបង្កើតហើយយើងធ្លាប់ជឿថាមិនអាចពិសោធន៍បានទេ តែនៅពេលនេះក្លាយទៅជារឿងធម្មតា សូមនិមន្តលោកម្ចាស់ពន្យល់ពីរឿងដែលបានឃើញសម្បត្តិក្នុងដីរបស់លោកម្ចាស់ទៀតចុះទាន

- អាត្មានឹងអធិប្បាយក្នុងពេលបន្តិចទៀតនេះ តែសូមសួរញោមទៀតថា កិច្ចការធម្មតាៗរបស់អ្នកវិទ្យាសាស្ត្រពិតជាអាចមើលធ្លុះទីអាថ៌កំបាំងផ្សេងៗបានដែរមែនទេ?

- មានច្រើនយ៉ាងដូចជា កម្លាំងពន្លឺអាចទម្លុះនូវរបស់ដែលមានទំហំគ្រាស់ៗបាន កម្លាំងសម្លេងអាចទម្លុះនូវរបស់ជិតៗ ចំណែកគាំរស្មីអិចវិញ ក៏អាចទម្លុះរបស់គ្រាស់បានដែរ

- ចិត្តក៏ជាកម្លាំងម៉្យាង ហើយក៏ជាកម្លាំងដ៏ពិសេសមានគុណសម្បត្តិខុសប្លែក ពីកម្លាំងវិទ្យាសាស្ត្រទាំងពួងដែលផ្នែកវិទ្យាសាស្ត្រធ្លាប់រកឃើញនោះ ត្រឹមតែអាចចាក់ធ្លុះរបស់ដែលមករាំងនៅមានកម្រិត ។ ប៉ុន្តែពន្លឺនៃចិត្តអាចចាក់ទម្លុះធ្លុះនូវរបស់ផ្សេងៗគ្រប់យ៉ាងបាន ដោយមិនចាំបាច់ប្រើឧបករណ៍វិទ្យាសាស្ត្រនោះទេ កម្លាំងរបស់ចិត្តធ្វើដំណើរបានលឿនក្នុងអត្រាដែលមិនមានកម្រិត ព្រោះ

ដូច្នេះហើយ ទើបយើងអាចបញ្ជូនកម្លាំងចិត្តរបស់យើង មើលឃើញអ្វីៗនៅទីណាក៏បាន និងបញ្ជូនឲ្យស្ដាប់នូវសម្លេងអ្វីៗនៅទីណាក៏បានដូចគ្នា

- អូ! បើដូច្នោះហេតុដូចម្ដេចបានជាខ្ញុំកូណាធ្វើមិនបាន ខ្ញុំកូណាក៏មានថាមពលចិត្តដូចគ្នាដែរ ?

- ញោមមានថាមពលខាងផ្លូវចិត្តក៏ពិតមែនហើយ, ក៏ប៉ុន្តែចិត្តរបស់ញោមមានទោសៈគ្រាស់ ដូចនេះទើបមានកម្លាំងចិត្តខ្សោយ មិនអាចប្រតិបត្តិក្នុងការមើល ការស្ដាប់របស់នៅជិតៗមិនបាន កម្លាំងចិត្តរបស់ញោមមានកម្រិតត្រឹមតែភ្នែក និងត្រចៀកប៉ុណ្ណោះ ។ បើសិនជាភ្នែកងងឹតហើយ ញោមក៏មើលអ្វីមិនឃើញដែរ ។ បើត្រចៀកថ្លង់វិញ ញោមក៏ស្ដាប់អ្វីមិនឮ ញោមមិនអាចបញ្ជូនក្រសែចិត្តចេញទៅធ្វើការ ក្រៅពីប្រព័ន្ធប្រសាទទាំងប្រាំមួយនេះបានទេ

- បើដូច្នេះត្រូវធ្វើដូចម្ដេចទៅលោកម្ចាស់ ?

- ញោមត្រូវអប់រំចិត្តតាមវិធីធ្វើសមាធិ ដោយហ្វឹកហាត់ការទីងគ្រោតឲ្យទន់ ត្រូវធ្វើចិត្តដែលមានកម្លាំងខ្សោយ ប្រែក្លាយជាមានកម្លាំងខ្លាំង ចិត្តរបស់មនុស្សធម្មតាគ្រាស់ឃ្មឹក ពីព្រោះចិត្តមិនបរិសុទ្ធ មានភាពច្របូកច្របល់ របស់ដែលនាំឲ្យចិត្តគ្រាស់ឃ្មឹក លោកហៅថា **នីវរណធម៌** មានប្រាំយ៉ាង គឺ៖

១. **កាមឆន្ទៈ** សេចក្ដីរីករាយក្នុងកាម ;

២. **ព្យាបាទ** សេចក្ដីព្យាបាទ គំនុំឬសេចក្ដីគុំក្លួនធ្វើ

ឲ្យអ្នកដទៃវិនាស ;

៣. **ថីនមិទ្ធៈ** ការងោកងក់ ការប្រអូសធុញទ្រាន់ ;

៤. **ឧទ្ធច្ចកុក្កុច្ចៈ** សេចក្ដីរើរវាយ រាយមាយក្នុងចិត្ត ;

៥. **វិចិកិច្ឆា** ការសន្ទិះសង្ស័យ ។

មនុស្សធម្មតាគ្រប់គ្នាអាចត្រូវ **នីវរណធម៌** ទាំងប្រាំនេះណាមួយ ឬច្រើនយ៉ាងមកចោមរោមព្រមៗគ្នាវាយចិត្តគ្រប់ពេល ទើបធ្វើឲ្យចិត្តខ្សោយមិនបរិសុទ្ធ ។ ម៉្យាងវិញទៀត ចិត្តរបស់មនុស្សធម្មតាមានកម្លាំងតិច ពីព្រោះបែកខ្ចាយចេញទទួលយកអារម្មណ៍ផ្សេងៗ ដែលហូរតាមប្រព័ន្ធប្រសាទទាំងប្រាំមួយ ប្រៀបដូចពន្លឺភ្លើងបញ្ចេញពន្លឺព្រឹមៗព្រោះតែកម្លាំងខ្សោយ ។ បើយើងអាចប្រមូលកម្លាំងចិត្តឲ្យទៅជាធ្លុងមួយបាន ចិត្តនឹងមានកម្លាំងខ្លាំង អាចបញ្ចេញទៅបានឆ្ងាយ ប្រៀបដូចជាយើងប្រមូលពន្លឺទៀន ពន្លឺចង្កៀង ឬពន្លឺពិលឲ្យរួមតែមួយបាន ។ យើងនឹងអាចបញ្ចេញពន្លឺនោះឲ្យគាន់តែចែងចាំងឡើងៗ

- ខ្ញុំកូណាអាចយល់បានហើយទាន ! បណ្ឌិតវិទ្យាសាស្ត្រពោល ហើយងក់ក្បាលក្នុងន័យយល់ព្រម ។ បើដូច្នេះ ព្រះសង្ឃដែលអង្គុយប្រតិបត្តិតាមផ្លូវក្នុង អាចមើលរបស់នេះ របស់នោះបាន ក៏មានន័យថា លោកអាចប្រមូលចិត្តជាធ្លុងមួយ ហើយក៏បញ្ចេញកម្លាំងចិត្តនោះទៅ មើលរបស់ផ្សេងៗដូចជាបញ្ចាំងភ្លើងពិលទៅមើលមែនទេទាន ?

- ត្រូវហើយញោម !

- តែខ្ញុំកូណាធ្លាប់បានឮគេនិយាយតៗគ្នាមកថា ពេល

អង្គុយសមាធិ មនុស្សគឺអស់សតិ អស់ការដឹងផ្សេងៗទាំងអស់ ខ្លួននៅនឹងមែនទេគុណម្ចាស់ ?

- ការធ្វើសមាធិមានពីរយ៉ាងគឺ៖ អ្នកដែលធ្វើសមាធិធ្វើចិត្តឲ្យស៊ប់ **ភវង្គចិត្ត**ដូចជាអ្នកដេកលក់ ឬ មនុស្សដែលអស់សតិ ទើបមិនមានការដឹងផ្សេងៗ ។ ប្រការមួយទៀតអ្នកធ្វើសមាធិ អាចបង្គាប់ចិត្តឲ្យកើតសមាធិជាន់ខ្ពស់ហៅថា **សញ្ញាវេទយិតនិរោធ** មិនទទួលនូវអារម្មណ៍ផ្សេងៗទាំងអស់សម្រាប់សមាធិធម្មតា ។ អ្នកធ្វើសមាធិប្រមូលផ្តុំចិត្តតែមួយមិនទទួលនូវអារម្មណ៍ខាងទ្វារសោឡស្ទៈទាំងប្រាំ គឺភ្នែក **ត្រចៀក ច្រមុះ អណ្តាត កាយ** ប៉ុន្តែនៅទទួលអារម្មណ៍ខាងផ្លូវចិត្តហៅថា **ធម្មារម្មណ៍** ឬ **មនោទ្វារ** គឺចិត្តនេះទទួលធម្មារម្មណ៍តែម៉្យាងប៉ុណ្ណោះ នៅមានការដឹង ការគ្រាក់ និងធម្មារម្មណ៍នៅឡើយ ។ ចិត្តកើតសមាធិបែបនេះ គឺមានកម្លាំងខ្លាំងប្រៀបដូចពន្លឺភ្លើង ដែលប្រមូលផ្តុំនៅកន្លែងតែមួយ ចំណែកសមាធិដែលមិនដឹងខ្លួន និងភវង្គចិត្ត ខណៈពេលដេកលក់ នោះភវង្គចិត្តនៅសល់តិចណាស់ ដើម្បីរក្សាផ្សែងជីវិតឲ្យតាំងនៅតែប៉ុណ្ណោះ យកទៅធ្វើអ្វីមិនបានទេ ។ ផលដែលបានមក គឺគ្រាន់បានតែសម្រាកកាយ និងចិត្តតែប៉ុណ្ណោះ ។

- ការប្រើកម្លាំងចិត្ត ដែលបានពោលមកនេះ គឺបានតែព្រះអរហន្ត ប៉ុណ្ណោះ ទើបអាចធ្វើបានមែនឬទេទាន ?

- មនុស្សធម្មតា ភិក្ខុបុថុជ្ជនដែលរៀនខាងផ្លូវអប់រំចិត្តក៏អាចប្រមូលចិត្តបាន ។ ព្រះអរហន្តមិនមានចំណុចពិសេស

ដូចគ្នាគ្រប់ៗអង្គដែរ ព្រះអរហន្តប្រភេទ សុក្ខវិបស្សកៈ ដែល រំលត់កិលេសបាន ក៏អាស្រ័យវិបស្សនាញាណ ដែលកើត ឡើងដោយបច្ចុប្បន្នភ្លាមៗ មិនបានរៀនអប់រំចិត្តទៅតាម គោលសមថមកពីមុន ។ ព្រះសង្ឃជាបុថុជ្ជនដែលមិនបានប ដិបត្តិខាងផ្លូវសមថ ជាពិសេសខាងផ្លូវចិត្ត តាមផ្លូវសមថជា មុន នឹងមិនអាចចម្រើនខាងផ្លូវចិត្តបានឡើយ ។ ព្រះ សង្ឃបុថុជ្ជនដែលបដិបត្តិខាងផ្លូវសមថបានពិតប្រាកដ អាច មានសេចក្តីវិសេសទាំងនោះបាន ទាល់តែចិត្តរបស់បុថុជ្ជន នោះ នៅមិនទាន់នឹងន ចិត្តរត់ចុះរត់ឡើង ផ្លាស់ប្តូរគ្រប់ ពេលវេលា ទើបរបស់ពិសេសនោះមិនពិតប្រាកដដែរ ។ ពេលខ្លះធ្វើបាន រួចពេលខ្លះធ្វើមិនបាន ដូចជាការសម្លឹង មើលរបស់ដែលនៅឆ្ងាយៗដោយចិត្ត ពេលខ្លះឃើញ ច្បាស់ ពេលខ្លះឃើញ ព្រិលៗ ពេលខ្លះមិនឃើញសោះតែ ម្តង ។ ប៉ុន្តែការរួមចិត្តធ្វើសមាធិបានតិច ឬច្រើនប៉ុណ្ណា មានតែព្រះអរហន្តទេ ដែលអាចពិសោធន៍ផ្លូវចិត្តទាំងនោះ ហើយការតស៊ូរបស់លោករហូតមកមិនសាបសូន្យ ពីព្រោះ ចិត្តរបស់លោកបានចាក់ឫសយ៉ាងមាំ ។ ជាពិសេសជាងនេះ ទៅទៀតនោះ អំណាចពិសេសទាំងអស់នោះ ក៏អាចធ្វើឲ្យ ភិក្ខុដែលមានកិលេសកើតសេចក្តីវង្វេង មួម៉ៅ និងប្រព្រឹត្តិ អំពើអាក្រក់ក៏មាន

- តើលោកម្ចាស់ចង់មានន័យយ៉ាងណា ? ដូងកែវសួរ ឡើងដោយការសង្ស័យ

- មានន័យថា អំណាចចិត្តទាំងនោះជាអំណាច

ពិសេសលើចិត្តចម្ងល់របស់មនុស្ស ។ ភិក្ខុបុថុជ្ជន ដែលបានទទួលអំណាចពិសេសទាំងនោះ នឹងកើតសេចក្ដីរីករាយសប្បាយជាមួយនឹងផ្លូវចិត្តហួសពេក ។ លុះដល់យល់ថាខ្លួនជាព្រះអរហន្តទៅ សេចក្ដីរីករាយសប្បាយចិត្តនេះនឹងក្លាយជាឧបសគ្គរាំងនូវសេចក្ដីចម្រើនទៅមុខ ក្នុងការបដិបត្តិផ្លូវចិត្តរបស់គេ ។ គេនឹងព្យាយាមធ្វើសមាធិដោយសេចក្ដីត្រូវការយ៉ាងខ្លាំងក្លា តាមរយៈភាពអស្ចារ្យពិសេសនោះទៀត សេចក្ដីត្រូវការនោះនឹងស្ទាក់ឃាត់មិនឲ្យចិត្តស្ងប់ ប្រែក្លាយជាសមាធិបាន ។ គេនឹងព្យាយាមយ៉ាងខ្លាំងរហូតដល់ហួសកម្លាំង នៅទីបំផុតនឹងកើតអាការៈវិកលចរិតខណៈពេលឃើញនិមិត្តបន្តិច ចិត្តក៏ចាប់ផ្ដើមស្ងប់ ក៏យល់ថាខ្លួនបានឃើញរបស់ពិត យកទៅនិយាយឲ្យអ្នកដទៃស្ដាប់យ៉ាងនេះយ៉ាងនោះ ថាខ្លួនបានឃើញនរក ឃើញឋានសួគ៌ ឃើញខ្មោច ឃើញទេវតា ឃើញនាគ ឃើញអ្វីៗផ្សេងៗ ។ លោកខ្លះទៀតពេលចាប់ផ្ដើមបានអំណាចពិសេសខាងផ្លូវចិត្ត ក៏ប្រញាប់យកទៅប្រាប់ញាតិញោមភ្លាម ពេលសមាធិចិត្តបានល្អក៏ អាចនិយាយប្រាប់ត្រូវ តែពេលវង្វេងខុស ច្រើនទាក់ទងជាមួយមនុស្សច្រើនឡើងសមាធិចិត្តក៏ធ្លាក់ចុះមិនអាចឃើញនូវអ្វី ប្រសិនបើនិយាយប្រាប់ញាតិញោមថា មិនបានឃើញអ្វីសោះ ច្បាស់ជាខូចកេរ្តិ៍ឈ្មោះ ក៏បញ្ចេញបញ្ចូលបន្ថែមផ្ទុចៗងងឹង ឲ្យញាតិញោមយល់ស្មានៗទៅតាមខ្លួនយល់ខុសខ្លះ ត្រូវខ្លះ តាមដែលខ្លួនបានយល់នោះទៅ ពីព្រោះហេតុនេះបានជាលោកគ្រូ

ធម្មាចារ្យអប់រំខាងផ្លូវចិត្ត ហាមសិស្សមិនឲ្យវង្វេងក្នុងអំណាចចិត្តទាំងនោះ ពីព្រោះវាជាទោសច្រើនជាងគុណដូចជាព្រះអរហន្តរំលត់កិលេសបានជ្រះស្រឡះហើយអាចយកមកប្រើក្នុងការកសាងនូវសទ្ធាដល់មនុស្សខ្លះ គឺមិនជាអ្វីទេ

- បើដូច្នោះ ការបដិបត្តិសមាធិក៏មានការប្រាថ្នាអ្វីផ្សេងជាង អំណាចពិសេសខាងផ្លូវចិត្ត ដូចបានពោលមកនេះ ?

- ត្រូវហើយ ! អំណាចពិសេសដូចបានពោល គ្រាន់តែជាផល ដែលបានកើតពីការធ្វើសមាធិតែប៉ុណ្ណោះ មិនមែនជាចំណុចដែលខ្ពស់នោះទេ ។ បើអ្នកណាវង្វេងសប្បាយរីករាយជាមួយរបស់ទាំងនោះ អ្នកនោះឯងក៏ដូចជាមនុស្សដែលដើរផ្លូវទៅរកអណ្តូងមាសប្រាក់ ប៉ុន្តែពេលទៅដល់ពាក់កណ្តាលផ្លូវ បែរជាជាប់ចិត្តរីករាយគើបយកដុំគ្រួស ដុំថ្ម មានពណ៌ប្លែកៗ ទីបំផុតក៏ភ្លាក់ជាចំណីរបស់ខ្លាគាចនៅកណ្តាលព្រៃនោះឯង

- អ្វីទៅជាចំណុចខ្ពស់បំផុតនៃការអប់រំចិត្ត ?

- ចំណុចខ្ពស់បំផុតនៃការអប់រំចិត្តនោះ គឺដំបូងធ្វើឲ្យចិត្តស្ងប់ទៅជាសមាធិ ពេលចិត្តជាសមាធិបានរឹងមាំហើយការនឹងជាគោលមួយរបស់ ចិត្តនឹងកើតថ្លាត្រជាក់ស្ងប់យ៉ាងមុតស្រួច ដែលខុសប្លែកពីធម្មតា ពីព្រោះនីវរណធម៌ដែលធ្វើឲ្យចិត្តល្អក់កករមិនស្អាតស្រឡះនោះ ត្រូវកម្ចាត់ចេញអស់ទៅ នាំមកនូវការចេះដឹងនូវការពិតមកពិចារណា គឺ **អនិច្ចំ** សេចក្តីមិនទៀងក្នុងជីវិត **ទុក្ខំ** សេចក្តីទុក្ខវេទនាក្នុង

ជីវិត និង**អនត្តា** សេចក្ដីមិនមែនជារបស់ខ្លួន ។ ខណៈពេល ពិចារណាទៅៗ វិបស្សនាញាណក៏កើតឡើង ប្រៀបដូច យើងបើកភ្លើងឲ្យភ្លឺស្វាងឡើង នៅក្នុងបន្ទប់ងងឹតពេល វិបស្សនាញាណកើតឡើងហើយ សេចក្ដីងងឹតក្នុងចិត្តគឺ **អវិជ្ជា** ក៏បាត់ ដែលពេលអវិជ្ជាបាត់ទៅ **តណ្ហា ឧបាទាន លោភៈ ទោសៈ មោហៈ** និង **កិលេសាសវៈ** ទាំងពួង អស់ទៅដោយពិត ។ បន្ថែមមកនៅសល់តែភាពស្អាតបរិសុទ្ធនៃចិត្តពន្លឺភ្លឺស្វាងដោយវិជ្ជា គឺសេចក្ដីដឹងពិតឃើញពិត និង សេចក្ដីស្ងប់សុខត្រជាក់ ដែលគ្មានអ្វីក្នុងលោកអាចមករំខាន ឬបំផ្លាញបានឡើយ ។ នេះគឺជាចំណុចខ្ពស់បំផុតក្នុងការធ្វើសមាធិ អាចហៅបានថា **និព្វាន** ក៏បាន ហៅថា **និរោធ** ក៏បាន ហៅថា **អរហន្ត** ក៏បាន ហៅថា **ជាទីផុតទុក្ខ** ក៏បានហៅថា **លោកុត្តរធម៌** ក៏បាន

- យល់ថាជាការបដិបត្តិដ៏លំបាក, ដួងកែវពោលឡើង ក្រោយពីនៅស្ងៀមគិតអស់ពេលជាយូរ, ខ្ញុំកូណាមិនដែល បានគិតពីមុនមកថា ព្រះពុទ្ធសាសនាមានការបដិបត្តិដ៏ លំបាកបែបនេះសោះ ខ្ញុំកូណាស្មាល់ ប្រហែលគ្មានសង្ឃឹម ឈានដល់ចំណុចខ្ពស់បែបនេះទេ ពីព្រោះដឹងខ្លួនឯងច្បាស់ ថានៅមានកិលេសក្រាស់ បញ្ញាក៏មិនដល់

- គ្រប់បន្ទប់ដែលមិនទាន់បើកភ្លើងឲ្យភ្លឺឡើង ក៏ត្រូវ ភាពងងឹតគ្របដណ្ដប់ដោយងាយៗ មិនថាងងឹតតិច ឬ ច្រើន ក៏នាំគ្នារត់ចេញទាំងអស់ មនុស្សធម្មតាគ្រប់ៗគ្នា តែងមានកិលេសក្រាស់ទាំងអស់ ព្រោះដូច្នេះទើបលោក

ហៅថា **បុថុជ្ជន** ប្រែថា មនុស្សដែលក្រាស់ទៅដោយកិលេស ប៉ុន្តែពេលកើតមានពន្លឺភ្លឺស្វាងកើតឡើងនៅក្នុងចិត្តហើយ កិលេសក៏បាត់អស់ដែរ ពីព្រោះកិលេសទាំងឡាយមាន **លោភៈ ទោសៈ** និង**មោហៈ** ជាដើម នៅពេលអវិជ្ជាបាត់ទៅ ពន្លឺក៏កើតឡើង កិលេសក៏បាត់ទៅដែរ ដូច្នេះគោលធំរបស់ព្រះពុទ្ធសាសនា គឺការកសាងនូវពន្លឺភ្លឺស្វាងនៅខាងក្នុង ដើម្បីកម្ចាត់សេចក្ដីងងឹតគឺអវិជ្ជា

- លោកម្ចាស់មានន័យថា មនុស្សគ្រប់គ្នាអាចបង្កើតពន្លឺខាងក្នុង ឲ្យកើតឡើងបានយ៉ាងនោះមែនឬទេទាន ? នាងស្រីសួរ

- ពរគ្រាហើយ ! ពន្លឺខាងក្នុង គឺសេចក្ដីចេះដឹងនោះឯង សេចក្ដីចេះដឹងតាមបែបព្រះពុទ្ធសាសនាមានបី ៖

**ទីមួយ ការដឹងដោយបញ្ញា** គឺការចេះចាំបាន នៅពេលបានឮ បានស្ដាប់ ឬបានអាន ដូចជាមនុស្សមកប្រាប់ថា អរិយសច្ចជាខនិបូង គឺទុក្ខ ។ ដោយយើងទទួលស្គាល់បែបនេះហើយ ទើបបញ្ញាក៏កើតឡើង ។ បញ្ញាបែបនេះហៅថា សុតមយបញ្ញាតែគ្រាន់ជាពន្លឺ មានកម្លាំងស្រាលដូចជាការយល់ដឹងដែលកើតឡើង នៅពេលមានអ្នកមកនិយាយពីស្រុកបាងកកឲ្យមនុស្សដែលមិនធ្លាប់ស្គាល់បានស្ដាប់ ។

សេចក្ដីដឹង**ទីពីរ គឺដឹងដោយទិដ្ឋិ ឬ ការឃើញត្រូវ** ការចេះដែលកើតចេញពីការគិត ការពិចារណា ព្រោះដូច្នោះហើយទើបលោកហៅថា ចិន្តាមយបញ្ញា ដូចជាពេលយើងដឹងថា អរិយសច្ចក្នុងគ្រាដំបូងគឺទុក្ខ ហើយនាំមកពិចារណា

ឲ្យឃើញនូវទុក្ខក្នុងខ្លួន ។ សេចក្តីដឹងថ្នាក់នេះភ្លឺច្បាស់ឡើង មានកម្លាំងចិត្តច្រើនឡើងៗ ប្រៀបដូចបានស្តាប់អំពីទីក្រុងបាងកក ថែមទាំងបានឃើញរូបថត និងផែនទីរបស់ទីក្រុងបាងកកថែមទៀតផង ។

សេចក្តីដឹងថ្នាក់ខ្ពស់វិញ **គឺដឹងដោយញាណ** ជាសេចក្តីដឹងដែលកើតពីការអប់រំផ្លូវចិត្ត លោកហៅថា ភាវនាមយបញ្ញា ពេលញាណកើតឡើងហើយ សូម្បីតែបានឃើញថាមានទុក្ខក្នុងខ្លួនយ៉ាងនេះហើយ ក៏នៅតែឃើញច្បាស់ថែមទៀតថា ក្ខន្ធទាំងមូលនេះ គឺជាទុក្ខដ៏ក្រៃលែង ប្រៀបដូចជាមនុស្សបានទៅទស្សនាពីទីក្រុងបាងកកដោយផ្ទាល់ បានឃើញនូវរបស់ពិតប្រាកដ ។

សេចក្តីដឹងគ្រប់យ៉ាងឲ្យកើតនូវពន្លឺខាងក្នុងឡើងបានប៉ុណ្ណោះ ខុសគ្នាត្រង់តែច្រើន ឬតិច ហើយសេចក្តីដឹងគ្រប់ចំណុច សុទ្ធសឹងតែធ្វើឲ្យកើតមានការផ្លាស់ប្តូរក្នុងផ្លូវល្អទាំងអស់ ។ ដូច្នេះ ញោមគួរតែព្យាយាម កសាងពន្លឺផ្សេងៗឲ្យកើតឡើង សេចក្តីដឹងតាមបញ្ញា ញោមអាចនឹងមានច្រើនល្មមហើយ ដូច្នេះព្យាយាមកសាងសេចក្តីចេះដឹងថ្នាក់ទិដ្ឋិ និងថ្នាក់ញាណឲ្យកើតឡើងតទៅ ។

# សទ្ធាជាគូនឹងបញ្ញា

បទពាក្យ៧

មុនដាក់ជំនឿទៅលើអ្វី ត្រូវតែវិនិច្ឆ័យឲ្យបានច្បាស់
កុំទាន់ជឿគេឆាប់រហ័ស នាំឲ្យវិនាសអន្តរាយគុណ ។
ត្រូវតែពិនិត្យគិតឲ្យយល់ បញ្ជាក់ហេតុផលប្រាកដមុន
កុំចេះតែជឿនាំស៊ីយស៊ុន យល់បានច្បាស់មុនអស់សង្ស័យ ។
ព្រោះកាលបើជឿទៅខាងខុស ផលត្រូវបាននោះគឺទោសភ័យ
ខាតបង់ប្រយោជន៍ខូចយប់ថ្ងៃ បង្កើតបានក្ដីទុក្ខសោកា ។
តាមមើលតាមស្ដាប់ចាប់ឲ្យទាន់ កុំជាមនុស្សអន់អប្បបញ្ញា
ចាញ់កលជនខ្លៅចិត្តពាលា មួយក្ដាប់នាំគ្នាដើរបោកប្រាស់ ។
សទ្ធាប្រកបដោយបញ្ញា ជាគូនឹងគ្នាបញ្ជាក់ច្បាស់
សាងប្រយោជន៍គុណប្រាកដណាស់ ចិត្តមិនវិបល្លាសតាមគេថា ។
ចេះពិចារណាទៅតាមហេតុ ពិនិត្យសង្កេតដោយបញ្ញា
ស្រាវជ្រាវរកផលប្រចក្សចារ ច្បាស់ក្នុងចិន្តាអស់សង្ស័យ ។
នេះបាននាមថាពុទ្ធបរិស័ទ មានការបដិបត្តិល្អប្រពៃ
តាមអង្គឱវាទព្រះជិនស្រី កំចាត់ទុក្ខភ័យវិបត្តិបាន ។

ដោយឧបាសក មុិញ សារ៉ាង

# ២៩. គុណសម្បត្តិរបស់សង្ឃ

ពេលព្រឹកឡើងក្រោយពីបានទៅបិណ្ឌបាត្រ និងឆាន់ចង្ហាន់ព្រឹករួច អាត្មារៀបចំរបស់របររៀបនឹងចេញដំណើរតទៅទៀត តែត្រូវឈប់ផ្អាក ពីព្រោះឆ្លងតែវិមកវកអាត្មាជាមួយនឹងមិត្រអាយុស្របាលគ្នាម្នាក់ទៀត ។

- លោកម្ចាស់រៀបចំរបស់របរនិមន្តទៅណាឬទាន? នាងស្រីសួរ ធ្វើដូចជាឆ្ងល់ក្នុងចិត្តខ្លាំងណាស់

- បើសិនជាញោមមកយឺតជាងនេះបន្តិច ប្រាស់ជាមិនបានជួបនឹងអាត្មាទេ អាត្មាកំពុងរៀបចំពនេចរបន្តទៀត, អាត្មាឆ្លើយបណ្ដើររៀបរបស់របរបន្តិចបន្តួច ដាក់ចូលទៅក្នុងបាត្របណ្ដើរ

- លោកម្ចាស់នឹងនិមន្តទៅណាទាន? ឆ្លងតែវិសួរបន្តទៀតឬកពាដូចជាឆ្ងល់ខ្លាំងឡើងៗ

- អាត្មាមិនធ្លាប់កំណត់ទុកមុនទេថា នឹងទៅទីណានោះទេះតែដើរៗតាមផ្លូវ យប់នៅទីណាក៏ឈប់សម្រាកនៅទីនោះទៅ

ឆ្លងតែវិ សម្លឹងមើលមុខមិត្ររបស់គេដូចជាងឿងឆ្ងល់ ចំណែកមិត្ររបស់គេប្រហែលជាឆ្ងល់ដូចគ្នាដែរ ។ មួយស្របក់ធំ បណ្ឌិតវិទ្យាសាស្ត្រស្រីទើបពោលឡើងថា៖

- ខ្ញុំកូណាស្មានថា លោកម្ចាស់នឹងគង់នៅទីនេះបានយូរជាងនេះទៀតតើទាន ប៉ុះតែមិនបានជួបលោកម្ចាស់

សំណាងល្អណាស់ដែលមកទាន់ ។ ខ្ញុំករុណានាំមិត្រមក ថ្វាយបង្គំលោកម្ចាស់ផង គេឈ្មោះ ប៉ុណ្ណិម៉ា ជាគ្រូបង្រៀនភាសាអង់គ្លេសក្នុងសាលាស្ត្រី

ប៉ុណ្ណិម៉ា លើកដៃសំពះអាត្មាដូចជាមិនសូវពេញចិត្ត ប៉ុន្មានទេ រួចហើយក៏អង្គុយដូចដើមវិញ ។ ដួងកែវសម្លឹងមើលមិត្រដោយមិនសូវពេញចិត្តហើយពោលថា៖

- តាមធម្មតាគេមិនសូវចូលវត្តទេ បើមិនចាំបាច់គេក៏មិនសំពះព្រះ គេមានគំនិតមិនសូវចូលចិត្តព្រះសង្ឃប៉ុន្មានទេ ខ្ញុំករុណាសូមទូលទានតាមត្រង់ទាន!

ពាក្យពោលប្រាប់របស់ដួងកែវ ធ្វើឲ្យអាត្មាចូលចិត្តឡើងភ្លាម អាត្មាដកដៃពីការរៀបចំរបស់របរ ក៏ងាកទៅមើលមុខអ្នកគ្រូហើយសួរថា៖

- ញោមពិតជាមិនសូវចូលចិត្តព្រះសង្ឃមែនឬ?

- ពិតមែនហើយគុណម្ចាស់! ប៉ុណ្ណិម៉ា ឆ្លើយដាច់ៗហើយអង្គុយស្ងៀមព្រងើយដូចដើម

- ព្រោះហេតុអ្វីទើបមានទស្សនៈមិនសូវល្អជាមួយភិក្ខុសង្ឃដូច្នេះ?

- ពីព្រោះភិក្ខុសង្ឃបដិបត្តិមិនល្អ មិនសមនោះឯង! នាងស្រីនោះឆ្លើយដោយសម្លេងច្បាស់ដាច់ៗ

- បដិបត្តិមិនល្អ មិនសមយ៉ាងម៉េចខ្លះ? អាត្មាសួរបន្តទៀត ព្យាយាមរម្ងាប់ចិត្តផ្សាយមេត្តាដល់នាងស្រីដែលកំពុងមានទុក្ខ ពីព្រោះត្រូវសេចក្តីស្អប់ និងសេចក្តីក្រោធគ្រងជាប់នៅក្នុងសន្តាន

- ភិក្ខុកម្លោះ លោកនេនចូលចិត្តធ្វើខ្លួនដូចជាបុរសមាន ស្នេហ៍ នៅខណៈពេលមួយខ្ញុំកូណាដើរកាត់វត្តនាំគ្នារត់ស្រមកអើតមើលតាមបង្អួច ខ្លះធ្វើមុខធ្វើមាត់ ខ្លះនិយាយពាក្យផ្សេងៗ ។ ភិក្ខុវ័យចំណាស់ខ្លះក៏មានលោភៈគ្រាស់បានរបស់អ្វីៗប្រមូលទុក ដូចនៅបាងកកខ្ញុំកូណាបានឃើញភិក្ខុវ័យចំណាស់ឈរបិណ្ឌបាតតាមផ្សារ ពេលពេញបាត្រក៏ឲ្យក្មេងយកទៅចាត់ចែងរបស់ណា ដែលអាចយកទៅលក់បាន ដើម្បីយកបច្ច័យមកចែកគ្នា ។ ភិក្ខុវ័យចំណាស់ខ្លះចូលចិត្តទិញឆ្នោតនៅផ្សារ ហើយក្នុងកុដិមានទូរទឹកកក វិទ្យុ ទូរទស្សន៍ រួចអង្គខ្លះទៀតមានម៉ាស៊ីនត្រជាក់ មានឡានផ្ទាល់ខ្លួនទៀតផង ។ មួយថ្ងៃៗមិនឃើញធ្វើអ្វីទេ ក្រៅពីឆាន់ចង្ហាន់ហើយចូលសឹង ។ អង្គខ្លះទៀតរៀនដល់ បរិប្រយោគ ប៉ុន្តែទេសនាមិនយល់អ្វីទាំងអស់ ។ តើដូច្នេះឲ្យខ្ញុំកូណាជឿយ៉ាងម៉េចបាន ហើយក៏ឈប់គោរពព្រះសង្ឃមកយូរហើយដែរ គោរពតែព្រះពុទ្ធ ព្រះធម៌តែប៉ុណ្ណោះ

អាត្មាតាំងចិត្តស្តាប់ពាក្យពោលរបស់អ្នកគ្រូ ដោយសេចក្តីក្រៀវក្រោះយ៉ាងខ្លាំង ព្យាយាមរម្ងាប់ចិត្តឲ្យជាប្រក្រតី ហើយពោលថា៖

- ពាក្យដែលញោមបានពោលមកនេះ គឺជាការពិត តែអាត្មាសុំសួរថា ភិក្ខុកម្លោះ ភិក្ខុវ័យចំណាស់ទាំងអស់នៅក្នុងប្រទេសថៃ សុទ្ធតែដូចពាក្យដែលញោមបានពោលនោះឬយ៉ាងណា ?

- ខ្ញុំកូណាមិនដឹងដែរ ព្រោះមិនមានឱកាសបានទៅ

សម្គាល់ទូទាំងប្រទេសនោះទេ, នាងស្រីឆ្លើយដូចជាមានប្រៀប, ពីដើមខ្ញុំករុណាគិតថា ប្រហែលជាមានភិក្ខុល្អខ្លះដែរ ប៉ុន្តែស្វែងរកមកយូរហើយ មិនទាន់បានជួបសោះ ទើបខ្ញុំករុណាយល់ថាឲ្យតែចេញឈ្មោះថា ភិក្ខុសង្ឃប្រហែលជាដូចគ្នាទាំងអស់ សេចក្ដីយល់ឃើញបែបនេះប្រហែលខុស ឬយ៉ាងណា ?

- នាងយល់ខុសហើយ ! ដួងកែវពោលឡើងម្ដង, ព្រះសង្ឃល្អក៏មានដែរ ក្នុងប្រទេសថៃមានភិក្ខុរាប់សែនអង្គជាងនឹងឲ្យល្អដូចគ្នាទាំងអស់ ឬ អាក្រក់ទាំងអស់បានដូចម្ដេចកើត ?

- ព្រះសង្ឃដូចគ្នា នៅក្នុងសាសនាដូចគ្នា រក្សាព្រះវិន័យស្មើគ្នា គួរតែបានដូចគ្នា, ប៉ុស្ណោរិម៉ាឆ្លើយដោយសម្លេងមិនប្រាកដក្នុងចិត្ត

- ចុះអ្នករាជការរបស់នាងនុ៎ះ ! ដួងកែវឆ្លើយគាត់ភ្លាម, ជាអ្នករាជការដូចគ្នា នៅក្នុងរបៀបវិន័យដូចគ្នា តើល្អដូចគ្នាឬទេ ? អ្នកខ្លះក៏ល្អសែនល្អ អ្នកខ្លះក៏មិនល្អ តើដូចម្ដេចបានជាដូច្នោះ ?

- ល្ហើយចុះ ! ចាំអាត្មាអធិប្បាយឲ្យស្ដាប់, អាត្មាពោលគាត់ឡើង, ក្នុងខណៈដែលអាត្មាជាភិក្ខុក្នុងចំណោមព្រះសង្ឃ អាត្មាយល់ច្បាស់ថាអ្វីខុសអ្វីត្រូវ ៗ អាត្មាសុំទទួលថា ក្នុងចំណោមព្រះសង្ឃសាមណេរ ប្រហែលពីរសែនអង្គក្នុងប្រទេសថៃនេះ លោកល្អក៏មាន លោកមិនល្អដូចញ្ញោមប៉ុស្ណោរិម៉ាពោលឡើងក៏មានច្រើន ៗ អំពើល្អ និងអាក្រក់ជា

អំពើរបស់បុគ្គលផ្ទាល់ខ្លួន មិនទាក់ទងជាមួយភេទ និង របៀបវិន័យនោះទេ ។ ការពិតរបៀបវិន័យ និងការបដិបត្តិ សម្រាប់ព្រះភិក្ខុ ដែលព្រះពុទ្ធអង្គទ្រង់បានបញ្ញត្តិទុកនោះ ដូចគ្នាទាំងអស់ ប្រហែលគ្នាទូទាំងប្រទេស ប៉ុន្តែភិក្ខុខ្លះ ប្រព្រឹត្តតាមបានច្រើន អង្គខ្លះបានតិច អង្គណាបដិបត្តិតាម បានច្រើនចាត់ ទុកថាជាភិក្ខុល្អ ចំណែកអង្គដែលបដិបត្តិ បានតិច ក៏ចាត់ថាភិក្ខុមិនល្អ ។ ការបដិបត្តិតាមបានច្រើនល្អ ឬ តិចនោះស្រេចទៅលើឧបនិស្ស័យរបស់អ្នកបួសនោះ កុំ ភ្លេចថាអ្នកបួសនោះចេញមកពីឃរាវាស ប្រសិនបើ ឧបាសកល្អ នៅពេលមកបួសក៏ជាភិក្ខុល្អដែរ ។ បើជា មនុស្សមិនល្អ ខូចខិល ពេលមកបួសជាភិក្ខុក៏ទៅជាភិក្ខុខូច ខិលផងដែរ លើកលែងតែខិតខំតាំងចិត្តរៀន និងខំបដិបត្តិ ខ្លួនបានល្អ ។ តាមតែអាត្មាបានសង្កេតមើល មនុស្សមក បួស ពីព្រោះមានចំណុចប្រាំប្រភេទ៖

១). ប្រភេទទីមួយ **បួសដើម្បីរក្សាប្រពៃណី** មនុស្សប្រភេទនេះ ភាគច្រើនមិនមានសទ្ធាក្នុងព្រះពុទ្ធ សាសនាពិតប្រាកដប៉ុន្មានទេ បួសពីព្រោះត្រូវឱពុកម្ដាយសុំ ឲ្យបួស ។ បួសដើម្បីបំពេញចិត្តឪពុកម្ដាយ ភាគច្រើននៅ ជាភិក្ខុបានតែប្រាំពីរថ្ងៃ ដប់ប្រាំថ្ងៃ មួយខែ ឬ បីខែយ៉ាង យូរ ។ អ្នកខ្លះបួសហើយក៏តាំងចិត្តរៀនសូត្រ ហើយខំ បដិបត្តិធម៌យ៉ាងពិតប្រាកដ ពីព្រោះឃើញថាខ្លួនឯងមាន ពេលនៅក្នុងព្រះពុទ្ធសាសនាតិច ។ ប៉ុន្តែអង្គខ្លះនាំយក ឧបនិស្ស័យចិត្ត និងការចេះដឹងនឹកគិតបែប **ឃរាវាស** ជាប់

តាមមកជាមួយពេញខ្លួន ទ្រាំនៅជាភិក្ខុដោយសេចក្តីទុក្ខវេទនា ដេករាប់ថ្ងៃ មិនតាំងចិត្តរៀនសូត្រ និងមិនខំបដិបត្តិទេ មិនមានការទទួលខុសត្រូវ ព្រោះឃើញថាខ្លួនមកនៅតែមួយរយៈប៉ុណ្ណោះ ។ មនុស្សរបៀបនេះតែង បង្ករឿងរ៉ាវនៅក្នុងវត្ត ហើយប្រព្រឹត្តមិនសូវបានល្អទេ តែទុកជាល្អហើយ ពីព្រោះគេមិនបាននៅក្នុងវត្តយូរតទៅរហូត

២). ប្រភេទទីពីរ **បួសដើម្បីរៀនសូត្រ** មនុស្សប្រភេទនេះភាគច្រើនមកពីគ្រួសារក្រលំបាក មកពីជនបទ ។ ឪពុកម្តាយ មិនមានប្រាក់បញ្ជូនឲ្យកូនទៅរៀនបន្តជាន់ខ្ពស់បាន តែចង់ឲ្យកូនបានរៀនថ្នាក់ខ្ពស់ៗនឹងគេឯងដែរ ទើបនាំមកឲ្យបួសជាសាមណេរ ដើម្បីឲ្យបានរៀនខាងធម្មៈ ។ សាមណេរពួកនេះបានរៀនទៅជានិច្ចតាំងតែ ប្រយោគទី ១ រហូតដល់ប្រយោគទី ៩, នៅពេលរៀនចប់ថ្នាក់ណាមួយហើយ លោកខ្លះក៏សឹកលាភេទជាអ្នកបួសចេញទៅ ។ លោកខ្លះមិនសឹកទេ លោកដែលមិនព្រមសឹកក៏បានទទួលសមណៈសក្តិ និងតំណែងការងារផ្សេងៗ លោកប្រភេទនេះអង្គខ្លះក៏បដិបត្តិល្អគួរឲ្យជ្រះថ្លា តែអង្គខ្លះបដិបត្តិមិនសមមិនគួរឲ្យជ្រះថ្លាទេ

៣). ប្រភេទទីបី **បួសដោយសារជ្រះថ្លា** មនុស្សប្រភេទនេះបានសិក្សារៀនសូត្រព្រះពុទ្ធសាសនា លុះកើតមានសទ្ធាជ្រះថ្លាហើយ ក៏តាំងចិត្តបដិបត្តិយ៉ាងល្អប្រពៃ ។ ភិក្ខុប្រភេទនេះអាចនឹងមកពីប្រភេទទី១ និងប្រភេទទី២ ក៏ថាបាន ភិក្ខុប្រភេទនេះមានចំនួនតិចតួចណាស់ ភាគច្រើនចូល

ចិត្តនៅក្នុងព្រៃ ឬ តាមល្អាងភ្នំ មិនចូលចិត្តនៅរីករាយជាមួយមនុស្ស មិនចូលចិត្តសេចក្តីអឺអរ មិនចូលចិត្តបុណ្យសក្តិ និងតំណែងតួនាទីផ្សេងៗ ឡើយ

៤). ប្រភេទទីបួន **បួសដើម្បីចិញ្ចឹមជីវិត** មានន័យថា មនុស្សដែលគ្មានញាតិមិត្តខ្វះទីពឹង ហើយមិនដឹងនឹងប្រកបរបររកស៊ីអ្វីក្នុងផ្លូវលោក ហើយទើបចូលមកបួសអាស្រ័យព្រះសាសនាជាគ្រឿងចិញ្ចឹមជីវិត ។ ភិក្ខុប្រភេទនេះមិនសូវតាំងចិត្តសិក្សា និងបដិបត្តិចិត្តពេញទៅដោយកិលេសផ្សេងៗ ចូលចិត្តសន្សំប្រាក់ទិញអីវ៉ាន់ ហើយទិញឆ្នោតតាមផ្សារ ពេលមានបានឡើងកាលណាក៏សឹកទៅភ្លាម

៥). ប្រភេទទីប្រាំ **គឺជាមនុស្សខ្ជិលធ្វើការងារ** ហើយថែមទាំងមានសេចក្តីប្រព្រឹត្តមិនល្អទៀតផង ឪពុកម្តាយមិនអាចអប់រំបាន ទើបនាំឲ្យទៅបួស ដោយសង្ឃឹមថាភេទបព្វជិត និងព្រះធម៌វិន័យអាចជួយដុសខាត់ឲ្យគេបានទៅជាមនុស្សល្អបាន ភិក្ខុបែបនេះមិនសូវមានច្រើនទេ លោកខ្លះប្រែជាល្អបាន ខ្លះក៏ផ្លាស់ប្តូរមិនបាន ។ លោកដែលកែខ្លួនមិនបាន ក៏ក្លាយទៅជាមារសាបការក្នុងព្រះពុទ្ធសាសនា ប្រព្រឹត្តថោកទាបផ្សេងៗ ដូចដែលញោមធ្លាប់បានជួបឃើញមកនោះឯង

ក្រៅអំពីប្រាំប្រភេទនេះ អាចនឹងមានភិក្ខុដែលបួសដោយហេតុផលផ្សេងៗខ្លះទៀត តែក្នុងចំណោមប្រាំប្រភេទនេះមានច្រើនយ៉ាងច្រើនបែបដូចនេះហើយ ក៏មានភិក្ខុ

ដែលមាននិស្ស័យសន្តានផ្សេងៗគ្នា ទើបមានភិក្ខុល្អខ្លះ មិនល្អខ្លះជាធម្មតា នឹងឲ្យបានល្អទាំងអស់ ឬខូចទាំងអស់នោះ គឺមិនអាចទៅរួចទេ ។ សូម្បីសម័យពុទ្ធកាលព្រះអង្គទ្រង់គង់នៅមានព្រះជន្មនៅឡើយ ភិក្ខុខូចៗក៏មានច្រើនដែរ ដូចជាភិក្ខុទេវទត្ត ភិក្ខុឧទាយិត្ថេរ ភិក្ខុឆព្វគិយជាដើម ។ កាលដែលឃើញភិក្ខុមិនល្អគ្រាន់តែជាផ្នែកខ្លះ ហើយក៏សម្រេចចិត្តភ្លាមថា ភិក្ខុមិនល្អទាំងអស់ គឺពិតជាមិនត្រឹមត្រូវទេ ។ ជាពិសេសជាងនេះទៅទៀត ដល់ថ្នាក់ឈប់រាប់អានព្រះសង្ឃនេះកាន់តែខ្លាំងទៅទៀតហើយ កុំភ្លេចថាព្រះសង្ឃមានពីរប្រភេទគឺ **សម្មតិសង្ឃ** បានដល់បុថុជ្ជនដែលបួសជាសង្ឃដោយសន្មត ។ មកពីនៅជាបុថុជ្ជនមានកិលេសក៏អាចនឹងមានល្អខ្លះ ខូចខ្លះ ឲ្យចេះរើសរាប់អានអង្គណាល្អឃើញក៏គោរពរាប់អាន ចំណែកអង្គណាដែលមិនល្អ ក៏មិនចាំបាច់គោរពរាប់អាន ។ ភិក្ខុមិនល្អឃើញមិនបាច់សំពះក៏បាន មិនមានបាបទេ បើឃើញនៅសំពះទៀតក៏បានតែបាបដដែល ពីព្រោះដូចជាជួយមារក្នុងព្រះពុទ្ធសាសនាអញ្ចឹងដែរ ។ ចំណែកព្រះសង្ឃមួយប្រភេទទៀត គឺព្រះ**អរិយសង្ឃ** អ្នកដែលសម្រេចមគ្គផលតាំងពីព្រះសោតា ឡើងទៅដល់ព្រះអរហន្ត ព្រះអរិយសង្ឃ ថ្នាក់អរហន្ត បើរាប់ដោយគុណហើយ ក៏ដូចគ្នានឹងព្រះពុទ្ធ ព្រះធម៌ផ្នែកលោកុត្តរៈ ព្រោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃថ្នាក់ជាន់ខ្ពស់ ទើបចូលគ្នាជាក្លុងមួយ ។ បើរាប់អានតែអង្គណាមួយក៏ប្រៀបដូចជាបានគោរពនូវអង្គទាំងអស់ មិនអាចថារាប់អានតែអង្គនេះ អង្គ

នោះមិនអាចបានទេ ដូច្នោះពាក្យដែលពោលមកថាគោរព តែព្រះពុទ្ធ និងព្រះធម៌ ចំណែកព្រះសង្ឃមិនគោរពទេ ទើបជាពាក្យមិនសមគួរ មិនត្រឹមត្រូវទាល់តែសោះ ៗ ពាក្យដែលគួរនិយាយឲ្យសម គឺថាគោរពព្រះពុទ្ធ ព្រះធម៌ និងព្រះអរិយសង្ឃ ចំណែកសម្មតិសង្ឃគោរពចំពោះតែអង្គដែលបដិបត្តិល្អយ៉ាងនេះ ទើបត្រឹមត្រូវពិត

នៅពេលបានស្តាប់ នូវពាក្យរៀបរាប់របស់អាត្មាចប់ហើយ ប៉ុណ្ណិម៉ាក៏មានមុខមាត់ស្រស់បស់ឡើង គេពោលឡើងដោយពាក្យស្រួលបួលថា៖

- ការពិតខ្ញុំកូណាគិត នឹងពោលដូចលោកម្ចាស់មានសង្ឃដីកាដែរ តែដោយមានការចេះដឹងផ្នែកពុទ្ធសាសនាតិច ទើបនិយាយមិនត្រូវ ៗ ខ្ញុំកូណាបានទទួលចំណេះដឹងបន្ថែមទៀតច្រើន តទៅនេះខ្ញុំកូណានឹងបដិបត្តិតាមលោកម្ចាស់បានពន្យល់មកនេះ

- ដូចម្តេចហ្ន៎! ព្រះសង្ឃមិនបដិបត្តិឲ្យបានល្អត្រឹមត្រូវបានដូចគ្នាទាំងអស់ទៅ ? ដ្បិតតែពោលឡើងជាពាក្យសួរល្មើយៗ

- ពីព្រោះលោកមិនបានបួសដោយសទ្ធាគ្រប់អង្គនោះទេ ពេលបួសរួចហើយមិនបានតាំងចិត្តសិក្សារៀនសូត្រឲ្យបានយល់ជ្រៅជ្រះ តាមពុទ្ធដីការបស់ព្រះបរមគ្រូនៃយើង ៗ បើរៀនក៏គ្រាន់តែរៀនចាំទៅតាមតម្រា ដើម្បីត្រឹមតែឲ្យប្រឡងជាប់បានថ្នាក់ខ្ពស់ៗ ពីព្រោះតែចេះចាំបានច្រើន ប៉ុន្តែមិនបានយល់ឲ្យបានជ្រៅក្នុងព្រះធម៌ ទើបព្រះធម៌មិនបាន

ជ្រាបចូលទៅដុសខាត់នូវឧបនិស្ស័យឲ្យបានស្អាត ភ្លឺស្វាង ស្ងប់នោះឡើយ ចិត្តនៅមានពេញណែនទៅដោយកិលេស ហើយក៏ប្រព្រឹត្តទៅតាមអំណាចនៃកិលេស មានពេលខ្លះកែប្រែនូវព្រះធម៌ ព្រះវិន័យថែមទៀតផង ។ ម្យ៉ាងទៀតនៅពេលរៀនបានច្រើនហើយ មិនបានបដិបត្តិក្នុងត្រ័យសិក្ខា គឺ **សីល សមាធិ បញ្ញា** ទើបមិនបានផលដល់ផ្លូវចិត្តសោះឡើយ

- ខ្ញុំកូណាយល់ថា ព្រះពុទ្ធសាសនា គឺព្រះសង្ឃនេះហើយសំខាន់ជាងគេបំផុត, ដូងកែវបញ្ចេញទស្សនៈបន្ត, ពីព្រោះព្រះពុទ្ធអង្គទ្រង់បរិនិព្វានទៅហើយ ចំណែកព្រះធម៌ក៏ជានាមធម៌ដែលជ្រៅ មានតែព្រះសង្ឃប៉ុណ្ណោះ ដែលនៅឲ្យបានឃើញរូបរាង ។ ព្រះសង្ឃមាននាទីជំនួសនូវព្រះពុទ្ធអង្គ និងព្រះធម៌ បើព្រះសង្ឃបដិបត្តិមិនល្អ មនុស្សគេអស់នូវសទ្ធា ក្នុងការគោរពព្រះពុទ្ធ និងព្រះធម៌ផងដែរ ។ ខ្ញុំកូណាយល់ឃើញថា ព្រះសង្ឃជាបុគ្គលកណ្ដាល ដែលអាចទាញឲ្យមនុស្សមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ឬក៏រុញច្រានឲ្យមនុស្សដើរចេញពីព្រះពុទ្ធសាសនាវិញក៏មាន តើលោកម្ចាស់ មានវិធីអាចអប់រំព្រះសង្ឃឲ្យបានល្អឡើងបានខ្លះឬទេទាន ?

- វិធីពិតជាមាន ! អាត្មាឆ្លើយ, តែអាចនឹងបដិបត្តិបានដោយលំបាក ។ ប្រការទីមួយ ត្រូវបដិបត្តិពីការសិក្សារបស់ព្រះសង្ឃជាមុនសិន ការរៀនសូត្រ ការបង្រៀនត្រូវយល់ឲ្យបានច្បាស់លាស់ក្នុងព្រះធម៌ ។ ផ្ទុយទៅវិញខំតែ

ទន្ទេញឲ្យចាំបានដូចជាសត្វសេក មិនបានយល់ក្នុងន័យ ការបដិបត្តិទៅតាមព្រះវិន័យ លោកគ្រូតាមវត្ត តាមខេត្ត ហេតុនេះរហូតដល់មហាថេរៈ មន្ទីរធម្មការសាសនា និងពុទ្ធបរិស័ទ ទាំងអស់ ត្រូវតែយកចិត្តទុកដាក់ជួយពិនិត្យ មើលនូវការ ប្រតិបត្តិរបស់ព្រះសង្ឃ ឲ្យបានជិតដល់កុំនៅស្ងៀម ដូចជា ក្នុងការបដិបត្តិធម៌គ្រប់វត្តតម្រូវឲ្យព្រះសង្ឃសាមណេរគ្រប់ អង្គត្រូវតែបដិបត្តិ**សមថកម្មដ្ឋាន** និង**វិបស្សនាកម្មដ្ឋាន**ជា កិច្ចបដិបត្តិរៀងរាល់ថ្ងៃ ។ បើសិនជាធ្វើបានដូច្នេះ ព្រះ សង្ឃ នឹងមានការចេះដឹងស្ទាត់ជំនាញក្នុងព្រះធម៌ ហើយមាន សេចក្តីបដិបត្តិល្អ ដែលគួរឲ្យជ្រះថ្លាគោរព ។ គ្រាន់តែ ប៉ុណ្ណោះក៏ល្អល្មមដែរហើយ បើនឹងឲ្យល្អជាងនេះ គួរមាន ភាពអង់អាចក្នុងការផ្សព្វផ្សាយផង គួរតែដាក់ផែនការចូល ក្នុងកម្មវិធីសិក្សាចំពោះការបង្រៀននូវការបដិបត្តិ ឲ្យបាន ហ្មត់ចត់ពិតប្រាកដ ។ អាត្មាយល់ឃើញថា បើព្រះសង្ឃ បដិបត្តិល្អបានតែបី ក៏អាចប្រើការបាន គឺបដិបត្តិ ការចេះ ដឹងជាខទី ១, ការប្រព្រឹត្តិជាខទី ២ និងចេះផ្សព្វផ្សាយអំពើ ល្អជាខទី ៣ ។

# សាសនពិធី

បទកាកគតិ

ព្រះពុទ្ធសាសនា ចាត់ជាមាគ៌ា និងពិធីមាន
ឲ្យពុទ្ធបរិស័ទ បដិបត្តិហាត់រៀន កុំថាដៅស្មាន
ខានខូចខុសន័យ ។
មានពិធីកម្ម ទុកឲ្យចំណាំ ចាំគ្រប់សម័យ
វន្ទានមស្ការ ព្រះរតនត្រ័យ បានភ្ជាប់និស្ស័យ
ត្រៃសរណគមណ៍ ។
មានសីលភាវនា សក្ការបូជា ហត្ថាប្រណម្យ
កាយវាចាចិត្ត ប្រព្រឹត្តអប់រំ ទាំងក្មេងចាស់ទុំ
ខិតខំសិក្សា ។
ឲ្យបានដឹងយល់ បញ្ញាចូលដល់ ខ្លឹមពុទ្ធសាសនា
គឺសីលសមា ធិនិងបញ្ញា នេះទើបឈ្មោះថា
ប្រតិបត្តិត្រូវចំ ។
មាគ៌ាព្រះពុទ្ធ ប្រសើរបំផុត ពិតឥតច្រឡំ
បដិបទា ជាគ្រឹះរឹងមាំ ធម្មនាវានាំ
ដល់ត្រើយសុខសាន្ត ៕

ដោយឧបាសក ម៉ិញ សារ៉ាន

# ៣០. បញ្ញា សីល សមាធិ

- ខ្ញុំករុណាយល់ថា លោកម្ចាស់ពន្យល់រឿងរ៉ាវផ្សេងៗ បានល្អ មានហេតុមានផលជាងគិត្តផងទៅទៀត ដែលខ្ញុំករុណា បានជួបប្រទះមក, ប៉ុន្តែមិញ ពេលឡើងដោយកិរិយាបង្ហាញ នូវការជ្រះថ្លាខុសពីកាលមកដល់ដំបូង, ខ្ញុំករុណាចង់ជួបព្រះ សង្ឃដូច្នេះមកយូរហើយ ប៉ុន្តែមិនបានជួបសោះ ខ្ញុំករុណា មានបញ្ហាខាងសាសនាច្រើនយ៉ាងដែរ ចង់សួរតែសួរ នរណាមិនដែលបានទទួលនូវចម្លើយក្បោះក្បាយសោះ ខ្ញុំ ករុណាសូមសួរព្រះអង្គ តើយ៉ាងណាដែរទាន?

- អាត្មាមិនថាអីទេ នឹងឆ្លើយនូវសំណួររបស់ញោម ប៉ុន្តែពាក្យឆ្លើយរបស់អាត្មាមិនច្បាស់ខ្លះ មានន័យថាមិនសូវ ក្បោះក្បាយ ខ្លាចក្រែងធ្វើឲ្យញោមមិនពេញចិត្ត តើមាន រឿងអ្វីសូមសួរមកចុះ!

- ខ្ញុំករុណាសូមសួរចំពោះលោកម្ចាស់ផ្ទាល់តែម្តង តើ លោកម្ចាស់ មានបំណងដូចម្តេចទើបចេញមកបួសជាភិក្ខុ សង្ឃដូច្នេះទាន?

- អាត្មាមិនមានការប្រាថ្នាអ្វីពិសេស ខុសពីការប្រាថ្នា របស់មនុស្សទាំងឡាយក្នុងលោក មនុស្សក្នុងលោកមាន នាទីការងារខុសៗគ្នា អ្នកខ្លះធ្វើគ្រូ អ្នកខ្លះធ្វើស្រែ ហើយធ្វើ កិច្ចការផ្សេងៗខុសៗគ្នាជាច្រើន ៗ សរុបមកអ្នកទាំងនោះ មានការប្រាថ្នាដូចៗគ្នា អាត្មាជាលោកសង្ឃក៏មានការប្រាថ្នា

ដូចមនុស្សឯទៀតស្មើៗគ្នាដែរ ។ បើសិនជាខុសគ្នា គឺខុសត្រង់គោលដៅដែលដើរឆ្ពោះទៅនោះ ពីព្រោះអាត្មាដើរតាមផ្លូវលោកសង្ឃ ញោមវិញដើរផ្លូវខាងគ្រូ អ្នកឯទៀតៗរើសយកផ្លូវជាកសិករ លក់ដូរ តែគ្រប់គ្នាឆ្ពោះទៅដល់ចំណុចគោលដៅដូចគ្នា

នាងស្រីទាំងពីរសម្លឹងមើលមុខគ្នាដោយឆ្ងល់ ហើយប៉ុណ្ណារិម៉ាបានសួរឡើងថា៖

- លោកម្ចាស់មានន័យយ៉ាងម៉េចនឹងទាន ខ្ញុំកូណានៅតែមិនទាន់យល់សោះ ការបួសជាព្រះសង្ឃ និងជាគ្រូ អ្នកជំនួញ កសិករ មានការប្រាថ្នាដូចគ្នាបានយ៉ាងណា ?

- បើដូច្នេះ អាត្មាត្រូវត្រឡប់ទៅជាអ្នកសួរញោមមុនសិន ការដែលញោមជាគ្រូបង្រៀន តើមានការប្រាថ្នាយ៉ាងណា ?

ប៉ុណ្ណារិម៉ាអង្គុយគិតយ៉ាងយូរតែម្តង គេប្រហែលដូចជនដទៃដែលភាគច្រើនមិនដឹង មិនយល់ មិនដែលបានគិតថាចំណុចដែលប្រាថ្នារបស់ជីវិតគឺជាស្អី ធ្វើដូចម្តេចទើបនឹងទៅដល់ចំណុចនោះ ។ គ្រាន់តែថាចេះតែធ្វើដដែលៗមួយថ្ងៃទៅមួយថ្ងៃ តាមហេតុការណ៍ទៅតាមទំនៀមទម្លាប់ប្រពៃណីរបស់មនុស្សលោករហូតដល់ពេលវេលា ហើយក៏ស្លាប់ទៅ ។

- សូមញោមឆ្លើយចេញមកតែម្តងពីការពិត, អាត្មាតឿនគេម្តងទៀត, យើងនិយាយគ្នាត្រង់ទៅត្រង់មកបែបបណ្ឌិត ដោយមិនចាំបាច់អៀន ឬខ្លាចអាក្រីទេ និយាយ

ជាមួយលោកសង្ឃដូចជាអាត្មានេះ មិនមានពិស មិនមាន
ភ័យអ្វីទាំងអស់

- ការដែលជាគ្រូបង្រៀន គឺជាមុខរបរការងារមួយ
ដែលទទួលបានមកវិញជាប្រាក់ការ និយាយដោយងាយៗ
គឺប្រាក់ខែនោះឯង បើនឹងនិយាយគ្រូបង្រៀនមានបំណង
ប្រាថ្នាដើម្បីឲ្យបានប្រាក់ខែ ក៏មិនខុសដែរ, គេឆ្លើយដូចជា
មិនសូវប្រាកដប្រជាក្នុងចិត្តរបស់ខ្លួនដែរ

- មិនខុស ហើយក៏មិនត្រូវទាំងស្រុងផងដែរ ពីព្រោះ
ប្រាក់គ្រាន់តែជាជណ្ដើរតាំទី ២ ប៉ុណ្ណោះឯង មិនមែនជាតាំ
ក្រោមបំផុតនោះទេ ។ អាត្មាចង់ដឹងថា ញោមបានប្រាក់ខែ
មកហើយ យកទៅធ្វើអ្វីទៀត សូមកុំយល់ថា អាត្មា
សាកសួរដេញដោលដូចជាកូនក្មេង ពីព្រោះត្រូវចាំបាច់
សាកសួរ ទៅដល់ចម្លើយដែលញោមចង់ដឹង

- បានប្រាក់មកហើយ ក៏នាំទៅទិញរបស់ប្រើប្រាស់
ដែលចាំបាច់ក្នុងជីវិតផ្សេងៗដូចជា អាហារ សំលៀកបំពាក់
ទីស្នាក់អាស្រ័យ ថ្នាំកែរោគជាដើម ដែលគេហៅថាបច្ច័យ៤
នោះឯងលោកម្ចាស់

- ញោមឆ្លើយបានត្រឹមត្រូវល្អណាស់ ពេលនេះយើង
មកដល់ជណ្ដើរជាន់ទី ៣ ហើយ ជាន់ទី ១ ជាគ្រូបង្រៀនជាន់
ទី ២ បានប្រាក់ខែ និងជាន់ទី ៣ បច្ច័យបួន អាត្មាចង់សួរទៅ
ទៀតថា ញោមយកបច្ច័យបួនមកធ្វើអ្វី ?

- យកមកបរិភោគ មកប្រើប្រាស់នោះឯង ! ប៉ុណ្ណិម៉ា
ឆ្លើយតបភ្លាម

- អាត្មាសូមសួរបញ្ហាមួយទៀតតែប៉ុណ្ណោះ ហើយចម្លើយដែលញោមត្រូវការនឹងបាននឹងហើយដែរ អាត្មាសួរងាយៗថា ដូចម្ដេចបានជាត្រូវបរិភោគ ត្រូវប្រើប្រាស់ បើកុំបរិភោគ កុំប្រើប្រាស់មិនបានទេឬ?

នាងស្រីទាំងពីរនាក់សើចឡើងព្រមគ្នា ហាក់បីដូចជាសំណួររបស់អាត្មាល្ងង់គួរឲ្យចង់សើច ។ ការពិតរបស់ដែលល្ងង់ៗងាយៗ ដែលមនុស្សតែងនឹងសម្លឹងរំលងទៅនោះ អាចនឹងជាសេចក្ដីពិតដែលមានតម្លៃ ។

- ពីព្រោះវាឃ្លាន បើមិនបរិភោគអាហារទេ ក៏ត្រូវស្លាប់តែប៉ុណ្ណោះ, នាងស្រីនោះឆ្លើយតបមកវិញ

- ញោមឆ្លើយនេះ ត្រឹមត្រូវតាមការពិតមែនហើយ ល្អហើយចុះ ផ្លូវនេះយើងមកដល់ជណ្ដើរជាន់ទី ៤ ដែលជាជាន់កំពូលបំផុតហើយ តែមុននឹងអាត្មាបង្ហាញឲ្យញោមឃើញចំណុចប្រាថ្នារបស់ជីវិតគឺជាអ្វីពិតប្រាកដ ។ អាត្មាចង់សួរពាក្យងាយៗមួយខទៀតថា នៅពេលញោមកំពុងឃ្លាននោះញោមទទួលនូវសេចក្ដីសុខ ឬសេចក្ដីទុក្ខ?

- មានសេចក្ដីទុក្ខ! ដួងកែវឆ្លើយជំនួស ប៉ុណ្ណារ៉ា ដែលសម្ដែងឫកពាឆ្ងល់

- បើដូច្នោះ ការដែលញោមបរិភោគអាហារនោះសេចក្ដីប្រាថ្នា ដើម្បីរម្ងាប់សេចក្ដីទុក្ខ គឺសេចក្ដីស្រេកឃ្លានមែនឬទេ?

- និយាយយ៉ាងនេះក៏ដូចគ្នាទាន, ប៉ុណ្ណារ៉ា ឆ្លើយ

- ល្អហើយចុះ! ដល់ពេលដែលអាត្មាពន្យល់ប្រាប់នូវ

ចំណុចរបស់អាត្មា និងរបស់អ្នកទាំងអស់គ្នាក្នុងលោក ហើយ ។ ចំណុចដែលមនុស្សគ្រប់គ្នាក្នុងលោក ក្នុងលោកដទៃផង គឺសេចក្ដីរំលត់ទុក្ខ គេបានដឹងខ្លួន ឬមិនដឹងក៏មិនជាអ្វីទេ គ្រប់គ្នាមានសេចក្ដីទុក្ខពេញណែននៅក្នុងខ្លួន ទុក្ខផ្លូវកាយក៏មាន ផ្លូវចិត្តក៏មាន ទុក្ខដូចជាការទុក្ខសោក ការឈឺដែលកើតមក ពីក្ដៅ ត្រជាក់ ឃ្លាន ស្រេក ឈឺបត់ជើងធំ ឈឺបត់ជើងតូច ឈឺអវយវៈផ្សេងៗ កើតរោគផ្សេងៗមកបៀតបៀន កើតដោយសារការប្រែប្រួល របស់ធាតុអាកាសកើតពីជំងឺ ភាពក្រីក្រអត់ឃ្លាន ដោយសារការចិញ្ចឹមជីវិតខ្លួនឯង និងមនុស្សជាទីស្រឡាញ់ ទុក្ខព្រួយដូចជាសេចក្ដីសោកសៅ ខូចចិត្ត ស្ដាយស្រណោះ ព្រាត់ប្រាសពីមនុស្សជាទីស្រឡាញ់ ពីព្រោះត្រូវជួបមនុស្សដែលខ្លួនស្អប់ ប្រាថ្នារបស់ណាមិនបានដូចសេចក្ដីប្រាថ្នា សេចក្ដីក្ដៅក្រហល់ក្រហាយចិត្ត ពីព្រោះត្រូវភ្លើង គឺសេចក្ដីស្រឡាញ់ សេចក្ដីលោភ សេចក្ដីប្រកាន់ សេចក្ដីក្រោធខឹង ការច្រណែនឈ្នានីស ការព្យាបាទ ចងអាឃាត ។ល។ ជាដើម ចមដុតបំផ្លាញចិត្តថ្លើមឲ្យភ័យ ខ្វល់ ខ្វាច ភ្ញាក់ផ្អើល ពីព្រោះលាភ យស សរសើរ ការប្រជែងប្រណាំងយកឈ្នះ យកចាញ់គ្នា នឹកឃើញនូវសេចក្ដីអាក្រក់ ដែលខ្លួនបានធ្វើហើយកាលពីមុនមក ។ សេចក្ដីឈឺចាប់ មិនសប្បាយចិត្ត ភ័យព្រួយ ខ្វល់ខ្វាយ ពីព្រោះសេចក្ដីចាស់ ជរា និងសេចក្ដីស្លាប់ សេចក្ដីទុក្ខផ្សេងៗទាំងអស់នោះ មកយាយីបំផ្លាញដល់មនុស្សគ្រប់ពេលវេលាគ្មានទំនេរសោះឡើយ ។ ជីវិត

របស់យើង ប្រៀបដូចជាទូកដែលកំពុងត្រូវភ្លើងទុក្ខដុត បំផ្លាញជានិច្ចគ្រប់ពេលវេលា ។

អាត្មាឈប់សម្រាកមួយសម្ទុះ ដើម្បីបើកឱកាសឲ្យនាងស្រីទាំងពីរបានគិត គេទាំងពីរនាក់ងកងស្ញើមធំៗ ហើយអន្ដុយឈ្ងោកមុខគិតបង្ហាញឲ្យឃើញថា មិនសូវសប្បាយចិត្តចេញមកឲ្យឃើញច្បាស់តែម្ដង ៗ

- រឿងរបស់ទុក្ខ មិនមាននរណាចូលចិត្តទេ មិនមាននរណាចង់ជួបទេ ៗ សូម្បីតែឈ្មោះក៏មិនចង់ឮ ពេលឮធ្វើឲ្យចិត្តមិនសប្បាយ សូម្បីយើងចូលចិត្ត ឬមិនចូលចិត្ត ទុក្ខក៏គង់នៅពេញលេញក្នុងជីវិតរបស់យើង ពីព្រោះជាអរិយសច្ច ដែលមានទុក្ខពេញខ្លួនយ៉ាងពិតប្រាកដ មិនថាយើងស្គាល់វា ឬមិនស្គាល់នោះទេ ៗ មនុស្សល្ងង់តែងស្អប់ និងខ្លាចទុក្ខ រួចក៏ខំកែប្រែទុក្ខ ដោយវិធីធ្មេចភ្នែក ហើយបញ្ឆោតថាទុក្ខមិនមាន អ្នកឆ្លាតអាចបើកភ្នែក ប្រឈមមុខជាមួយនឹងទុក្ខយ៉ាងអង់អាច ហើយព្យាយាមតស៊ូជាមួយវាគ្រប់វិធី លុះត្រាតែទុក្ខនោះរំលត់បាត់ទៅ

- សេចក្ដីទុក្ខជាបញ្ហាដ៏ធំចំពោះមនុស្សគ្រប់រូប ដោយសារបានយល់នូវរឿងនេះបានល្អហើយ ទើបព្យាយាមរំលត់ទុក្ខគ្រប់គ្នា កិច្ចការគ្រប់យ៉ាង ដែលមនុស្សធ្វើគ្រប់គ្នា គ្រប់ពាក្យដែលមនុស្សនិយាយ គ្រប់រឿងដែលមនុស្សគិត បើស៊ើបសួរទៅ លុះត្រាដល់ទីបំផុតហើយ ក៏រកផ្លូវរំលត់នូវទុក្ខប៉ុណ្ណោះឯង ៗ ញោមជាគ្រូក៏ពីព្រោះរំលត់ទុក្ខ អ្នកផ្សេងៗជាកសិករ ជាអ្នកជំនួញក៏ដូចគ្នា ដូច្នេះទើបអាត្មា

ពោលហើយតាំងពីដំបូងថា ការប្រាថ្នាសំខាន់របស់មនុស្ស
គ្រប់គ្នាក្នុងលោកគឺ **រំលត់សេចក្ដីទុក្ខ**

អាត្មាឈប់មួយរយៈ, ខ្លួនកែវងគងង្អើមធំ ហើយក៏
ពោលឡើងថា៖

- នេះមិនមែនជាការមើលជីវិតក្នុងផ្លូវអាក្រក់ពេកទេឬ
ពីព្រោះ តែលបានសង្កេតមើលយល់ថា មនុស្សទូទៅមាន
សេចក្ដីទុក្ខគ្រប់ៗគ្នា

- មុននឹងគាត់សេចក្ដីថា ជាការមើលជីវិតក្នុងផ្លូវអាក្រក់
ឬផ្លូវល្អ អាត្មាចង់សួរញោមជាមុនសិនថា សេចក្ដីទុក្ខ
ផ្សេងៗ ដែលអាត្មាពោលមកនោះមានមែនឬទេ ?

- មានពិតមែនហើយទាន តែសេចក្ដីសុខក៏មានដូចគ្នា
ដែរ

- សេចក្ដីសុខដែលញោមថាមាននោះគឺអ្វី ? សូមមេត្តា
ញោមពោលត្រួសៗ ឲ្យអាត្មាស្ដាប់ផងមកមើល៍

- ដូចជាយើងឈឺមិនស្រួល តែពេលបានជាពីឈឺ
ហើយយើងក៏មានសេចក្ដីសុខ ៗ យើងឃ្លានអាហារពេល
បានទទួលទានអាហារឆ្អែតហើយ ក៏មានសេចក្ដីសុខ ៗ
យើងចង់បានសំលៀកបំពាក់ស្អាតៗ ពេលបានមកហើយ ក៏
សប្បាយចិត្ត បើដូច្នេះពោលថាមិនមានសេចក្ដីសុខសោះ
ដូចម្ដេចនឹងកើត

- អាត្មាមិនបានពោលថា មិនមានសេចក្ដីសុខនោះទេ
សុខមានប្រាកដដូចញោមបានពោលមកនេះត្រូវហើយ តែ
សេចក្ដីសុខ ដែលញោមលើកមកជាភស្ដុតាងឲ្យស្ដាប់មក

នេះ មើលទៅដូចជាផលពីការរំលត់ទុក្ខទៅ ដូចជាការឃ្លានជាទុក្ខ នៅពេលទទួលទានអាហារឆ្អែត សេចក្ដីឃ្លានក៏បាត់ទៅ យើងក៏បានទទួលនូវសេចក្ដីសុខខ្លះទៅ ។ ការឈឺចាប់ជាទុក្ខ នៅពេលបានព្យាបាលជាសះស្បើយ សេចក្ដីឈឺចាប់ក៏បាត់ទៅ យើងក៏បានសេចក្ដីសុខ ។ ការចង់បានសំលៀកបំពាក់ក៏ជាទុក្ខ ពីព្រោះធ្វើឲ្យចិត្តខ្វល់ខ្វាយ ពេលបានសំលៀកបំពាក់ដូចប្រាថ្នាហើយ ការចង់បានក៏រំលត់ទុក្ខទៅ ការរីករាយក៏កើតឡើង ។ ផលដែលបណ្ដាលកើតឡើងមកដោយខ្លួនឯង នៅពេលសេចក្ដីទុក្ខរំលត់ទៅ មិនមែនជាការសាងសេចក្ដីសុខទេ តែជាការរំលត់សេចក្ដីទុក្ខបានមួយគ្រា ដរាបណាយើងនៅមានទុក្ខ យើងមិនអាចកើតនូវសេចក្ដីសុខបានឡើយ ។ បើយើងរំលត់ទុក្ខបានសុខក៏កើតឡើងឯង ដូច្នេះទើបលោកបង្រៀននូវរឿងទុក្ខនិងវិធីរំលត់នូវទុក្ខ ច្រើនជាងការបង្រៀនពីសេចក្ដីសុខ និងវិធីសាងនូវសេចក្ដីសុខ អាត្មានឹងប្រៀបធៀបឲ្យឃើញយ៉ាងនេះ សន្មតថាយើងមានសំពត់កខ្វក់មួយផ្ទាំង យើងមិនចូលចិត្ត យើងស្អប់ស្អោកគ្រោក ។ យើងត្រូវការស្អាត តើយើងធ្វើដូចម្ដេចឲ្យសំពត់នោះស្អាត យើងគួរទៅរករបស់ស្អាតៗយកមកដាក់ក្នុងសំពត់នោះ ឬថាគួរយកទៅបោកគក់ពីភាពកខ្វក់នោះចេញភ្លាម ដោយមិនចាំបាច់គិតយករបស់ស្អាតមកដាក់ក្នុងសំពត់នោះទេ ពីព្រោះនៅពេលយើងបោកគក់ភាពកខ្វក់នោះក៏ជ្រះអស់ហើយ ភាពស្អាតក៏កើតឡើងឯងដោយមិនបាច់ទៅរកពីទីណា ។ ដូច្នេះបញ្ហា

ចំពោះមុខរបស់យើង គឺវិធីរំលត់ទុក្ខមិនមែននៅត្រង់ការ
កសាងសេចក្តីសុខដូចជាមនុស្សលោកយល់ខុស គិតថា
សេចក្តីសុខជារបស់ដែលបង្កើតឡើងបាន ។ ទើបរកផ្លូវ
កសាងសេចក្តីសុខ ខំនាំគ្នាស្វែងរកសេចក្តីសុខ តែនៅ
ពេលខំសាងនូវសេចក្តីសុខច្រើន ទុក្ខក៏កាន់តែច្រើនឡើង
ពីព្រោះសេចក្តីទុក្ខមាននៅសល់ ប្រៀបដូចយកម្សៅពណ៌
សមកលាយកប់សាកសព ដែលកំពុងស្អុយមិនអាចធ្វើឲ្យ
សាកសពនោះបាត់ក្លិនបានឡើយ ។ ចំណែកជីវិតក្នុងផ្លូវ
អាក្រក់ ឬផ្លូវល្អនោះអាស្រ័យទៅលើមនុស្ស ពីព្រោះល្អ ឬ
អាក្រក់មិនមែននៅលើរបស់អស់ទាំងនោះទេ ។ ប៉ុន្តែស្ថិត
នៅលើទស្សនៈរបស់អ្នកមើល ដែលព្រះពុទ្ធសាសនា
បង្រៀនឲ្យមើលនូវសេចក្តីទុក្ខ មិនមែនឲ្យមើលផ្នែកអាក្រក់
មិនមែនឲ្យមើលផ្នែកល្អ តែឲ្យមើលតាមការពិតដែលកំពុង
មាន ឲ្យមើលនូវការបដិបត្តិ ដើម្បីឲ្យស្គាល់នូវទុក្ខ និង
ឃើញផ្លូវរំលត់នូវទុក្ខ

ប៉ុណ្ណិម៉ា ដែលអង្គុយស្ងៀមមកយូរហើយ ពោល
ឡើងថា៖

- បើចំណុចប្រាថ្នារបស់ជីវិត គឺការរំលត់ទុក្ខ ហើយបើ
ការងារគ្រប់យ៉ាងជាផ្លូវ រំលត់ទុក្ខដូចគ្នា បើដូច្នេះម្តេចបានជា
ចាំបាច់បួសជាភិក្ខុធ្វើអ្វី ?

- ការងារគ្រប់យ៉ាងមានគោលបំណង ដើម្បីរំលត់ទុក្ខ
ក៏ពិតមែន ប៉ុន្តែការរំលត់ទុក្ខបែបគ្រហស្ថជាការរំលត់ទុក្ខ
ម្តងមួយគ្រាប៉ុណ្ណោះ គឺពេលទុក្ខឆ្ងន់ឲ្យមកជាស្រាល ដូចជា

ពេលឃ្លានបានបរិភោគ ចង់បាន ចង់មាន ចង់អ្វីៗ ក៏ខំព្យាយាមរករបស់នោះមកបំពេញចំណង់ ។ បើគាលណារកមកមិនបាន ទុក្ខក៏កើនឡើង បើរកបានរបស់ដែលត្រូវការនោះបាន ក៏ជាសុខមួយរយៈ រួចហើយការចង់បានក៏កើតឡើងម្ដងទៀត ត្រូវរករបស់ដែលចង់បានមកទៀត ធ្វើដូច្នេះតាំងតែពីកើតរហូតដល់ស្លាប់ ។ ទីបំផុត ក៏មិនអាចបំពេញសេចក្ដីត្រូវការនោះបាន ត្រូវស្លាប់ដោយសេចក្ដីអត់ឃ្លាន ការរំលត់ទុក្ខបែបគ្រហស្ថដូចជា ការរោះស្រែងពេលរមាស់ឡើង រោះរមាស់ក៏បាត់ទៅ ប៉ុន្តែមិនយូរប៉ុន្មានក៏រមាស់ទៀត ត្រូវរោះទៀត រោះរហូតដល់ស្លាប់ទៅជាមួយគ្នា ។ ប៉ុន្តែការរំលត់ទុក្ខរបស់តថាគតនៃយើង ជាបែបរំលត់នូវឫសគល់សេចក្ដីទុក្ខ ពីការចង់បាន ជាការព្យាបាលរោគស្រែងឲ្យជាសះស្បើយតែម្ដង ដោយមិនបាច់រោះតទៅទៀត អាត្មាចូលចិត្តវិធីរំលត់ទុក្ខបែបព្រះបរមគ្រូ ទើបបានជ្រើសយកជីវិតតាមផ្លូវរបស់ព្រះសម្មាសម្ពុទ្ធ

- ក្នុងការរំលត់ទុក្ខបែបព្រះពុទ្ធគុណម្ចាស់ ត្រូវបដិបត្តិយ៉ាងណាខ្លះ ?

- ត្រូវបដិបត្តិតាមគោល គឺ **សីល សមាធិ** និង**បញ្ញា** ត្រូវរក្សា**សីល ២២៧** យ៉ាងច្បាស់ពិតប្រាកដ ពីព្រោះ**សីល ២២៧** ជាគ្រឿងធ្វើឲ្យមនុស្សក្លាយជាព្រះសង្ឃ បើរក្សា**សីល ២២៧** មិនបានគ្រប់បរិបូរណ៍ ក៏ទៅជាព្រះសង្ឃមិនបរិបូរណ៍ដែរ ដូច្នេះ គោលបដិបត្តិសម្រាប់ព្រះសង្ឃត្រូវចាប់ផ្ដើមដោយមានសីលជាមុន បន្ទាប់មកទៀតបដិបត្តិ**សមាធិ** ធ្វើចិត្តឲ្យ

ស្ងប់រម្ងាប់ជាកម្មដ្ឋាន ដើម្បីជម្រះចិត្តឲ្យបានបរិសុទ្ធចាកនីវរណធម៌ និងកិលេសខ្នាតកណ្ដាលផ្សេងៗ ។ ចុងក្រោយគឺបញ្ញាបរិសុទ្ធកើតឡើង ដើម្បីបណ្ដោញនូវ**អវិជ្ជា** **តណ្ហា** **ឧបាទាន** ដែលជាឫសនៃសេចក្ដីទុក្ខឲ្យអស់ផុតចេញទៅ

- ចំណែកគ្រហស្ថ ត្រូវចាប់ផ្ដើមតាមគោល**អរិយមគ្គអង្គ ៨** គឺចាប់ផ្ដើមពី**បញ្ញា**ជាមុន ហើយទើបដល់**សីល** និង **សមាធិ** តាមលំដាប់ តែ**បញ្ញា** ក្នុងអរិយមគ្គគ្រាន់តែសេចក្ដីឃើញ ឬ ទស្សនៈគតិដែលត្រូវកើតពីការ ស្ដាប់ ការគិតពិចារណាប៉ុណ្ណោះ មិនមែនបញ្ញាថ្នាក់ញាណ ដែលជាបញ្ញាថ្នាក់ខ្ពស់ កើតក្រោយពីធ្វើសមាធិបានបរិបូរណ៍ដល់កម្រិតនោះទេ ។ ដូច្នេះមុនដំបូង គ្រហស្ថដែលគោរពកាន់សាសនាព្រះពុទ្ធ ត្រូវស្ដាប់ឲ្យបានច្រើន អានច្រើន គិតពិចារណាច្រើនៗ លុះត្រាកើតសម្មាទិដ្ឋិ ឬទស្សនៈគតិឲ្យបានត្រឹមត្រូវក្នុងជីវិត...

# ក្រពះតណ្ហា

បទពាក្យ៨

ក្រពះតណ្ហាធំហួសស្រមៃ ពេលបានឆ្អែតផ្ទៃស្ងៀមមួយសន្ទុះ
បន្តិចក្រោយមកម្ទីម្ទាស្ទាស្ទុះ ផុះស៊ី ស៊ីផុះពោះមិនបាត់ឃ្លាន ។
មាត់ទ្វារប្រាំមួយនាំព្រួយក្រៃក្រាស់ ស៊ីណាស់ឃ្លានណាស់បំបះគម្លាន
ត្រូវក្ដិចបំបាក់ត្រួយឧបាទាន ទើបអាចសុខសាន្តក្សេមក្សាន្តកាយចិត្ត៕

ដោយឧបាសក ហ៊ិម ឆាន់

# ព្រះពុទ្ធដីកា

បទពាក្យ៧

| | | |
|---|---|---|
| ព្រះធម៌ជាព្រះពុទ្ធដីកា | ព្រះអង្គទេសនាមានគ្រប់គ្រាន់ | |
| ប្រាំបីម៉ឺនបួនពាន់ធម្មក្ខន្ធ | ពុទ្ធបរិស័ទកាន់តាមលំអាន | ។ |
| ជាន័យពិស្តារចារប្រាកដ | ទៅតាមកំណត់បែបបទមាន | |
| វិន័យព្រះសូត្រអភិធម្មបាន | ជាច្បាប់ទូន្មានតាមនិស្ស័យ | ។ |
| តែបើសម្តែងដោយសង្ខេប | បំព្រួញជាបែបបញ្ចោក់ខ្លី | |
| ងាយស្រួលចំណាំចាំយប់ថ្ងៃ | ទៅតាមនិស្ស័យនៃសព្វសត្វ | ។ |
| គឺសីលសមាធិបញ្ញា | ទាំងអស់គ្រប់គ្នាត្រូវរៀនហាត់ | |
| ទន្ទេញសូត្រអានឲ្យបានស្ទាត់ | បដិបត្តិប្រាកដតាមមាគ៌ា | ។ |
| រំដោះកាយចិត្តចាកវដ្ដៈ | ដែលជាអន្ទាក់ពពួកមារ | |
| គឺខន្ធភារៈអវិជ្ជា | មោហៈអន្ធការនាំវង្វេង | ។ |
| ធ្វើដំណើរត្រូវផ្លូវមជ្ឈិមា | អរិយមគ្គាមិនស្ដាំឆ្វេង | |
| ពន្លឺបញ្ញាចាំងចិញ្ចេង | យល់ច្បាស់ខ្លួនឯងអស់ចម្ងល់ | ។ |
| ឆ្លងផុតចាកភាពបថុជ្ជន | ជាអរិយជនព្រោះបានដល់ | |
| ក្នុងចិត្តប្រចក្សមគ្គនិងផល | ចាក់ធ្លុះយល់ស្គាល់ព្រះនិព្វាន | ។ |
| នេះទើបរួចផុតចាកអន្ទាក់ | កាត់ផ្ដាច់ច្រវាក់វដ្ដៈបាន | |
| រួចផុតចាកទុក្ខដែលធ្លាប់មាន | ទទួលដាក់បានបរមសុខពិត | ។ |
| ទិសដៅនៃព្រះពុទ្ធដីកា | គឺជាមាត្រាដុសខាត់ចិត្ត | |
| ជាពុទ្ធោវាទល្អប្រណីត | មាគ៌ាជីវិតចេញចាកទុក្ខ | ៕ |

ដោយឧបាសក ម៉ិញ សារ៉ាង

# ៣១. មនុស្សខ្លាចសាសនា

**ស្ត្រី**ទាំងពីរអង្គុយស្ងៀមគិតមួយសន្ទុះ ហើយ ឆ្លួនកែវបានពោលឡើងថា៖

- ខ្ញុំកូណាធ្លាប់បានឮ បានស្តាប់មកតាំងតែពីយូរយារ មកហើយថា គោលការបដិបត្តិរបស់អ្នកកាន់សាសនាព្រះ ពុទ្ធត្រូវចាប់ផ្តើមអំពីគោលធំៗ **សីល សមាធិ បញ្ញា** លុះត្រា ចាំបានស្ទាត់ ។ ខ្ញុំកូណាទើបតែបានឮពាក្យរបស់ព្រះគុណ ម្ចាស់នៅថ្ងៃនេះឯងថា ត្រូវរៀនចាប់ផ្តើមអំពីបញ្ញាជាមុន ទើបបានឈានទៅដល់សីល និងសមាធិទៅតាមលំដាប់ រាប់ថាជាសេចក្តីចេះដឹងថ្មី ដែលគួរយកចិត្តទុកដាក់មែន

- ការពិត មិនមែនជាការចេះដឹងថ្មីអ្វីទេ អាត្មានឹង អធិប្បាយនេះជាការចេះដឹងចាស់ទេ ដែលព្រះពុទ្ធអង្គទ្រង់ ត្រាស់សម្តែងទុកមកជា ២០០០ ឆ្នាំមកហើយ រួមទាំងអង្គ ៨ របស់អរិយមគ្គ បើបង្រួមមកគឺនៅសល់តែ ៣ អង្គប៉ុណ្ណោះ គឺការឃើញត្រូវនិងការយល់ត្រូវ ចាត់ជាបញ្ញា, វាចាត្រូវ និងការងារត្រូវ ចិញ្ចឹមជីវិតត្រូវ ចាត់ជាសីល, ព្យាយាមត្រូវ តាំងសតិត្រូវ តាំងចិត្តត្រូវ ចាត់ជាសមាធិ ។ បើបដិបត្តិតាម នេះអ្នកកាន់សាសនាព្រះពុទ្ធ ត្រូវដើរតាមគោលគឺ **បញ្ញា សីល សមាធិ** មិនមែន **សីល សមាធិ បញ្ញា** តាមដែលជន ទូទៅនាំគ្នាយល់នោះទេ

- បើដូច្នោះ ការដែលអ្នកកាន់សាសនាព្រះពុទ្ធចាប់

ផ្ដើមបដិបត្តិដោយការរក្សាសីល ក៏ជាការខុសទៅហើយ នាងប៉ុណ្ណារិម៉ា ពោលឡើងខ្លះ

- មិនខុសទេ! អាត្មាឆ្លើយតប តែមិនទាន់ត្រូវប្រាកដទេ ការពិតនោះ គោលព្រះធម៌គ្រប់យ៉ាងក្នុងព្រះពុទ្ធសាសនាជាអំពើល្អទាំងអស់ អ្នកណាចង់ចាប់ផ្ដើមអំពីស្អីមុនក៏បានដែរ ប៉ុន្តែការបដិបត្តិផ្សេងៗក៏ដោយ បើខ្វះសម្មាទិដ្ឋិជាដួងប្រទីបនាំផ្លូវហើយ តែងតែទៅជាសីលព្វតបរាមាសៈ គឺជាការកាន់សីលមិនច្បាស់ស្រពេចស្រពិល គ្រាន់តែជាពិធីការ ដូចជាអ្នកកាន់ព្រះពុទ្ធសាសនានៅក្នុងពេលនេះ ក៏កាន់សីលព្វតបរាមាសៈ អ្នកខ្លះកាន់សីលទេវៈនិយម គឺយល់ចូលចិត្តថា ព្រះពុទ្ធអង្គជាព្រះអាទិទេពធំបំផុតនៅក្នុងអាកាស ចាំស្ដាប់នូវពាក្យបន់ស្រន់អង្វរករ ហើយចាំជួយថែរក្សាជនអ្នកកាន់ព្រះពុទ្ធសាសនា អ្នកខ្លះក៏កាន់សីលវិញ្ញាណនិយម គឺយល់ចូលចិត្តថាមានវិញ្ញាណដែលស័ក្ដិសិទ្ធិ ហៅថាពុទ្ធានុភាពចូលនៅក្នុងព្រះពុទ្ធរូប នៅចាំស្ដាប់ពាក្យគ្រាបសំពះអង្វរ និងការរាប់រៀបរបស់អ្នកកាន់ព្រះពុទ្ធសាសនា ហើយនឹងជួយបានដូចបំណង ។ អ្នកខ្លះកាន់សីលសៃយសាសន៍ ជឿថាមានអំណាចស័ក្ដិសិទ្ធិ លាក់កំបាំងនៅក្នុងព្រះពុទ្ធរូបសូម្បីអង្គតូច មានការផ្ដិតស្នោះដូចជាគ្រឿងស័ក្ដិសិទ្ធិទាំងឡាយ ។ មានមនុស្សតិចណាស់ ដែលគោរពព្រះរតនត្រ័យបានត្រឹមត្រូវពិតប្រាកដ នេះក៏ពីព្រោះខ្វះបញ្ញា គឺសម្មាទិដ្ឋិនោះឯង អ្នកដែលកាន់សាសនាព្រះពុទ្ធ ហើយខ្វះនូវសម្មាទិដ្ឋិនេះ នៅពេលរក្សាសីលក៏រក្សាគ្រាន់តែជាពិធី

វេលាព្រះសង្ឃលោកឲ្យសីល ក៏ធ្វើមាត់ជីបអូចតាមគេទៅ នៅពេលកំបាំងអំពីព្រះសង្ឃ ក៏ចាប់ផ្ដើមជប់លៀងសុរាគ្នា ជាការធំ នេះធ្វើដូចស្វាលីបលៗម្ចាស់វា នេះជាការមើលងាយព្រះពុទ្ធសាសនាតែម្ដង ។ អ្នកកាន់ព្រះពុទ្ធសាសនាដែលខ្វះសម្មាទិដ្ឋិ នៅពេលធ្វើបុណ្យឲ្យទាន តែងសង្ឃឹមថាផលនឹងឲ្យមកគេវិញ គឺសូមឲ្យរកស៊ីមានបាន មានទ្រព្យសម្បត្តិច្រើន ពេលធ្វើបុណ្យអ្វីបន្តិចបន្តួចតែងប្រាថ្នាឲ្យបានត្រូវឆ្នោត សូមឲ្យបានជួបគូស្រករល្អ ឲ្យឈ្នះក្ដីក្ដាំ សូមឲ្យបានកូនប្រុស ។ល។និង ។ល។ នៅពេលមិនបានសម្រេចដូចសេចក្ដីប្រាថ្នា ក៏នាំគ្នាយល់ថាធ្វើបុណ្យធ្វើអំពើល្អ មិនបានល្អ នេះក៏ពីព្រោះខ្វះសម្មាទិដ្ឋិនោះឯង ។ សម្មាទិដ្ឋិដូចជាភ្លើងបំភ្លឺផ្លូវដើរទៅក្នុងទីងងឹត អ្នកកាន់សាសនាព្រះពុទ្ធដែលមានភ្លើងបំភ្លឺគឺសម្មាទិដ្ឋិ មិនមានថ្ងៃនឹងដើរវង្វេងផ្លូវឡើយ ។ ដូច្នេះព្រះពុទ្ធអង្គទើបទ្រង់ត្រាស់ទុកមកថា ៖ នៅពេលដែលបុគ្គល មានសេចក្ដីយល់ឃើញថាត្រូវហើយ របស់គ្រប់យ៉ាងនិងត្រូវតាមមកទាំងអស់ ផ្ទុយទៅវិញ បើសិនជាយល់ឃើញខុស របស់គ្រប់យ៉ាងនិងខុសទៅតាមដូចគ្នាទាំងអស់ ។ អ្នកកាន់ព្រះពុទ្ធសាសនាភាគច្រើន នៅពេលនេះ នៅមិនទាន់មានភ្លើងបំភ្លឺ គឺសម្មាទិដ្ឋិតែថាបានចេញធ្វើដំណើរទៅក្នុងសេចក្ដីងងឹតទៅហើយ អ្នកខ្លះបានដើរទៅក្នុងផ្លូវសីល អ្នកខ្លះបានដើរទៅខាងផ្លូវទាន អ្នកខ្លះខាងផ្លូវភាវនា ប៉ុន្តែខំដើរទៅក៏គាន់តែជួបប្រទះនូវសេចក្ដីងងឹត ឯបំណាងទៅចុងផ្លូវនោះ ទោះបីនៅឯណាក៏មិនដឹង ។

នៅទីបំផុតក៏ត្រូវត្រឡប់ទៅដល់កន្លែងដើមវិញគឺ ខ្លួនអញរបស់អញ ។ ការបដិបត្តិផ្សេងៗសូម្បីនឹងនាំទៅដល់ទីដៅនៃព្រះពុទ្ធសាសនា ផ្ទុយទៅវិញទៅជារបស់ចិញ្ចឹមតណ្ហាឲ្យធាត់ធំឡើង នេះគឺជាផលនៃការខ្វះសម្មាទិដ្ឋិ ព្រោះដូច្នេះសម្មាទិដ្ឋិឬបញ្ញា ត្រូវមកមុនតាមគោលអរិយមគ្គដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ទុកមក យកបញ្ញាដាក់នៅខាងក្រោយនេះហើយទើបជារឿងរវល់

- ខ្ញុំកូណាយល់ព្រមតាមព្រះអង្គគ្រប់ប្រការ ! , ប៉ុន្ណោះម៉ាពោលឡើងក្រោយពីនៅស្ងៀមគិតអស់ពេលជាយូរ

- គួរនឹងនិយាយថា យល់ឃើញតាមព្រះពុទ្ធជាម្ចាស់ទើបត្រូវពិត ពីព្រោះរឿងនេះមិនមែនការយល់ឃើញរបស់អាត្មាទេ តែជាគោលដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ដាក់មកហើយ

- បានហើយទាន ! ខ្ញុំកូណាយល់តាមព្រះពុទ្ធអង្គ, ប៉ុន្ណោះម៉ាពោលញឹមៗ, តែនៅសង្ស័យខ្លះទៀតថា សម្មាទិដ្ឋិការយល់ត្រូវនោះគឺឃើញអ្វី? ឬឃើញដូចម្ដេច?

- ឃើញត្រូវនោះគឺ ឃើញអរិយសច្ច៤ ពោលគឺ៖ ឃើញសេចក្ដីទុក្ខ ជាសេចក្ដីទុក្ខពិត មិនមែនឃើញទុក្ខទៅជាសុខ ឬឃើញសុខទៅជាទុក្ខ ត្រូវឃើញនូវឫសគល់របស់សេចក្ដីទុក្ខ គឺសេចក្ដីចង់បានឬតណ្ហា មិនមែនទេវតា មេឃ ដី ព្រះចន្ទ គ្រោះកម្មផ្សេងៗ គឺត្រូវឲ្យឃើញថាទុក្ខជារបស់ដែលយើងអាចរំលត់បាន ដោយការព្យាយាមរបស់ខ្លួនយើង ត្រូវឃើញថា អរិយមគ្គមានអង្គប្រាំបី ជាផ្លូវតែមួយ

ប៉ុណ្ណោះ ដែលនឹងនាំទៅដល់ការរំលត់ទុក្ខ ។ ក្រៅពីអរិយ-មគ្គមានអង្គប្រាំបីហើយ មិនមានបុគ្គលឬរបស់ខាងក្រៅណា ដែលនឹងអាចជួយរំលត់ទុក្ខបានឡើយ មិនមានខ្មោចបិសាច ទេវតា បុគ្គលវិសេសមានមន្តអាគមណាមួយ មកជួយរំលត់ទុក្ខរបស់យើងបានទេ ពីព្រោះទុក្ខប្រៀបដូចជាការរមាស់ ដែលកើតអំពីរោគស្រែងរបស់យើងតែម្តងគឺយើងត្រូវព្យាបាលរោគស្រែងរបស់យើងឲ្យបានសះជាមុនសិន អាការៈរមាស់ទើបវិនាស់ អ្នកដទៃអាចជួយបានត្រឹមតែប្រាប់ថ្នាំតែប៉ុណ្ណោះ ។ បើនៅពេលរមាស់ឡើងមកហើយនឹងទៅលុនក្រាបសំពះអង្វរ ឲ្យរបស់ស័ក្តិសិទ្ធិមកជួយធ្វើឲ្យបាត់រមាស់នោះ មិនអាចមានផ្លូវសម្រេចបានឡើយ ។ ការដែលរម្ងាប់នូវសេចក្តីទុក្ខដោយមិនរំលត់នូវតណ្ហា ក៏មិនអាចរកផ្លូវទៅរួចជាដាច់ខាតដូច្នេះឯង ការឃើញអរិយសច្ច ៤ ដោយបញ្ញានេះហើយដែលហៅថាសម្មាទិដ្ឋិ

- តើត្រូវធ្វើយ៉ាងណាទៅ ទើបកើតសម្មាទិដ្ឋិ? ដូងដែរពោលឡើង

- អាត្មាបានពោលហើយថា សម្មាទិដ្ឋិឬបញ្ញា អាចនឹងកើតឡើងបាន ៤ ផ្លូវដូចគ្នាគឺ **សុតមយប្បញ្ញា** បញ្ញាដែលកើតឡើងអំពីការស្តាប់ ពុទ្ធសាសនិកជនត្រូវជាអ្នកចេះស្តាប់ឲ្យបានល្អ ជាអ្នកចូលចិត្តស្តាប់ ស្តាប់ធម៌ណើងផ្សេងៗស្តាប់ធម៌ ស្តាប់លោកបរិយាយរឿងផ្សេងៗ ស្តាប់នូវការសន្ទនាអំពីរឿងដែលនឹងធ្វើឲ្យឃើញអរិយសច្ច ។ អាត្មា

យល់ថាពុទ្ធបរិស័ទសម័យនេះ មិនសូវបានស្តាប់ប៉ុន្មានទេ ពិលាលោកសម្តែងព្រះធម៌ទេសនាឲ្យស្តាប់នៅវត្ត គឺមាន តែមនុស្សចាស់ៗទៅស្តាប់ ហើយមានមិនសូវច្រើនផង ។ ព្រះសង្ឃលោកឃើញដូច្នេះ ក៏គិតថាអ្នកស្រុកប្រហែលមិន មានពេលពិលាទៅស្តាប់នៅឯវត្ត លោកក៏ខំព្យាយាមទៅ ទេសនាតាមប៉ុស្តិ៍វិទ្យុ ដើម្បីឲ្យស្រួលបានស្តាប់នៅឯផ្ទះ ។ ប៉ុន្តែភាគច្រើន នៅតែមិនចង់ស្តាប់ដដែល នៅពេលគេ ប្រាប់ថា នឹងមានព្រះសង្ឃលោកសម្តែងព្រះធម៌ទេសនាតែ ប៉ុណ្ណោះ ក៏ប្រញាប់ប្រញាល់ប្តូរទៅបើកប៉ុស្តិ៍ដទៃផ្សេងវិញ ដើម្បីស្តាប់ភ្លេងខ្លះ ល្ខោនខ្លះ ។ បើមិនមានរាយការណ៍អ្វី ផ្សេងទេ គឺត្រូវតែបិទវិទ្យុទុកឲ្យព្រះសង្ឃទេសនាតែម្នាក់ឯ ងទៅ នៅពេលដូច្នេះ សម្មាទិដ្ឋិ ក៏មិនអាចកើតបានឡើយ

ក្នុងសម័យពុទ្ធកាល សៀវភៅមិនទាន់មានចេញ ផ្សាយ មនុស្សមានការចេះដឹងដោយការស្តាប់ដាដំបូង លោកបានពន្យល់ឲ្យស្តាប់តែម្យ៉ាងៗ ប៉ុន្តែនូវសម័យនេះ សៀវភៅមានច្រើន សុតមយប្បញ្ញាត្រូវតែកើតអំពីការអាន ផង ។ ពុទ្ធបរិស័ទត្រូវជាអ្នកចូលចិត្តអាន ហើយចូលចិត្ត មើលរឿងរ៉ាវដែលធ្វើឃើញច្បាស់នូវអរិយសច្ច ។ យល់ ថាពុទ្ធបរិស័ទរបស់យើង មិនសូវចូលចិត្តអានរឿងរ៉ាវដែល មានសារប្រយោជន៍ តែនៅមានចំណូលចិត្តអានខ្លះៗដែរគឺ អានរឿងកំប្លែង រឿងប្រលោមលោក រឿងរ៉ាវផ្សេងៗ និង ទស្សនាវដ្តីមានរូបភាព សារព័ត៌មានប្រចាំថ្ងៃ គឺលក់ដាច់ដូច ចាក់ទឹក បើជាសៀវភៅធម៌វិញ លក់មិនសូវដាច់ទេ ត្រូវ

បោះពុម្ពចែកឲ្យក្នុងពេលមានបុណ្យសព ឬពេលធ្វើបុណ្យទានផ្សេងៗ ហើយយកទៅទុកចោលទទេៗ ។ លុះដល់នៅពេលចាស់ជរាបន្តិច ឈឺញឹកញាប់ ចាប់ផ្ដើមរកទៅណារួចហើយនោះទើបយកមកអានខ្លះៗ នៅពេលអានចប់ហើយក៏ដល់ពេលឈឺ ហើយក៏ស្លាប់ល្មម...

នាងស្រីទាំងពីរនាក់សើចឡើងព្រមគ្នាហើយដួងកែវពោលឡើងថា៖

- ព្រះគុណម្ចាស់ចេះមានពីតាកំប្លែងផងទាន! ខ្ញុំករុណាគិតថាព្រះអង្គនឹងមានសម្ដីតាតែរឿងគោលៗ

- ពុទ្ធបរិស័ទរបស់យើង ធ្វើបែបនេះភាគច្រើន, អាត្មាអធិប្បាយបន្តទៅទៀត, ទើបទៅមិនបានឆ្ងាយ ក្រៅពីការស្ដាប់និងអានហើយ ពុទ្ធបរិស័ទត្រូវកសាង ចិន្តាមយប្បញ្ញា គឺសេចក្ដីចេះដឹងដែលកើតអំពីការគិត ។ ពុទ្ធបរិស័ទត្រូវជាមនុស្សចូលចិត្តគិតស្រាវជ្រាវ ចូលចិត្តពិចារណារកហេតុផលនូវរបស់ផ្សេងៗ នៅពេលអារម្មណ៍ផ្សេងៗបានចូលតាមភ្នែក តាមត្រចៀក តាមច្រមុះ ប៉ះត្រូវអណ្ដាត តាមផ្លូវកាយ និងផ្លូវចិត្ត ត្រូវយកមកគិតមកស្រាវជ្រាវរក កុំឲ្យវាកន្លងហួសទៅដោយឥតប្រយោជន៍ ។ ការពិតនោះរបស់ផ្សេងៗ ដែលយើងបានជួបប្រទះឃើញនៅរាល់ថ្ងៃនោះអាចឲ្យនូវការចេះដឹងដល់យើងបានយ៉ាងច្រើនបើយើងចេះគិត មើលតែព្រះពុទ្ធអង្គយើងចុះ មុនពេលត្រាស់ដឹងព្រះអង្គក៏ជាបុថុជ្ជននៅមានកិលេសនិងសេចក្ដីទុក្ខដូចយើងដែរតែក្រោយពីបានត្រាស់ដឹងហើយ ព្រះអង្គក៏ក្លាយទៅជា

អរិយបុគ្គល ប្រាសចាកកិលេសនិងទុក្ខ ទៅជាបរមគ្រូរបស់មនុស្សច្រើនជាង ២០០០ ឆ្នាំកន្លងមកហើយ តើញោមនឹងដែរឬទេថា ដំណើរជីវិតរបស់ព្រះអង្គ ចាប់ផ្តើមប្តូរពីមនុស្សធម្មតា ទៅជាជីវិតដ៏ប្រសើរចាប់ពីពេលណាដែរ ?

នាងស្រីទាំងពីរនៅស្ងៀម សម្លឹងមុខគ្នាអស់ពេលជាយូរ សម្តែងឲ្យឃើញថាមិនអាចឆ្លើយនូវសំណួររបស់អាត្មារូប ទើបអាត្មាពោលតទៅទៀតថា៖

- ញោមអាចភ្លេចនូវពុទ្ធប្រវត្តិហើយក៏បាន! អាត្មានឹងឆ្លើយដោយខ្លួនឯងវិញក៏បាន ។ ដំណើរជីវិតរបស់ព្រះពុទ្ធអង្គ ចាប់ផ្តើមប្រែប្តូរធំបំផុត នៅពេលព្រះអង្គនៅជាព្រះអង្គម្ចាស់ **សិទ្ធត្ថ** ។ នៅពេលមួយស្តេចបានយាងប្រពាតឧទ្យាន បានទតព្រះនេត្រឃើញមនុស្សចាស់ មនុស្សឈឺមនុស្សស្លាប់នៅក្នុងឧទ្យាននោះ ។ នៅពេលឃើញទិដ្ឋភាពទាំងបីនេះហើយ ព្រះអង្គមិនបានបណ្តោយឲ្យវាហួសទៅទេ តែទ្រង់បាននាំមកត្រិះរិះគិតពិចារណាប្រៀបធៀប នៅទីបំផុតក៏ទ្រង់ឃើញនូវអរិយសច្ចជាដំបូងគឺទុក្ខ ។ នៅពេលឃើញនូវសេចក្តីទុក្ខ ក៏កើតសម្មាទិដ្ឋិឡើងក្នុងព្រះហឫទ័យហើយសម្មាទិដ្ឋិនោះឯង បាននាំព្រះអង្គទៅដល់ការលះបង់យសវិសចេញ មកបំពេញព្យាយាមក្នុងនេក្ខម្មៈ ។ ហើយការត្រាស់ដឹងនៅទីបំផុត យើងម្នាក់ៗក៏ធ្លាប់ឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់មករាប់មិនអស់ តែយើងមិនបានគិតឲ្យបានច្បាស់ ឃើញហើយក៏ហួសទៅៗ ទើបយើងមិនកើតសម្មាទិដ្ឋិ ព្រោះដូច្នោះពុទ្ធបរិស័ទត្រូវរៀនជាអ្នក

ស្រាវជ្រាវពិចារណា តាមដែលបានឃើញមកដូចជាមិនសូវចង់គិតពិចារណានៅរបស់ណាជ្រៅៗ ចូលចិត្តតែរឿងណាងាយៗ ហើយសប្បាយរីករាយ ហ៊ឺហា មិនបាច់គិតអ្វីច្រើនបើដូច្នេះ បញ្ញា គឺ សម្មាទិដ្ឋិក៏មិនកើតដែរ ៗ អាត្មាយល់ឃើញថាពុទ្ធបរិស័ទដែលពិតប្រាកដនោះ ត្រូវជាអ្នកចូលចិត្តស្តាប់ ចូលចិត្តអាន ហើយជាអ្នកត្រិះរិះពិចារណាលុះត្រាកើតសម្មាទិដ្ឋិ នៅពេលកើតសម្មាទិដ្ឋិហើយ ទានសីល ភាវនាក៏នឹងអាចកើតមកដែរ ៗ បើនៅមិនទាន់កើតសម្មាទិដ្ឋិនោះទេ សូម្បីនឹងបំពេញ ទាន សីល ភាវនា ក៏នឹងគ្រាន់តែជាពិធីកម្ម ឬជាសីលព្វតបរាមាសតែប៉ុណ្ណោះ ៗ

- បើដូច្នេះ ការបដិបត្តិខាងផ្លូវព្រះពុទ្ធសាសនា មើលទៅដូចជាមិនពិបាកទេ? ប៉ុណ្ណឹងម៉ាពោលឡើង

- បើបដិបត្តិចាប់ផ្តើមដោយបញ្ញាជាមុន ដូចអាត្មាបាននិយាយមកនេះក៏មិនមានអ្វីឲ្យពិបាកសោះ ងាយជាងការឲ្យទាន និងការរក្សាសីលទៅទៀត ៗ ការឲ្យទានត្រូវមានចតុប្បច្ច័យ ត្រូវមានអ្នកឲ្យ អ្នកទទួល ចំណែករឿងរបស់សីលក៏ជារឿងមានខហាមឃាត់ផ្សេងៗ ហាមមិនឲ្យធ្វើរបស់នេះ មិនឲ្យនិយាយយ៉ាងនោះ ៗ តាមធម្មតាមនុស្សឃើញមិនសូវចូលចិត្តបទបញ្ញាហាមប្រាមនោះទេ បើខាងព្រះសង្ឃវិញនោះ មានការសំខាន់នៅការហាមគឺសីល អ្នកដែលចេះតិច និងការគិតមិនសូវយល់ ក៏នាំគ្នាយល់ថាសាសនាមិនមានស្អីទេ មានតែការហាមប៉ុណ្ណោះ ហើយក៏យល់ថា សាសនាជាគ្រឿងឃាត់ឃាំងសេរីភាពរបស់ខ្លួន

ធ្វើឲ្យខ្លាចភ័យនូវព្រះពុទ្ធសាសនា ហើយសូមចេញអំពីពុទ្ធសាសនា គិតថាសាសនាជាកិច្ចរបស់ព្រះសង្ឃ សាមណេរ ដូនជី និងមនុស្សចាស់ មិនរវល់នូវជីវិតរបស់ខ្លួនដោយប្រការណាមួយ អ្នកខ្លះបានយល់លើសពីនេះទៀតថា សាសនាជារបស់ហួសសម័យ មិនសមល្មមនិងអ្នកដែលប្រកបកិច្ចការរករបរលក់ដូរផ្សេងៗ នៅក្នុងលោកបច្ចុប្បន្ន មនុស្សប្រភេទខ្លាចសាសនានេះ មានច្រើនណាស់តែម្តង រវាងពុទ្ធបរិស័ទ ។ នេះហើយគឺជាផលនៃការយកសីលដាក់ជាលំដាប់ខាងមុខបញ្ញានោះឯង ។

បើយើងលើកយកបញ្ញាទុកមុនសីល និងសមាធិ ការបដិបត្តិនូវព្រះពុទ្ធសាសនាក៏បានងាយឡើង ពីព្រោះការសាងសម្មាទិដ្ឋិមិនបាច់ចុះកម្លាំងអ្វីទេ គឺគ្រាន់តែពន្យល់ឲ្យទៅជាមនុស្សចូលចិត្តស្តាប់ ចូលចិត្តអាន និងចូលចិត្តគិតទាក់ទងនឹងរឿងអរិយសច្ចប៉ុណ្ណោះ ក៏ឈ្មោះថាបដិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គហើយ ។ ការបដិបត្តិយ៉ាងនេះនឹងទៅធ្វើនៅឯណាក៏បានដែរ ធ្វើនៅពេលណាក៏បាន ហើយបានផលយ៉ាងត្រឹមត្រូវពិតប្រាកដ ។ នៅពេលកើតសម្មាទិដ្ឋិហើយ នឹងកើតសទ្ធាពិតប្រាកដក្នុងព្រះរតនត្រ័យ បន្តអំពីនេះទៅ ទាន សីល ភាវនា និងគុណធម៌ផ្សេងៗក៏នឹងតាមមកឯង សន្និមថាញោមមុខជាបានយល់ហើយ

- ព្រះគុណម្ចាស់! ប៉ុណ្ណិម៉ាពោលឡើង, ពាក្យដែលព្រះគុណម្ចាស់អធិប្បាយ ធ្វើឲ្យខ្ញុំកូណាដូចជាបានចេញ

អំពីទីងងឹតមកជួបនឹងពន្លឺភ្លឺស្វាង ខ្ញុំករុណាទើបតែមើលឃើញផ្លូវនៃការបដិបត្តិ ខាងផ្លូវព្រះពុទ្ធសាសនានៅក្នុងថ្ងៃនេះឯង បើនិយាយថាខ្ញុំករុណាចាប់ផ្ដើមជាពុទ្ធបរិស័ទដ៏ពិតប្រាកដក្នុងថ្ងៃនេះក៏មិនខុស ។ នៅពេលមុនៗនោះ ខ្ញុំករុណាបានយល់ថា សាសនាមិនមានអ្វីក្រៅតែពីការធ្វើពិធីបុណ្យ ការធ្វើបុណ្យឲ្យទាននិងរក្សាសីល ដែលជារឿងត្រូវអស់ដើមទុនកម្លាំងតែប៉ុណ្ណោះ ខ្លួនខ្ញុំករុណាផ្ទាល់បានធ្វើខ្លះមិនធ្វើខ្លះ ដែលបានធ្វើក៏គ្រាន់តែធ្វើទៅតាមប្រពៃណីហើយធ្វើទៅតាមអ្នកឯទៀតតែប៉ុណ្ណោះ ធ្វើទៅដោយមិនយល់នៅចំណុចប្រាថ្នាឲ្យពិតប្រាកដ ធ្វើដើម្បីអ្វីគ្រាន់តែធ្វើៗទៅដូច្នេះឯង

នាងស្រីនេះលើកនាឡិកាដៃមើល ហើយពោលបន្តថា៖

- នេះជិតដល់ម៉ោង១១ហើយ, ខ្ញុំម្ចាស់ចង់និមន្តព្រះអង្គទៅឆាន់ត្រង់នៅឯផ្ទះទាន, ឆាន់ត្រង់រួចហើយនឹងនិមន្តព្រះអង្គទេសនា ឲ្យម្ដាយខ្ញុំករុណាដែលចាស់ជរា បានស្ដាប់ដើម្បីឲ្យគាត់យល់នូវផ្លូវបដិបត្តិឲ្យបានត្រឹមត្រូវផង សូមនិមន្តព្រះគុណម្ចាស់ឥឡូវនេះ

- អាត្មាមិនអាចទទួលនូវការនិមន្តរបស់ញោមបានទេ! ពីព្រោះអាត្មាឆាន់អាហារពេលព្រឹកតែមួយពេលប៉ុណ្ណោះថ្ងៃនេះក៏បានឆាន់រួចទៅហើយ ហើយបានតាំងចិត្តថានឹងចេញដំណើរក្នុងថ្ងៃរសៀលនេះឯង

- សូមមេត្តាប្រោសទៅចុះព្រះគុណម្ចាស់, ប៉ុណ្ណឹងម៉ា

ពោលឡើង ព្រមទាំងលើកដៃសំពះដោយសេចក្តីអង្វរករ, គិតថាឃើញដល់សត្វដែលនឹកនឹងដល់ទៅចុះទាន ខ្ញុំករុណាមិនដែលបានជួបប្រទះព្រះសង្ឃ ដែលចេះដឹងដូចជាលោកម្ចាស់កាលពីមុនមកសោះ នៅពេលជួបហើយ ក៏ចង់ឲ្យអ្នកម្តាយលោកបានទទួលនូវពន្លឺព្រះធម៌អំពីព្រះគុណម្ចាស់ផង ពីព្រោះអ្នកម្តាយគាត់ចាស់ហើយ មិនដឹងជាពេលណានឹងព្រាត់ទៅ មុននឹងគាត់យ៉ាងម៉េចៗទៅ ខ្ញុំករុណាចង់ឲ្យគាត់បានកើតជាបុគ្គលសម្មាទិដ្ឋិជាមុនសិន បើមិនយល់ដល់ខ្ញុំករុណាទេ សូមព្រះអង្គយល់ដល់មនុស្សចាស់ជរារបស់ខ្ញុំករុណានោះផងចុះទាន ឥឡូវគិតយ៉ាងនេះចុះ ស្អែកពេលព្រឹកខ្ញុំករុណាសូមនិមន្តព្រះអង្គទៅឆាន់ពេលព្រឹកនៅផ្ទះ....

នៅទីបំផុត អាត្មាក៏មិនអាចចាកចេញរួចពីសៀងម៉ែងដែល...

# ដឹងដោយខ្លួនឯង

បទពាក្យ៧

**អ្វីៗត្រូវដឹងយល់ខ្លួនឯង ឲ្យប្រចក្សចែងដោយបញ្ញា**
**កុំទាន់ជឿឮតាមគេថា ខ្វះពិចារណារកហេតុផល ។**
**ក្នុងនាមជាពុទ្ធបរិស័ទ ត្រូវខំរៀនហាត់ឲ្យដឹងយល់**
**ទៅតាមឱវាទព្រះទសពល បំបាត់ចម្ងល់សង្ស័យបាន ៕**

ដោយឧបាសក មុិញ សារ៉ាង

# ៣២. ចំណុចចាប់ផ្ដើមជីវិតថ្មី

ពេលព្រឹកស្អែកឡើង ប៉ុណ្ណិម៉ា ឲ្យអ្នកបើករថយន្ត មកទទួលអាត្មាពីព្រឹកព្រហាម ។ នៅពេលដល់ទីប្រជុំជន អាត្មាសូមអនុញ្ញាតអំពីអ្នកបើកបររថយន្ត ចុះដើរបិណ្ឌបាត មួយកន្លែងដើម្បីរក្សាកិច្ចវត្ត ដែលធ្លាប់ធ្វើមករាល់ថ្ងៃមិនដែលដាច់ហើយក៏ត្រឡប់មកឡើងរថយន្តវិញ តម្រង់ទៅផ្ទះរបស់នាងប៉ុណ្ណិម៉ា ដែលជាផ្ទះឈើសង់បែបបុរាណមួយខ្នងធំនៅកណ្ដាលចំការមៀនដ៏ត្រជាក់ ។

ប៉ុណ្ណិម៉ា បាននាំស្រីចាស់ជរាម្នាក់ អាយុប្រមាណ ៧០ ឆ្នាំ ចូលមកថ្វាយបង្គំអាត្មា ហើយណែនាំឲ្យស្គាល់ថា គាត់ជាមាតារបស់នាង ។ គាត់មានអាយុច្រើនហើយ តែមើលទៅដូចជានៅរឹងមាំ រូបរាងមិនធាត់មិនស្គម មុខមាត់សាច់ឈាមផូរផង់ ពាក្យសម្ដីគួរឲ្យគោរពរាប់អាន ។ អាត្មាបានដឹងនៅពេលក្រោយមកថា ម្ដាយរបស់នាងប៉ុណ្ណិម៉ា ឈ្មោះម្ចាស់ប៉ែ បួរខាំ ជាកូនចៅរបស់លោកម្ចាស់គ្រងនគរឆៀងម៉ៃ ។

- ប៉ុណ្ណិម៉ាបាននិយាយឲ្យខ្ញុំព្រះករុណាស្ដាប់ថា បានទៅជួបព្រះសង្ឃទ្រទ្រង់សីល ទ្រង់ធម៌មួយអង្គ ទើបសូមនិមន្តព្រះអង្គមកឆាន់ពេលព្រឹកនៅនឹងគេហដ្ឋាន ខ្ញុំកូណាក៏សប្បាយចិត្ត ពីព្រោះយូរៗទើបបានជួបព្រះសង្ឃទ្រង់សីលទ្រង់ធម៌ម្ដង

ស្ត្រីចាស់ពោលឡើងឱនឈ្ងោកមុខចូលមក សម្លឹងពិនិត្យមើលអាត្មាយ៉ាងជិត ហើយពោលថា៖

- លោកម្ចាស់មើលឫកពាដូចជានៅក្មេងណាស់ ខ្ញុំករុណាស្មានថាជាព្រះសង្ឃចាស់ទៅហើយ រូបរាងស្អាតសង្ហាទៀតផង អញ្ចឹងថាបានជាប៉ុស្ណិម៉ាចេះតែពោលមិនដាច់ពីមាត់ប្រាប់ខ្ញុំករុណា ប្រាប់ខ្ញុំករុណាបន្តិចបានឬទេថាលោកម្ចាស់ជាអ្នកស្រុកណា បួសបានប៉ុន្មានវស្សាហើយ?

អាត្មារម្ងាប់ចិត្តផ្សាយមេត្តាដល់ស្ត្រីចាស់ ហើយតបទៅវិញថា៖

- អាត្មាជាអ្នកបាត់ដំបង បួសបាន ៨ វស្សាហើយ!

- ហ្ន៎! ជាជនបាត់ដំបងទៀតផង! ម្ចាស់ម៉ែពោលឡើងសម្ដែងនូវការពេញចិត្តថែមទៀត, ម្ដាយ ឪពុករបស់ព្រះអង្គរស់នៅឬទេ? ហើយប្រកបមុខរបរអ្វីទៅ?

- បិតារបស់អាត្មាបានចែកឋានទៅហើយ នៅពេលដែលអាត្មាទៅសិក្សានៅប្រទេសក្រៅ មាតារស់នៅបាត់ដំបង បិតាអាត្មាធ្វើការរាជការ មុននឹងចេញអំពីរាជការ លោកជាបាឡាត់ក្នុងក្រសួងមានបណ្ណាសក្តិជាហ្លួង គ្រួសាររបស់អាត្មាមានឋានៈគ្រាន់បើ ពីព្រោះមានទ្រព្យសម្បត្តិជាកេរមរតកអំពីបុព្វបុរស អាត្មាជាកូនពៅ ចំណែកបងៗគេមានគ្រួសារមាំទាំអស់ហើយ

- ដូចគ្នានឹងប៉ុស្ណិម៉ាគ្រប់យ៉ាង, ម្ចាស់ម៉ែនិយាយអំពីកូនស្រីម្ដងទៀត, បងៗគេមានគ្រួសារចេញទៅអស់ហើយ នៅសល់តែនាងម្នាក់ឯង មើលថែបងិបត្ថិបម្រុងម្ដាយ ស្ត្រី

ចាស់ជរាភាគទៅបញ្ជាកូនស្រី ឲ្យនាំយកម្ហូបអាហារឆាប់ៗ ហើយពោលបន្តទៅទៀតថា, គួរអនុមោទនាជ្រះថ្លាខ្លាំងណាស់ ជាកូនអ្នកធំមានត្រកូលជាជនកំសើតទីក្រុង តែមកបួសជាព្រះសង្ឃបានដល់ទៅ ៨ វស្សា ហើយព្រះគុណម្ចាស់គិតនឹងលាចាកសិក្ខាបទឬទេ ឬនឹងនៅជាបព្វជិតរហូតទៅ?

អាត្មានឹកចង់សើច នូវសំណួរត្រង់ទៅត្រង់មករបស់ម្ចាស់ម៉ែ មនុស្សចាស់ជាមួយក្មេងមានលក្ខណៈដែលអស់សំណើច ហើយគួរឲ្យស្រឡាញ់ម្យ៉ាងគឺមានអ្វីនៅក្នុងចិត្តគឺនិយាយចេញមកដោយត្រង់ៗ មិនមានលាក់លៀម ធ្វើឲ្យចិត្តស្ងប់ ផ្សាយមេត្តាដល់ស្ត្រីជរាហើយឆ្លើយតបវិញថា៖

- រឿងលាចាកសិក្ខាបទនេះ អាត្មាមិនទាន់បានគិតទេ ពីព្រោះជារឿងរបស់អនាគត ដែលរកអ្វីឲ្យប្រាកដមិនបាន អាត្មាពេញចិត្តតែក្នុងរឿងបច្ចុប្បន្ន បើបច្ចុប្បន្នបានល្អហើយ ទៅអនាគតក៏បានល្អដែរ បើនៅក្នុងសមណភេទរហូតទៅ ឬក៏មិនប្រាកដទៀតដូចគ្នា អាត្មាមិនចង់ទទួលឆានាអំពីរឿងអនាគតទេ

ការសន្ទនាអំពីរឿងផ្ទាល់ខ្លួនក៏ឈប់ស្លេះសិន នៅពេលដែលប៉ុណ្ណិម៉ានាំយកម្ហូបអាហារមកប្រគេន នៅពេលព្រមគ្នានោះ ដួងកែវនិងមិត្តស្រីៗ ២-៣ នាក់ទៀត មកដល់ព្រមគ្នាជាមួយនឹងម្ហូបអាហារម្នាក់បន្តិចៗ ដើម្បីយកមកចូលធ្វើបុណ្យជាមួយផង ។ មានការទទួលរាក់ទាក់ដោយសម្លេងសើចយ៉ាងរីករាយទៅតាមទំនៀម ការធ្វើបុណ្យធ្វើទានដោយចិត្តបរិសុទ្ធ តែងធ្វើឲ្យកើតសេចក្តី

រីករាយត្រេកអរក្នុងចិត្ត និងការសោមនស្សរីករាយយ៉ាងនេះជានិច្ច ។

នៅពេលដែលអាត្មាផ្ទុសបាយ និងម្ហូបប្លែកផ្សេងៗ ក្នុងបន្តិចៗដាក់ចូលក្នុងបាត្រ គ្រប់គ្នាសម្លឹងមើលដោយពេញចិត្ត ផ្ទុយទៅវិញមានទឹកមុខដូចជាកំពុងមិនសប្បាយ ហើយពោលឡើងថា៖

- ខ្ញុំករុណាឃើញព្រះអង្គ ផ្ទុសម្ហូបគ្រប់យ៉ាងដាក់ចូលក្នុងបាត្រអស់ហើយ នៅផ្ទុសបន្ថែមដាក់ចូលទៅថែមទៀត មាននិយថា លោកម្ចាស់នឹងឆាន់ជាមួយគ្នាទៅទាំងអស់ដូច្នេះមែនឬ ?

នៅពេលដែលអាត្មាឆ្លើយទទួល គេក៏ធ្វើមុខភ្ញាក់ៗ ហើយពោលថា៖

- លោកម្ចាស់ ! លេងឆាន់ចូលគ្នាបែបនេះវិរហើយ !

- បើវិរ អាត្មាប្រហែលជាវិរមកយូរហើយ ពីព្រោះអាត្មាឆាន់បែបនេះអស់រយៈពេល ៨ ឆ្នាំមកហើយ

ទាំងអស់គ្នាសម្លឹងមើលមកអាត្មាដោយសេចក្តីងឿងឆ្ងល់ ហើយប៉ុណ្ណឹម៉ាក៏សួរឡើងថា៖

- តើវាមានរសជាតិឆ្ងាញ់ដែរឬទេ ទានម្ចាស់ ?

- អាត្មាមិនមែនឆាន់អាហារដើម្បីឲ្យឆ្ងាញ់នោះទេ តែឆាន់ដើម្បីរំងាប់នូវការស្រេកឃ្លាន គឺឲ្យជីវិតរស់នៅបានតទៅទៀតតែប៉ុណ្ណោះ

គ្រប់គ្នាអង្គុយនៅស្ងៀម សម្លឹងមើលមកអាត្មា មួយសន្ទុះក្រោយមក ផ្ទុយទៅវិញប្រហែលជាឆ្ងល់ ហើយក៏មិនសប្បាយចិត្តយ៉ាងខ្លាំង ដែលឃើញអាត្មាឆាន់អាហារចម្លាប

និងបង្អែមព្រមៗគ្នា ទើបសួរឡើងថា៖

- នេះព្រះគុណម្ចាស់ឆាន់ចម្អាប និងបង្អែមព្រមគ្នាមែនទេទាន?

- មែន! អាត្មាឆ្លើយ, អាត្មាមិនបានឆាន់រសជាតិអាហារ គឺចាប់បានត្រង់ណា បានស្អី ក៏ដាក់ចូលក្នុងមាត់ហើយទំពារលេប ពីព្រោះអាត្មាឆាន់ដើម្បីឲ្យជីវិតគង់នៅដូចបានពោលមកហើយ ទើបមិនបានរើសយកថា នេះជាបង្អែម នេះជាចម្អាប ណាមួយឆ្ងាញ់ ណាមួយមិនឆ្ងាញ់ សូមឲ្យជាអាហាររបស់មនុស្សទៅបានហើយ

- ខ្ញុំកូណាទើបតែនឹងបានឃើញជាលើកដំបូងក្នុងជីវិតដួងកែវពោលទាំងនឿងឆ្ងល់ក្នុងចិត្ត, ព្រះគុណម្ចាស់ដូចជាប្លែកខុសអំពីធម្មជាតិតែម្ដងហើយ

- នឹងខុសពីធម្មជាតិ ឬមិនខុសធម្មជាតិនោះ ស្រេចលើញោមយល់ចុះ ប៉ុន្តែដែលអាត្មាបានយល់មកនោះ ធម្មជាតិសាងគ្រពះអាហារមក គ្រាន់តែគ្រពះមួយប៉ុណ្ណឹងមិនមានគ្រពះបង្អែម គ្រពះចម្អាបយ៉ាងណានោះឡើយ ឃើងឆាន់អ្វីចូលទៅ វាក៏ចាត់ការកិនទៅតាមនាទីរបស់វាមិនឃើញវារើសរូសថា ត្រូវកិនចម្អាបមុនហើយកិនបង្អែមក្រោយ

មុននឹងដួងកែវហាមាត់ប្រកែក ម្ចាស់ម៉ែនិយាយកាត់ពាក្យឡើងមុនថា៖

- ពួកឯងនេះ ចេះតែនាំគ្នាទៅសាកសួរដេញដោលលោកក្នុងរឿងមិនបានការ ព្រះអង្គឆាន់បែបណា ឆាន់ស្អី

មុន ឆាន់ស្ទីក្រោយ ជារឿងរបស់លោក កុំទៅរវល់នឹងលោក ទុកឲ្យលោកឆាន់បានស្រួលៗទៅ តិចបានបាបមានកម្មទទេៗទៅ លោកជាព្រះសង្ឃកុតង្គផង តើឲ្យព្រះអង្គឆាន់ដូចលោកធម្មតាបានដូចម្តេចកើត

ពាក្យរបស់ម្ចាស់ប៉ៃបានផល ទាំងអស់គ្នានៅស្ងៀមមួយរំពេច អាចទុកឱកាសឲ្យអាគ្គាបានឆាន់ ហើយពិចារណានូវអាហារបដិកូលសញ្ញាតាមសម្រួល ៗ ដូងតែជាអ្នកនិយាយច្រើន បានពោលឡើងម្តងទៀតនៅពេលអាគ្គាបានឆាន់រួចថា៖

- ព្រះគុណម្ចាស់ឆាន់តិចម្ល៉េះ ឆាន់ឲ្យច្រើនៗ ញោមនិងសប្បាយចិត្ត ហើយបានបុណ្យច្រើនៗ

- ការឆាន់អាហារនោះ បើឆាន់តាមសេចក្តីពេញចិត្តរបស់អ្នកដទៃនោះមិនបានទេញោម គឺត្រូវឆាន់តាមសេចក្តីត្រូវការរបស់រាងកាយ នៅពេលរាងកាយប្រាប់ថាល្មមហើយក៏គួរតែឈប់ឆ្លាម បើនៅតែឆាន់ទៀតដើម្បីយកចិត្តអ្នកដទៃ អាចកើតទៅជាទោស ចំណែកការចង់បានបុណ្យច្រើនឬតិចនោះ មិនមែនមកពីការឆាន់បានតិចឬច្រើននោះទេ គឺនៅលើសេចក្តីបរិសុទ្ធ ៣ ប្រការ គឺ**ទេយ្យទានជារបស់បរិសុទ្ធ, អ្នកឲ្យមានចេតនាបរិសុទ្ធ និងអ្នកទទួលមានសីលមានធម៌បរិសុទ្ធ** បើមានសេចក្តីបរិសុទ្ធ ៣ ប្រការនេះគ្រប់បរិបូណ៌ហើយ សូម្បីតែលោកឆាន់តិចក៏បានបុណ្យច្រើនដែរ

នៅពេលកូនចៅលើកយកចានទៅលាង ហើយ

បរិភោគទាំងអស់គ្នានៅខាងក្រៅ ម្ចាស់ប៉េប្លូរខាំបានពោល ឡើងថា៖

- ក្មេងៗពួកនេះវាអាត់ក និយាយច្រើន ហើយចូលចិត្តសប្បាយ បើសិនជាគេនិយាយ ឬសួរពាក្យដែលមិនសមគួរ សូមព្រះអង្គអត់ឱនទោសឲ្យពួកគេផងទាន ហើយសូមកុំឲ្យមានបាបកម្មតទៅទៀតគុណម្ចាស់

នៅពេលអាត្មាបានពោលឲ្យបានស្ងប់ចិត្តហើយ ម្ចាស់ប៉េក៏បានវិលមករករឿងដើម ដែលបានសន្ទនាដាច់ទៅ

- ខ្ញុំកូណាចង់ដឹងរឿងផ្ទាល់ខ្លួនរបស់ព្រះអង្គ បន្ថែមបន្តិចបន្តួចទៀត គឺចង់ដឹងថា តើព្រះអង្គគិតយ៉ាងណាទើបចេញបួសទាំងនៅក្មេង ហើយព្រមទាំងបាន ៨ ឆ្នាំទៀតផងសូមករុណាម្ចាស់និទានឲ្យខ្ញុំកូណាស្តាប់ផងទាន

- រឿងនេះ ហាក់ដូចជាវែងបន្តិច អាចត្រូវប្រើពេលច្រើន សូមឲ្យញោមអញ្ជើញទៅពិសាបាយជាមួយកូនចៅសិនទៅ រួចហើយសិមអញ្ជើញត្រឡប់មកវិញស្តាប់ទាំងអស់គ្នា ជួនកាលអាចនឹងបានសេចក្តីចេះដឹងអំពីរឿងអាត្មាខ្លះ !

- ល្អដែរ ! ម្ចាស់ប៉េពោលឡើង ហើយក៏ក្រាបគ្រោកចេញទៅខាងក្រៅ

- ពេលអាត្មានៅជាគ្រហស្ថ អាត្មាក៏ដូចជាក្មេងកំលោះគ្រប់គ្នាទាំងឡាយ, អាត្មាចាប់និយាយនៅពេលដែលអ្នកទាំងអស់គ្នាមកអង្គុយព្រមគ្នាហើយ, គឺជាពុទ្ធសាសនិកជនត្រឹមតែឈ្មោះ មិនមានសេចក្តីចេះដឹងនិងការយល់ឲ្យបាន

*ជ្រៅជ្រះក្នុងព្រះពុទ្ធសាសនា កាលពីកុមារភាពនៅក្នុងសាលារៀន ក៏គ្រូបង្រៀនត្រឹមតែរឿងពិធីកម្មពុទ្ធប្បវត្តិ និងសីលធម៌បន្តិចបន្តួច ទៅតាមគោលធម៌ដែលខាងក្រសួងកំណត់ទុកឲ្យ ធ្វើឲ្យឃើញបានថា ព្រះពុទ្ធសាសនាមិនមានអ្វីក្រៅអំពីថ្វាយបង្គំព្រះ សូត្រធម៌ ធ្វើបុណ្យ ឲ្យទាន រក្សាសីលធ្វើឲ្យយល់ថាសាសនាជារឿងរបស់មនុស្សចាស់ រឿងរបស់លោកនេនេ ដូនជី ជារឿងហួសសម័យ មិនទាក់ទងជាមួយជីវិតរបស់មនុស្សសម័យថ្មី ។ នៅពេលបានយល់ដូច្នេះហើយ អាត្មាក៏មិនរវល់ក្នុងព្រះពុទ្ធសាសនា សូម្បីត្រូវធ្វើនូវពិធីកម្មក្នុងព្រះពុទ្ធសាសនា ក៏ចេះតែធ្វើៗទៅតាមប្រពៃណីតែប៉ុណ្ណោះ ។*

*ក្នុងពេលដែលអាត្មាសិក្សានៅថ្នាក់ទី ៥, មានកើតហេតុការណ៍មួយឡើង ហើយហេតុការណ៍ពេលនោះបានធ្វើឲ្យសទ្ធារបស់អាត្មាដែលមានតិចតួចផងស្រាប់ ឲ្យរឹតតែធ្លាក់ចុះតិចទៅទៀត ពេលគឺលោកយាយរបស់អាត្មាបានទទួលអនិច្ចកម្មទៅ ។ ពេលនោះលោកឪពុកអ្នកម្តាយឲ្យអាត្មាបួសជាសាមណេរ ដឹកសពដែលគេនាំគ្នាហៅថាបួសមុខភ្លើង នៅពេលបុណ្យសពរួចចប់សព្វគ្រប់អស់ហើយ លោកឪពុកអ្នកម្តាយក៏ឲ្យអាត្មានៅតទៅទៀត ១៥ ថ្ងៃនៅវត្តជិតផ្ទះអាត្មា ។ ក្នុងរយៈពេល ១៥ថ្ងៃនេះឯងដែលអាត្មាបានឃើញការបដិបត្តិក្រៅវិន័យ ក្រៅធម៌ របស់ព្រះសង្ឃក្នុងវត្តនោះ ហើយធ្វើឲ្យអាត្មាអស់សទ្ធាក្នុងព្រះពុទ្ធសាសនា ។ អាត្មាមិនឃើញព្រះសង្ឃលោកធ្វើអ្វី ភ្ញាក់*

ឡើងពេលព្រលឹមទៅបិណ្ឌបាត, រសៀលមកបន្តិចក៏សឹង រហូតដល់ម៉ោង ៣ រសៀល តើនឡើងក៏ប្រជុំគ្នាលេងអុក នៅក្នុងកុដិមួយរហូតដល់យប់ ស្រង់ទឹកពេលយប់ហើយក៏ ប្រជុំគ្នាឆាន់តែ ឬកាហ្វេ ជជែកគ្នាយ៉ាងសប្បាយរីករាយ អំពីផ្លូវលោក លុះដល់យប់ជ្រៅទើបបែកគ្នាទៅសឹង ។ អាត្មាទ្រាំនៅបានលុះគ្រប់ ១៥ ថ្ងៃ ដោយសេចក្ដីអស់សំណើច ក្នុងចិត្តយ៉ាងខ្លាំង ។ នៅពេលអាត្មាលាចាកសិក្ខាបទមក អាត្មាមិនដែលទៅជិតវត្តនោះសោះឡើយ នឹងថាជាសេចក្ដី ខុសរបស់មនុស្សច្រាស់ក៏បាន ដែលទៅរើសយកវត្តដូច្នោះ ឲ្យអាត្មានៅ ពីព្រោះឃើញវត្តនៅជិតផ្ទះស្រួលទៅមក ។ អាត្មាគិតថា មុននឹងបញ្ជូនឲ្យកូនចៅបួសគួររើសរកវត្តឲ្យ បានល្អ គួររកវត្តដែលមានការរៀនសូត្រ និងបដិបត្តិយ៉ាង ហ្មត់ចត់ មិនគួរឃើញតែការស្រួល បើឃើញការស្រួល ហើយនៅវត្តដែលគ្មានការសិក្សា និងបដិបត្តិឲ្យបានពិត ប្រាកដ ក៏ត្រឡប់ទៅជាបានផលអាក្រក់ទៅវិញ ហើយជា បាបកម្ម បើកូនចៅមានឧបនិស្ស័យអាក្រក់ហើយ ក៏នឹងទៅ ជាខិលខូចជាមួយលោកទាំងនោះ ជួយនាំគ្នាញាំញីព្រះពុទ្ធ សាសនា ។ បើសិនជាកូនចៅមានឧបនិស្ស័យល្អហើយ នៅពេលទៅឃើញការប្រព្រឹត្តថោកទាបរបស់លោក ក៏នឹង ទៅជាអ្នកអស់សទ្ធាក្នុងព្រះពុទ្ធសាសនា ដូចជាអាត្មាបាន ជួបប្រសព្វ បានជួបប្រទះមកហើយនេះ ។

នៅពេលរៀនចប់ថ្នាក់ទី ៨ ហើយ មកពីប្រឡងបាន ពិន្ទុខ្ពស់ ទើបបានទទួលអាហាររូបករណ៍អំពីរដ្ឋាភិបាលឲ្យ

ទៅរៀនតខាង "គីមីវិទ្យា" នៅមហាវិទ្យាល័យទីក្រុងឡុងដ៍នា ប្រទេសអង់គ្លេស ។ មុននឹងចេញទៅបរទេសនោះ លោកឪពុក អ្នកម្ដាយបានធ្វើពិធីភ្ជាប់ពាក្យរវាងអាត្មានិងស្ត្រីម្នាក់ ដែលមានឋានៈនិងត្រកូលប្រហាក់ប្រហែលគ្នា ហើយជាមិត្តជិតស្និទ្ធគ្នាមកយូរហើយ ។ អាត្មាមិនមានសេចក្ដីស្រឡាញ់នឹងនាងនោះទេ ត្រឹមតែស្គាល់គ្នាជាធម្មតា ពីព្រោះយល់ឃើញដល់ឪពុកម្ដាយ ទើបព្រមបងិបត្តិតាមបំណងរបស់លោកដោយស្រួលទៅ តែចំណែកស្រីនោះវិញ នាងមានចិត្តស្រឡាញ់ចំពោះអាត្មាច្រើន ពីព្រោះនៅពេលអាត្មានៅបរទេស នាងសរសេរសំបុត្រទៅឲ្យអាត្មារាល់អាទិត្យ ហើយនិយាយតែអំពីសេចក្ដីស្រឡាញ់យ៉ាងខ្លាំងជានិច្ច

- ហើយព្រះអង្គវិញ តើព្រះអង្គបានសរសេរឆ្លើយតបទៅនាងវិញដែរឬទេ? ដួងកែវ សួរញឹមៗ

- សរសេរដែរ ម្ដងម្កាល! អាត្មាឆ្លើយ

- ហើយព្រះគុណម្ចាស់ និយាយពីសេចក្ដីព្រមព្រៀងស្រឡាញ់យ៉ាងខ្លាំងខ្លះទេទាន? ប៉ុណ្ណរិម៉ាសួរបន្ថែម

- ក៏និយាយខ្លះដែរ, អាត្មាឆ្លើយទៅតាមការពិត, ពីព្រោះនៅពេលក្រោយមក អាត្មាមានការស្រឡាញ់គេដែរ ពីព្រោះមកនៅបរទេស មានការអផ្សុកហើយនឹងនឹកមកផ្ទះ ដល់ពេលមានគេព្យាយាមយកចិត្តទុកដាក់ ទើបមានចិត្តនឹកដល់គេ

- ឈប់សួរពីរឿងមិនបានការនេះទៅ! ម្ចាស់ម៉ែពោលហាមនាងទាំងពីរដោយសម្លេងមាំ សូមនិមន្តព្រះអង្គនិទាន

រឿងតទៅទៀត កំពុងតែជក់ស្ងាប់

- នៅឯផ្ទះសំណាក់របស់មហាវិទ្យាល័យឡុងដ៍នោះ , អាត្មាបានស្គាល់មិត្តស្និទ្ធស្នាល ជាមួយនឹងកំលោះជនជាតិអង់គ្លេសម្នាក់ឈ្មោះ ចនវិល្លាម(John William) គេជាមនុស្សចូលចិត្តសប្បាយ ហើយអាត្មាក៏រកការសប្បាយសុខស្រួលទៅគ្រប់ទីកន្លែងក្នុងទីក្រុងឡុនដុនដែរ ។ បើសិនជាអាត្មាភ្លេចសតិមិនគិតដល់ខ្លួនឯងនោះទេ គឺអាចក្លាយទៅជាមនុស្សខូចខ្លួន ហើយរៀនក៏មិនបានសម្រេចក៏អាចបាន តែមកពីមានសតិល្អ ការរៀនសូត្ររបស់អាត្មាទើបមិនខូចខាតអ្វីសោះ ប្រឡងបានលេខល្អទៀតផងរាល់ៗឆ្នាំ នៅពេលអាត្មាកំពុងរៀននៅឆ្នាំទី ៣ នៅពេលមហាវិទ្យាល័យបិទទ្វារក្នុងរដូវក្តៅ អាត្មាបានតាមនាយចន ទៅសម្រាកនៅឯផ្ទះរបស់គេនៅស្រុកណោតទីងហែម (Nottingham) នៅនាខាងត្បូងក្រុងឡុនដុន តាមពាក្យបបួលរបស់គេ ។

វិថីជីវិត បានចាប់ប្តូរផ្លាស់នៅស្រុកណោតទីងហែម (Nottingham) នោះឯង, រឿងនោះគឺថា នារសៀលថ្ងៃមួយអាត្មានិងនាយចន បានទៅអង្គុយលេងលើវាលស្មៅនៅក្នុងសួនខាងក្រោយផ្ទះ ។ នៅពេលកំពុងតែនិយាយគ្នាលេងយ៉ាងសប្បាយរីករាយ នឹកដល់រឿងផ្សេងៗអស់ហើយនាយ ចន បានពោលឡើងថា ៖

- យើងដូចជាមិនសូវបាននិយាយ ជជែកគ្នាលេងអំពីរឿងដែលមានប្រយោជន៍សោះហ្ន៎ ! តែថ្ងៃនេះយើងចង់និយាយ គ្នាអំពីបញ្ហាធំៗ ជាមួយឯងខ្លះ ឯងជាពុទ្ធបរិស័ទ

មែនឬទេ ?

- មែន! អាត្មាឆ្លើយបែបភ្ញាក់ និងឆ្ងល់ មិនបាននឹកស្មានថាគេសួរនូវបញ្ហាដូច្នោះទេ

- ល្អហើយ! គេពោលដោយមានស្នាមញញឹមនៅលើផ្ទៃមុខយ៉ាងពេញចិត្ត, ខ្ញុំមានការពេញចិត្តក្នុងទស្សនៈនៅខាងបូព៌ាមកយូរហើយ តែមិនមានឱកាសបានសន្ទនាជាមួយអ្នកមកពីបូព៌ាក្នុងរឿងនេះសោះ យើងចង់ដឹងថាតើគោលបំណងខ្ពស់បំផុតក្នុងលទ្ធិសាសនារបស់ឯងគឺអ្វី ?

សំណួររបស់មិត្តក្រៅប្រទេស ដូចជាមានដុំថ្មមួយយ៉ាងធំធ្លាក់មកលើមុខរបស់អាត្មាយ៉ាងដំណំ ធ្វើឲ្យអាត្មាភ្ញាក់វង្វេងទៅអស់ ពីព្រោះមិនបាននឹកគិតថា គេនឹងសួរនូវបញ្ហាយ៉ាងជ្រៅដូច្នេះសោះ វាជាបញ្ហាដែលអាត្មាមិនដែលបានគិត មិនដែលរវល់ មិនបានយកចិត្តទុកដាក់ ហើយមិនមានការចេះដឹងពីដើមមកបន្តិចសោះ ។ អាត្មាអង្គុយនៅស្ងៀម ដោយគានគិតក្នុងចិត្តមួយសន្ទុះ ហើយបានឆ្លើយទៅតាមការពិតដោយទឹកមុខស្លូតថា ៖

- ខ្ញុំមិនដឹងទេ!

នៅពេលនោះឯងនាយចន សម្លឹងមើលមកអាត្មាដោយក្រសែភ្នែកចម្លែក ដែលមិនធ្លាប់សម្លឹងអំពីកាលមុនសោះ ។ កែវភ្នែកទាំងគូនោះពោរពេញទៅដោយន័យនៃសេចក្ដីចម្លែកប្លែកក្នុងចិត្ត សេចក្ដីខុសបំណង សេចក្ដីត្រូវការមើលងាយ ហើយការគិតយល់ផ្សេងៗពេលអាត្មាឃើញហើយ មានសេចក្ដីខ្លាចភ័យ ខ្មាសអៀន តូចចិត្ត ខូច

ចិត្ត និងសេចក្ដីក្រោធខឹងចូលលាយឡំគ្នា ៗ

- ងងដាពុទ្ធបរិស័ទសែបលាហ្នឹង? នាយចន និយាយតិចៗ ហើយងាកមុខទៅទីផ្សេង

មិនមានពេលណាក្នុងជីវិតអាត្មា ដែលអាត្មានឹកស្មានខ្មាស តូចចិត្ត ស្ដាយហើយខឹងក្ដៅចិត្តនឹងខ្លួនឯងស្មើនឹងពេលនោះទេ នេះហើយគឺជាចំណុចដំបូងនៃជីវិតថ្មីរបស់អាត្មា...

# ចេះមិនឈ្នះទាល់

បទពាក្យ៧

ជីវិតពិតជាមានចម្ងល់ បញ្ហាទុញទាល់រាប់មិនអស់
សំណួរចម្លើយត្រូវស្រាយដោះ ចោទឡើងគ្រប់មនុស្សក្នុងលោកា ។
បើគ្មានបទរៀនគ្មានន័យជីវិត បើខ្វះការគិតពិតឥតប្រាជ្ញា
ប្រសិនមិនមានទេបញ្ហា ប្រាកដឥតមានការដោះស្រាយ ។
ប្រសិនមិនទាល់មិនឆ្ងល់សោះ នាំឲ្យចិត្តមនុស្សបែរមាក់ងាយ
ប្រមាទប្រហែសគិតរាយមាយ ធ្លាក់ចុះអន្តរាយក្លាយវិនាស ។
ចម្ងល់ទាល់ទុកជាបទរៀន ប្រដៅប្រាប់ប្រៀនមានឱភាស[១]
ទាល់ឆ្ងល់ស្វែងយល់រកអំណោះ សិក្សាស្រាយដោះអស់ឆ្ងល់បាន ។
ពាក្យចាស់ថាចេះមិនឈ្នះទាល់ មិនបាច់ចាំឆ្ងល់ពាក្យបុរាណ
ទោះជាប្រាជ្ញប្រៀនរៀនប៉ុន្មាន លែងអីនឹងមានការទុញទាល់ ៕

ដោយឧបាសក ម៉ិញ សារ៉ាង

---

(១)សេចក្ដីពន្យល់ឲ្យភ្លឺ, ការឲ្យន័យឬឲ្យទំនង, ការសម្ដែងអាការកិរិយាឲ្យដឹងច្បាស់

# បានត្រឹមទ្រឹស្តី

បទកាកគតិ

ចេះត្រឹមទ្រឹស្តី ទោះពេលយប់ថ្ងៃ បានខាងវោហារ
ហូរចេញដូចទឹក នឹកទៅអស្ចារ្យ មិនខុសពាក្យថា
ដូចជាត្រដោក ។
ចងក្រងក្របី ទិវារាត្រី បន្លឺប៉ោកៗ
តែឥតដែលឆ្អែត ហេតុជាត្រដោក ផលដែលបានមក
ឆ្អែតពោះក្របី ។
ន័យនេះពាក្យចាស់ បញ្ជាក់ចែងច្បាស់ ជូនញាតិប្រុសស្រី
ដូចជាជនខ្លះ ច្បាស់ណាស់ទ្រឹស្តី ពូកែពោលស្តី
យប់ថ្ងៃកោកៗ ។
តែឥតបដិបត្តិ ពុំដែលចែងចាត់ គិតលៃរិះរក
ក្នុងប្រហោងធ្លុង ដូចជាត្រដោក ផលត្រូវបានមក
ជាជនទទេ ៕

ដោយឧបាសក ម៉ិញ សារ៉ាង

# ៣៣. តណ្ហា ជាអ្នកធ្វើទារុណ

នៅពេលត្រឡប់មកដល់ទីក្រុងឡុងដ៍វិញ អាត្មាចាប់ផ្ដើមសិក្សាស្រាវជ្រាវនូវទ្រឹស្ដីព្រះពុទ្ធសាសនា យ៉ាងប្រញាប់ប្រញាល់ ។ អាត្មាយកពេលវេលាដែលទំនេរសម្ងំនៅក្នុងបណ្ណាល័យ អានគ្រប់សៀវភៅដែលទាក់ទងនឹងព្រះពុទ្ធសាសនា ។ សៀវភៅដែលមាននៅក្នុងបណ្ណាល័យទាំងប៉ុន្មាន នៅតែមិនទាន់គ្រប់គ្រាន់ទៀត អាត្មាបានទៅសិក្សាស្រាវជ្រាវរកតាមបណ្ណាគារ ដែលនៅតាមមហាវិថី (Great Russell Street) នៅជិតៗនិងសារមន្ទីរអង់គ្លេសទៀតផង ។ អាត្មាក៏បានចំណាយប្រាក់កាសទិញសៀវភៅខាងផ្លូវព្រះពុទ្ធសាសនាផ្សេងៗ បានយ៉ាងច្រើនតែម្ដង ។ ក្នុងចំណោមសៀវភៅទាំងនោះ អាត្មាចូលចិត្តសៀវភៅរបស់ព្រះនារទៈមហាថេរ នៅវត្តវជិរារាមក្រុងគូឡាឡាំពួរ, ប្រទេសលង្ការ ច្រើនជាងរបស់អ្នកណាទាំងអស់ ពីព្រោះលោកអធិប្បាយព្រះពុទ្ធសាសនា ដោយពាក្យងាយៗ ហើយប្រៀបធៀបនឹងការចេះដឹងសម័យថ្មី អានបានយល់យ៉ាងងាយ ។ មិនយូរប៉ុន្មាន អាត្មាក៏មានការចេះដឹងក្នុងព្រះធម៌ ដែលជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ បានច្រើនល្មមសមគួរ ។ ការចេះដឹងក្នុងព្រះធម៌នោះ ធ្វើឲ្យកើតមានពន្លឺឡើងក្នុងចិត្ត ពន្លឺនោះ បានបញ្ចាំងឲ្យអាត្មាមើលឃើញនូវការពិតនៃជីវិត ដែលមិនធ្លាប់បានឃើញពីកាលមុនមក ហើយការពិតនោះ

ធ្វើឲ្យផ្លូវជីវិតរបស់អាត្មាប្ដូរផ្លាស់ទៅយ៉ាងពិតប្រាកដ ។

- តើផ្លាស់ប្ដូរទៅជាយ៉ាងណាទៅទានម្ចាស់ ? ដួងកែវសួរដោយឫកពាសង្ស័យ

- គឺប្ដូរអំពីជីវិតកំលោះសប្បាយហ៊ឺហា ទៅជាអ្នកមានធម្មៈ, ធម្មកើតឡើងមកមួយរំពេច លុះត្រាតែមិត្តភក្ដិប្លែកក្នុងចិត្តគ្រប់ៗគ្នា

- ព្រះគុណម្ចាស់ប្រាប់ថា លោកបានឃើញការពិតក្នុងជីវិត ទើបនឹងផ្លាស់ទៅ ខ្ញុំកូណាចង់ដឹងថា តើការពិតទៅដែលលោកម្ចាស់ឃើញនោះគឺជាស្អីដែរ ? ប៉ុណ្ណឹងម៉ាសួរឡើងខ្លះ

- គឺអាត្មាមើលឃើញថា ជីវិតអ្នកវិការយដែលវក់វីជាមួយនឹងស្រា ស្រី ភ្លេងតន្ត្រី កីឡា ដែលអាត្មាធ្លាប់ឃើញថាជាសេចក្ដីសុខនោះ ការពិតគឺជាការព្រមទៅជាខ្ញុំកញ្ជះនៃនាយចៅហ្វាយដែលកាចសាហាវគឺ **តណ្ហា** នោះឯងតណ្ហាគឺសេចក្ដីចំណង់ ចង់បាន បង្គាប់ឲ្យយើងត្រូវតស៊ូននៀលដើម្បីស្វែងរករូប សម្លេង ក្លិន រស សម្ផស្ស បម្រុងបម្រើវានៅពេលវាបានបរិភោគនូវរបស់ទាំងនោះឆ្អែតហើយ វាបានដេកលក់ទៅមួយស្របក់ ធ្វើឲ្យយើងមានសេចក្ដីសុខខ្លះទៅ តែមិនយូរប៉ុន្មានវានឹងក្រោកឡើងដោយការស្រេកឃ្លានទៀតលើសពីគាលមុន វានឹងបញ្ជាឲ្យយើងតស៊ូរត់បម្រះស្វែងរករបស់ផ្សេងៗមកបញ្ចុកទៀត ។ បើនឹងប្រៀបធៀបដូចជាខ្លាដែលស្រេកឃ្លាន មានខ្លួនធំសឹមហិមានេះយើងចិញ្ចឹមវាទុក នៅពេលគម្លានកើតឡើងមក វានឹងដើរ

តម្រង់ចូលមកត្របាក់ខាំត្រីយើងយ៉ាងទារុណ យើងនឹងរត់ទៅរកអាហារមកឲ្យវាស៊ី ដោយសេចក្ដីលំបាកវេទនា នៅពេលស៊ីឆ្អែតហើយ វាក៏ដេកលក់ទៅមួយភ្លែត បណ្ដោយឲ្យយើងមានពេលវេលាសម្រាកបានខ្លះ ៗ នៅពេលនេះហើយដែលយើងអាចមានសេចក្ដីសុខខ្លះ ប៉ុន្តែមិនយូរប៉ុន្មាន ខ្លាកំណាចនេះវាភ្ញាក់ឡើងមកជាមួយសេចក្ដីស្រេកឃ្លាន ហើយងាកចូលមករកយើងទៀត យើងត្រូវប្រញាប់រត់ទៅរកអាហារមកឲ្យវាទៀតមិនមានពេលចប់ ៗ ហេតុការណ៍ដូច្នេះ នឹងដំណើរប្រព្រឹត្តទៅតាំងពីកើតលុះត្រាដល់ពេលស្លាប់ ៗ សូម្បីយើងស្លាប់ទៅហើយ ខ្លាគឺតណ្ហាវាមិនបានស្លាប់ទៅតាមជាមួយយើងទេ នៅពេលមិនយូរយើងក៏កើតមកទៀត ហើយក៏ក្លាយទៅជាខ្ញុំកញ្ជះទទួលបម្រើវាទៀត ៗ ខ្លាធម្មតាប្រសើរជាងខ្លាតណ្ហា ពីព្រោះខ្លាធម្មតាវាគ្រាន់តែមានមាត់តែមួយ វាស៊ីសាច់ជាចំណីតែមួយមុខ នៅពេលវាស៊ីឆ្អែតហើយ វាឈប់ក៏ឈប់ស៊ីតទៅទៀត ប៉ុន្តែខ្លាតណ្ហានេះ មានមាត់ដល់ទៅប្រាំមួយឯណោះ មាត់ស៊ីអាហារដល់ទៅ៦ យ៉ាងគឺ ៖ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ហើយចម្រើនរីកធំឆាត់មិនមានព្រំដែនកំណត់ គាន់តែបរិភោគច្រើន ក៏គាន់តែធាត់ធំខ្លាំង គាន់តែធំ ក៏គាន់តែត្រូវការអាហារច្រើនឡើង ដូចស្រមោលអន្ទោលតាមប្រាណ ៗ

ការពិតដែលបានទៅជួបនឹងព្រះធម៌នេះ ធ្វើឲ្យអាត្មាមើលឃើញទោសរបស់ខ្លាតណ្ហា ស្លុប់ហើយខ្លាចវា មិន

ចង់នៅឋានកញ្ចុះ ខ្ញុំបម្រើរបស់វាតទៅទៀត អាត្មានឹកសង្វេគភ័យតក់ស្លុតក្នុងចិត្ត ។ នៅពេលគិតត្រឡប់ពីអតីតដែលបានធ្លាក់ទៅឋានកញ្ចុះរបស់តណ្ហា មិនដឹងជាប៉ុន្មានម៉ឺន សែនជាតិមកហើយ វានាំឲ្យអាត្មាវិលវល់ វិលស្លាប់ វិលកើតនៅក្នុងភពទាំង ៣ មកទាល់តែរើខ្លួនមិនរួច ។ បើសិនមិនបានជួបនូវពន្លឺនៃព្រះធម៌ បញ្ចាំងឲ្យឃើញនូវការពិត “ខ” នេះទេ អាត្មាក៏ប្រហែលជាធ្លាក់ទៅឋានកញ្ចុះរបស់វាបន្តទៅទៀត ។

អាត្មាឈប់និយាយ ដើម្បីសង្កេតមើលនូវកិរិយារបស់អ្នកស្តាប់គ្រប់ៗគ្នា គេអង្គុយនៅស្ងៀម មានទឹកមុខសោកសៅស្លុត បញ្ចាំងឃើញនៅលើផ្ទៃមុខពួកគេ ។

- សូមនិមន្តនិទានបន្តទៀតចុះ! ប៉ុណ្ណិម៉ាពោលឡើងនៅពេលឃើញអ្នកទាំងអស់គ្នា ស្ថិតនៅក្នុងការស្ងប់ស្ងៀមយូរហួសពេក

- ចាប់តាំងពីពេលនោះមក អាត្មាបានតាំងចិត្តយ៉ាងដាច់ខាតថា នឹងកាត់ផ្តាច់ការទាក់ទងជាមួយតណ្ហា និងមិនព្រមឲ្យខ្លួនធ្លាក់ទៅឋានកញ្ចុះ ទៅរកចំណីអាហារមកបម្រុងបម្រើវាតទៅទៀតឡើយ និងទុកឲ្យវាអត់ឃ្លានដល់ស្លាប់ទៅ ។ នៅទីបំផុត អាត្មាឈប់ដើរលេងរហោតរហូត ទៅទីកន្លែងដែលក្មេងៗគេទៅសប្បាយ គឺឈប់បានភ្លាមទាន់ចិត្ត តាំងចិត្តខំរៀនយ៉ាងពិតប្រាកដ ។ ដល់ពេលប្រឡងចេញបានពិន្ទុល្អគ្រាន់បើ ហើយគិតត្រឡប់មកប្រទេសថៃវិញ។

នៅពេលមកដល់ផ្ទះបានមិនទាន់ប៉ុន្មានថ្ងៃផង អាត្មាបានជំរាបអ្នកម្តាយថានឹងបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនា ។

- ល្អហើយកូនអើយ! អ្នកម្ដាយពោលឡើងដោយសេចក្ដីរីករាយ, ម៉ែតាំងចិត្តថានឹងប្រាប់កូនដែរ ប៉ុន្តែមិនចង់រំខានកូន នៅពេលនេះកូននិយាយចេញមកដោយខ្លួនឯងនេះជាការល្អហើយ ម៉ែនឹងចាត់ចែងរៀបចំរបស់របរផ្សេងៗទុកដាក់ឲ្យហើយ តើកូនចង់បួសនៅពេលណា?

- បើបានក្នុងពេលឆាប់ៗនេះ រឹតតែល្អប្រសើរ!

អ្នកម្ដាយ សម្លឹងមើលមកអាត្មាដោយអាការៈងឿងឆ្ងល់ តែគាត់ក៏ញញឹមឡើងវិញយ៉ាងរីករាយ ហើយពោលជាពាក្យលេងថា៖

- ហើយនឹងប្រញាប់សឹកមករៀបការឆាប់ៗមែនទេ? ល្អហើយកូន ប្រញាប់បួសហើយបានទទួលការចេះដឹងដូចចាស់ៗពីបុរាណ, បើ ជិន្តណា គូដណ្ដឹងរបស់កូនបានដឹងប្រហែលជាសប្បាយយ៉ាងណាទេ!

អាត្មាគិតក្នុងចិត្តថា បើសិនជាអ្នកម្ដាយបានដឹងនូវការពិតដែលសេចក្ដីតាំងចិត្តរបស់អាត្មា ប្រហែលលោកខូចចិត្តជាខ្លាំង អាត្មាមិនចង់បំផ្លាញនូវសេចក្ដីសុខរបស់អ្នកម្ដាយក្នុងពេលហ្នឹង ទើបមិនឆ្លើយតបអ្វីទាំងអស់ ៗ

- ល្អហើយចុះ! ល្ងាចនេះម៉ែនឹងនាំឯងទៅស្នើនឹងលោកគ្រូដើម្បីណាត់ថ្ងៃ ពេលវេលាហើយនិងរៀបចំចាត់បោះពុម្ពសំបុត្រអញ្ជើញភ្ញៀវ និងគ្រឿងរបស់អីវ៉ាន់ផ្សេងៗឲ្យបានគ្រប់នឹងបួស

- តែកូនមិនចង់បួសនៅវត្តជិតផ្ទះនេះទេ!

- ហ្អា! តើដូចម្ដេចទៅកូន? អ្នកម្ដាយសួរហើយ

សម្លឹងមើលមកអាត្មាដោយសេចក្ដីងឿងឆ្ងល់

- បើកូនបួសនៅវិត្តជិតផ្ទះ អាចនឹងមានបងប្អូនញាតិមិត្តទៅមករកសួរសុខទុក្ខជាញឹកញាប់ លុះត្រាតែមិនមានពេលវេលាថ្វាយបង្គំព្រះ ភាវនាធម៌ កូនចង់នៅស្ងាត់ៗ នឹងមានពេលវេលាសិក្សា និងបដិបត្តិឲ្យបានច្រើន

- តែបើកូននៅវិត្តជិតផ្ទះយើងនេះ ម៉ែនឹងមានឱកាសឲ្យកូនបានស្រួល កូននឹងមិនពិបាកក្នុងបច្ច័យ ៤ ម៉ែក៏នឹងបានបុណ្យច្រើនទៀតផង

- ម៉ែកុំព្រួយ ! កូនថាកូនឥតពិបាកទេ ព្រោះប្រទេសថៃជាប្រទេសកាន់ព្រះពុទ្ធសាសនា ពុទ្ធបរិស័ទជាអ្នកមានចិត្តបុណ្យទាន គេមិនបណ្ដោយឲ្យព្រះសង្ឃអត់ចង្ហាន់ស្លាប់ជាដាច់ខាត ជាពិសេសជាព្រះសង្ឃបដិបត្តិល្អ ៗ ការពិតបើសិនជាអត់ឃ្លាន ពិបាកខ្លះៗទៅ ក៏ល្អម្យ៉ាងដែរនឹងមានកម្លាំងចិត្តបដិបត្តិឲ្យបានល្អឡើងទៀត បើសំបូរណ៍មានអតិរេកលាភច្រើន ស្លូត សប្បាយ តែងខ្ជិលច្រអូស ហើយតែងតែគិតទៅរករឿងក្រៅអំពីវិស័យសមណៈភេទ ចំណែករឿងបានបុណ្យតិច ឬបុណ្យច្រើននោះ ម៉ែកុំព្រួយ ម៉ែមុខជាបានបុណ្យយ៉ាងពិតប្រាកដ ពីព្រោះកូននឹងតាំងចិត្តបដិបត្តិតាមព្រះធម៌ឲ្យបានយ៉ាងល្អហ្មត់ចត់ ហើយឧទ្ទិសនូវបុណ្យកុសលទាំងអស់ជូនដល់ម៉ែ ជួនកាលក៏អាចបានបុណ្យច្រើនជាងការថ្វាយនូវបច្ច័យ ៤ ទៅទៀតផង

អ្នកម្ដាយសម្លឹងមើលមកអាត្មា ដោយក្រសែភ្នែកពោរពេញទៅដោយសេចក្ដីពេញចិត្ត ហើយលោកពោល

ឡើងថា៖

- កូនរបស់ម៉ែបានប្តូរច្រើន ខុសគាលអំពីមុនៗ ដែលមិនសូវជ្រះថ្លាក្នុងព្រះពុទ្ធសាសនាទេ នៅពេលនេះត្រឡប់ជាចេះនិយាយរឿងរ៉ាវព្រះពុទ្ធដូចជាអ្នកប្រាជ្ញ ម៉ែសប្បាយចិត្តណាស់ ល្អហើយចុះ! កូនចង់បួសនៅឯណា ជាមួយអង្គណាក៏ស្រេចតាមចិត្តកូនចុះ ចូរប្រាប់មកម៉ែនឹងចាត់ចែងរៀបចំឲ្យកូន

- កូនបានឮអំពីមិត្តភក្តិខ្លះថា នៅឯព្រះខ្ចងមានវត្តថ្មីមួយកន្លែង ស្ថិតនៅក្នុងព្រៃសង្កែ ឆ្ងាយអំពីភូមិអ្នកស្រុក មានលោកគ្រូកម្មដ្ឋានមួយអង្គគង់នៅវត្តហ្នឹង បានឮថា លោកជាសង្ឃដែលប្រាថ្នាតិច ឆាន់ចង្ហាន់តែមួយពេល ទ្រព្យសម្បត្តិរបស់លោកមានតែអដ្ឋបរិក្ខារ[១] ព្រះអង្គលោកបដិបត្តិពិតប្រាកដ ហ្មត់ចត់គួរឲ្យជ្រះថ្លា លុះដល់មានមិត្តខ្លះប្រាប់ថា លោកបានសម្រេចជាព្រះអរហន្ត ហើយកូនមានចិត្តជ្រះថ្លានូវភិក្ខុសង្ឃអង្គនោះ បើម៉ែយល់ឃើញដូចកូនដែរ កូនចង់ទៅបួសនៅជាមួយលោកអង្គនោះ

- អើ! រឿងនេះម៉ែក៏ធ្លាប់បានឮមកដែរដូចគ្នា តែមិនទាន់បានជួបលោក ដូចជាលោកទើបនឹងនិមន្តធ្វើធុតង្គមក

---

(១) អដ្ឋបរិក្ខារ គ្រឿងប្រើប្រាស់ ២ យ៉ាង សម្រាប់ព្រះពុទ្ធនិងបព្វជិតពុទ្ធសាសនិកត្រូវមានគឺ សង្ឃាដី, ឧត្តរាសង្គ (ចីពរ), អន្តរវាសក (ស្បង់), កាយពន្ធនៈ (វត្ថពន្ធចង្កេះ), បាត្រ (ព្រមទាំងស្លោកនិងឃោគផង), កាំបិតកោរ (ព្រមទាំងថ្មសំលៀងផង), ម្ជុល (ព្រមទាំងបំពង់ម្ជុលនិងចេសផង), តម្រងទឹក (ទាំងតួនិងសំពត់សម្រាប់ត្រងផង); ឯបរិក្ខារក្រៅពីនេះក៏ជាគ្រឿងប្រើប្រាស់ដែរ ហៅថា បរិក្ខារពិសេស ពុំរាប់ថាជា អដ្ឋបរិក្ខារឡើយ ។

នៅប្រចាំទីនោះប្រហែលជាពីរឆ្នាំនេះឯង តែម៉ែឪដូចជាបាន
ឮដឹងមកថា លោកនៅទីនោះប្រហែលក្នុងវស្សានេះទេណាំ
កូន ពេលចេញវស្សាហើយ ព្រះអង្គនឹងចេញធុតង្គចូលក្នុង
ព្រៃភ្នំជានិច្ច រហូតដល់ពេលជិតចូលព្រះវស្សាទើបលោក
ត្រឡប់មកវត្តវិញម្ដងទៀត ពេលនេះទើបតែខែឧសភា
ប៉ុណ្ណោះ នៅពីរខែឆ្ងាយទៀតទើបដល់ព្រះវស្សា ម៉ែឪបារម្ភ
ថាក្រែងលោកមិនគង់នៅបន្តទៅទៀតផង

នៅពេល បានស្ដាប់រឿងរ៉ាវរបស់ព្រះសង្ឃអង្គនោះ
អំពីមាតា សេចក្ដីជ្រះថ្លានិងសទ្ធាដែលមាននៅហើយ បាន
កើនឡើងបន្ថែមទៀត ទើបសម្រេចចិត្តប្រាប់មាតាថា៖

- កូនចង់បួសរៀនជាមួយលោកអង្គនោះ បើព្រះអង្គ
មិនទាន់និមន្តត្រឡប់មកវិញទេ កូនសុខចិត្តនៅចាំលោក
លុះត្រាលោកនិមន្តត្រឡប់មកវិញ តើយើងគួរតែទៅមើល
លោកសវត្តសិនល្អឬទេ នឹងបានដឹងថាលោកនៅឬមិននៅ

មាតាអង្គុយស្ងៀមត្រិះរិះមួយសន្ទុះ ហើយគាត់ក៏
ពោលឡើងថា៖

- យើងគិតដូច្នេះវិញ ម៉ែនឹងទូរស័ព្ទទៅសួរលោកឃុន
នាយបានយិន មើលសិន គាត់ប្រហែលជាដឹង ពីព្រោះគាត់
ទៅមកវត្តហ្នឹងញឹកញាប់ណាស់

លទ្ធផលនៃការទូរស័ព្ទ បានប្រាកដមកថាលោកមិន
គង់នៅក្នុងវត្តទេ លោកបាននិមន្តធ្វើធុតង្គទៅហើយតាំងតែ
ពីខែឧស្ភម្ព៉ះ ៗ លោកបានប្រាប់ថានឹងនិមន្តទៅទិសឈៀសាន
ប៉ុន្តែគ្មាននរណាដឹងថា នៅពេលនេះព្រះអង្គនៅទីណា

តំបន់ណាទេ ៗ អាត្មានឹកខុសបំណាងខ្លះ តែតាំងចិត្តថានឹងនៅរង់ចាំលោក ៗ

ពេលល្ងាចថ្ងៃមួយ អាត្មាបានទៅជួបនឹងគូដណ្ដឹង ហើយប្រាប់នាង នូវសេចក្ដីតាំងចិត្តដែលនឹងបួសដល់គេជាលើកដំបូង៖

- ជិន្តណា ថ្ងៃនេះខ្ញុំមានរឿងសំខាន់ដែលនឹងប្រាប់អ្នក
- រឿងស្អីទៅចាស៎! នាងសួររាងដូចជាភ្ញាក់ផ្អើល
- គឺខ្ញុំតាំងចិត្តនឹងបួសជាព្រះសង្ឃក្នុងពេលឆាប់ៗនេះ

ជិន្តណា នៅស្ងៀមមួយសន្ទុះ ហើយនិយាយឡើងថា៖

- ក៏ល្អហើយអញ្ចឹងនោះលោកបង! បួសរៀន អានសរសេរ ហើយសុំសឹកចេញមកមានគ្រួសារ ត្រូវហើយទៅតាមទំនៀមរបស់ចាស់ទុំ ជិន្ត សូមអនុមោទនាជាមួយផង! នឹងបួសនៅវត្តជិតផ្ទះមែនឬចាស៎?
- មិនមែនទេ នឹងបួសនៅវត្តថ្មីមួយកន្លែង នៅឆ្ងាយព្រះខ្ញុំ ខ្ញុំក៏មិនដែលបានទៅដែរ មិនទាន់ដឹងថានៅឯណាដូចគ្នា

ជិន្តណា ធ្វើមុខឆ្ងល់ហើយសួរថា៖

- ដូចម្ដេចបានជាទៅបួសនៅឯវត្តនោះផង មានហេតុផលអ្វីឬ?
- បានដឹងថា មានលោកគ្រូអាចារ្យ លោកបដិបត្តិហ្មត់ចត់ គង់នៅក្នុងវត្តហ្នឹងមួយអង្គ បើសិនជាបានបួសជាមួយនឹងលោក ការបួសនេះនឹងបានផលកាន់តែប្រសើរ

ឡើង បួសរៀនផង ហើយចង់ឲ្យបានប្រយោជន៍ច្រើនផង មិនចង់បួស គ្រាន់តែជាពិធីប្រពៃណីដូចជាមនុស្សភាគច្រើន គេនាំគ្នាធ្វើនោះទេ

- តើលោកបងចង់បួសយូរប៉ុណ្ណា ? ជិន្តណាសួរ

ពាក្យសួររបស់គេ ធ្វើឲ្យអាត្មាត្រិះរិះយ៉ាងយូរតែម្តង ពីព្រោះបើនឹងប្រាប់នាងទៅតាមការពិតថា នឹងបួសរហូត ទៅប្រហែលគេខូចចិត្តច្រើន តែបើនឹងប្រាប់ថាបួសមួយ វស្សាក៏មិនត្រូវនឹងសេចក្តីតាំងចិត្តនូវការពិតរបស់អាត្មា

- ដូចម្តេចបានជានៅស្ងៀមចាំគិតផងលោកបងចា៎ ? ជិន្តណាសួរដោយទឹកមុខឆ្ងល់, លោកបងនៅមិនទាន់បាន គិតមែនទេ ថានឹងបួសយូរប៉ុណ្ណា ?

អាត្មាបានតួរទ្រូង ប្តូរបរិយាកាសដោយការសើច យ៉ាងត្រជាក់ចិត្ត ហើយពោលថា៖

- អ៊ើ ជិន្តណា ! បើសិនជា “ណា” នេះគ្រាន់តែសន្មតថា បើសិនជាខ្ញុំបួសហើយមិនសឹក តើនាងគិតយ៉ាងណា ?

ជិន្តណាអង្គុយសញ្ជឹងគិត ហើយពោលថា៖

- កុំសន្មតអី “ជិន្ត” ក៏មិនចង់ឮរឿងសន្មត រឿងព្រួយ យ៉ាងនេះទេ !

- ធ្វើជាមនុស្សព្រលឹងតិចទៅកើត ជិន្តណា រឿងនេះ យើងគ្រាន់តែសន្មត និយាយគ្នាលេងសប្បាយតែប៉ុណ្ណោះ ងង កុំគិតយកជាសាច់ការអ្វី ចូរនាងប្រាប់មកមើលថា ប្រ-សិនជាលោកបងបួសហើយមិនសឹក តើនាងគិតយ៉ាងណា

- លោកអាចសាកល្បងចិត្ត “ជិន្ត” មើលឬមែនទេ ?

នាងស្អៀងគស្សួរ, លោកបងនៅមិនទាន់ច្បាស់ក្នុងចិត្ត ក្នុងសេចក្តីស្រឡាញ់របស់ "ជិន្ត" ប្រសិនលោកបងបួសមិនសឹក "ជិន្ត" ក៏នឹងត្រូវធ្វើអ្វីមួយ៉ាង ដែលនឹងពិសោធន៍ឲ្យឃើញនូវសេចក្តីស្រឡាញ់ដែលបរិសុទ្ធមិនផ្លាស់ប្តូររបស់ "ជិន្ត"

- "ជិន្ត" នឹងធ្វើយ៉ាងណា ? អាត្មាសួរដោយសេចក្តីរីករាយ

- ខ្ញុំមិនទាន់ឆ្លើយក្នុងពេលនេះទេ ពីព្រោះវាជារឿងសំខាន់របស់អនាគតដែលនៅវែងឆ្ងាយ ចូរលោកបងចាំមើលខ្លួនឯងចុះថាតើ "ជិន្ត" នឹងធ្វើយ៉ាងណា ?

- យ៉ាងណាៗក៏ដោយ យើងក៏ព្រមទទួលហើយថា វាជារឿងគ្រាន់តែសន្មត "ជិន្ត" នឹងប្រាប់ខ្ញុំក្នុងពេលនឹទ្បូវនេះមិនបានទេឬ ថា "ជិន្ត" នឹងធ្វើយ៉ាងណា ?

- បើលោកបងចង់ដឹងពិតមែន "ជិន្ត" នឹងប្រាប់បាន តែសូមឲ្យគ្រាន់តែជារឿងសន្មតទេណា បើសន្មតថាលោកបងបួសហើយមិនសឹក "ជិន្ត" ក៏សូមនៅម្នាក់ឯងយ៉ាងនេះអស់មួយជីវិត ហើយនៅពេលដល់វេលាដ៏សមគួរ "ជិន្ត" នឹងបួសជាដូនជីដែរ

ពាក្យឆ្លើយរបស់គូដណ្តឹង គួរនឹងធ្វើឲ្យអាត្មាកើតសេចក្តីរីករាយក្នុងការស្រឡាញ់ប្តូរផ្តាច់របស់គូដណ្តឹង បានធ្វើឲ្យចិត្តត្រឡប់ជាមានសេចក្តីស្រងូតស្រងាត់យ៉ាងខ្លាំងទៅវិញ ។

ពេលល្ងាចថ្ងៃហ្នឹង អាត្មាបាននាំ ជិន្តណា ទៅបរិភោគអាហារនៅកន្លែងរាត្រីកំសាន្តមួយកន្លែងក្នុងទីក្រុង

ដើម្បីប្ដូរបរិយាកាសដែលធ្ងន់ធ្ងរនេះ ឲ្យបានធូរស្រាលខ្លះ តែស្ថានការណ៍ត្រឡប់ទៅជាធុនជាបន្ថែមទៀត ពីព្រោះ បរិយាកាសអឹកធឹកនៅក្នុងក្លិប សម្លេងតន្ត្រីដែលគេនិយម ល្បីល្បាញថាពីរោះខ្លាំងណាស់ ភាពកំលោះក្រមុំសង្គមជាន់ខ្ពស់អង្គុយកៀកគើយគ្នា ឱបគ្នា នៅពេញទីកន្លែងនោះងង ស្រែកឡូឡាដោយសម្លេងស្រីងស្រោ មិនបានធ្វើឲ្យអាត្មាកើតនូវសេចក្ដីបានធូរស្រាលក្នុងចិត្ត សូម្បីតែបន្តិចបន្តួច ផ្ទុយទៅវិញអាត្មាដូចជាតឹងទ្រូង ដូចជាធ្លាក់ទៅក្នុងគុកដែលមានអ្នកជាប់ឃុំគ្នាឲ្យអាណិត កំពុងតែត្រូវនាយតណ្ហាបង្ខំ ឲ្យបម្រុងបម្រើវាយ៉ាងវេទនា ៗ

- លោកបងប្ដូរផ្លាស់ទៅច្រើន, ជិន្តណា ពោលឡើង, មកពីយើងបែកគ្នានៅយប់នេះ ហើយ“ជិន្ត”ខ្វល់ចិត្តណាស់ បើលោកបងនឹងបួសមិនសឹកមែនដូចយើងបានសន្យា...

# ដឹងមិនដល់... ឆ្ងល់មិនអស់

| | |
|---|---|
| ***អ្វីណាដែលចិត្តដឹងមិនដល់*** | ***នាំឲ្យចម្ងល់កើតសង្ស័យ*** |
| ***ពោលបដិសេធភ្លាមមិនប្រពៃ*** | ***ពិចារណាយប់ថ្ងៃតាមហេតុការណ៍។*** |
| ***ឲ្យឃើញថាពិតឬមិនពិត*** | ***បច្ច័យនាំចិត្តអស់សង្កា*** |
| ***កុំទាន់ថ្កោលទោសតិះដៀលថា*** | ***ដោយខ្វះបញ្ញាការយល់ដឹង ៕*** |

ដោយឧបាសក មុិញ សារ៉ាង

# ៣៤. ភិក្ខុចម្លែក

ពីមកទៀតប្រហែលជា ២ អាទិត្យ នៅពេលដែលអាត្មាកំពុងលក់យ៉ាងស្រួលនៅលើកន្លែងគេងនាពេលព្រឹក ត្រូវម្តាយខ្ញុំគាត់ដាស់ឲ្យភ្ញាក់ឡើងយ៉ាងប្រញាប់ប្រញាល់ ៗ

- កូន! មានព្រះភិក្ខុសង្ឃចម្លែកមួយអង្គនិមន្តមកឈរចាំបិណ្ឌបាតនៅមុខផ្ទះយើង, អ្នកម្តាយប្រាប់អាត្មាដោយការភ្ញាក់ផ្អើល, ម៉ែបានប្រាប់ក្មេងឲ្យយកចង្ហាន់ទៅដាក់បាត្រហើយ តែលោកមិនព្រមនិមន្តទៅទេ លោកប្រាប់ថាលោកចង់ជួបនឹងកូនប្រុសម្ចាស់ផ្ទះ ៗ នៅពេលនាង "តែវ" មកប្រាប់ម៉ែៗក៏ប្រញាប់មកដាស់កូនភ្លាម ចូរកូនទៅជួបនឹងលោកបន្តិចទៅកូន ជួនកាលលោកអាចស្គាល់កូនផងក៏មិនដឹង?

- ឥឡូវនេះលោកនៅឯណាម៉ែ? អាត្មាសួរដោយរបៀបភ្ញាក់ផ្អើល

- លោកនៅឈរឯរបងមុខផ្ទះណា៎កូន!

- បើដូច្នេះសូមម៉ែទៅនិមន្តព្រះអង្គ ឲ្យលោកចូលមកគង់ក្នុងបន្ទប់ទទួលភ្ញៀវសិនទៅ ខ្ញុំប្រញាប់ទៅលុបលាងមុខរៀបចំខ្លួនហើយនឹងទៅជួបលោក ហើយអ្នកម៉ែមិនដែលស្គាល់លោកទេឬ?

- មិនស្គាល់ទេកូន! ហើយម៉ែមិនដែលបានជួបលោកពីមុនមកទេ ម៉ែគិតថាប្រហែលជាកូនទេស្គាល់លោកនោះ

- ខ្ញុំក៏រកនឹកមិនឃើញថាធ្លាប់ស្គាល់លោកនៅទីណាទេ តាមពិតខ្ញុំក៏មិនដែលស្គាល់ ទាក់ទងជាមួយនឹងព្រះសង្ឃនៅទីណា ក្រៅអំពីលោកចៅអធិការវត្តនៅជិតផ្ទះ ល្អហើយចុះសុំប្រញាប់ទៅនិមន្តលោកចុះ ហើយកុំភ្លេចរកទឹកតែ ឬក៏កាហ្វេប្រគេនលោកផងណា!

អាត្មាក៏ប្រញាប់ប្រញាល់លុបលាងមុខ រៀបចំខ្លួន ហើយក៏ចុះទៅជួបព្រះសង្ឃចម្លែកនោះ ។ នៅពេលអើត ចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ ក៏បានជួបនឹងព្រះសង្ឃមួយអង្គព្រះជន្មប្រហែលជា ៤៥ ទៅ ៥០ វស្សា អង្គុយបត់ជើងឈ្វាកព្រះភក្ត្រស្ងៀម នៅលើកៅអីទទួលភ្ញៀវ គ្រងចីវរពណ៌ក្រមៅ ហើយឱបបាត្រនៅលើភ្លៅ ។ អាត្មាអង្គុយចុះក្រាបលើព្រំក្រាលភ្លារ ថ្វាយបង្គំលោកហើយសួរលោកថា៖

- ព្រះគុណម្ចាស់ចង់ជួបខ្ញុំកូណាមែនឬទេទាន?

ព្រះសង្ឃចម្លែក លោកងើយព្រះភក្ត្រឡើងយឺតៗ មើលមកអាត្មា ក្រសែភ្នែកពោរពេញដោយក្តីមេត្តា ករុណា ហើយលោកឆ្លើយដោយសម្លេងតិចៗថា៖

- មែនហើយ!

- សូមអភ័យទោសទាន ខ្ញុំកូណាចាំមិនបានទេទានថាធ្លាប់បានជួប ឬស្គាល់ព្រះតេជគុណនៅទីណាទេទាន!

- នឹងថាមិនដែលស្គាល់គ្នាក៏មិនមែន នឹងថាស្គាល់ក៏មិនពិត តែការនោះមិនសំខាន់អ្វីទេ សូមឲ្យតែយើងបានស្គាល់គ្នានៅពេលនេះក៏បានហើយ អាត្មាមកពេលនេះគឺតាំងចិត្តនឹងមកអនុគ្រោះញោមដោយចំពោះ

- មកអនុគ្រោះខ្ញុំម្ចាស់! អាត្មាពោលចេញមកដោយសេចក្ដីសង្ស័យនូវពាក្យពោលរបស់ព្រះភិក្ខុចម្លែក, ព្រះអង្គនឹងអនុគ្រោះខ្ញុំករុណាក្នុងរឿងអ្វីដែរគុណម្ចាស់?

- បាននឹងថាញោមចង់សូមបួសមែនឬ? ព្រះសង្ឃចម្លែកសួរទាំងញញឹម

ពាក្យសួររបស់លោក ធ្វើឲ្យអាត្មាកើតសេចក្ដីអស្ចារ្យក្នុងចិត្ត លុះត្រាតែព្រឺក្បាលឡើងខ្វាក ពីព្រោះមិនដឹងថាព្រះភិក្ខុចម្លែកនេះ លោកដឹងបានដូចម្ដេចថាអាត្មានេះចង់សូមបួស អាត្មាទើបតែនិយាយរឿងនេះជាលើកដំបូងជាមួយអ្នកម្ដាយហើយ និងគូដណ្ដឹងកាលពី ២ - ៣ ថ្ងៃមុននេះឯង នៅមិនទាន់បាននិយាយរឿងនេះ ប្រាប់ដល់នរណាឡើយ

- លោកម្ចាស់បានជ្រាបយ៉ាងណាថា ខ្ញុំករុណាចង់សូមសាងផ្នួស? អាត្មាសួរដោយសេចក្ដីងឿងឆ្ងល់

- រឿងនេះហាក់ដូចជាកើងបន្តិច, ព្រះភិក្ខុចម្លែកពោលឡើងដោយសម្លេងស្មើៗថា ៖ ថ្ងៃក្រោយញោមនឹងបានជ្រាបដោយខ្លួនឯងជាមិនខានថាតើ អាត្មាដឹងបានយ៉ាងណានៅក្នុងថ្ងៃនេះ អាត្មាចង់ដឹងនូវសេចក្ដីតាំងចិត្តរបស់ញោមថាតើញោមចង់ក្លាយទៅជាបព្វជិតពិតមែនឬទេ?

- ខ្ញុំករុណាពិតជាចង់សូមបួស មែនទាន!

- ប្រាប់អាត្មាបន្តិចបានទេថា ហេតុដូចម្ដេចបានជាញោមចង់បួស?

- ខ្ញុំករុណា បានពិចារណាយ៉ាងល្អិតល្អន់ថា លុះត្រាកើតសេចក្ដីនឹងពិតច្បាស់ហើយ តាំងតែពីនៅស្រុកក្រៅថា

ជីវិតនេះមិនមានអ្វី មានតែការតស៊ូរើបម្រះ ដើម្បីស្វែងរក បច្ច័យផ្សេងៗមកផ្គត់ផ្គង់នូវសេចក្ដីចំណង់ បើមិនបានសម ដូចបំណងនោះទេក៏ទៅជាទុក្ខ បើបានដូចចំណង់ហើយគឺ មានសេចក្ដីសុខ សេចក្ដីពេញចិត្តមួយភ្លែត នៅមិនយូរ ប៉ុន្មានក៏ចង់ទៀត ហើយចំណង់នោះខ្លាំងឡើងជាងពីមុន ត្រូវប្រឹងប្រែងខ្វាយខ្វល់រកមកឲ្យសេចក្ដីចំណង់ទៀត មក បំពេញចំណង់របស់ខ្លួនមិនទាន់បានគ្រប់គ្រាន់ផង ត្រូវទៅ រកនូវសេចក្ដីចង់បានរបស់អ្នកដទៃៗទៀត នៅទីបំផុតក៏មិន អាចនឹងពេញនូវចំណង់នោះបាន ក៏ត្រូវស្លាប់យ៉ាងអត់ឃ្លាន ជាមួយគ្នាប៉ុណ្ណោះ តាំងតែកើតមក ខ្ញុំកូណាមិនដែលមាន សេចក្ដីសុខពិតៗសោះឡើយ ហើយខ្ញុំកូណាមិនជឿថា នឹង មានឃរាវាសណាមួយមានសេចក្ដីសុខយ៉ាងពិតប្រាកដ ពីព្រោះដែលបានឃើញមិនថាជាសេដ្ឋីឬអ្នកសូមទានម្នាក់ៗ តស៊ូននៀលបម្រះ ដើម្បីតបស្នងនូវចំណង់គ្រប់ៗគ្នាទាំង-អស់ ខ្ញុំកូណាមើលមិនឃើញចំណុចផ្លូវណាផ្សេងៗក្នុង ជីវិតឃរាវាស ខ្ញុំកូណាបាននឹងថា ជីវិតជាសមណៈ ជាជីវិត ដែលឈប់តស៊ូននៀល បម្រះដើម្បីចិញ្ចឹមសេចក្ដីចំណង់ ជាជីវិតដែលស្ងប់សុខ ទើបខ្ញុំកូណាចង់សូមបួស

ភិក្ខុចម្លែកគង់ស្ងៀម ស្ដាប់អាគន្តុកនិយាយ ព្រះអង្គ បានតាំងចិត្តស្ដាប់តាំងតែពីដើមដំបូង នៅពេលអាគន្តុកឈប់ និយាយ ទើបលោកមានសង្ឃដីកាឡើងថា៖

- ញោមកើតសម្មាទិដ្ឋិ គឺសេចក្ដីឃើញត្រូវ តាមពាក្យ ប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ហើយ ពីព្រោះព្រះបរម-

សាស្តាសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ទុកមកថា ជីវិតឃរាវាសរីក់ជាមួយកាម មានសេចក្តីទុក្ខច្រើន មានសេចក្តីខ្វះខាតច្រើន មានសេចក្តីសុខតិច ប្រៀបដូចជាឆ្កែដែលមានសេចក្តីឃ្លានមកបៀតបៀន ហើយទៅឈរក្បែរជ្រុញរបស់គោឃាតៗ ក៏បោះឆ្អឹងដែលគេយកសាច់ចេញអស់ហើយបោះឲ្យឆ្កែ ឆ្កែនោះក៏រត់ចូលទៅខាំមកអង្គៀម ស៊ីនូវឆ្អឹងនោះ ហើយយល់ថាឆ្ងាញ់ណាស់ ពីព្រោះទឹកមាត់របស់ខ្លួនឯង ។ ប្រការមួយទៀត គឺសុខកើតអំពីកាមប្រៀបដូចដុំសាច់ដែលសត្វខ្លែងឬសត្វត្មាតពាំហើរទៅ មាន សត្វខ្លែងសត្វត្មាតមួយហ្វូងធំ ហើរតាមទៅដើម្បីដណ្តើមយកដុំសាច់នោះ ។

ម្យ៉ាងទៀត សុខដែលកើតអំពីកាម ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ប្រៀបធៀបទៅនឹងគប់ភ្លើង ដែលបុរសកាន់ដើរបញ្ច្រាសខ្យល់ គេនឹងបានទទួលនូវពន្លឺត្រឹមតែបន្តិចបន្តួច តែនឹងបានទទួលនូវការលំបាកច្រើនអំពីគប់ភ្លើងនោះ មានផ្សែងនិងកម្តៅដែលជះមកលើផ្ទៃមុខ ។

ប្រការមួយទៀត ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ប្រៀបធៀបសេចក្តីសុខដែលកើតអំពីកាម ដូចកាលដែលបុរសយល់សប្តិឃើញសួនដែលជាទីរីករាយ តែនៅពេលភ្ញាក់ឡើង មិនឃើញមានអ្វីសោះ ។

ប្រការមួយទៀត ព្រះដ៏មានព្រះភាគទ្រង់ប្រៀបសេចក្តីសុខដែលកើតអំពីកាមដោយរបស់ខ្ចីគេ ដូចបុរសដែលខ្ចីនូវសម្បត្តិកែវមណី របស់មានតម្លៃផ្សេងៗអំពីអ្នក

ផងទេងាក់លើរថយន្តបរទៅផ្សារនៅពេលមនុស្សទាំងឡាយ ឃើញហើយក៏នាំគ្នាស្រែកសរសើរថា គេក៏មានអ្វីម្លេះហ្ន៎ តែមិនយូរប៉ុន្មានម្ចាស់ដើមគេមកនាំយកទ្រព្យរបស់គេទៅវិញ...

ការដែលញោមឃើញទោសរបស់កាមហើយប្រាថ្នានិងចេញបួសនេះ គិតថាត្រូវហើយ ត្រឹមត្រូវតាមពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះបរមសាស្តាហើយ អាត្មាជឿថាជីវិតព្រហ្មចរិយ្យរបស់ញោមនឹងចម្រើនទៅមុខយ៉ាងពិតៗ ។

អាត្មាអង្គុយនៅស្ងៀម ចាំស្តាប់ពាក្យបរិយាយរបស់ព្រះសង្ឃចម្លែក ដោយសេចក្តីសទ្ធាជ្រះថ្លាថែមឡើងទៀតយ៉ាងខ្លាំង នៅពេលពិចារណាមើលព្រះពុទ្ធបទដែលលោកលើកយកមកពោលប្រៀបធៀប ជាមួយសេចក្តីសុខខាងឃរាវាសដែលអាត្មាធ្លាប់បានទទួលមក ដូចជាសេចក្តីពិតយ៉ាងគួរឲ្យអស្ចារ្យពែន

- លោកម្ចាស់ ! អាត្មាពោលឡើងក្រោយពីបានអង្គុយស្ងៀមគិតអស់ពេលយ៉ាងយូរ ខ្ញុំកូណាមិនដែលបួសហើយមិនសូវមានការចេះដឹងទាក់ទង នឹងជីវិតអ្នកបួសទេ ខ្ញុំកូណាចង់ដឹងថា នៅពេលខ្ញុំកូណាបានបួសហើយតើខ្ញុំកូណានឹងមានសេចក្តីសុខពិតឬទេទានម្ចាស់ ?

ព្រះសង្ឃចម្លែកញញឹមហើយឆ្លើយថា ៖

- ការដែលមានសេចក្តីសុខ ឬមិនសុខនោះស្រេចនៅលើចិត្តរបស់អ្នកបួស មុនដំបូងអ្នកបួសត្រូវមានសម្មាទិដ្ឋិគឺសេចក្តីយល់ត្រូវ មានទស្សនៈគតិដែលត្រឹមត្រូវចំពោះជីវិត

និងលោកជាមុនសិន សេចក្តីយល់ត្រូវក៏គឺឃើញនូវទុក្ខរបស់ជីវិតមនុស្ស ដែលរស់នៅបានក្នុងពេលបច្ចុប្បន្ននេះពោរពេញទៅដោយសេចក្តីទុក្ខ ។ ព្រះអង្គមានព្រះភាគទ្រង់ត្រាស់សម្តែងនូវទុក្ខ ទុកមកមាន ១០ ប្រការគឺ៖

**និពទ្ធទុក្ខ** ទុក្ខជាប្រចាំ បានដល់ការមិនសប្បាយកាយមិនសប្បាយចិត្ត ដែលកើតអំពីត្រជាក់ ក្តៅគម្លាន ស្រេកឈឺបន្ទោបង់តូចធំ ឈឺចុករោយតាមចំណែកផ្សេងៗនៃរាងកាយ ទុក្ខបែបនេះជាទុក្ខប្រចាំកាយគ្រប់គ្នា គ្រប់សត្វដែលមានរូបរាងកាយ ត្រូវទទួលនូវទុក្ខបែបនេះប្រហែលៗគ្នាដូចជាការឃ្លាន គ្រប់ៗគ្នាត្រូវឃ្លានពេលឃ្លានឡើងត្រូវកើតទុក្ខ ត្រូវប្រញាប់រកថ្នាំកែ គឺអាហារមកបរិភោគកែរោគឃ្លាន ។ មនុស្សម្នាក់ៗត្រូវលេបថ្នាំកែរោគឃ្លានក្នុងមួយថ្ងៃ ២ ឬ ៣ ដង ហើយត្រូវព្យាបាលរាល់ថ្ងៃលុះដល់ពេលស្លាប់មិនមាននរណាម្នាក់អាចយកឈ្នះរោគឃ្លាននេះបានឡើយ សូម្បីជាសេដ្ឋីមានទ្រព្យរាប់មិនអស់ ភ្ញាក់ពីព្រលឹមឡើងត្រូវប្រញាប់លេបថ្នាំកែរោគឃ្លានភ្លាម ដូចគ្នានឹងអ្នកសូមទានម្នាក់ ព្រោះហេតុនេះហើយ ទើបព្រះពុទ្ធអង្គទ្រង់ត្រាស់ទុកថា៖

## ជិឃច្ឆា បរមា រោគា

### ការស្រេកឃ្លានគឺជារោគដ៏ធំ

**ព្យាធិទុក្ខ** ការមិនស្រួលកាយ មិនសប្បាយចិត្តដែលកើតអំពីរោគភ័យ គ្រុន ឈឺចុកចាប់ផ្សេងៗ ញ្រោមក៏នឹង

ហើយថា មានសត្វតូចៗដែលមើលមិនឃើញរូប វាមានរស់រានរស់នៅគង់នៅក្នុងអាកាស ក្នុងទឹក ក្នុងសំពត់អាវ ក្នុងផ្ទះ ដែលអាស្រ័យនៅក្នុងច្រមុះ នៅក្នុងមាត់ ក្នុង ពោះវៀន ហើយនៅតាមអវយវៈផ្សេងៗរបស់យើង ដោយមេរោគទាំងអស់នេះវាឃើញមនុស្សយើង ជាអាហារដែលឆ្ងាញ់របស់វា វាក៏លើកគងទ័ពចូលមកវាយលុកនូវចំណុចផ្សេងៗរបស់យើងគ្រប់ពេលវេលា ដោយសារតែទាំងពីរខាងនៅមានកម្លាំងអាចតតាំងគ្នាបាន ទើបយើងមិនទាន់ឈឺ នៅពេលណាកម្លាំងទប់ទល់របស់យើងខ្សោយ គងទ័ពរបស់សត្រូវដែលមើលមិនឃើញរូបរាង នឹងប្រមូលគងកម្លាំងវាចូលវាយដោយគ្មានប្រណីមួយរំពេច ហើយយើងនឹងដួលដេកឈឺអាចចុះចាញ់លុះដល់បាត់បង់ជីវិត ។ នៅពេលថ្ងៃណាមួយ មនុស្សក្នុងលោកត្រូវសត្រូវដែលមើលមិនឃើញរូបមកសម្លាប់មិនតិចទេ មិនមាននរណាអាចយកឈ្នះសត្រូវទាំងនេះបានដាច់ខាត ទោះបីជាវិជ្ជាពេទ្យចម្រើនដល់ណា រោគ ការឈឺចាប់ក៏ចម្រើនប៉ុណ្ណោះដែរ ។

**សតាវទុក្ខ** សេចក្ដីមិនសប្បាយកាយ មិនស្រួលចិត្តដែលកើតអំពី ជាតិ ជរា ព្យាធិ មរណៈ ការកើតជាទុក្ខ ការចាស់ជាទុក្ខ ការឈឺថ្កាត់ជាទុក្ខ ការស្លាប់ក៏ជាទុក្ខ

- លោកម្ចាស់! អាត្មាសួរឡើងដោយសេចក្ដីសង្ស័យ សេចក្ដីចាស់ សេចក្ដីស្លាប់ដែលថាជាទុក្ខនោះ ខ្ញុំកូណាអាចមើលឃើញបាន តែដែលថាការកើតជាទុក្ខនោះ មិនទាន់

មើលឃើញច្បាស់ ពីព្រោះមនុស្សគ្រប់ៗគ្នាចង់កើតណាស់ សប្បាយចិត្តនៅពេលមានការកើត ដូចម្ដេចបានជាព្រះអង្គចាត់ថាជាទុក្ខផង ?

- ពិតដូចញោមថាមែន! ការកើតមិនគួរចាត់ជាទុក្ខទេ ពីព្រោះបានមកជាការចម្រើន តែបើគិតមើលឲ្យបានហ្មត់ចត់ក៏នឹងឃើញថា ការកើតជាទុក្ខមែន ដូចលោកបានពោលទុកមក ញោមក៏ព្រមទទួលហើយថាការចាស់និងការស្លាប់ជាទុក្ខ តែអាត្មាសូមសួរថា មនុស្សយើងបើមិនកើត តើមានចាស់ មានស្លាប់ដែរឬទេ ?

- មិនមានទេ! អាត្មាឆ្លើយ, ហើយចាប់ផ្ដើមយល់ឃើញថា ការកើតជាទុក្ខពិតមែន

- ពីព្រោះមនុស្សកើតមកហើយ ទើបមានការចាស់ ការស្លាប់មែនទេ ?

- មែនព្រះតេជគុណម្ចាស់!

- បើដូច្នេះ ការកើតក៏ជាដើមហេតុរបស់ទុក្ខ ជាទុក្ខធំខ្លាំងជាងការចាស់ និងការស្លាប់ទៅទៀត ប្រៀបដូចដើមឈើមានពិស ឫសក៏មានពិស ដើមក៏មានពិស យើងនឹងស្អប់ខ្លាចចំពោះតែដើម និងមែកសន្លឹក មិនខ្លាចឫស តើជាការត្រឹមត្រូវឬទេ ? បើនឹងនាំគ្នាមើលឲ្យល្អិតល្អន់ទៅតាមការពិត យើងក៏បែកមិនដាច់ថា កើតនៅទីណា ស្លាប់នៅទីណា បើតាមសេចក្ដីនេះ កើតនៅទីណាចាស់ក៏នៅទីនោះ ចាស់នៅកន្លែងណា ស្លាប់ក៏នៅកន្លែងនោះ ស្លាប់នៅទីណា កើតក៏នៅទីនោះ ។ កើត ចាស់ ស្លាប់ នៅក្នុងខ្សែជីវិត

ជាមួយគ្នា ការដែលយើងនិយាយថា មនុស្សកើតថ្ងៃនោះ ចាប់ផ្ដើមចាស់ពេលអាយុ ៤០ ឆ្នាំហើយស្លាប់នៅពេល អាយុ៦៥ឆ្នាំនោះជាការនិយាយយ៉ាងស្មានៗ ដើម្បីឲ្យយល់ ទៅតាមសន្មតរបស់លោកប៉ុណ្ណោះ ។ បើនឹងនិយាយឲ្យ ត្រូវ គួរប្រាប់ថា កើត ចាស់ ស្លាប់ ជាទុក្ខជាមួយគ្នា ហៅ ថាសភាវទុក្ខ ញោមអាចនឹងមើលឃើញហើយឬនៅ?

- កូណាឃើញហើយទាន សូមទាននិមន្តសម្ដែងបន្ត ទៅទៀតចុះ

- **អាហារបរិយេដ្ឋិទុក្ខ ឬ អាជីវទុក្ខ** ទុក្ខកើតពីការស្វែង រកអាហារ បានដល់សេចក្ដីលំបាកព្រួយ ការមិនសប្បាយ កាយ មិនសប្បាយចិត្ត ដែលកើតមកពីការរកចិញ្ចឹមមាត់ ក្រពះរបស់ខ្លួនឯងនិងអ្នកដទៃ ។ ការរកចិញ្ចឹមជីវិតនេះ លំបាកលំបិនយ៉ាងណាយាយវិសញ្ញាតិញោមគ្រប់គ្នា បាន យល់អស់ហើយ ទើបអាត្មាសូមមិនអធិប្បាយច្រើន

**បកិណ្ណកទុក្ខ** គឺជាទុក្ខប្រចាំ គឺបានដល់សេចក្ដីសោក សៅ ទោមនស្ស ខូចចិត្ត ក្ដៅចិត្ត ព្រួយចិត្ត នៅពេលព្រាត់ ប្រាសពីអ្នកដែលខ្លួនស្រឡាញ់ របស់ជាទីស្រឡាញ់ មកជួប ប្រទះមនុស្សដែលស្អប់ របស់ដែលស្អប់ ។ ប្រាថ្នារបស់ ណាមិនបានដូចប្រាថ្នា បុថុជ្ជនគ្រប់គ្នាតែងមានសេចក្ដី ស្រឡាញ់ សេចក្ដីពេញចិត្តនៃមនុស្សទាំងឡាយ ក្នុងរបស់ ច្រើនយ៉ាង តែមនុស្សនិងរបស់ជាទីស្រឡាញ់ទាំងនោះ អាច មិននៅជាមួយនឹងយើងរហូតទេ ហើយយើងក៏មិនអាចនៅ ជាមួយមនុស្សនិងរបស់ទាំងនោះបានរហូតដែរ បើយើង

មិនទៅចោលគេ ក៏គេត្រូវទៅចោលយើង មិនបែកគ្នាឆាប់ក្រោយមកក៏ត្រូវបែកគ្នា ដូចជាកូន ភរិយា ស្វាមី មិត្តសម្លាញ់ដែលយើងសែនស្រឡាញ់ ជួនកាលគេបែកទៅមុន បេះតែទៅតាមគ្នាម្តងមួយៗ អ្នកខ្លះទៅមួយរយៈ អ្នកខ្លះទៅដោយមិនបានត្រឡប់មកវិញ ។ យើងនៅក្នុងលោកនេះគាន់តែឃ្លាប៉ុណ្ណោះ ក៏គាន់តែស្រងេះស្រងោចខ្លាំងឡើងពីព្រោះ ភរិយា ស្វាមី បុត្រាបុត្រីជាទីស្រឡាញ់ទៅចោលអស់ កុំថាតែអ្នកដទៃ របស់ដទៃឡើយ សូម្បីតែសម្បត្តិក្នុងកាយរបស់យើងវាក៏ទៅចោលយើងដែរ វាចាកចោលយើងម្តងមួយៗ ដូចជាធ្មេញ សក់ពណ៌ខ្មៅក្រិប ក៏វាទៅចោលយើងម្តងមួយសរសៃ ភ្នែកធ្លាប់ភ្លឺច្បាស់បែស ក៏វាទៅចោលយើងម្តងបន្តិចៗ ត្រចៀកធ្លាប់ឮច្បាស់ ក៏ទៅចោលយើងម្តងបន្តិចៗ កម្លាំងក៏ទៅចោលយើងបន្តិចទៅៗ បើខ្លួនយើងមិនទាន់ចាកចេញអំពីលោកនេះទៅទេ ក៏នៅសល់ត្រឹមតែកាយជរា ទ្រុឌទ្រោមដូចសំពត់អាវចាស់របែកយើរយ៉ែ ដែលគេបោះចោលជាគ្រឿងរាត់ជូតរបស់ផ្សេងៗមិនមាននរណាចង់មើល ក្រៅពីគេត្រូវការជូតជើងជូតដៃ។

ជួនកាល យើងចាំបាច់ត្រូវតែនៅជាមួយមនុស្សដែលយើងស្អប់, របស់ដែលយើងមិនចូលចិត្ត និងទីកន្លែងដែលយើងមិនពេញចិត្ត ដូចជាធុញថប់យ៉ាងខ្លាំងនឹងរត់ទៅណាក៏មិនរួច ត្រូវតែតស៊ូទ្រាំនៅដូចជាអ្នកជិតខាង ផ្ទះខ្លះអាក្រក់សែនអាក្រក់ យើងចង់ឲ្យគេប្តូរចេញទៅជួនកាលកើតចិត្តអកុសល ចង់ឲ្យគេស្លាប់ទៅ តែគេមិនព្រមទៅ

*លាតសោះ ហើយមិនព្រមស្លាប់ទៀត ដូចដោយមបាលមិន ត្រូវការគេ ។ ជួនកាលយើងចាំបាច់នៅជាមួយរោគ ឈឺចាប់សែនវេទនា ចង់ឲ្យវាចេញឲ្យផុតទៅ វាមិនព្រមចេញទៅទៀត អស់ប្រាក់ អស់មាសច្រើនប៉ុន្មានជួលគ្រូពេទ្យមកដេញវាចេញ វាមិនព្រមចេញទៅសោះ។ អ្នកខ្លះទ្រាំមិនបាន ដល់ទៅធ្វើអត្តឃាតខ្លួនឯងដើម្បីរត់គេចអំពីវាក៏មានដែរ*

# ព្រះពុទ្ធដីកា

## (វាចាគួរចងចាំ)

*បទពាក្យ៨*

***កាយមិនមានរោគជាលាភយ៉ាងធំ ទ្រព្យដ៏ឧត្តមគឺចិត្តសន្តោស***
***ក្តីស្នេហ៍ស្នាលស្និទ្ធជាមិត្រខ្ពង់ខ្ពស់ ព្រះនិព្វានទោះជាបរមសុខា ។***
***ក្នុងលោករោគអ្វីមិនស្មើរោគឃ្លាន ទុក្ខអ្វីមិនមានស្មើនឹងខន្ធា***
***អ្នកប្រាជ្ញយល់ច្បាស់ទៅតាមហេតុការណ៍ ឃើញដោយបញ្ញានិព្វានគួរគាប់។***
***កើតមកជាមនុស្សព្រោះតែបុណ្យ សាងពីជាតិមុនបានជាធនទ្រព្យ***
***ព្យាយាមបំពេញបុណ្យប្រសើរគាប់ កុំឲ្យអភ័ព្វអស់ជាតិជាមនុស្ស ៕***

ដោយឧបាសក មុិញ សាវ៉ាង

# ៣៩. បន្ទប់ងងឹតទាំង ៣

នៅពេលដែលភិក្ខុចម្លែក កំពុងសម្ដែងព្រះធម៌ ពណ៌នាអំពីរឿងទុក្ខនោះឯង អ្នកម្ដាយរបស់អាត្មាបានចូលមក ព្រមជាមួយទឹកតែកាហ្វេ នំប៉័ង បង្អែម និងផ្លែឈើ ៗ

- និមន្តព្រះអង្គឆាន់នៅទីនេះតែម្ដងទៅចុះ! មាតាគាត់ពោលឡើងនៅពេលដែលគាត់ដាក់របស់នៅលើតុ, នេះជាសំណាងល្អដែលព្រះសង្ឃ លោកចូលមកក្នុងផ្ទះដោយមិនបានគិត ខ្ញុំករុណាក៏នឹងបានធ្វើបុណ្យដោយចៃដន្យ សំណាងល្អមែនទែន, អ្នកម្ដាយងាកមកខាងអាត្មាហើយពោលថា, កូនប្រុសខ្ញុំករុណាកំពុងតែចង់បួសល្មម លោកម្ចាស់មានអ្វីក៏សូមនិមន្តទេសនាប្រៀនប្រដៅគេផង, ពោលហើយគាត់ក៏ដើរចេញពីបន្ទប់ទៅ

- និមន្តព្រះអង្គទេសនាបន្តទាន ខ្ញុំករុណាកំពុងតែពិរោះ

- ពរ! ទុក្ខម៉្យាងទៀតហៅថា **សន្តាបទុក្ខ** បានដល់សេចក្ដីក្ដៅក្រហាយ ពីព្រោះត្រូវភ្លើងកិលេសដុតរោលបុំផ្ញុនគ្រប់គ្នាឲ្យកើតកិលេសផ្សេងៗ ឡើងនៅក្នុងចិត្តមួយថ្ងៃៗច្រើនឯង ដូនកាលសេចក្ដីស្រឡាញ់ សេចក្ដីពេញចិត្តកើតឡើង ដូនកាលសេចក្ដីលោភចង់បានរបស់នេះរបស់នោះដូនកាលសេចក្ដីក្រោធស្អប់កើតឡើង ដូនកាលការខ្លាចកើតឡើង ដូនកាលសេចក្ដីឈ្នានីសព្យាបាទកើតឡើង ដូនកាលសេចក្ដីច្រណែនកើតឡើង ៗ កិលេសនីមួយៗ សុទ្ធតែធ្វើឲ្យចិត្ត

ខ្វល់ខ្វាយ រសាប់រសល់ ក្តៅក្រហាយទាំងអស់ មានឈ្មោះថា កិលេសហើយ មិនមានអ្វីឡើយដែលនឹងធ្វើឲ្យចិត្តថ្លាស្អាតស្ងប់សុខ មានតែនឹងធ្វើឲ្យចិត្តថ្លើមកករល្អក់ ក្តៅក្រហាយខ្វល់ខ្វាយទាំងអស់ បើយើងអាចឃាត់ឃាំងវាបាន វានឹងដុតចំពោះចិត្តរបស់យើងម្នាក់ឯង តែអ្នកខ្លះមិនអាចរារាំងទប់មិនបាន កិលេសវានឹងផ្ទុះចេញមកតាមវាចាតាមផ្លូវកាយខ្លះ រាលដាលទៅដុតឆេះដល់អ្នកដទៃទៀតៗ ធ្វើឲ្យកើតសេចក្តីក្តៅក្រហាយទាំងផ្ទះ ទាំងស្រុកទៀតក៏មាន

**វិបាកទុក្ខ** ទុក្ខកើតពីកម្មចាស់តាមឲ្យផល បានដល់សេចក្តីក្តៅក្រហាយ សេចក្តីសោកសៅខូចចិត្ត សេចក្តីខ្លាចភ្ញាក់ផ្អើល ការខ្មាសអៀនដែលកើតមកអំពីកម្ម អំពើអាក្រក់ដែលខ្លួនធ្វើទុកមកក្នុងអតីត ៗ មនុស្សគ្រប់គ្នាតែងបានធ្វើអំពើអាក្រក់យ៉ាងណាមួយ កាលពីមុនមកគ្រប់គ្នា ដោយចេតនាខ្លះ ដោយអចេតនាខ្លះ ដោយសេចក្តីចាំបាច់ខ្លះ គ្រប់ពេលតែងរំឭកនឹកឃើញឡើងកើតសេចក្តីក្តៅក្រហាយ

**សហគតទុក្ខ** (**វិបរិណាមទុក្ខ**) បានដល់សេចក្តីមិនសប្បាយកាយ មិនសប្បាយចិត្ត ដែលមកព្រមគ្នា លាភ យស សរសើរ និងសេចក្តីសុខកាយសប្បាយចិត្ត

- ទានម្ចាស់! លាភ យស សរសើរ និងសេចក្តីសុខកាយសប្បាយចិត្ត ធ្វើឲ្យកើតសេចក្តីទុក្ខដែរឬ ? អាត្មាសួរលោកដោយសេចក្តីមន្ទិលសង្ស័យ, ខ្ញុំករុណាយល់ថារបស់ទាំងអស់នេះធ្វើឲ្យកើតក្តីសុខទៀតផង គ្រប់ៗគ្នាក៏គេយល់ដូច្នេះដែរ ពីព្រោះឃើញមនុស្សគ្រប់គ្នាចង់បានលាភ យស

សរសើរ សុខសប្បាយទាំងអស់គ្នា ដូចម្តេចបានជាព្រះគុណម្ចាស់ថាជាសេចក្តីទុក្ខទៅវិញ ?

ភិក្ខុចម្លែកសើចតិចៗ ដោយអារម្មណ៍ត្រជាក់ ហើយពោលថា៖

- មែនដូចជាញោមមានប្រសាសន៍អញ្ចឹងមែន! លាភ យស សរសើរ សុខសប្បាយកាយនេះ បើយើងមើលដោយស្មានៗ ក៏នឹងឃើញបានថាជាសេចក្តីសុខហើយប៉ុន្តែ បើពិចារណាឲ្យបានល្អិតល្អន់ទៅនឹងយល់បានថា វាជាហេតុឲ្យកើតទុក្ខដូចគ្នា លើកឧទាហរណ៍ដូចជា "លាភ" ដែលសំដៅទៅដល់ទ្រព្យសម្បត្តិផ្សេងៗនោះ បើយើងមានវាអាចឲ្យសេចក្តីស្រួលសប្បាយដល់យើងបានខ្លះដែរ ប៉ុន្តែ ក្នុងពេលជាមួយគ្នានោះ វាក៏នាំឲ្យមានសេចក្តីព្រួយពិបាកផ្សេងៗមកឲ្យយើងដែរ ។ ឧបមាថា ញោមមិនមានរថយន្ត ញោមអាចនឹងមិនបានទទួលនូវសេចក្តីស្រណុកសុខស្រួល ក្នុងការធ្វើដំណើរ តែញោមក៏អាចនឹងធ្វើដំណើរបាន ដោយវិធីផ្សេងៗ ។ នៅពេលញោមមានរថយន្ត ញោមអាចធ្វើអាចនឹងទៅណាមកណា បានស្រួលរហ័សទាន់ចិត្ត តែនៅពេលជាមួយគ្នានោះ ញោមក៏ត្រូវជួបប្រសព្វនូវបញ្ហាផ្សេងៗដូចជា បង់ពន្ធដារជូនរដ្ឋ កង់បែកធ្លាយ ដុសខាត់ ប្រេងសាំង ម៉ាស៊ីនខូចតាមផ្លូវ... ដែលពីគាលមុនញោមមិនដែលរវល់ខ្វល់សោះឡើយ ។ បើញោមនៅម្នាក់ឯង ញោមអាចជួបប្រទះនូវបញ្ហាការរៀនសូត្រ ការធ្វើដំណើរ សន្តិសុខ សុខភាព អនាម័យរបស់ខ្លួនឯងតែម្នាក់ បើសិនជា

ញោមមានភរិយា ញោមត្រូវជួយមើលកែនូវបញ្ហាផ្សេងៗឲ្យភរិយា បើញោមមានកូន ក៏ត្រូវជួយកែបញ្ហាឲ្យកូនទៀត បើមានច្រើន បញ្ហាក៏ច្រើនថែមទៀត បើកែបញ្ហាច្រើនក៏គាន់តែមានសេចក្តីវិក់ សេចក្តីព្រួយក៏យខ្វល់ ទុក្ខក៏គាន់តែច្រើន ៗ ទាំងអស់នេះក៏ព្រោះតែមកពីរបស់ដែលយើងមាននោះ វាមានចំណោទខ្វះខាតនៅក្នុងខ្លួនរបស់វា នៅពេលវាមកនៅជាមួយនឹងយើង វាក៏យកបញ្ហានោះមកឲ្យយើងជួយកែ ជួយបំពេញវាផងដែរ

- ពិតហើយទាន! ខ្ញុំកូណាយល់ឃើញដូចលោកម្ចាស់ហើយ លាភ យស សរសើរ សុខសប្បាយគាយវាធ្វើឲ្យកើតទុក្ខបាន

- ដូចជាលាភនោះឯងញោម! បើញោមមិនមានយស ញោមក៏មិនបាច់ខ្វល់ថែរក្សា ឬមិនខ្វល់នឹងយស ៗ យសជារបស់ដែលពួកគេតែងតាំងឲ្យនៅពេលគេពេញចិត្ត គេក៏អាចដកយកទៅវិញបានដែរ បើយើងមិនចេះថែរក្សាយសនោះ ដូច្នេះយើងត្រូវស្គាល់ចេះរក្សានូវយស ត្រូវយកចិត្តទុកដាក់ថែរក្សាយសឲ្យបានល្អតែម្តង ចង់ធ្វើ ចង់និយាយ ចង់ទៅ ចង់យក ជិតស្លាប់តែមិនអាចធ្វើបានពីព្រោះបុណ្យស័ក្តិមិនឲ្យធ្វើ ៗ មនុស្សមានយសស័ក្តិ ដូចជាសត្វនៅក្នុងទ្រុងមាស សុខស្រួលសប្បាយគាយមែន ប៉ុន្តែមិនសប្បាយចិត្ត ការសរសើរក៏ដូចគ្នា មនុស្សដែលត្រូវគេសរសើរហើយត្រូវប្រយ័ត្នខ្លួនតែម្តង ត្រូវព្យាយាមធ្វើខ្លួនឲ្យគេសរសើរ ៗ មនុស្សដែលមានសុខភាពល្អក៏ត្រូវ

ប្រយ័ត្នសុខភាព រឹងមាំជឿនព្រួយខ្វល់ទាំងអស់ ទើបលោក ហៅថា **សហគតទុក្ខ ឬ វិបរិណាមទុក្ខ**

- បើដូច្នោះ យើងមិនមានអ្វីសោះឡើយ នឹងមិនមាន សេចក្ដីសុខសប្បាយឬ?

- បើសិនជាញោមមិនមានអ្វី ហើយញោមមិនចង់ មាន ក៏សុខសប្បាយស្រួល បើញោមនៅចង់មាន តែវាមិន មាន ញោមនឹងទៅជាកើតទុក្ខ

អាត្មានឹកសរសើរ នូវពាក្យដែលមានន័យល្អរបស់ ភិក្ខុចម្លែកនៅក្នុងចិត្តអាត្មា ហើយក៏សួរបន្តទៅទៀតថា៖

- ហើយតើនៅមានទុក្ខអ្វីទៀតឬទេទានម្ចាស់?

- **វិវាទមូលកទុក្ខ** ទុក្ខកើតពីការឈ្លោះទាស់ទែងគ្នា គឺសេចក្ដីក្ដៅក្រហាយអន្ទះអន្ទែងពីព្រោះការឈ្លោះប្រកែក ប្រណាំងប្រជែងដណ្ដើមយកល្អជាមួយអ្នកដទៃ ៗ មនុស្ស យើងនៅកណ្ដាលប្រជុំជនតែម្នាក់ឯង មានឧបនិស្ស័យចិត្ត ថ្លើមនិងអារម្មណ៍ជារបស់ផ្ទាល់ខ្លួនឯង បើឧបនិស្ស័យចិត្ត ថ្លើមនិងអារម្មណ៍របស់គេចូលគ្នាបានជាមួយយើង ក៏ជា ការប្រសើរទៅ តែបើចូលគ្នាមិនចុះ ក៏ក្លាយទៅជាការទាស់ ទែងឈ្លោះប្រកែកវិវាទគ្នាឡើង ធ្វើឲ្យកើតជាទុក្ខ កើត សេចក្ដីក្ដៅក្រហាយឡើង

- មនុស្សដែលមិនចេះឈ្លោះប្រកែកគ្នាសោះ តើមាន ដែរឬទេទាន? អាត្មាសួរឡើងដោយសេចក្ដីសង្ស័យ

- មិនមានទេញោម សូម្បីស្រឡាញ់គ្នាអាចនឹងលេបគ្នា បាន ក៏មានថ្ងៃទាស់គ្នាទាល់តែបាន កុំថាតែអ្នកដទៃឡើយ

ខ្លួនរបស់យើងនេះ នៅមានឈ្មោះជាមួយខ្លួនឯងមួយថ្ងៃៗ ច្រើនឯងដែរមែនទេញោម?

- ត្រូវតែម្ដងហើយទាន! ក្រៅពីនេះ មានទុក្ខអ្វីទៀតទេទាន?

- **ទុក្ខក្ខន្ធ** គឺជាទុក្ខបុងក្រោយនេះ មានន័យថាជីវិត ចិត្តថ្លើមនិងរាងកាយរបស់មនុស្ស ដែលប្រកបដោយរាងកាយ សេចក្ដីនឹង ការចងចាំ ការគិត ហើយសេចក្ដីនឹងដល់មនុស្សយើងប្រកាន់ថាជាខ្លួន ឬរបស់ខ្លួននេះជាទុក្ខ ហើយវិលស្លាប់វិលកើតនៅក្នុងភពទាំងបីគឺកាមភព រូបភព អរូបភព នេះចាត់ជាទុក្ខ ភពទាំងបីនេះប្រៀបដូចជាឃុំបន្ទប់ងងឹតទាំង ៣ បន្ទប់ ដែលពោរពេញទៅដោយសត្វកាចសាហាវ មនុស្សដែលវង្វេងវិលវល់ក្នុងការកើតនៅក្នុងភពទាំង ៣ នេះ ប្រៀបដូចជាមនុស្សដែលដើរវិលវល់នៅក្នុងបន្ទប់ងងឹតទាំង ៣ បានទទួលទុក្ខវេទនាយ៉ាងក្រៃលែង អំពីសត្វកាចសាហាវ បញ្ចេញសម្លេងយំយ៉ាងខ្លាំង នៅរហូតលុះត្រាដល់ពេលព្រះនឹមានព្រះភាគ ព្រះអង្គទ្រង់ឃើញទោសនិងភ័យក្នុងបន្ទប់ងងឹតទាំង ៣ នេះ ទើបបានស្ដេចយាងចេញបួស ស្វែងរកច្រកចេញ នៅទីបំផុតក៏ទ្រង់រកឃើញច្រកចេញ ហើយទ្រង់យាងចេញទៅផុតភ័យក្រោយអំពីនោះ ដោយសេចក្ដីអាណិតស្រណោះនូវពពួកសត្វដែលជាប់នៅក្នុងទីងងឹត ទើបព្រះអង្គស្ដេចយាត្រាចូលទៅក្នុងបន្ទប់ងងឹត ជួយដឹកនាំសត្វដែលគួរឲ្យអាណិតទៅដល់ទ្វារ ៗ មានសត្វខ្លះ តែមានចំនួនតិច បានឃើញភ័យក្នុង

បន្ទប់ងងឹតនោះ បានចេញរួចហើយទៅដល់ដែនកម្រកម្ពុជាន្ត បានសម្រេច ដែលមួយផ្នែកធំទៀតនៅជាប់វង្វេងវង្វាន់នៅក្នុងបន្ទប់ងងឹតនោះតទៅ ។

ការសង្កេត រន្ធត់ស្លុតចិត្តនៃសេចក្តីទុក្ខក្នុងជីវិតរបស់អាត្មា ថែមទៀតជាច្រើនគុណ នៅពេលបានស្តាប់ការទេសនាអំពីរឿងទុក្ខពីព្រះគិរីសង្ឃបម្លែក អាត្មាមើលទៅជុំវិញខ្លួនហើយ បានឃើញរបស់របរដែលមានតម្លៃយ៉ាងច្រើននៅក្នុងបន្ទប់ទទួលភ្ញៀវនោះ ក្នុងខណៈនេះដូចជាមិនមានតម្លៃអ្វីសោះឡើយសម្រាប់អាត្មា ។ បន្ទប់ទាំងមូលមើលទៅដូចជាបន្ទប់ងងឹត ទ្រព្យសម្បត្តិទាំងអស់មើលទៅដូចជាច្រវាក់ដែលនឹងចាប់ចងអាត្មា ឲ្យនៅក្នុងបន្ទប់ងងឹតតទៅ ។ នៅពេលមនុស្សឃើញនូវទុក្ខបានច្បាស់ ដូចបានពោលមកនេះ បើគេនៅមានបារមីចាស់ក្លា គេនឹងកើតសេចក្តីត្រិះរិះត្រូវ ២ ប្រការ គឺគំនិតដែលមិនបៀតបៀនអ្នកណា ពីព្រោះគេនឹងឃើញមនុស្សដទៃ សត្វដទៃ ពេញពោរទៅដោយសេចក្តីទុក្ខដូចគេដែរ គេនឹងឃើញគ្រប់គ្នាស្លាយរបស់យ៉ាងឆ្ងន់គឺទុក្ខទាំង ១០ កងនៅលើស្មា ដើរទ្រេតទ្រោតបម្រះនៀលនៅក្នុងលោក គេនឹងកើតសេចក្តីអាណិតអ្នកដទៃ សត្វដទៃយ៉ាងជាប់ចិត្ត គេនឹងមិនគិតបៀតបៀនអ្នកណា ដោយកាយ វាចា ចិត្ត ពីព្រោះការបៀតបៀនគេស្មើនឹងបន្ថែមទុក្ខឲ្យដល់យើង ដោយមិនចាំបាច់ ។

សូម្បីនៅពេលដែលគេត្រូវអ្នកដទៃបៀតបៀន គេក៏មិនបានបៀតបៀនតប ដូចជាយើងត្រូវគេជេរ យើងគួរតែ

កុំដើរតបវិញ ពីព្រោះមនុស្សដែលមកជេរយើងនោះ គេមានសេចក្តីទុក្ខច្រើនជាងយើង យ៉ាងតិចបំផុតគេក៏មាន **(សន្តាបទុក្ខ)** គឺត្រូវសេចក្តីក្រោធខឹងដុតរោលចិត្តថ្លើមរបស់គេទ្រាំមិនបានហើយ ទើបមកបញ្ចេញនូវទុក្ខឲ្យមកដល់យើង ដោយការជេរប្រទេចយើង បើយើងមិនខឹងតបយើងក៏មិនបានទទួលនូវទុក្ខរបស់គេមកទុកដែរ ។ គេនឹងសប្បាយចិត្តព្រោះបានបញ្ចេញនូវទុក្ខមកហើយ រឿងក៏បានចប់អស់តែប៉ុណ្ណោះ ។ មនុស្សដែលបានឃើញទុក្ខនៅពេលត្រូវគេជេរ គួរតែនឹងខឹង តែគេបែរជាយល់ថាជាសិរីវិញ ។ ព្រោះមនុស្សដែលជេរ បានរើសយកគេជាទីបញ្ចេញនៅសេចក្តីទុក្ខ ដែលមិនអាចទៅបញ្ចេញជាមួយអ្នកផ្សេង ។ មានន័យថាអ្នកដែលគេជេរ គេឃើញថាយើងអាចទទួលនូវទុក្ខពីគេបាន ទើបគេបញ្ចេញជាមួយយើង នេះគឺគុណតម្លៃនៃការឃើញទុក្ខ សម្រាប់អ្នកមានបារមីនៅទន់ខ្ចី ។ អ្នកដែលមានបារមីចាស់ក្លា នៅពេលឃើញទុក្ខហើយនិងកើតសេចក្តីស្អែតស្អន់ក្នុងទុក្ខ ហើយនឹងមានចិត្តបង្អោនទៅរកនេក្ខម្មៈ គឺការលះជីវិតគ្រហស្ថដែលចង្អៀតចេញ បម្រុងជីវិតជាសមណៈដែលធំទូលាយ ហើយមានតស្សរៈសេរី-ភាព ។ នៅពេលក្នុងភេទជាបព្វជិតហើយ គេនឹងសាងសីល សមាធិ បញ្ញា ឲ្យកើតឡើងក្នុងខ្លួន កម្លាំងរបស់សីល សមាធិ បញ្ញា ចាស់ក្លាឡើងប៉ុណ្ណា កម្លាំងរបស់កិលេសទាំងឡាយ ក៏ស្រកចុះប៉ុណ្ណោះ កិលេសស្រកចុះទៅប៉ុណ្ណាសេចក្តីស្ងប់សុខក៏កើតឡើងច្រើនប៉ុណ្ណោះ ។ អាត្មាឃើញ

ថាញោមមានបារមីចាស់ក្លា ឃើញទុក្ខថ្នាក់ដំបូងហើយថែម មានចិត្តចុះស៊ប់ទៅរកនេក្ខម្មៈផង ទើបមកអនុគ្រោះញោម នៅពេលនេះ

- ព្រះគុណម្ចាស់! ខ្ញុំកូណាតាំងចិត្តនឹងបួសពិតប្រាកដ ហើយនឹងបួសឲ្យបានលឿនបំផុត ដែលអាចធ្វើទៅបាន ពេលនេះ ជាពេលដែលព្រះអង្គគួរតែឆាន់អាហារហើយ សូមនិមន្តទាន និមន្តឆាន់សិនចុះ

ថាហើយ អាត្មាក៏នាំយកម្ហូបអាហារមកប្រគេនព្រះ សង្ឃចម្លែក ។ ព្រះអង្គយកនំនិងផ្លែឈើដាក់ក្នុងបាត្រ ហើយចាប់ផ្ដើមឆាន់ដោយអាការសង្រួម លុះត្រាមិនមាន សម្លេងផ្សេងៗ បើមិនសង្កេតប្រហែលនឹងមិនដឹងថាលោក កំពុងឆាន់ទេ ។ ការសង្រួមរបស់លោក ធ្វើឲ្យអាត្មាកើត សេចក្ដីជ្រះថ្លាយ៉ាងខ្លាំង ក្នុងពេលជាមួយគ្នាក៏កើតសេចក្ដី ក្រែងចិត្ត មិនហ៊ានបបួលព្រះអង្គសន្ទនាតទៅទៀត

- និមន្តព្រះអង្គឆាន់តាមសប្បាយទាន! ខ្ញុំកូណាសូម ចេញទៅជួបអ្នកម្ដាយនៅខាងក្រៅមួយភ្លែត ហើយនឹង ត្រឡប់មកវិញទាន

អាត្មាក្រាបថ្វាយបង្គំលោកហើយ ក៏ចេញមកជួបអ្នក ម្ដាយនៅក្នុងផ្ទះបាយ

- ម៉ែ! កូនឃើញថាព្រះអង្គនេះ ជាព្រះសង្ឃចម្លែក ខ្លាំងណាស់ម៉ែ

- ប្លែកយ៉ាងណាទៅកូន? ម៉ែដាក់ការងារក្នុងផ្ទះបាយ ចោលមួយរយៈរួចសួរជាសំណួរឡើង

- មើលឫកពាលោក ជាព្រះសង្ឃស្រុកក្រៅ តែមានការចេះដឹង និងយល់ក្នុងព្រះពុទ្ធសាសនាយ៉ាងជ្រៅជ្រះណាស់ និយាយរឿងអ្វីៗផ្សេងៗបានច្បាស់ធ្លាយដូចជាបានឃើញនឹងភ្នែក លោកនិយាយរឿងខ្ពស់ៗទាំងអស់ តែចេះប្រើភាសាងាយៗ ដែលមនុស្សធម្មតាស្ដាប់យល់ចូលចិត្ត កូនមានសេចក្ដីជ្រះថ្លានឹងលោកម្ចាស់នេះហើយ

អ្នកម្ដាយមិនបាននិយាយអ្វីទេ លោកគ្រាន់តែងក់ក្បាលចុះឡើងយឺតៗ

- ជាពិសេសទៅទៀតនោះ លោកមានសង្ឃដីកាដូចជាបាននឹងរឿងស្អីផ្សេងៗ ដែលទាក់ទងជាមួយនឹងកូនយ៉ាងច្បាស់លាស់ កូននឹងសូមបួស ព្រះអង្គក៏ដឹង កូនមានសេចក្ដីនឹកគិតយ៉ាងណាទាក់ទងជាមួយជីវិត ព្រះអង្គក៏ដឹងមិនយល់ថាតើលោកដឹងបានយ៉ាងណាទេ ?

- ជួនកាល ព្រះអង្គក៏ដឹងបានដោយវិធីអង្គុយសមាធិទេដឹងកូន ! អ្នកម៉ែនិយាយឡើងដោយភ្ញាក់ផ្អើល

- មិនដឹងដែរ អាចប្រហែលមែនក៏បាន អាត្មាឆ្លើយដោយមិនសូវប្រាកដច្បាស់ក្នុងចិត្ត, ម៉ែ ! បើសិនកូននឹងសូមប្រគល់ខ្លួនសូមបួសជាមួយភិក្ខុសង្ឃនេះ តើម៉ែយល់យ៉ាងណាដែរ ?

អ្នកម៉ែគាត់សម្លឹងមើលអាត្មាដូចជាងឿងឆ្ងល់ក្នុងចិត្ត ហើយក៏សួរថា៖

- តែកូនបានតាំងចិត្តថានឹងបួសជាមួយគ្រូដែលគង់នៅវត្តព្រះខ្មូង មិនមែនទេឬ ?

- ខ្ញុំបាទក៏គាំងចិត្តយ៉ាងនោះដែរ តែនៅពេលនេះខ្ញុំដូចជាចង់ប្តូរចិត្តវិញហើយ

- តាមចិត្តកូនទៅចុះ ! ម៉ែនិយាយបណ្តើរ វាគទៅចាប់កិច្ចការដែលគាត់ដាក់ចោលនោះបណ្តើរ តែគាត់វាគមកនិយាយបន្ថែមទៀត, ហ្អើ ! តែយើងមិនទាន់នឹងសោះថា ព្រះសង្ឃនោះជានរណា មកពីណា ការដែលយើងនឹងប្រគល់ខ្លួនជាសិស្សរបស់លោក បើយើងមិនស្គាល់ប្រវត្តិលោកផង តើជាការគួរសមដែរឬទេ ?

- ណ្ហើយចុះ ! ចូរកូនទូលសួរលោកមើលថា ព្រះអង្គជានរណា មកពីណា

ថាហើយ អាត្មាក៏ឡើងទៅមានធុរៈនៅខាងលើបន្ទប់ដេកមួយសន្ទុះ ៗ នៅពេលត្រឡប់ចុះមកបន្ទប់ទទួលភ្ញៀវវិញ ព្រះសង្ឃចម្លែកលោកបានឆាន់រួចហើយ លោកកំពុងតែយកកន្សែងជូតបាត្រយ៉ាងយកចិត្តទុកដាក់ ហើយឃើញអ្នកម្តាយកំពុងតែអង្គុយសន្ទនាជាមួយលោកទៅហើយ

- កូនរបស់ញោម គាត់មានសេចក្តីគាំងចិត្តល្អណាស់, លោកពោលឡើង, អាត្មាអង្គុយចុះក្រាបជិតព្រះអង្គ, នៅពេលបានបួសហើយ ក៏គាំងចិត្តបដិបត្តិយ៉ាងហ្មត់ចត់ ញោមនឹងបានទទួលបុណ្យកុសលយ៉ាងច្រើនអនេកតែម្តង

- ខ្ញុំកូណាយល់ថា គេយកម៉ែនទែនហើយទាន, អ្នកម្តាយពោលឡើង, ខ្ញុំកូណាព្រួយតែម្យ៉ាងប៉ុណ្ណោះគឺសូរទូលតាមត្រង់ ក្រែងគេបួសហើយមិនសឹក ពីព្រោះចង់បួសតែមួយវស្សាទេ

ភិក្ខុចម្លែកសើចតិចៗ ហើយពោលថា៖

- បើគេបួសហើយមិនសឹក គេក៏នឹងជាប្រយោជន៍ដ៏ធំដល់ប្រជាជននិងព្រះពុទ្ធសាសនា ញោមគួរតែសប្បាយចិត្តដែលកូនញោមជាអ្នកប្រសើរដូច្នេះ

- តើគុណល្អហ្នឹងរបស់គេនោះ? អ្នកម្ដាយសួរឡើង

- គុណល្អហ្នឹងនោះគួរតែសប្បាយត្រេកអរ ដែលមានគុណល្អហ្នឹងជាមនុស្សវិសេសប្រសើរបំផុតដូច្នេះ

អ្នកម្ដាយមិនឆ្លើយ គាត់ដកដង្ហើមធំ ហើយឱនមុខចុះនៅស្ងៀម ៗ

- ព្រះគុណម្ចាស់! អាត្មាពោលឡើង, នៅពេលដំបូងខ្ញុំករុណា បានតាំងចិត្តនឹងបួសជាមួយលោកគ្រូវត្តថ្មីនាផ្លូវព្រះខ្នង តែពេលនេះខ្ញុំករុណាបានប្ដូរចិត្តទៅហើយ ខ្ញុំករុណាចង់ផ្ញើខ្លួនជាកូនសិស្សរបស់ព្រះគុណម្ចាស់វិញ ចង់បួសរៀនជាមួយព្រះអង្គ តែខ្ញុំករុណាចង់ដឹងថាព្រះអង្គគង់ជាប្រចាំនៅវត្តណាដែរទាន!

ព្រះភិក្ខុចម្លែកសើចញឹមៗ ហើយទើបមានសង្ឃដីកាថា៖

- បើដូច្នោះ ពេលល្ងាចថ្ងៃនេះ ឬស្អែកទៅជួបនឹងអាត្មាបានហើយ

- នឹងឲ្យខ្ញុំករុណាទៅជួបនឹងព្រះអង្គនៅឯណាទាន?

- ក៏នៅវត្តថ្មី នៅឯព្រះខ្នងនោះឯងណា៎!

សង្ឃដីកា របស់ភិក្ខុចម្លែក ធ្វើឲ្យអាត្មានិងអ្នកម្ដាយភ្ញាក់ព្រើត អង្គុយសម្លឹងមុខគ្នាអស់ពេលយ៉ាងយូរតែម្ដង...

# ៣៦. សន្ទម្មប្បដិរូប ព្រះធម៌បន្លំ

ថ្ងៃស្អែកឡើង អាត្មាបានទៅជួបលោកគ្រូអាចារ្យនៅវិទ្ធថ្មីព្រះខ្នងតាមពាក្យលោកគ្រូណាត់ ហើយបានសួរលោកគ្រូអាចារ្យថា៖

- ថ្ងៃម្សិលមិញ លោកគ្រូបានប្រាប់ថាមកអនុគ្រោះដល់ខ្ញុំករុណា, ខ្ញុំករុណាចង់ដឹងថា តើហេតុដូចម្ដេចទើបលោកម្ចាស់មានមេត្តាដល់ថ្នាក់នេះ ?

លោកគ្រូអាចារ្យសើចយ៉ាងត្រជាក់ចិត្ត ហើយឆ្លើយថា៖

- អាត្មាឃើញថា ញោមនឹងបានជាប្រយោជន៍ដ៏ធំធេងដល់ព្រះពុទ្ធសាសនា ទើបបានជាប្រញាប់រូតរះចុះមកពីទិសឆ្ងាយនេះដើម្បីមកអនុគ្រោះ

- ខ្ញុំករុណានឹងជាអ្នកមានប្រយោជន៍ដ៏ធំធេង ដល់ព្រះពុទ្ធសាសនាយ៉ាងណាដែរទាន ? អាត្មាសួរលោកដោយសេចក្ដីសង្ស័យ ពីព្រោះនៅពេលនោះមើលមិនទាន់ឃើញខ្លួនឯងជាអ្នកមានប្រយោជន៍ដល់ព្រះពុទ្ធសាសនាដូចម្ដេច

- វេលានេះ ញោមមិនទាន់ជាប្រយោជន៍ដល់ព្រះពុទ្ធសាសនាទេ តែនៅថ្ងៃខាងមុខញោមនឹងទៅជាប្រយោជន៍យ៉ាងច្រើន ពីព្រោះបងិបទារបស់ញោម ដំណើរបែបព្រះបរមសាស្ដា និងព្រះអរហន្តសាវ័កទាំងឡាយ

- ព្រះគុណម្ចាស់គាន់តែអធិប្បាយ ខ្ញុំករុណាក៏គាន់តែ

ឆ្ងល់ ! អាត្មាពោលឡើងដោយសេចក្ដីឆ្ងល់ពិតៗ, ខ្ញុំករុណា មិនដឹងថា ខ្ញុំករុណាមានដំណើរតាមបែបព្រះពុទ្ធអង្គយ៉ាង ណា ?

- ញោមធ្លាប់អានសៀវភៅ "**ពុទ្ធប្បវត្តិ**" មកហើយមែន ទេ ? លោកអាចារ្យសួរ

- ខ្ញុំករុណាធ្លាប់បានអានហើយទាន !

- ញោមអាចនឹងប្រាប់អាត្មាបានឬទេថា តើហេតុដូច ម្ដេច បានជាព្រះអង្គម្ចាស់ "សិទ្ធត្ថ" ទ្រង់លះឃរាវាសវិស័យ ចេញបួស ?

- ដែលខ្ញុំករុណាបានដឹងមក ក៏ព្រោះតែព្រះអង្គទ្រង់ ឃើញទុក្ខដែលនៅក្នុងមនុស្សចាស់ មនុស្សឈឺ មនុស្ស ស្លាប់ ទ្រង់តុញទ្រាន់នូវទុក្ខ ប្រាថ្នាទៅរកផ្លូវរំដោះទុក្ខ ទើប ស្ដេចយាងចេញបួស បញ្ជា ខ្ញុំករុណាបានអានមកយ៉ាងនេះ ឯងទាន

- ត្រូវហើយ ! លោកគ្រូអាចារ្យពោលឡើងនិងញញឹម យ៉ាងពេញចិត្ត, ព្រះអង្គម្ចាស់ "សិទ្ធត្ថ" ទ្រង់ឃើញទុក្ខដែល ជាអរិយសច្ចៈប្រការដំបូង ទើបស្ដេចយាងចេញទៅបួស ។ ម្ដងនេះ នៅពេលព្រះអង្គទ្រង់លះបង់វិស័យឃរាវាស ចេញ ទៅបួសហើយ តើព្រះអង្គត្រឡប់ទៅរកដំណើរជីវិតបែប ឃរាវាសទៀតឬ ?

- មិនត្រឡប់មកទៀតទេ ទ្រង់គង់នៅក្នុងបព្វជិតលុះ ត្រាអស់ព្រះជន្មាយុ

- ដូចម្ដេចហ្ន៎ ! ទើបព្រះអង្គមិនត្រឡប់មកជាឃរាវាស

វិញនោះ ?

- គុណម្ចាស់! ខ្ញុំក្ខុណាមើលទៅនឹងឆ្លើយមិនរួចទេទាន

លោកគ្រូអាចារ្យសើចយ៉ាងត្រជាក់អារម្មណ៍ដូចសព្វ ដង ហើយទើបមានសង្ឃដីកាថា៖

- គិតយកដូច្នេះវិញចុះ សន្មតថាញោមកំពុងលេង ល្បែងភ្នាល់ សប្បាយរីករាយនៅក្នុងផ្ទះធំមួយ នៅពេល កំពុងភ្លេចខ្លួននោះ ស្រាប់តែភ្លើងឆេះផ្ទះនោះឡើង ឆេះឆាប ជិតមកដល់ទើបស្ទុះស្រែកឲ្យអ្នកទាំងអស់នោះរត់ចេញ តែ មនុស្សទាំងនោះរវល់តែសប្បាយក្នុងការលេងល្បែង ទើប មិនព្រមក្រោកចេញអំពីកន្លែងនោះសោះ ញោមឃើញ ភ្លើងឆេះជិតមកដល់ខ្លួនហើយ ទើបក្រោកឡើងរត់គាត់ អណ្ដាតភ្លើង និងផ្សែងចេញមកក្រៅ ៗ នៅទីបំផុតភ្លើងក៏ ឆាបឆេះពេញផ្ទះ មនុស្សក្នុងផ្ទះត្រូវភ្លើងឆេះស្លាប់ទាំងអស់ នៅពេលភ្លើងកំពុងឆេះផ្ទះយ៉ាងខ្លាំងនោះ សួរថាបើសិនជា ញោមវិញ តើញោមត្រឡប់ចូលទៅលេងល្បែងភ្នាល់ក្នុង ផ្ទះមួយនោះទៀតឬទេ ?

- មិនទៅទេលោកម្ចាស់ !

- យ៉ាងណាក៏ដោយ ជីវិតរបស់គ្រហស្ថប្រៀបដូចជា មនុស្សដែលកំពុងតែសប្បាយ លេងភ្នាល់នៅក្នុងផ្ទះ ដែល កំពុងត្រូវភ្លើងឆេះ ភ្លើងគឺសេចក្ដី ចាស់ ឈឺ ស្លាប់ សេចក្ដី សោកសៅ ខូចចិត្ត ចង្អៀតចង្អល់ ស្រែកដើមទ្រូង ពើត ព្រោះការខុសបំណង ភ្លើងគឺការតស៊ូ បម្រះ នឿយនៅ ការរកចិញ្ចឹមមាត់ ចិញ្ចឹមពោះរបស់ខ្លួនឯង និងអ្នកដទៃ ៗ

ព្រះពុទ្ធអង្គ ប្រៀបដូចមនុស្សដែលបានរត់គេចចេញពីភ្លើង ទៅផុតពីគ្រោះថ្នាក់ហើយ ការដែលនឹងត្រូវត្រឡប់ចូលមកក្នុងភ្លើងទៀត ទើបមិនមានជាដាច់ខាត ។ ពេលនេះញោមឃើញភ្លើងហើយ នឹងកំពុងតែដើរចេញអំពីគំនរភ្លើង អាត្មាជឿថា ញោមនឹងនៅជាគេទបញ្ជិតរហូតអស់មួយជីវិត និងតាំងចិត្តបដិបត្តិតាមព្រះធម៌វិន័យយ៉ាងពិតប្រាកដ ដើម្បីរំលត់នូវភ្លើងខាងក្នុងគឺកិលេសរបស់ខ្លួនឯង ។ នៅពេលរំលត់ភ្លើងរបស់ខ្លួនឯងបានហើយ ក៏នឹងជួយរំលត់នូវភ្លើងអ្នកដទៃតៗទៅ ព្រោះដូច្នោះទើបអាត្មាពោលថា ញោមនឹងបានជាប្រយោជន៍ដល់ព្រះពុទ្ធសាសនាយ៉ាងច្រើន ការឃើញដូចញោមនេះ រកបានដោយកម្រណាស់ ក្នុងមួយម៉ឺននាក់ សូម្បីតែម្នាក់ក៏រកពិបាកផង

- ព្រះអង្គមានន័យថា មនុស្សដែលចេញបួសពីព្រោះឃើញទុក្ខមុន រកបានដោយពិបាកមែនទេទាន ?

- ត្រូវហើយ ភាគច្រើនដែលសូមបួសនោះ មិនបានបួសពីព្រោះឃើញនូវទុក្ខជាមុននោះទេ តែសូមបួសដោយហេតុផ្សេងៗ ដូចជាបួសតាមប្រពៃណី ឪពុកម្ដាយឲ្យបួសក៏បួសទៅ ដើម្បីបំពេញចិត្តឪពុកម្ដាយ អត់ទ្រាំនៅបានមួយវស្សា នៅដោយត្រវល់ត្រវាយក្នុងចិត្ត នៅពេលចេញវស្សាក៏ត្រឡប់រត់ចូលក្នុងគំនរភ្លើងនោះវិញ ។ អ្នកខ្លះក៏បួសដើម្បីរៀន នៅពេលរៀនប្រឡងបានថ្នាក់ខ្ពស់ៗហើយក៏សឹក ហើយក៏ត្រឡប់ចូលទៅគំនរភ្លើងទៀតទៅ ។ អ្នកខ្លះបួសពីព្រោះសេចក្ដីក្រីក្រ បួសពឹងអាស្រ័យព្រះសាសនា

ចិញ្ចឹមជីវិត នៅពេលមានអតិថិជនលាភ សន្សំមាស ប្រាក់បានច្រើនហើយ ក៏វិលត្រឡប់ទៅចូលគំនរភ្លើងទៀត ។ អ្នកខ្លះទៀតបួសគេចអំពីការជំពាក់ប្រាក់គេ គេចពីភ័យ គេចពីក្ដីក្ដាំ នៅពេលផុតពីក្ដីក្ដាំហើយ ក៏ត្រឡប់ទៅគំនរភ្លើងនោះវិញទៀត ។ មនុស្សប្រភេទនេះ ចូលមកបួសហើយ ក៏មិនបានតាំងចិត្តបដិបត្តិ ដើម្បីរំលត់ភ្លើងកិលេសរបស់ខ្លួនឯង មានតែរករបស់មកបន្ថែមឲ្យភ្លើងកាន់តែឆេះឡើងថែមទៀត ។ នៅពេលខ្លួនឯងនៅមានភ្លើងឆុតនៅឡើយ តើនឹងអាចទៅជួយរំលត់ភ្លើងឲ្យអ្នកដទៃបានដូចម្ដេច តើជាការពិតឬទេញោម ?

- ពិតមែនតែម្ដងហើយទាន !

- ស្ថានការណ៍ របស់ភិក្ខុបួសក្នុងព្រះពុទ្ធសាសនានៅពេលនេះ គួរឲ្យព្រួយណាស់, លោកគ្រូអាចរៀបរាប់យាយតទៅ, បើសិនជាបណ្ដោយឲ្យទៅជាបែបនេះ គួរឲ្យភ័យខ្លាចព្រះពុទ្ធសាសនា នឹងស្ថិតនៅមិនគ្រប់ប្រាំពាន់ព្រះវស្សាទេ ព្រះពុទ្ធសាសនាដ៏បរិសុទ្ធផូរផង់ កំពុងតែត្រូវសទ្ធម្មប្បដិរូប ដែលប្លែងបន្លំផ្សេងៗ ចូលមកលុកលុយ

- សទ្ធម្មប្បដិរូប គឺជាអ្វីទៅលោកម្ចាស់ ខ្ញុំកូណាមិនទាន់បានយល់ទេទាន ?

- គឺជាពាក្យប្រៀនប្រដៅ ដែលផ្ទុយអំពីព្រះពុទ្ធសាសនាដែលភិក្ខុក្នុងព្រះពុទ្ធសាសនានាំយកមកផ្សព្វផ្សាយញាំញីព្រះធម៌ដែលបរិសុទ្ធរបស់ព្រះបរមសាស្ដានោះឯង

- ដូចជាអ្វីខ្លះទៅទាន ?

- ដូចជារឿងគ្រឿងស័ក្តិសិទ្ធិពូកែជាដើម ពេលនេះដូចជាគិត្តពុទ្ធសាវិកជាអ្នកផ្សព្វផ្សាយធម៌គាថ្ឡែ នេះហើយជាការធំ លោកគ្រូអាចារ្យអ្នកមានសីលអាគមពូកែកើតឡើងដូចជាផ្សិត ដើរផ្លុំស្លោះ ឲ្យរបស់ខ្លាំងពូកែស័ក្តិសិទ្ធិ ចែកចាយដល់ប្រជាជន ដើរដូរយកមាសប្រាក់ ធ្វើឲ្យប្រជាជនកើតមោហៈ វង្វេងក្នុងព្រះធម៌ ចាកឆ្ងាយអំពីព្រះធម៌ដែលបរិសុទ្ធ ជាពុទ្ធបរិស័ទតែឈ្មោះ ភាគច្រើនមានព្រះជាគ្រឿងព្យួរពេញក តែមិនបានយល់ក្នុងពាក្យទូន្មានរបស់ព្រះពុទ្ធជាម្ចាស់បង្រៀនអ្វីខ្លះនោះទេ លោភៈ ទោសៈ មោហៈ នៅពេញណែនក្នុងសរីរាង្គកាយ រំលត់នូវទុក្ខរបស់ខ្លួនឯងមិនបាន ថែមទាំងដើរទៅប្រាប់បង្គុនូវទុក្ខឲ្យអ្នកដទៃទៀត

- ព្រះតេជគុណ ព្រះអង្គមិនជឿទេថាគ្រឿងស័ក្តិសិទ្ធិនោះពូកែមែនទាន?

- អាត្មាជឿថា គ្រឿងស័ក្តិសិទ្ធិខ្លះដែលពូកែយ៉ាងនេះយ៉ាងនោះ មិនពិតទេ ពីព្រោះអាត្មាបានឃើញមកច្រើនហើយ ពួកចោរទាំងឡាយដែលត្រូវគ្នាក់អាសន្និសុខគម្រូតបាញ់សម្លាប់ជាញឹកញយនោះ សុទ្ធតែមានព្រះពូកែៗពាក់នៅពេញក ទាំងនោះបើជាគ្រឿងស័ក្តិសិទ្ធិពូកែមែនគួរតែមិនស្លាប់ដោយគ្រាប់កាំភ្លើងនោះទេ

- ខ្ញុំករុណាបានដឹងមកថា ក្នុងព្រះពុទ្ធរូបដែលស័ក្តិសិទ្ធិផ្សេងៗតែងតែមានពុទ្ធានុភាពសណ្ឋិតនៅជាមួយមែនឬទេ អាត្មាសួរដោយសេចក្តីសង្ស័យ

- ពិតឬមិនពិត សូមញោមគិតមើលទៅថា ពុទ្ធានុ-

ភាពនោះគួរមាននូវគុណសម្បត្តិផ្សេងៗ ដូចព្រះពុទ្ធអង្គដែរមែនទេញោម ?

- ក៏គួរនឹងពិតដូច្នោះមែន !

- ព្រះពុទ្ធអង្គអាចមានគុណសម្បត្តិយ៉ាងប្រសើរ គឺមានព្រះបញ្ញាត្រាស់ដឹងក្នុងព្រះធម៌ ទាំងផ្នែកលោកិយ៍និងផ្នែកលោកុត្តរៈ, មានវិសុទ្ធិគុណ គឺសេចក្ដីបរិសុទ្ធស្អាតប្រាសចាកអវិជ្ជា តណ្ហា ឧបាទាន លោភ ទោស មោហទាំងពួង, មានព្រះមហាករុណាទិគុណ គឺសេចក្ដីអាណិតស្រលាញ់ដល់សព្វសត្វ មិនរើសជាតិ ថ្នាក់ វណ្ណៈ មានទឹកព្រះទ័យស្មើដូចគ្នាទាំងអស់នូវសត្វទាំងពួង មិនចូលខាងអ្នកនោះ ចេញខាងអ្នកនេះ ។ បើសិនជាពុទ្ធានុភាពមានពិត ហើយពុទ្ធានុភាពមានគុណសម្បត្តិទាំងឡាយនោះមែនពុទ្ធានុភាពនោះ គួរតែសណ្ឋិតនៅក្នុងព្រះពុទ្ធរូបគ្រប់ៗអង្គស្មើគ្នា ។ ព្រះពុទ្ធរូបគ្រប់អង្គ មិនថាតូចឬធំ ធ្វើដោយវត្ថុផ្សេងៗ គួរតែមានភាពស័ក្តិសិទ្ធិស្មើៗគ្នា តែដែលមាននៅក្នុងពេលនេះ ញោមក៏ដឹងហើយថា ពុទ្ធានុភាពមិនបានសណ្ឋិតនៅក្នុងព្រះពុទ្ធរូបគ្រប់អង្គស្មើគ្នាទេ លោកទៅសណ្ឋិតរួមគ្នានៅជាមួយព្រះពុទ្ធរូបអង្គខ្លះប៉ុណ្ណោះ ធ្វើឲ្យព្រះពុទ្ធរូបអង្គនោះមានសេចក្ដីស័ក្តិសិទ្ធិ មានមនុស្សទៅគោរពរាប់អានច្រើន បណ្ដោយឲ្យព្រះពុទ្ធរូបអង្គផ្សេងៗមិនមានសេចក្ដីស័ក្តិសិទ្ធិ អង្គខ្លះត្រូវមនុស្សពាលគំនិតអាក្រក់កាត់យកព្រះសិរសយកទៅលក់ឲ្យជនបរទេសក៏មាន ។ បើការពិតនៅមានដូច្នេះ ញោមនឹងអាចជឿបានឬថាមាន

ពុទ្ធានុភាពសណ្ឋិតនៅក្នុងព្រះពុទ្ធរូបអង្គខ្លះ ?

- មានអ្នកខ្លះគេប្រាប់ខ្ញុំករុណាថា ការដែលព្រះពុទ្ធរូបអង្គខ្លះស័ក្តិសិទ្ធិ អង្គខ្លះមិនស័ក្តិសិទ្ធិនោះ ពីព្រោះអង្គខ្លះមានការសូត្រពុទ្ធាភិសេកយ៉ាងត្រឹមត្រូវ នៅពេលកសាងឬឆ្លាក់ព្រះពុទ្ធរូបរួចហើយ មានការប្រកបធ្វើពិធីនិមន្តលោកគ្រូអាចារ្យ អ្នកមានមន្តអាគមពូកែ មកសូត្រពុទ្ធាភិសេកគឺអភិសេកព្រះពុទ្ធរូបឆម្លងា ឲ្យទៅជាព្រះពុទ្ធរូបស័ក្តិសិទ្ធិចំណែកអង្គដែលមិនស័ក្តិសិទ្ធិនោះ មិនបានធ្វើពិធីពុទ្ធាភិសេក គេនិយាយគ្នាយ៉ាងនេះ តើព្រះគុណម្ចាស់យល់យ៉ាងណាដែរ ?

លោកគ្រូសើចបែបអារម្មណ៍ត្រជាក់ ហើយលោកក៏មានសង្ឃដីកាថា៖

- បើយ៉ាងនោះ រឿងក៏ទៅជាធំធេងឆ្ងាយ រឹបង្ហាញឲ្យឃើងឃើញច្បាស់ថែសហើយថា ដែលតាមការពិតទៅពុទ្ធានុភាពនោះក៏មិនជាវិសេសវិសាលអ្វីទេ គ្រាន់តែពួកអាចារ្យ បុថុជ្ជន ដែលនៅមានកិលេសក្រាស់ បញ្ញាអន់និងឆ្កិស្មោះ តែងឆ្លាក់ សូត្រឆ្កិ សូម្បីតែខ្លួនឯងឲ្យបានសម្រេចអ្វីឲ្យប្រសើរ មើលទៅមិនសមនឹងជាពុទ្ធានុភាពជំនួសព្រះបរមសាស្តាសោះឡើយ ។ ពួកគ្រូអាចារ្យទាំងនោះតើចេះពូកែអ្វី អាចធ្វើពិធីឲ្យព្រះឥដ្ឋ ព្រះថ្ម ព្រះសំរឹទ ក្លាយទៅជាព្រះពុទ្ធអង្គឡើងមកបាន ? អាត្មាឃើញថាបើលោកអាចារ្យទាំងអស់នោះពូកែពិតមែន គួរតែជួយបញ្ចូលឲ្យភិក្ខុសង្ឃដូចជាយើង ឲ្យទៅជាព្រះពុទ្ធអង្គឡើងមកខ្លះ នឹងមានព្រះ

ពុទ្ធអង្គច្រើនព្រះអង្គ ជួយនាំគ្នាប្រោសសត្វដែលកំពុងសោយសុខទុក្ខបុះទៅរាល់ៗថ្ងៃ មិនគួរទៅអភិសេកជុំឥន្ទ ជុំកំពោរ សំរឹត ស្ពាន់ ដូចដែលនាំគ្នាធ្វើតៗមក ឬញោមមានសេចក្ដីយល់ឃើញយ៉ាងណាដែរ ?

- ខ្ញុំករុណាយល់ឃើញ និងយល់ស្របដូចលោកគ្រូគ្រប់ប្រការទាន !

- ការដែលព្រះពុទ្ធអង្គបានសម្រេចព្រះធម៌ មិនមែនសម្រេចដោយការបញ្ចុលស្តុំ ស្តោះទេញោម បើសិនបានសម្រេចដោយការបញ្ចុលអញ្ចឹង ព្រះពុទ្ធអង្គក៏គង់មានពេញផ្ទះ ពេញស្រុក ព្រះបរមសារស្ដារបស់យើងក៏គង់មិនចាំបាច់បំពេញបារមីមកអស់រយៈពេល ៤ អសង្ខេយ្យកម្រៃសែនកប្ប បើការសូត្រស្តុំធ្វើឲ្យមនុស្សរួចចាកទុក្ខបាន ព្រះពុទ្ធអង្គ ក៏គង់ទ្រង់បង្រៀនតែពីរឿងស្តុំស្តោះ ទន្ទេញគាថាមន្តអាគម តែការពិតព្រះអង្គ ទ្រង់ហាមមិនឲ្យភិក្ខុសង្ឃរៀនទេ ទ្រង់បញ្ញត្តថាជា តិរច្ឆានវិជ្ជាទៅវិញ ទ្រង់បង្រៀនតែអំពីទុក្ខ ហេតុរបស់ទុក្ខ សេចក្ដីរំលត់ទុក្ខ និងផ្លូវទៅរកសេចក្ដីរំលត់ទុក្ខតែប៉ុណ្ណោះ

- បើដូច្នោះ ការស្តុំស្តោះ ដើម្បីឲ្យកើតសេចក្ដីស័ក្តិសិទ្ធិគឺខុសអំពីគោលដៅ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គទៅហើយអញ្ចឹងទាន ?

- ខុសពិតប្រាកដមែនហើយ !

- បើដូច្នោះ ដូចម្ដេចព្រះសង្ឃអង្គខ្លះទើបនៅធ្វើដែរទាន ?

- ហេតុដែលព្រះសង្ឃអង្គខ្លះ នៅតែធ្វើក៏ពីព្រោះមកពីអំណាចលោភៈ សេចក្ដីលោភក្នុងលាភ ក្នុងយស ហើយមោហៈ សេចក្ដីវង្វេង ម្ហូម៉ៅក្នុងកិត្តិយស ឈ្មោះសម្លេងព្រះសង្ឃប្រភេទនេះ នៅមានឧបនិស្ស័យសន្ដានមិនល្អ នៅពេលមិនអាចនឹងបដិបត្តិតាមព្រះធម៌វិន័យ យ៉ាងពិតប្រាកដឲ្យមនុស្សសទៀតជ្រះថ្លាបាន ក៏រកទៅអាស្រ័យតិរច្ឆានវិជ្ជាជាគ្រឿងសម្រាប់ចិញ្ចឹមជីវិត

- ការប្រព្រឹត្តយ៉ាងនេះ តើមានបាបច្រើនឬទេទាន?

- បាបច្រើនតែម្ដង ពីព្រោះព្រះពុទ្ធអង្គត្រាស់ទុកថា កម្មណាដែលធ្វើដោយអកុសលជាមូល គឺសេចក្ដីលោភ សេចក្ដីខឹងក្រោធ សេចក្ដីវង្វេង កម្មនោះជាបាបអកុសល នឹងឲ្យផលទៅកើតនៅក្នុងទុគ្គតិមាននរកជាដើម ។ ការផ្សព្វផ្សាយតិរច្ឆានវិជ្ជា ជាការធ្វើដោយលោភៈនិងមោហៈ ជាបាបមួយជាន់ទៅហើយ ការចំណាយបែកគ្រឿងស័ក្តិសិទ្ធិពូកែ ជាការដឹកនាំឲ្យប្រជាជនវង្វេងទៅដោយមោហៈ បន្ថែមបាបមួយជាន់ទៀត ។ ការអាស្រ័យព្រះសង្ឃបួសក្នុងព្រះពុទ្ធសាសនា គឺជាកន្លែងដែលផ្សព្វផ្សាយនូវពាក្យបង្រៀនក្រៅសាសនា ជាបាបធ្ងន់ជាន់ទីបី ជាការល្មើសគុណនឹងព្រះបរមសាស្ដា ចូលមកអាស្រ័យម្លប់ព្រះពុទ្ធសាសនាហើយ គួរតែនឹងតបស្នងគុណបុណ្យលោកដោយការលះបង់លោភៈ ក្រោធ វង្វេង ផ្សព្វផ្សាយធម៌ជាគ្រឿងកំចាត់លោភៈ ក្រោធ វង្វេង ត្រឡប់ជាទៅផ្សាយធម៌ការឡប្រៀបដូចជាមនុស្សអាក្រក់ដែលគេអាណិត ឲ្យអាស្រ័យនៅក្នុង

ផ្ទះ គួរតែនឹងបដិបត្តិតាមរបៀបបែបផែនការរបស់ម្ចាស់ផ្ទះ គ្រាន់ប៉ុទៅជាបង្កើតគ្រឿងមិនល្អ ធ្វើនូវសេចក្ដីសៅហ្មងខូចខាតឲ្យដល់ផ្ទះនិងម្ចាស់ផ្ទះ ទើបជាបាបធ្ងន់ណាស់

- ខ្ញុំកូណាតនៅមានមន្ទិលសង្ស័យ ទាក់ទងនឹងសេចក្ដីស័ក្តិសិទ្ធិរបស់ព្រះពុទ្ធរូបដែលគេនាំគ្នាហៅថា "**លោកឳ**" ឬគេផ្ទើលនិយាយថា "**លោកឳអង្គខ្លះ**" មានភាពស័ក្តិសិទ្ធិមែន ដូចជាមនុស្សម្នាក់ត្រូវគេប្ដឹងក្នុងរឿងសម្លាប់មនុស្ស គេជាអ្នកខុសពិតផង ពីព្រោះតែសេចក្ដីខ្លាចដែលនឹងត្រូវទទួលទោស ទើបគេធ្វើពិធីបន់ស្រន់ជាមួយព្រះពុទ្ធរូបដែលស័ក្តិសិទ្ធិមួយអង្គ ដែលមានមនុស្សនាំគ្នាគោរពរាប់អានច្រើន កាលដល់ពេលកាត់សេចក្ដីប្រាកដថាគេជាអ្នកឈ្នះក្ដីដោយមិនបានទទួលនូវទោសយ៉ាងនេះ តើលោកគ្រូយល់ឃើញយ៉ាងណាខ្លះដែរទាន ?

- អាត្មាយល់ឃើញថាជារឿងរបស់កម្មចាស់ បុកនឹងភ័ស្តុតាង សាក្សីផ្សេងៗក្នុងក្ដីនោះ ច្រើនជាងដែលនឹងជាអំណាចរបស់ពុទ្ធានុភាព ពីព្រោះបើពុទ្ធានុភាពមានមែន ពុទ្ធានុភាពនោះក៏គួរនឹងមានគុណធម៌យ៉ាងខ្ពស់ ដូចគ្នានឹងព្រះពុទ្ធអង្គដែលបានពោលមកហើយ មិនគួរនឹងទៅជួយឲ្យមនុស្សធ្វើខុសឲ្យឈ្នះក្ដី ដែលធ្វើឲ្យខុសច្បាប់ សេចក្ដីយុត្តិធម៌ មិនគួរទៅទទួលបម្រើអ្នកស្រុកផ្សេងៗ ដូចជាធ្វើឲ្យគេត្រូវឆ្នោតខ្លះ ឲ្យមានកូនខ្លះ ជាពីដប្ដីខ្លះ ឲ្យឈ្នះនូវក្ដីខ្លះ ពីព្រោះឃើញនូវរបស់ជាឈ្នួលបន្តិចបន្តួច ដូចជាល្ខោនគេលេងបញ្ឆោតកូនក្មេង នំ ទឹកដោះគោ ស្លែឈើ មាន់អាំង

ក្បាលជ្រូក អាត្មាមិនជឿថាជាពុទ្ធានុភាពនឹងមានចិត្តថ្លើម ថោកទាបដូច្នោះ បើ "**លោកឪអង្គខ្លះ**" មានភាពស័ក្តិសិទ្ធិមែនជាម្តងម្កាល ក៏គួរតែមិនមែនការធ្វើរបស់ពុទ្ធានុភាព អាចនឹងជាការធ្វើរបស់ទេវតាថ្នាក់ទាបខ្លះ ដែលអាស្រ័យព្រះពុទ្ធរូប រកស៊ីជាមួយមនុស្សល្ងង់ច្រើនជាង ដែលអាត្មាឃើញយ៉ាងនេះ ឬញោមមានការយល់ឃើញយ៉ាងណា ?

- ខ្ញុំករុណាក៏យល់ឃើញដូចព្រះអង្គដែរ យល់ថាពុទ្ធបរិស័ទវង្វេងនៅក្នុងរឿងរបស់ស័ក្តិសិទ្ធិច្រើនណាស់ តើព្រះអង្គនឹងគិតកែខៃយ៉ាងណាទាន ?

- មានតែផ្លូវមួយប៉ុណ្ណោះឯងញោម ដែលនឹងកែខៃស្ថានការណ៍កំពុងចុះដុនដាបខ្លាំងបាន គឺនៅពេលគេនាំគ្នាផ្សព្វផ្សាយមោហៈនោះ យើងក៏ត្រូវផ្សព្វផ្សាយបញ្ញា, នៅពេលគេឲ្យសេចក្តីងងឹតដល់ប្រជាជន យើងត្រូវឲ្យពន្លឺភ្លឺស្វាងដល់ប្រជាជន ពីព្រោះមានតែបញ្ញាប៉ុណ្ណោះ ទើបអាចបង្ក្រាបនូវមោហៈបាន ពន្លឺប៉ុណ្ណោះនឹងបង្ក្រាបនូវសេចក្តីងងឹតបាន យើងនឹងត្រូវសិក្សាឲ្យយល់នូវព្រះធម៌ដែលបរិសុទ្ធរបស់ព្រះបរមសាស្ដា, យើងនឹងត្រូវបដិបត្តិតាមគោលអរិយមគ្គ ដើម្បីរំលត់ភ្លើងរបស់ខ្លួនឯងជាមុនសិនរំលត់សេចក្តីងងឹតរបស់ខ្លួនយើងមុន នៅពេលមានពន្លឺភ្លឺស្វាងហើយ ទើបចាប់ផ្តើមដើរចែកចាយពន្លឺដល់ប្រជាជន អាត្មាឃើញថាញោមនេះហើយ ជាអ្នកមានសេចក្តីយល់ឃើញល្អ ទើបបានមកអនុគ្រោះដើម្បីនឹងបានពន្លឺថែមមួយដួងទៀត ជួយគ្នាកំចាត់សេចក្តីងងឹតក្នុងសន្តានចិត្តរបស់

មនុស្ស

- ករុណាលោកម្ចាស់ ក្រោយពេលដែលបានស្តាប់ព្រះអង្គមានសង្ឃដីការឿងផ្សេងៗមកតាំងតែពីដំបូង ខ្ញុំករុណាដូចជាចង់បួសឲ្យបានលឿនបំផុត ដែលអាចធ្វើទៅបាន នឹងឆាប់បានប្រព្រឹត្ត បដិបត្តិកំចាត់ លោភៈ មោហៈ ឲ្យហើយ ព្រះតេជគុណម្ចាស់នឹងឲ្យខ្ញុំករុណាបួសគាលណាទាន ?

លោកគ្រូញញឹមយ៉ាងពេញចិត្ត ហើយពោលថា៖

- ល្អហើយចុះ ! អាត្មានឹងចាត់ការបំបួសញោមមិនយូរទេ តែការបួសដែលនឹងបានលទ្ធផលល្អនោះ ត្រូវអស់ការៈគ្រឿងចំណងផ្សេងៗ ទាំងផ្លូវកាយទាំងផ្លូវចិត្ត អាត្មាចង់នឹងថាតើញោមនៅមានការៈអ្វីដែលនឹងត្រូវចាត់ការ ដាក់ចុះឲ្យរៀបរយសិនទៅឬទេ ដូចជាកិច្ចការទាក់ទងខាងផ្លូវរាជការតើមានឬទេ ? ការជាប់ជំពាក់ជាមួយគ្រួសារតើមានឬទេ ? ការជាប់ជំពាក់ជាមួយអ្នកផ្សេងៗតើមានឬទេ ? ប្រសិនបើមាន ត្រូវប្រញាប់ទៅចាត់ការឲ្យបានរៀបរយសិនទៅ ៗ

អាត្មាទទួលពាក្យលោកអាចារ្យហើយ ក៏ក្រាបលាត្រឡប់មកផ្ទះ...

# សាងផ្នួសព្រោះអ្វី ?

បទពាក្យ៧

បើបួសតាមតែប្រពៃណី ឥតបានសំភីខំសូត្ររៀន
សិក្សាបដិបត្តិចាត់ជាយាន ពុទ្ធដីកាមានជាតម្រា ។
បួសនោះឈ្មោះថាមិនប្រពៃ ឥតបានយល់ន័យពុទ្ធសាសនា
ដូចអ្នកសម្លឹងមើលអាហារ មិនបានភោក្តាស្គាល់រសជាតិ ។
បួសលេងបួសទ្រុស្តនឹងសាសនា បួសខ្ជិលធ្វើការខូចមារយាទ
បួសបានបង្អែករអាងពួកញាតិ បួសគ្រាន់ឆ្លកឆ្លៀតចិញ្ចឹមជីវិត ។
បួសខ្លះប្រឹងខំសន្សំទ្រព្យ បួសសែនអភ័ព្វមិនល្អពិត
លោភមច្ឆរិយបិទបាំងចិត្ត ស្ថិតក្នុងងងឹតឥតពន្លឺ ។
បួសតាមប្រភេទដូចពោលស្តី បញ្ជាក់ប្រាប់ន័យឲ្យដឹងព្ធ
បួសនេះគឺជាសោះអង្គឺ ប្រាសចាកពន្លឺប្រយោជន៍គុណ ។
បួសព្រោះដើម្បីចេញចាកទុក្ខ បំណងក្តីសុខសន្សំបុណ្យ
វិរិយខន្តីក្តីអត់ធន់ មិនស្មៀមទម្រន់ធន់សិក្សា ។
បរិយត្តិបដិបត្តិដុសខាត់ចិត្ត ប្រាកដជាក់ពិតបានភ្លឺថ្លា
បានដល់បដិវេធជាក់ប្រាថ្នា ទម្លុះអវិជ្ជាមោហៈបាន ។
បួសនេះទើបឧត្តមប្រសើរ គឺជាដំណើររំដោះប្រាណ
ចេញចាកវដ្តៈទុក្ខសោកបាន ឈោងយកនិព្វានបានសុខី ។
បួសជួយចម្លងអាត្មាឯង ឲ្យផុតចម្បែងទុក្ខរោគភ័យ
ទាំងបានជួយយោងជនដទៃ បួសនេះប្រពៃពេកកន្លង ៕

ដោយឧបាសក មិុញ សាវ៉ាង

# ៣៧. ទីណាមានចំណង់ ទីនោះមានទុក្ខ

ថ្ងៃស្អែកឡើង បងប្រុសធំដែលជាមេបញ្ជាការ នគរបាលបានមកលេងផ្ទះ ហើយគាត់សួរអាត្មាដោយ សម្លេងម៉ឺងម៉ាត់ថា៖

- បងបានឮថា ឯងនឹងសូមសាងផ្នួសមែនឬ?
- ពិតមែន! អាត្មាឆ្លើយ
- លោកប៉ាបានប្រាប់បងថា ឯងនឹងសាងផ្នួសហើយ មិនសឹកមែនឬទេ?
- នៅពេលនេះប្រាប់មិនទាន់បានទេ សូមទុកពេលឲ្យ ខ្ញុំគាត់សេចក្ដីសិនទើបបានស្រេច, អាត្មាឆ្លើយតបក្រោយពី គិតអស់រយៈពេលមួយសន្ទុះក្រោយមក

បងប្រុសធំសម្លឹងមើលមកអាត្មា ដូចជាឃើញអាត្មា ជាមនុស្សប្លែកមុខ ហើយសួរដោយពាក្យខ្លីៗថា៖

- ឯងគិតបានល្អហើយឬ?
- បាទបង! បានគិតល្អហើយ
- ដែលឯងថាគិតល្អហើយនោះ តើមានន័យថាយ៉ាង ណា?
- ប្អូនគិតថា ជីវិត "**ឃរាវាស**" មិនមានអ្វីក្រៅពីកញ្ចុះ កិលេស តណ្ហារបស់ខ្លួនឯងទេ មួយថ្ងៃៗមិនឃើញមានអ្វី ក្រៅពីរត់លោតរកនូវរបស់ផ្សេងៗ យកមកបម្រើនូវសេចក្ដី ចំណង់ ។ សេចក្ដីសុខមានបន្តិចបន្តួច តែសេចក្ដីទុក្ខនឹង

ការៈដែលនឹងត្រូវលីសែងមានច្រើនជាង នៅទីបំផុតក៏ស្លាប់អស់ ស្លាប់ឃ្លានជាមួយគ្នាទាំងអស់

- នាងនិយាយដូចជានាងហ្នឹងជាព្រះសោតាបន្ន! បងប្រុសធំនិយាយហើយសើចយ៉ាងខ្លាញ់, និយាយយ៉ាងនេះបង្ហាញឲ្យឃើញថានាងមិនតស៊ូជាមួយនឹងលោក នាងព្រមចុះចាញ់នឹងលោកយ៉ាងច្បាស់ ហើយនឹងគិតរត់យករួចខ្លួនមែនឬ?

- ស្រេចតែលើបងគិតចុះ តែសម្រាប់ប្អូនវិញ បានយល់ថាអ្នកបួសនោះហើយ គឺមនុស្សដែលគិតតស៊ូជាមួយលោក ខំព្យាយាមយកឈ្នះលោក ពីព្រោះគេមិនព្រមធ្លាក់ទៅជាកញ្ជះកិលេស តណ្ហារបស់ខ្លួន គេព្យាយាមនឹងយកឈ្នះកិលេសតណ្ហា ។ មនុស្សដែលមិនបួសនោះហើយ គឺជាមនុស្សព្រមចាញ់លោក ធ្លាក់ទៅជាកញ្ជះកិលេស តណ្ហារបស់ខ្លួននាង បណ្ដោយខ្លួនទៅតាមត្រសែលោកហើយស្រេចលើលោកនឹងបក់នាំទៅផ្លូវណា

បងប្រុសនៅស្ងៀម គិតមួយសន្ទុះ ហើយពោលថា៖

- នាងនិយាយបានល្អតែមិនទាន់ឃើញថានាងព្យាយាមយករួចខ្លួននោះនាង កុំភ្លេចណាំថាប៉ែចាស់ហើយ នាងនឹងធ្វើចិត្តអាក្រក់ចេញទៅចោលប៉ែឬ?

- ប្អូនព្រមទទួលថា ប្អូនព្យាយាមយករួចខ្លួនសិនចុះ មនុស្សយើងគួរតែយកខ្លួនឲ្យរួចមុនសិន ទើបគួរទៅជួយអ្នកដទៃឲ្យរួចដែរ បើខ្លួននាងមិនទាន់រួចផងនឹងទៅជួយអ្នកដទៃម្ដេចនឹងកើតទៅ យើងត្រូវចេះហែលទឹកជាមុនសិន

ទើបអាចទៅជួយអ្នកលង់ទឹកបាន បើមិនចេះហែលទឹកផង ចង់ទៅជួយអ្នកលង់ទឹកយ៉ាងម៉េចបាន នៅទីបំផុតលិចទឹកស្លាប់ទាំងពីរនាក់ ។ ចំណែកម៉ែនោះប្អូនមិនបានគិតចោលគាត់ទេ ផ្ទុយទៅវិញប្អូននឹងជួយឲ្យមានទីពឹងយ៉ាងប្រសើរគឺបុណ្យជូនម៉ែ បុណ្យនឹងជួយឲ្យម៉ែមានសេចក្ដីសុខទាំងក្នុងជាតិនេះ និងជាតិមុខ បើប្អូននៅជាឃរាវាសហើយនៅជាមួយម៉ែយ៉ាងល្អ ក៏អាចជាទីពឹងដល់លោកបានដោយកម្លាំងកាយ និងកម្លាំងទ្រព្យលុះដល់អាយុក្ខ័យរបស់លោកប៉ុណ្ណោះ តែបើប្អូនបានបួស លោកនឹងបានពឹងបុណ្យកុសលអំពីប្អូនទៀតទៅច្រើនភពច្រើនជាតិតែម្ដង

- ពាក្យឯងនិយាយមានវិគ្គ មានឃ្លាច្រើន, បងប្រុសធំពោលហើយសើចតិចៗ, ចង់នឹងថាឯងទៅប្រទេសក្រៅនោះ ឯងទៅរៀនខាងវិជ្ជាគីមី ឬទៅរៀនខាងសាសនាពិតប្រាកដ នេះមានន័យថាឯងនឹងមិនចិញ្ចឹមម៉ែមែនទេ ?

- ចិញ្ចឹម ! តែចិញ្ចឹមដោយអាហារដ៏ពិសេស ប្រសើរគឺបុណ្យ ឯការចិញ្ចឹមដោយបាយ ត្រីសាច់ អាហារនោះប្អូនសូមបើកឱកាសឲ្យបងៗបានធ្វើផង ពីព្រោះមិនមានឱកាសសងគុណម៉ែដោយការបួស គិតថាយើងជួយគ្នាចិញ្ចឹមម៉ែម្នាក់មួយផ្លូវ ពីរផ្លូវក៏ស្រេចហើយ ម៉ែនឹងបានទាំងអាហារធម្មតា និងអាហារប្រសើរ

- ចុះ "ជិន្តណា" គូដណ្ដឹងរបស់ឯងនុ៎ះ ឯងមិនអាណិតគ្នាខ្លះទេឬ ?

- អាណិតនោះគឺអាណិតហើយ តែនៅពេលជាមួយ

គ្នានេះ ក៏អាណិតមនុស្សទូទៅផងដែរ ពីព្រោះគ្រប់ៗគ្នានៅអណ្តែតតកកនៅក្នុងទន្លេទុក្ខជាមួយគ្នា ទាំងនោះបើប្អូនមិនចេញទៅបួសទេនោះ ហើយទៅរៀបការនៅដេកស៊ីជាមួយ “ជិន្តណា” ប្អូនក៏មានប្រយោជន៍សម្រាប់តែ “ជិន្តណា” តែម្នាក់ តែបើប្អូនចេញទៅបួស ប្អូននិងបានប្រយោជន៍ដល់មិត្តមនុស្សរាប់មិនអស់

- នាងគង់នឹងខូចចិត្តពិតប្រាកដហើយ,បងប្រុសពោលសម្លេងតិចៗ

- នាងអាចខូចចិត្តខ្លះជាធម្មតា ពីព្រោះទីណាមានសេចក្ដីស្រឡាញ់ សេចក្ដីជាប់ជំពាក់ ទីនោះក៏មានសេចក្ដីទុក្ខជាធម្មតារបស់សត្វលោក តែបើគេគិតថា ប្អូនទៅដោយល្អ មិនបានទៅក្នុងផ្លូវអាក្រក់ នាងក៏គង់មិនខូចចិត្តច្រើនទេ ហើយសេចក្ដីល្អរបស់ប្អូន នាងក៏នឹងអាចមានចំណែកដែរ នាងនឹងបានបុណ្យច្រើនដូចគ្នា បើគេទទួលត្រេកអរជាមួយ

- ហើយកិច្ចការងាររបស់ងងនោះ តើងងនឹងគិតធ្វើយ៉ាងណា កុំភ្លេចណាំថាងងទៅរៀនក្រៅប្រទេសដោយរាជការជាអ្នកចិញ្ចឹម ងងនឹងត្រូវធ្វើការឲ្យហ្លួងជាថ្នូរនឹងក្នុងពេលដែលងងរៀននៅក្រៅប្រទេស

អាត្មានឹកភ្ញាក់ព្រើត ពីព្រោះមិនដែលគិតដល់រឿងនេះមកពីមុនសោះ បើដោះស្រាយបញ្ហានេះមិនបាន ក៏នឹងមិនអាចបួសបានដែរ ពិតមែនតើរឿងនេះនឹងធ្វើយ៉ាងណាល្អទៅហ្ន៎ ?

បងប្រុសញញឹមយ៉ាងពេញចិត្តជាលើកដំបូង ហើយពោលថា៖

- បើឯងចង់បួសមែនក៏មិនពិបាក ចាំបងចាត់ការឲ្យ

- ចាត់ការយ៉ាងណា? អាត្មាសួរដោយសេចក្ដីត្រេកអរ

បងប្រុសគាត់បម្រុងនឹងឆ្លើយ តែគាត់បែរជាដើរចូលទៅក្នុងផ្ទះមួយស្របក់ ហើយត្រឡប់មកវិញព្រមទាំងកាន់ក្រដាសមួយសន្លឹក

- មើល "**ពិន័យកម្ម**" របស់លោកឪពុក! គាត់ពោលហើយហុចក្រដាសមួយហ្នឹងមកឲ្យអាត្មា អំពី "ពិន័យកម្ម" ច្បាប់នោះ

អាត្មាក៏បានដឹងជាលើកដំបូង ដែលបិតាបានប្រគល់ទ្រព្យសម្បត្តិតម្លៃមហាសាលឲ្យអាត្មា ពោលគឺមានដីស្រែប្រហែល ៣០០ រ៉ៃ នៅបរិវេណភូមិរងស្រសិត និងមានដីឡូត៍ ១០ ឡូត៍ទៀតនៅឯផ្លូវបន្ទាត់មាស ៗ

- ឯងទៅរៀននៅឯបរទេស យកប្រាក់ហ្លួងមួយខែប៉ុន្មានដែរ? បងប្រុសសួរ

- មួយខែ ៣០០០ បាត!

បងប្រុសនៅស្ងៀមគិតមួយសន្ទុះ ហើយពោលថា៖

- មួយខែ ៣០០០ បាតអស់ពេល ៤ ឆ្នាំ សរុបទាំងអស់ទៅ គិតជាប្រាក់ជិតពីរសែន តែល្អហើយចុះ ចាំបងនឹងជួយចាត់ចែងសងជំនួសឲ្យ គឺបងពេញចិត្តនឹងជួយប្រាក់ឲ្យហ្លួងមួយខែ ៣០០០ បាត លុះត្រាតែសងរួចថ្លៃដែលជំពាក់ ឲ្យឯងគិតថាបងជាអ្នកជំពាក់ហ្លួងជំនួសឯងក៏ហើយគ្នា

អាត្មានឹកស្ដែកក្នុងចិត្ត មិននៅៗ បងប្រុសមករ៉ប់រង ទទួលសងជំពាក់ជំនួសខ្លួនឯង ជាទំនងជួយឲ្យបានទៅបួស ពីមុននេះបន្តិច ធ្វើឫកពាឃាត់មិនចង់ឲ្យបួសយ៉ាងច្បាស់តែ អាត្មាឆ្លើយតបគាត់វិញថា៖

- អរគុណបងច្រើន ដែលបានជួយសងប្រាក់ជំនួស ប្អូន តែប្អូនមិនចង់រំខានបងឲ្យបងពិបាក ពីព្រោះប្អូនយល់ ថា បងមានកិច្ចការរវល់ច្រើន គិតយកយ៉ាងនេះវិញដើម្បីកុំ ឲ្យមានភារៈដល់បង ប្អូនសូមអនុញ្ញាតអ្នកម្ដាយដើម្បីលក់ ដីនិងដីឡូត៍នៅផ្លូវបន្ទាត់មាស យកប្រាក់ទៅសងថ្លៃជំពាក់ ហ្លួងឲ្យរួចតែម្ដងទៅ

បងប្រុសធំអង្គុយនៅស្ងៀម សម្ដែងនូវសេចក្ដី ក្រវល់ក្រវាយក្នុងចិត្តមួយសន្ទុះហើយក៏ពោលឡើងថា៖

- បើឯងលក់ ឯងអាចនឹងបានប្រាក់ច្រើនសងជំពាក់ ហ្លួងរួចអស់ក្នុងពេលនេះតែម្ដង តែយើងត្រូវអស់សម្បត្តិ ទាំងអស់ បើយើងមិនលក់ទេ យកតែថ្លៃឈ្នួលបន្ទប់ទៅ សងក្នុងមួយខែ ៣០០០ បាត នៅពេលអស់ជំពាក់ហើយ ផ្ទះឈ្នួលក៏នៅតែជារបស់យើងៗ អាចទាញយកផល ប្រយោជន៍បានរហូតទៅ គិតយ៉ាងនេះចុះ ទុកជាយ៉ាងណា ឯងនឹងបួសទៅហើយ ប្រគល់ទ្រព្យសម្បត្តិទាំងអស់នោះ ឲ្យមកបងទៅ រាអស់រឿងខ្វល់ និងបានបួសបំពេញធម៌ យ៉ាងពេញទំហឹង

អាត្មាអង្គុយគិតពិចារណា ដូចជាយល់ស្របជាមួយ នឹងខពន្យល់របស់បងប្រុស ពីព្រោះយល់ថា បងប្រុសធំនេះ

ឋានៈគាត់អន់ជាងបងៗឯទៀតៗ ថែមទាំងមានកូនច្រើនទៀតផង បើសិនជាលើកទ្រព្យសម្បត្តិឲ្យគេ ក្រៅអំពីការសងប្រាក់ឲ្យប្អូនហើយ នៅជាការសង្គ្រោះទៀតផង ។

នៅពេល ដែលអាត្មាកំពុងគិតនឹងលើកទ្រព្យសម្បត្តិឲ្យទៅបងប្រុសធំនោះឯង បងប្រុសទីពីរដែលជាអ្នកជំនួញក៏ចូលមកដល់

- បងបានដឹងថាឯងនឹងបួសមែនឬ? គាត់សួរឡើងដូចជាបងប្រុសធំដែរ
- មែន! អាត្មាឆ្លើយដូចសព្វដង
- ហើយទ្រព្យសម្បត្តិ ដែលជាមរតករបស់ឯងនោះ ឯងនឹងចាត់ការយ៉ាងម៉េចដែរ?

គាត់សួរឡើងដល់ចំណុចត្រង់ៗ ។

- គេលើកឲ្យបងអស់ហើយ! បងប្រុសធំពោលឡើងដូចជាមានសោកដឹយ
- ហ្ន៎! ធ្វើដូច្នេះតើវាត្រូវឬអី? បងប្រុសទីពីរនិយាយឡើងដោយសម្លេងបែបខ្លាំង សម្តែងនៅការមិនពេញចិត្ត ធ្វើឲ្យអាត្មាចាប់ផ្តើមមើលឃើញព្រិលៗ ដល់សេចក្តីពិបាកដែលនៅចាំខាងមុខ និងចាប់ផ្តើមឃើញឧបនិស្ស័យពិតប្រាកដរបស់បងប្រុសធំ ដែលនិយាយយកតែបាន ដើម្បីការពារប្អូនប្រុសរបស់ខ្លួនឯង
- ហើយនឹងធ្វើយ៉ាងណាទើបត្រូវ? បងប្រុសធំសួរ
- គឺត្រូវតែចែកឲ្យបានគ្រប់ៗគ្នាទៅ! បងប្រុសបន្ទាប់ឆ្លើយ

- គ្រប់គ្នាឬមិនគ្រប់គ្នា វាជារឿងរបស់ម្ចាស់មរតក គេមានសិទ្ធិនឹងបែងចែកឲ្យនរណា យ៉ាងណាក៏បាន ពេលនេះគេលើកឲ្យបងហើយ នងមិនគួរនឹងមកជ្រៀតជ្រែកធ្វើឲ្យរឿងនេះខ្វាយខ្វល់ទេ

បងប្រុសទីពីរ ងាកមកសម្លឹងអាគ្នាដោយកែវភ្នែកមានកំហឹងហើយសួរថា៖

- នងគិតយ៉ាងណា ទើបបានជាលើកមរតកឲ្យទៅបងធំម្នាក់ឯង ដូចម្ដេចបានជានងមិនចែកចាយឲ្យគ្រប់គ្នា បងប្អូនយើងទាំងអស់គ្នា មានសិទ្ធិនឹងបានទទួលចំណែកចែករបស់នងទាំងនោះ នងធ្វើបែបស្រឡាញ់ មិនចូលចិត្តម្នាក់ឬធ្វើដូច្នេះមិនត្រូវទេ បងប្អូនផ្សេងៗគេមិនយល់ព្រមទេ ហើយមិនអនុមោទនាក្នុងការបួសរបស់នងទៀតផង តើការបួសរបស់នងមានសេចក្ដីបរិសុទ្ធបានយ៉ាងណា ?

- នងនឹងនៅលោកនោះ ទោសោះដល់ណាទៀត, បងប្រុសធំពោលស្ទាក់ឡើង, នរណាៗក៏គេដឹងហើយថា នងមានឋានៈល្អ ខ្ពង់ខ្ពស់ជាងអ្នកដទៃក្នុងគ្រួសារយើង ?

- ពុទ្ធោអើយ ! បងដឹងអ្វី, បងប្រុសរងពោលឡើងខ្លះជីវិតអ្នកជិនួញ បងនឹងទៅយកអ្វីឲ្យបានពិតប្រាកដជាមួយវានោះ ជួនកាលក៏មិនល្អក៏គ្រាន់ល់បាត បងមិនដឹងទេឬថានៅពេលនេះ ខ្ញុំជិពាក់ឆនាគាររាប់លានហើយ បើបងដឹងបងនឹងធ្លាក់ទឹកចិត្ត

- តែបងឃើញនងនៅហ៊ុំបរាធូរធារមែនទែន នេះជួនកាលឃើញដប់លៀងភ្ញៀវ អស់ទាំងពាន់ទាំងម៉ឺនក្នុង

មួយយប់ៗ បើមនុស្សមិនមាន មិនអាចធ្វើបែបនេះបានឬ?

- នេះជារឿងនយោបាយការរកស៊ី បើសិនជាមិនមាន ប៉ុន្មានក៏ដោយយើងត្រូវតែរកយកមកដប់លៀងគេលុះត្រាតែបាន ដើម្បីសាងកេរ្តិ៍ឈ្មោះកិត្តិយសទុកក្នុងអ្នកជំនួញឬមិត្តភក្តិរួមធ្វើជំនួញ តែខាងក្រោយខ្នងពិតៗ ឋានៈរបស់ខ្ញុំពិបាកខ្លាំង ឋានៈរបស់បងនៅល្អជាងប្អូនឆ្ងាយណាស់

- ពុទ្ធោអើយ! ឯងនឹងមកប្រៀបធៀបស្អីជាមួយមេនគរបាលក្រដូចបងនេះ អាស្រ័យប្រាក់ខែដែលហ្លួងលោកឲ្យស៊ីមួយខែៗ តើទៅយកពីណាមកធ្វើមានបាននោះ ជាអ្នករដ្ឋការរៀនល្អតែយសស័ក្តិប៉ុណ្ណោះ គិតសង្ឃឹមថាឲ្យមានបានអំពីការងាររាជការនោះគ្មានផ្លូវសោះឡើយ

- យ៉ាងម៉េចមិនមាន, បងប្រុសបន្ទាប់និយាយឡើងដូចនឹងរឿង, ជាមេនគរបាលដូចបងនេះឯង បើចេះរកស៊ីមានរហ័សណាស់ ឲ្យគេបើកបនល្បែង ២ ឬ ៣ កន្លែងទៅខ្ជិលយកប្រាក់ ធ្វើអ្នកមាន ខ្ញុំឃើញអ្នកឯទៀតគេមានច្រើនណាស់ ឲ្យចេះប្រើអំណាចនាទីឲ្យបានជាប្រយោជន៍ខ្លះទៅ

- ពួកអ្នកជំនួញយ៉ាងនេះឯង, បងប្រុសធំនិយាយដោយសម្លេងបញ្ឈឺ, ឃើញតែពីស៊ីចុក ដោយមិនបានគិតដល់សីលធម៌ និងច្បាប់របស់ស្រុក គឺគិតឲ្យតែពីបាន អ្នកណាចង់ទៅជាស្អីក៏មិនរវល់ដែរ គឺថាពួកអ្នកជំនួញនេះហើយដែលធ្វើឲ្យអ្នករាជការខូច ពួកអ្នកឯងយកមាសយកប្រាក់ឬរបស់ផ្សេងៗទៅប្រគេន ដើម្បីសូកអ៊ីម៉ាង ទើបការពុករលួយបានកើតឡើង

បងប្រុសរងសើចបញ្ឆោះឲ្យ ហើយពោលថា៖

- បើសិនជាអ្នករាជការប្រាកដមែន ក៏មិនគួរទទួលទ្រព្យសំណូកអំពីអ្នកជំនួញទេ បើអ្នកទទួលមិនទទួលទេ ហើយក៏មិនមានស្អីកើតឡើងដែរ

- ឯងនិយាយយកតែបានដូចសព្វដង, បងប្រុសធំឆ្លើយ បើបងនឹងពោលថា, បើសិនមិនមានអ្នកមានទ្រព្យឲ្យទេតែម្យ៉ាង ក៏គ្មានអ្វីកើតឡើង តើឯងថាយ៉ាងម៉េច ពីព្រោះមកពីមានអ្នកឲ្យទើបមានអ្នកទទួល ព្រោះមានអ្នកស្នើសុំទើបមានអ្នកប្រគល់ បើគ្មានអ្នកឲ្យទេ ក៏គ្មានអ្នកទទួល ដូច្នោះសេចក្ដីខុសដំបូង គឺមកពីអ្នកឲ្យ

- អ្នកឲ្យវាត្រូវមានមួយថ្ងៃដល់យប់ ពីព្រោះការឲ្យជាការចុះដើមទុនម្យ៉ាង អ្នកជំនួញត្រូវមានការចុះដើមទុនដើម្បីយកចំណេញ បើមិនមានការចុះដើមទុនទេ ក៏មិនមានចំណេញ បើមិនមានដើមទុន មិនមានចំណេញ ក៏មិនមែនជំនួញដែរ

- អញឃើញឯងចុះដើមទុនរបស់ឯងតាមសប្បាយចុះ តែកុំមកចុះដើមទុនជាមួយបងក៏ហើយគ្នា មិនមានការសម្រេចឡើយ បងនឹងមិនបំផ្លាញច្បាប់ សីលធម៌ និងកិត្តិយសកេរ្តិ៍ឈ្មោះសម្លេងរបស់វង្សត្រកូល ពីព្រោះឃើញតែរបស់គេយកមកសែនទេ

- មានមនុស្សគេនិយាយថា បើនៅតែការពារយស ក៏អត់ឃ្លាន !

- បងសុខចិត្តអត់ស្លាប់ ល្អជាងរស់នៅក្អែតសប្បាយ

តែត្រូវគេដើរប្រទេចផ្កាសា

- ដូច្នេះសឲ្យឃើញថា បងមិនត្រូវការសេចក្តីសប្បាយ មានទ្រព្យសម្បត្តិច្រើនទេ មានបន្តិចបន្តួចក៏ចាយវាយតាមនឹងទៅ មួយថ្ងៃៗក៏ល្មមហើយមែនទេ ? បើដូច្នោះបងនឹងយកសម្បត្តិមរតក របស់ប្អូនទៅធ្វើអ្វី លើកឲ្យមកខ្ញុំវិញទាំងអស់មកមិនល្អទេឬ ?

- មិនមែនបងមិនចង់បាននោះទេ គឺបងចង់បានដែរ តែបានដោយផ្លូវសុចរិតត្រឹមត្រូវ មិនមែនមានក្នុងផ្លូវទុច្ចរិត ខុសច្បាប់ និងសីលធម៌ សម្បត្តិរបស់ប្អូនដែលបានមកដោយធម៌ បងក៏ទទួល ឯងមានឋានៈល្អស្តុកស្តម្ភជាងបង ឯងមិនគួរមកទាមទារសិទ្ធ ឬមួយឯងថាយ៉ាងម៉េច ?

បងប្រុសធំ វាគមកសួរអាត្មាជាលើកដំបូង ក្រោយពីអធិប្បាយជាមួយបងប្រុសបន្ទាប់ មកអស់រយៈពេលយ៉ាងយូរ ៗ អាត្មាមិនឆ្លើយ ពីព្រោះឃើញថាមិនចាំបាច់អ្វី ដែលនឹងទៅរួមប្រកែកដោយអំណាចសេចក្តីលោភ សេច-ក្តីខឹងក្រោធ ការវង្វេងជាមួយបងទាំងពីរនោះ ថែមទាំងមានសេចក្តីសង្វេគ ស្លុតចិត្តនូវសេចក្តីលោភដែលមិនចេះចប់របស់មនុស្ស ៗ តាមការពិតទៅ ជីវិតមនុស្សត្រូវការអាហារល្មមមួយចំអែត មួយថ្ងៃមួយពេលឬពីរពេលត្រូវការសំពត់អាវល្មមការពារកម្តៅ និងសេចក្តីអៀនខ្មាសត្រូវការកន្លែងនៅល្មមដាក់ខ្លួនដេកបាន ដាក់ខ្លួនអង្គុយបានត្រូវការថ្នាំល្មមបំបាត់ទុក្ខវេទនា ដែលកើតពីរោគភ័យគ្រុនឈឺប៉ុណ្ណោះ ៗ បើមនុស្សមានត្រឹមតែបច្ច័យបួនបម្រុងរាង

គាយដែលរោបច្ច័យ ហើយមានមេត្តា ករុណា មុទិតា ឧបេក្ខាដល់គ្នានិងគ្នា ក៏អាចនៅក្នុងលោកនេះបានយ៉ាង មានសេចក្តីសុខ តែពីព្រោះមនុស្សធ្លាក់ទៅរកញ្ញុះរបស់ តណ្ហា បម្រើតណ្ហាច្រើនរាងដែលនឹងបម្រុងជីវិតទើបមាន ការបៀតបៀនដូចរោសម្លាប់គ្នា ទើបលោកនេះក្តៅក្រហាយ ខ្វល់ខ្វាយ ។ អាត្មាសម្រេចចិត្តប្រាប់បងទាំងពីរថា៖

- ប្អូននឹងមិនលើកមរតកឲ្យនរណាទាំងអស់ ហើយ អាចនឹងមិនបួសទៀត

ហើយក៏ដើរចាកចេញពីផ្ទះទៅ ដោយទុកឲ្យបង ប្រុសទាំងពីរភ្ញាក់ផ្អើលនៅក្នុងចិត្ត...

# មានតែកង្វះ

បទពាក្យ៧

| | | |
|---|---|---|
| ជីវិតគិតតែពីក្តីសុខ | នឹងជួបក្តីទុក្ខជាក់មិនខាន | |
| បើចិត្តគិតតែពីចង់បាន | លែងអីនឹងមានតែកង្វះ | ។ |
| រស់នៅក្នុងទុក្ខឥតស្គាល់ទុក្ខ | មុខជាជួបទុក្ខប្រាកដណាស់ | |
| កើតមកមួយជាតិឲ្យឃ្លាតព្រះ | ប្រាកដពិតណាស់ជួបតែប្រេត | ។ |
| បណ្តោយជីវិតឥតសិក្សា | ខ្វះមនសិការមិនសង្កេត | |
| ពុំបានដឹងយល់ផលនិងហេតុ | ភ្នែកឃើញក្រឡៅតដឹងមិនដល់ | ។ |
| ជាទាសករនៃតណ្ហា | ចៅហ្វាយបញ្ញាក៏មិនស្គាល់ | |
| ប្រណាំងប្រជែងវង្វេងកង្វល់ | ទីបំផុតដល់ក្តីមរណា | ។ |
| ស្លាប់ទៅទាំងខ្វះមិនគ្រប់ពិត | នេះគឺជីវិតសព្វសត្តា | |
| អន្ទោលស្លាប់កើតក្នុងសង្សារ | ពុំដែលសត្វណាពោលថាគ្រប់ | ៕ |

ដោយឧបាសក ម៉ិញ សារ៉ាង

# ៣៨. កុំរត់តាមសេចក្ដីសុខ

អាត្មាដូចដាស់ស្មារតីចិត្ត ចំពោះសេចក្ដីលោភលន់ដែលមិនចេះគ្រប់គ្រាន់របស់មនុស្ស ។ ដើម្បីបន្ធូរបន្ថយសេចក្ដីតានតឹងក្នុងទ្រូង ទើបបើករថយន្តចេញពីផ្ទះតម្រង់ទៅជួបលោកអាចារ្យនៅវត្ត ហើយក៏ពិតលោកឲ្យជ្រាបដល់ឫកពាបងប្អូនទាំងពីរនាក់ឲ្យលោកស្ដាប់ ។ លោកគ្រូសើចយ៉ាងគ្រដាក់អារម្មណ៍ ហើយពោលថា៖

- មនុស្សប៉ុប៉ុន្មាននេះដូចគ្នាទាំងអស់ហ្នឹងញោមអើយ! ពាក្យថាល្មមមិនមានសម្រាប់គេទេ បានហើយចង់បានទៀត គាន់តែមាន ចង់មានទៀត នៅពេលមិនទាន់បានមិនទាន់មាន ក៏គិតថា បើបានយ៉ាងនោះ មានយ៉ាងនេះ ខ្ញុំប្រហែលនឹងមានសេចក្ដីសុខ នៅពេលបានហើយ សមដូចសេចក្ដីប្រាថ្នាហើយ ក៏យល់ថាវាមានសេចក្ដីសុខមួយរយៈប៉ុណ្ណោះ បន្តិចទៀតក៏អស់សេចក្ដីសុខ ហើយក៏គិតតទៅទៀតថា បើខ្ញុំមានយ៉ាងនេះ បានយ៉ាងនោះ ប្រហែលនឹងមានសេចក្ដីសុខ ដល់បានមកដូចសេចក្ដីប្រាថ្នាហើយ ក៏យល់ថា មានសេចក្ដីសុខបានមួយភ្លែត ហើយក៏ចង់បានចង់មានថែមច្រើនៗឡើងទៅទៀត មិនមានទីបញ្ចប់ ។ មនុស្សគ្រប់គ្នា ត្រូវការសេចក្ដីសុខដូចគ្នាទាំងអស់ តែនៅពេលបានសុខហើយ គួរតែចាប់វាទុក ត្រឡប់ទៅដាក់បោះវាចោលទៅខាងមុខ ហើយរត់តាមវាទៀត ។ នៅពេលតាម

វាទាន់ហើយ គួរនឹងចាប់វាទុក ត្រឡប់ជាបោះវាទៅខាងមុខ ហើយរត់ដេញតាមទៀត ។ ធ្វើយ៉ាងនេះជានិច្ចលុះដល់ថ្ងៃស្លាប់ វាក៏ដូចជាអ្នកលេងកីឡាបាល់ទាត់ រត់ទៅផុតជើងល្អមទៅទាន់កូនបាល់ហើយគួរតែចាប់វាទុក ត្រឡប់ជាទាត់វាទៅខាងមុខ ហើយក៏រត់តាមទៅផុតជើង បើដូច្នេះ ទើបមិនមាននរណាមានសេចក្ដីសុខយ៉ាងពិតប្រាកដ មិនថាក្រ ឬមានតែងតែរត់ដេញតាមសេចក្ដីសុខគ្រប់ៗគ្នា យ៉ាងផុតជើងទាំងអស់

- បើយ៉ាងដូច្នេះ ធ្វើយ៉ាងណាទាន ទើបនឹងមានសេចក្ដីសុខយ៉ាងពិតប្រាកដ ?

- បើចង់មានសេចក្ដីសុខឲ្យពិតប្រាកដ ត្រូវឈប់រត់បោះសេចក្ដីសុខទៅខាងមុខ ចូរពេញចិត្តក្នុងបច្ចុប្បន្ន សុខក្នុងខណៈនេះ សុខឥឡូវនេះ សេចក្ដីសុខមិនមាននៅនឹងរបស់ដទៃ មិនមែននៅទីផ្សេង សេចក្ដីសុខនៅក្នុងចិត្តរបស់យើងនេះឯង ។ ចិត្តដែលឈប់រត់តាមរបស់ខាងក្រៅ ឈប់ឃ្លាន ឈប់ស្រេក មានតែសេចក្ដីស្អាត ភ្លឺ ស្ងប់ មិនថានឹងនៅទីណា តែមានសេចក្ដីសុខ ។ មនុស្សលោកចូលចិត្តថា សេចក្ដីសុខនៅក្នុងវត្ថុខាងក្រៅ នៅនឹងអ្នកដទៃ នៅក្នុងទីកន្លែងខ្លះ ទើបរត់ទៅរកសេចក្ដីសុខអំពីរបស់នោះៗ អំពីទីកន្លែងនោះៗ តែនៅទីបំផុតក៏មិនបានជួបសេចក្ដីសុខដែលពិតប្រាកដ ជួបតែសេចក្ដីស្រួល សេចក្ដីសប្បាយ និងសេចក្ដីរីករាយដែលជាសំបករបស់សេចក្ដីសុខ តែមិនអាចជួបសេចក្ដីសុខពិតប្រាកដ ។ លោកនេះ

ចម្រើនឡើង មនុស្សមានសេចក្តីចេះដឹងក៏ច្រើនឡើងហើយ ក៏បានប្រើការចេះដឹងនោះ ក្នុងការប្រឌិតនូវរបស់ជំនួយ សេចក្តីស្រួល សប្បាយ ស្រណុកឲ្យដល់ខ្លួន មនុស្សមាន សេចក្តីស្រួលសប្បាយ ស្រណុកច្រើនឡើង តែក៏មាន សេចក្តីសុខតិចចុះរាល់ថ្ងៃ ។ មនុស្សចម្រើនឡើងតែសេចក្តី លោភ សេចក្តីខឹង សេចក្តីវង្វេង ក៏ចម្រើនឡើងតាម ចំណែកធ្វើ ឲ្យក្តៅក្រហាយអន្ទះអន្ទែងច្រើនឡើងរាល់ថ្ងៃ បៀតបៀនជីវិត ទ្រព្យសម្បត្តិនិងមនុស្សស្រឡាញ់របស់គ្នា និងគ្នាច្រើនឡើងៗរាល់ថ្ងៃ អាត្មាយល់ថាលោកកំពុងតែដើរ ផ្លូវទៅរកសេចក្តីវិនាសយ៉ាងលឿន ។ បើយើងមើលបែប សើៗ យើងនឹងឃើញថា មនុស្សកំពុងសាងលោក តែបើ យើងពិនិត្យមើលឲ្យបានជ្រៅ យើងអាចនឹងឃើញថា មនុស្សកំពុងបំផ្លាញលោកនិងបំផ្លាញខ្លួនឯង

- លោកម្ចាស់មានន័យថាយ៉ាងណាទាន? អាត្មាសួរ ដោយសេចក្តីសង្ស័យ

- យកយ៉ាងនេះវិញល្អជាង អាត្មានឹងនិយាយរឿង ប្រៀបធៀបឲ្យស្តាប់ដើម្បីឲ្យចូលចិត្តងាយឡើង មានរឿង និយាយថា៖ ក្នុងមហាសមុទ្រមានមច្ឆាដ៏ធំមួយ ហៅថាត្រី អានន្ទ, ត្រីអានន្ទហែលដេញស៊ីត្រីតូចធំក្នុងមហាសមុទ្រ រាល់ៗថ្ងៃ ហើយធំធាត់ទៅជាលំដាប់ ។ កាន់តែធំឡើង ក៏ កាន់តែស៊ីត្រីច្រើនឡើងដែរ នៅទីបំផុតត្រីតូចធំអស់រលីង ពីមហាសមុទ្រ ។ មានថ្ងៃមួយពេលដែល ត្រីអានន្ទកំពុង ហែលវិលនៅក្បៀនភ្នំក្នុងកណ្តាលមហាសមុទ្រ វាក៏បាន

ឃើញកន្ទុយរបស់វា, ដោយសេចក្តីស្រេកឃ្លាន ត្រីអានន្ទ នឹកស្មានថាជាត្រីធំមួយទៀត ទើបដេញត្របាក់មិនឈប់ ៗ នៅទីបំផុតវាក៏ខាំត្របាក់កន្ទុយខ្លួនឯងបានហើយ ខាំស៊ីយ៉ាងឆ្ងាញ់ វាខាំស៊ីខ្លួនរបស់វាដើរទៅៗជារៀងរាល់ថ្ងៃ ៗ នៅទីបំផុតនៅសល់តែឯក្បាល វាបានត្របាក់យកខ្លួនឯងលេបចូលទៅជាពេលចុងក្រោយ នេះគឺថាត្រីអានន្ទជួបវិបាកចុងក្រោយព្រោះសេចក្តីស្រេកឃ្លានរបស់ខ្លួនឯង ៗ

អាត្មាឃើញថា មនុស្សយើងរាល់ថ្ងៃនេះ ក៏ដូចជាត្រីអានន្ទដែរ មនុស្សមានសេចក្តីល្មោភមិនចេះអស់មិនចេះហើយ មនុស្សបានជីករកទ្រព្យសម្បត្តិក្នុងដី ក្នុងទឹក យកឡើងមកបម្រើសេចក្តីចង់បានរបស់ខ្លួន ទាល់តែអស់ទៅហើយ នៅពេលដែលមនុស្សកាត់ធំឡើង លោកត្រឡប់ជាស្គមស្គាំងអន់ថយចុះជារៀងរាល់ថ្ងៃ នៅពេលទ្រព្យធម្មជាតិអស់ទៅ មនុស្សទើបចាប់ផ្តើមងាកមកប្រណាំងប្រជែងគ្នាឯង ដណ្តើមគ្នានៅ ដណ្តើមគ្នាធ្វើ ដណ្តើមគ្នាស៊ី ដណ្តើមគ្នារៀន ហៀតហៀនដូចជាសម្លាប់គ្នាច្រើនឡើងៗរាល់ថ្ងៃ ៗ សង្គ្រាមលោកលើកទីមួយ ដូចជាមនុស្សបានស៊ីកន្ទុយរបស់ខ្លួនឯង, សង្គ្រាមលោកលើកទីពីរ ដូចជាបានស៊ីខ្លួនរបស់ខ្លួនឯង, សង្គ្រាមលោកលើកទីបី កើតឡើងពេលណា ពេលនោះដូចជាមនុស្សបានត្របាក់ស៊ីក្បាលរបស់ខ្លួនឯង វាប្រៀបបាននឹងវិបាកចុងក្រោយរបស់មនុស្សជាតិពីព្រោះអំណាចរបស់អាវុធប្រល័យលោកដែលមនុស្សបានសាងឡើងនឹងធ្វើឲ្យមនុស្សជាតិសូន្យបាត់ទៅពីលោកនេះ ៗ

ពីព្រោះហេតុនេះហើយ អាត្មាទើបពោលថា មនុស្ស កំពុងតែដើរតាមផ្លូវ ឆ្ពោះទៅរកសេចក្ដីវិនាសយ៉ាងលឿនប្រញាប់ អាត្មាឆកឆល្ងើមភើង ដោយសេចក្ដីនឹកគិតសង្វេគក្នុងចិត្ត ហើយអាណិតសត្វ ដែលកំពុងត្រូវលោភ ក្រោធ វង្វេងដឹកច្រមុះទៅរកសេចក្ដីវិនាស

- តើមានវិធីណាខ្លះទេទាន ដែលនឹងការពារមិនឲ្យលោកដើរទៅរកសេចក្ដីវិនាស ហិនហោច? អាត្មាទូលសួរលោកគ្រូ ក្រោយពីអង្គុយនឹកមួយសន្ទុះ

- ពិបាកណាស់! លោកគ្រូឆ្លើយតបដោយសម្លេងហ្មត់ចត់, ពិបាកមែនៗ មិនមាននរណាអាចទប់ស្កាត់នូវគ្រាប់នៃលោភៈ ទោសៈ មោហៈ របស់មនុស្សទាំងអស់នដីបាន តែយ៉ាងនេះចុះ រឿងរបស់លោកជារឿងធំ ជួនកាលហួសវិស័យដែលយើងនឹងទៅកែខៃ ផ្លាស់ប្ដូរឬទប់ស្កាត់បាន នៅពេលយើងចាត់ការជាមួយលោកធំមិនបាន ក៏សូមឲ្យយើងងាកមកចាត់ការជាមួយលោកតូចៗ របស់យើងវិញ លោកដែលភើងឆ្ងាយគ្រាស់របស់យើងម្នាក់ៗនេះ និង សូមឲ្យយើងចាត់ការបង្ក្រាបលោភ ក្រោធ វង្វេងក្នុងលោក តូចៗរបស់យើងនេះជាមុនសិន នៅពេលយើងបង្ក្រាបលោកតូចៗរបស់យើងបានហើយ យើងអាចនឹងជួយបង្ក្រាប លោភៈ ទោសៈ មោហៈ របស់អ្នកដទៃបានខ្លះសូម្បីមិនបានទាំងអស់នដី បានត្រឹមតែមួយផ្នែកក៏ល្អដែរយ៉ាងហោចណាស់ យើងមានសេចក្ដីស្ងប់សុខសមនូវតម្លៃជីវិតដែលបានកើតមកមិនស្ដាយកំណើត យើងនាំគ្នាមក

បួសប្រសើរជាង

- លោកគ្រូម្ចាស់ ! សូមទានជួយពន្យល់ដល់ខ្ញុំកូណាផងចុះថា តើត្រូវចាត់ការយ៉ាងណាល្អជាមួយមរតកដែលពួកបងៗ កំពុងប្រជែងដណ្តើមគ្នានោះ ?

លោកគ្រូគង់បិទភ្នែកមួយសន្ទុះធំ ហើយបើកភ្នែកឡើងពោលថា ៖

- ការពិតរឿងមរតករបស់ញោម វាជារឿងរបស់ញោម អាត្មាមិនចង់រវល់ទាក់ទងជាមួយរឿងរបស់លោកពីព្រោះបានលះបង់អស់ហើយ តែសម្រាប់ញោមអាត្មានឹងផ្តល់យោបល់ខ្លីៗជាពិសេស ព្រោះអ្វីៗក៏បានតាំងចិត្តហើយថានឹងអនុគ្រោះ គោលវាយៗក៏មានមកថា បើមានមនុស្ស ២ នាក់ដណ្តើមរបស់តែមួយ ក៏គួរចែកឲ្យដល់គេទាំង ២ ស្មើៗគ្នាដែរ តែសូម្បីតែដូច្នោះ ក៏មិនទាន់ល្មមគេចមិនផុតពីការជេរប្រមាថគ្នា ពីព្រោះម្នាក់ៗ នឹងអាងហេតុផលផ្សេងៗថាខ្លួនគួរតែបានច្រើនជាង ។ ដើម្បីកាត់បញ្ហាដ៏ស្មុគស្មាញនេះ គួរលើកឲ្យមនុស្សទីបី ដែលមិនបានឈ្លោះប្រកែកជាមួយនរណា ងចំណែកមរតកនៅផ្លូវបន្ទាត់មាស អាត្មាឃើញថាគួរនឹងលើកឲ្យម្ដាយ ពីព្រោះម៉ែជាបុគ្គលដែលបងប្អូនទាំងពីរគោរពខ្លាចក្រែងចិត្ត គេមិនហ៊ានតាមទៅដណ្តើមអំពីម៉ែ មួយផ្នែកទៀតដែលនៅសល់អូររម្យសិតនោះក៏គួរឲ្យដល់បុគ្គលទី ៣ ដូចគ្នា

លោកគ្រូឈប់នៅស្ងៀមតែប៉ុណ្ណោះ លោកមិនបានបញ្ចេញឈ្មោះបុគ្គលទី ៣ ជាម្ចាស់មរតកឡើយ ។ ងិបូង

អាត្មាដូចជាចម្លែកក្នុងចិត្តទើបពិតសួរលោកថា៖

- លោកគ្រូមានន័យថា លើកឲ្យប៉ុន៉ុណ្ណឹងទៀតមែនទេ?

- អាត្មាគិតថាប្រហែលហ្នឹងហើយ! លោកគ្រូឆ្លើយដោយការពិចារណាយ៉ាងល្អិតល្អន់, កុំឲ្យអាត្មាឆ្លើយប្រសើរជាង គិតយ៉ាងនេះវិញល្អជាង បើមានពេលទំនេរអាត្មាចង់ឲ្យញោមទៅត្រួតពិនិត្យមើលដីស្រែ ៣០០ រ៉ៃនោះមើល ពេលទៅឃើញទីដីស្រែនោះហើយ ញោមអាចនឹងគាត់ចិត្ត សម្រេចខ្លួនឯងហើយ ថាតើនឹងលើកឲ្យអ្នកណាទៅទើបល្អ

នៅពេលព្រឹកស្អែកឡើង អាត្មាបានសុំអនុញ្ញាតពីអ្នកម្តាយ ឲ្យនាយតើម អ្នកបម្រើចាស់នៅក្នុងផ្ទះបើកឡានជូនទៅអូររស្សិត ដើម្បីទៅមើលស្រែ ពីព្រោះនាយតើមនឹងស្គាល់រ៉ៃនៃស្រែនោះយ៉ាងច្បាស់លាស់ ៗ នាយតើមនាំអាត្មាមកឈប់រថយន្តហួសអូររស្សិត ទៅផ្លូវខាងត្បូងបន្តិច ហើយក៏នាំគ្នាដើរតាមភ្លឺស្រែទៅទិសខាងកើតត្រង់ទៅដល់ផ្លូវព្រៃឫស្សី ដែលនៅឆ្ងាយអំពីផ្លូវធំឆ្ងាយ គួរសម ៗ មុននឹងដល់ផ្លូវព្រៃឫស្សី នាយតើមបានឈប់ហើយចង្អុលឲ្យអាត្មាមើលទំហំដីស្រែដ៏ធំធេង ដែលជាមរតករបស់លោកឪពុកប្រគល់ឲ្យអាត្មា ៗ

នាយតើមពន្យល់ថា នៅមួយដូរនេះដីកំពុងតែឡើងថ្លៃសម្បើមណាស់ ពីព្រោះរដ្ឋការកំពុងពិចារណា និងចាត់ចែងបរិវេណនេះទៅជារោងចក្រ វេលានេះមានបរិស័ទឧស្សាហកម្មច្រើនកន្លែង កំពុងរត់រកទិញដីដើម្បីសាងសង់រោងចក្រ ខ្ញុំគិតថាបើលោកនឹងលក់ក៏អាចលក់បាន

ចំណែកកន្លែងនិងផ្ទះជួលនៅឯផ្លូវបន្ទាត់មាស ខ្ញុំយល់ថាកុំអាលលក់ ពីព្រោះយើងបានផលប្រយោជន៍អំពីវាច្រើន

- ចុះស្រែនេះយើងបានផលប្រយោជន៍យ៉ាងណាដែរ? អាត្មាសួរ ពីព្រោះមិនសូវនឹងរឿង មកពីមិនដែលគិតមកអំពីមុន

- យើងចែកឲ្យអ្នកស្រុកជួលធ្វើ, នាយកើមអធិប្បាយ មានអ្នកស្រុកកំពុងជួលធ្វើប្រហែល ២០០ គ្រួសារ ខ្លះជួលធ្វើ ១០ ហិ៍ ខ្លះ ២០ ហិ៍ ខ្លះស្រេចតែកម្លាំងរបស់គេ យើងយកផលប្រយោជន៍គិតជាឆ្នាំ យកជាប្រាក់ខ្លះ ជាស្រូវខ្លះ ស្រេចទៅលើអ្នកជួលគេឲ្យ តែមិនសូវជាបានប៉ុន្មានទេ ឆ្នាំណាស្រូវល្អក៏យកបានច្រើន ឆ្នាំណាស្រូវមិនសូវល្អក៏បានតិច ឆ្នាំខ្លះមិនបានសោះ លោកម្ចាស់លោកចិត្តល្អហួសពេក អ្នកណាមកសុំលោះលោះអ្វីៗ លោកព្រមទាំងអស់

- ឪពុកខ្ញុំចិត្តល្អដូច្នេះ នាយកើមនៅគិតថា លោកមិនល្អទៀតឬ?

- ល្អណាស់ទាន! នាយកើមឆ្លើយយ៉ាងច្បាស់ៗ ប្រហែលគេសង្កេតឃើញឫកពាមិនពេញចិត្តរបស់អាត្មា, ឪពុកលោកចិត្តល្អណាស់ ខ្ញុំគោរពលោកដូចជាឪពុកបង្កើតរបស់ខ្ញុំតែម្តង តែការចិត្តល្អរបស់លោក ជួនកាលធ្វើឲ្យយើងខូចប្រយោជន៍ដូចគ្នាដែរ

- ល្មើយចុះ! កុំនិយាយអំពីលោកឪពុករបស់ខ្ញុំអី នាំឲ្យខ្ញុំនឹកគិតដល់លោក

- ខ្ញុំសូមទោសទាន! នាយកើមនិយាយតិចៗ ឈ្ងោក

មុខចុះក្រោម

- មិនអីទេ ខ្ញុំចង់ដឹងថា ឆ្នាំទៅមិញនេះ តើស្រូវល្អដែរឬទេ ?

- អន់សល្អើមហើយ ត្រៅពីរាំងស្ងួតហើយ ស្រូវត្រូវគណ្តុរស៊ីទៀត បានផលប្រយោជន៍បន្តិចបន្តួចប៉ុណ្ណោះ ឆ្នាំនេះក៏ព្រួយពិបាកទៀត ថ្មីនេះទៅហើយមិនទាន់មានភ្លៀងធ្លាក់មកទៀត

- នាយតើមអាចនាំខ្ញុំទៅជួបអ្នកដួលស្រែ បានម្នាក់ពីរបានឬទេ? ខ្ញុំចង់និយាយជាមួយនឹងគេបន្តិច

- បានទាន! នាយតើមឆ្លើយហើយ ដើរនាំមុខអាត្មាទៅដល់ផ្លូវដើមព្រៃឫស្សី

យើងបានមកដល់ផ្ទះមួយខ្នងដំបូង ដែលសង់នៅលើទួលក្បែរគុម្ពឫស្សី ៗ គារពិតគួរតែហៅថាខ្ទម ឬតូបល្អជាងដែលហៅថាផ្ទះ ពីព្រោះជារោងតូចៗ ដែលប្រក់ដោយស្លឹកចាកចាស់ៗ ដំបូលទាបលើកទីកន្លែងនៅខ្ពស់ជាងដី ដោយសសរយកគល់ឈើលះសំបកចេញតូចៗហើយចងគួបគ្នា ៗ មុននឹងចូលទៅក្នុងផ្ទះ យើងឃើញកូនក្មេងខ្មៅៗ ស្លៀកខោរហែករយ៉ៃ ២ - ៣ នាក់ ឈរមើលយើងយ៉ាងយកចិត្តទុកដាក់ ៗ នៅពេលមកដល់មុខផ្ទះមានស្ត្រីម្នាក់អាយុប្រហែល ៤០ ឆ្នាំឆ្ងាយ ចេញមកពីក្នុងផ្ទះឈរមើលយើងដោយពិនិត្យពិច័យ គេស្លៀកសំពត់ចងក្បិនពណ៌ខ្មៅ មានសំពត់ស្បៃចាស់ៗរុំនៅជុំវិញដើមទ្រូងសក់ខ្លី ដូចជាស្រីអ្នកស្រែទីយកណ្តាលទូទៅ ៗ

- ហ្ន៎! លោកតើមទេតើ នឹកស្មានថាអ្នកណា, ស្រីម្ចាស់ផ្ទះទទួលរាក់ទាក់ ហើយក៏ស្ទោះទឹកមាត់ស្លាទៅលើឪ, អញ្ជើញអង្គុយសិនចាំ

- ខ្ញុំនាំលោកតូច កូនប្រុសរបស់លោកម្ចាស់ មកមើលស្រែ, នាយតើមឆ្លើយដោយសម្លេងសម្តែងអំណរចបន្តិចបន្តួច, ម្ចាស់ផ្ទះលើកដៃសំពះអាត្មា ហើយក៏បញ្ចេញពាក្យសូមឲ្យអញ្ជើញអង្គុយលើផ្ទះ គាត់ស្រវាយកកន្ទេលបក់គ្រើជូតរនាបផ្ទះយកតែម៉ែនទែន

នាយតើម ក៏នាំអាត្មាឱនក្បាលចូលទៅតាមគ្រោមដំបូលខ្ពម ចូលទៅអង្គុយលើគ្រែគ្រាលដែលធ្វើអំពីបន្ទះឫស្សីគ្រាលឆ្លាស់គ្នា ។ នៅពេលម្ចាស់ផ្ទះកំពុងរវល់រៀបចំផ្ទះសម្បែង បរិយាកាសក្នុងផ្ទះងងឹតស្លុងៗ ។ នៅជញ្ជាំងខាងក្បាលដំណេក មានប្រតិទិនរបស់ហាងលក់ថ្នាំព្យួរមួយផ្ទាំង ហើយមានព្រះបរមឆាយាលក្ខណ៍របស់ស្តេចឃ្យូហ្សូរ និងរូបភាពខ្នាតតូចៗព្យួរជាច្រើន ខាងជ្រុងបន្ទប់ផ្នែកខាងកើត មានវ៉ាំងននចាស់ៗរហែកព្យួរបាំង ប្រហែលជាបន្ទប់ដេករបស់កូនក្រមុំ ឬជាបន្ទប់ទុកអីវ៉ាន់ ។ តាមជញ្ជាំងខាងកើត មានសំពត់អាវចាស់ៗព្យួរទុករយីងរយោង ។ លើកម្រាលផ្ទះមានជើងគ្រានបាយ និងចានឆ្នាំង ពាងទឹកស្អួកស្អះបង្ហាញឲ្យឃើញថាជាផ្ទះបាយ ។

ស្ត្រីម្ចាស់ផ្ទះបាននាំយកទឹកមួយផ្តិល ដែលធ្វើអំពីអាលុយមីនីញូមចាស់ទៀចមាត់ ចូលមកដាក់ចុះនៅមុខអាត្មាអង្គុយបត់ជើងចុះហើយពោលថា៖

- សូមទោសផងចាស៎ ផ្ទះសម្បែងមិនសូវរៀបរយ !

- មិនអីទេអ៊ំ! អាត្មាឆ្លើយតប, ខ្ញុំមិនមែនចៅហ្វាយមកត្រួតមើលផ្ទះអ៊ំនោះទេ មកមើលដីស្រែ ហើយក៏ឆៀងចូលមកប៉ុណ្ណោះឯង ពីព្រោះខ្ញុំបានទទួលដីស្រែនេះ ជាមរតកអំពីលោកឪពុកខ្ញុំនៅមិនទាន់បានឃើញ ឆ្លៀតពេលទំនេរក៏ឲ្យនាយអើមនាំខ្ញុំមកមើល

- ហ្អ៎! ដូច្នេះឬចាស៎? កាលលោកម្ចាស់ លោកនៅក៏លោកធ្លាប់មកមើលញឹកញាប់ដែរ និយាយអំពីលោកម្ចាស់ តែងនឹកដល់លោក. . . ស្រីម្ចាស់ផ្ទះលើកដៃដាក់លើក្បាល លោកជាមនុស្សចិត្តបុណ្យទាន អាណិតអ្នកក្រីក្រ អ្នកផ្ទះម្តុំនេះទាំងអស់ គោរពរាប់អានទុកលោកដូចជាឪពុកអញ្ចឹង

- ក្នុងផ្ទះនេះមានគ្នាប៉ុន្មាននាក់អ៊ំ? អាត្មាសួរ

- មាន៦ នាក់ចាស៎, មានឪពុកក្មេង ខ្ញុំនេះ កូនប្រុសធំ កូនស្រីម្នាក់ និងកូនប្រុសតូចៗពីរនាក់ទៀត

- ដូចជាគ្រួសារធំគួរសមដែរ ហើយគេទៅណាអស់ហើយ?

- ឪពុករបស់ក្មេង គាត់ទៅមើលគេជល់មាន់ កូនប្រុសទៅជាមួយកូនស្រីធ្វើការ កូនតូចៗពីរនាក់ទៀត នៅលេងជិតៗនេះឯង

- ដែលថាទៅធ្វើការនោះ តើគេធ្វើការអ្វីដែរ? អាត្មាសួរដោយសេចក្តីត្រេកអរ

- កូនប្រុសទៅធ្វើការជាកម្មករសំណង់, កូនស្រី

ទៅធ្វើកម្មករគាយដីជាមួយឡានដឹកដី

- ហើយបានថ្លៃឈ្នួលក្នុងមួយថ្ងៃប៉ុន្មានដែរ ?

- មួយថ្ងៃបាន ១០ បាត, ១៥ បាតប៉ុណ្ណោះឯង

- តើយ៉ាងណាដែរ ល្មមនឹងការចាយវាយគ្រប់ទេ ?

- ក៏ល្មមចាយវាយ ទទួលទានបានមួយថ្ងៃៗទៅ បើមិនមានជំពាក់គេទេ ក៏ល្មមចាយវាយទៅបាន តែនេះមិនដូច្នេះទេ បានមកប៉ុន្មានៗ យកទៅសងគេអស់ ឆ្នាំមុននេះស្រូវមិនល្អ ត្រូវខ្ចីប្រាក់គាសចៅកែសេងយកមកសងថ្លៃម៉ាស៊ីនភ្ជួរដែលគេមកភ្ជួរស្រែ ក៏មិនទាន់យកទៅឲ្យគេ តែក៏គ្រាន់បើដែរ ដែលមានកម្លាំងច្រើនជួយ ចាស៎ !

អាត្មាដើរចេញពីផ្ទះទីមួយទៅ ដោយចិត្តអាណិតយ៉ាងខ្លាំង ។ ផ្ទះទីពីរយើងទៅសួរ មានលក្ខណៈតែមួយដូចគ្នានឹងផ្ទះដំបូង ខុសគ្នាតែធ្វើអំពីស័ង្កសី ដែលធ្វើអំពីប៉ោតចាស់ៗជាដំបូល មានក្មេងពូជចិនស្គមមួយ ចេញមកទទួលយើងដោយការព្រួស ដូចជាមិនសូវពេញចិត្តពេកទេ ហើយក៏មានស្រីក្រមុំម្នាក់ស្លៀកពាក់សំពត់ពណ៌ខ្មៅ អាវដៃវែងដល់កដៃពណ៌ស្រអាប់ ចេញមកអញ្ជើញយើងឲ្យចូលទៅក្នុងផ្ទះ ប្រុសចំណាស់ម្ចាស់ផ្ទះទាញភួយចេញអំពីខ្លួន ខំប្រឹងក្រោកឡើងទទួលយើង នៅពេលនាយតើមណែនាំឲ្យស្គាល់អាត្មា បុរសចំណាស់នោះលើកដៃសំពះ ហើយពោលដោយសម្លេងរអាក់រអួលថា ៖

- ខ្ញុំមិនសូវស្រួលខ្លួនជាច្រើនថ្ងៃហើយ គ្រុនដេកនៅផ្ទះយូរថ្ងៃមកហើយ ទៅណាមិនរួច, សយ ! សយអើយ !

យកទឹកនាំមកទទួលលោកឆាប់ឡើង, បុរសចាស់បញ្ជាកូនស្រី ហើយនិយាយបន្តទៅទៀត, កូនប្រុសគេទៅបាងកកតាំងតែពីម្សិលមិញ ថ្មើនេះទៅហើយមិនទាន់ត្រឡប់មកវិញ

- គេទៅមានធុរៈអ្វីដែរតាំ? អាត្មាសួរដោយសេចក្ដីអាណោត

- ឲ្យវាទៅទាក់ទងជាមួយញាតិជិតខាង នៅភូមិទំនប់ទឹក ដើម្បីរកកន្លែងស្នាក់នៅ នៅពេលម្ចាស់ស្រែលោកលក់ដីស្រែឲ្យគេសាងសង់រោងចក្រ ក៏នឹងនាំគ្នាទៅនៅជាមួយញាតិឯបាងកក ។ កូនពីរនាក់ ស៊ីឈ្នួលធ្វើការលើសែងទៅតាមដំណើរ គង់តែល្មមរស់នៅបានមួយថ្ងៃៗ

- អាំបាននឹងមកពីណា ថាម្ចាស់ស្រែគេនឹងលក់ស្រែ? អាត្មាសួរដោយសេចក្ដីសង្ស័យ

- កាលពីថ្ងៃសីលមុន ខ្ញុំបានទៅវត្តបានឮពួកអ្នកស្រុកគេនិយាយគ្នា គេប្រាប់ថា នៅពេលអស់បុណ្យលោកម្ចាស់ហើយ ក្រុមញាតិរបស់លោក ក៏នឹងលក់ដីនេះឲ្យគេធ្វើរោងចក្រ គ្រប់គ្នានាំគ្នាភ័យព្រួយខ្វល់ទាំងអស់ ពីព្រោះមិនដឹងនឹងគិតទៅនៅរកស៊ីទីណា!

អាត្មាចេញពីផ្ទះទីពីរទៅ ដោយបេះដូងធ្ងន់ដូចគេសង្កត់តាំងជាពីរគ្រួត....

# ជីវិតកសិករ

បទពាក្យ៧

ជីវិតកសិករត្រដររស់ មួយថ្ងៃមួយពោះស្ទើរមិនបាន
ខំប្រឹងសម្លឹងមើលអ្នកមាន វិឡាលុយឡានក្សាន្តយប់ថ្ងៃ ។
កសិករត្រដរខំធ្វើការ ក្រោមផ្ទៃសុរិយាញាប់ជើងដៃ
អ្នកមានហ៊ឺហាឥតខ្វះអ្វី ស្លៀកថ្មីពាក់ថ្មីចាយសប្បាយ ។
កសិករត្រដរខំធ្វើស្រែ កាយចិត្តឥតល្ហែបែកញើសខ្លាយ
អ្នកមានក្សាន្តសុខទាំងចិត្តកាយ ឥតគិតខ្វល់ខ្វាយពីរឿងក្រ ។
កសិករត្រដរស៊ូទ្រាំរស់ ក្រោមខ្ទមធ្លាយធ្លុះមិនគាប់គួរ
អ្នកមានរស់ក្នុងគ្រឹហាល្អ សប្បាយសម្បូណ៌ឥតខ្វះអ្វី ។
កសិករត្រដរដោះបំណុល ខ្វះខាតខ្ចីបុលគេយប់ថ្ងៃ
អ្នកមានខ្លះខ្វះចិត្តប្រណី ឥតមានសំចៃលែងចងការ ។
កសិករត្រដរឲ្យបានរស់ ទោះអាប់ឱនឈ្មោះទោះយ៉ាងណា
បានព្រឹកខ្វះល្ងាចមិនត្អូញថា ច្រើនមានមេត្តាស្លូតត្រង់ល្អ ។
ធ្វើស្រែចំការដោយសុចរិត កាយវាចាចិត្តពិតមានធម៌
ភាគច្រើនស្លូតត្រង់មិនកូតករ តស៊ូឥតថ្ងូរនៅតែក្រ ។
កូនចៅឥតបានចូលសាលា គ្មានបានសិក្សាចេះអក្សរ
ជីវិតធ្លាក់ចុះជាទាសករ ព្រោះដ្បិតតែក្រត្រដររស់ ។
ត្រូវធ្លាក់ជាឈ្នាន់នៃសង្គម ច្រើនគេសើចយំអាប់អន់ឈ្មោះ
បំណុលស្ទួពូជពុំអាចដោះ នេះគួរស្រណោះអាណិតណាស់ ។

ដោយឧបាសក ម៉ិញ សាវ៉ាង

# ៣៩. ស្រែស្រូវ - ស្រែបុណ្យ

ចេញពីផ្ទះទីពីរ អាត្មាបានមកដល់ផ្ទះទីបី ទីបួន ទៅតាមលំដាប់ដល់ផ្ទះទីប្រាំ ។ គ្រប់យ៉ាងដែលអាត្មាបានឃើញ ការពិតដូចគ្នា គឺសេចក្ដីក្រីក្រអត់ឃ្លាន ខ្វះខាត គ្រប់យ៉ាងក្រីក្រក្នុងទ្រព្យសម្បត្តិ ក្រីក្រក្នុងការចេះដឹង ក្រីក្រក្នុងឱកាសដែលនឹងឈានទៅមុខក្នុងជីវិត ។ ការពិតដែលអាត្មាបានជួប ធ្វើឲ្យកើតសេចក្ដីព្រួយចិត្ត និងអាណិតអ្នកស្រែទាំងអស់នោះជាខ្លាំង

- នាយកើម! អាត្មាហៅនាយកើម នៅពេលចេញមកពីផ្ទះទីប្រាំ

- បាទទាន! លោកមានអ្វីនឹងប្រើខ្ញុំឬទាន? នាយកើមសួរសម្លឹងមើលមកអាត្មាទាំងឿងឆ្ងល់ គេគង់សង្កេតឃើញសេចក្ដីប្រែប្រួលក្នុងទឹកមុខរបស់អាត្មា

- មាន! អាត្មាឆ្លើយ, ខ្ញុំចង់ឲ្យលោកកើមទៅផ្ទះមុន ខ្ញុំប្រហែលទៅជាមួយមិនបានទេ ដូចជាហាក់មែនទែន ទៅប្រាប់ឲ្យលោកមេឃុំហៅប្រជុំអ្នកផ្ទះ ដែលជួលស្រែរបស់ខ្ញុំធ្វើទាំងអស់ក្នុងរសៀលថ្ងៃនេះនៅក្នុងវិត្ត វេលាប្រហែលម៉ោង៤រសៀល ខ្ញុំមានរឿងសំខាន់នឹងប្រកាសឲ្យគេដឹង

- លោកនឹងលក់ស្រែនេះមែនទេទាន? នាយកើមសួរដោយទឹកមុខញញឹមញញែម ប្រហែលជាគេគិតថា អាត្មានឹងលក់ដីស្រែនេះទៅ គេសង្ឃឹមថានឹងបានគាតរយយ៉ាង

ច្រើន

- ល្អហើយចុះ! លក់ឬមិនលក់ក៏នឹងដឹងគ្នាក្នុងថ្ងៃនេះហើយ នាយភើមប្រញាប់ទៅប្រាប់មេឃុំទៅបានហើយ

- បាទ! នាយភើមទទួលពាក្យហើយ ក៏ប្រញាប់ដើរគ្រនៗចេញទៅ

អាត្មាទម្លាក់ខ្លួនអង្គុយលើភ្លឺស្រែ បានដើមឫស្សីជាម្លប់ត្រជាក់ សម្លឹងមើលទៅវាលស្រែដែលធំធេងឆ្ងាយផុតកន្ទុយភ្នែក ហើយក៏ចាប់គិតគូរនូវសេចក្ដីខុសគ្នារវាងខ្លួនឯង និងអ្នកស្រែដែលគួរឲ្យអាណិតទាំងនោះ ៗ ក្នុងពេលដែលអាត្មាកើតមកនៅក្នុងគំនរមាសប្រាក់ សូម្បីមិនបាច់ធ្វើអ្វី ក៏រស់នៅបានយ៉ាងសប្បាយលុះអស់ជីវិត មិនដែលធ្លាប់ភ្លក្សរសជាតិការអត់ឃ្លានវេទនា ចំណែកអ្នកស្រែទាំងនោះផ្ញើជីវិតដែលវេទនាទុកនៅក្នុងផែនដី ទឹកភ្លៀង និងមេឃអាកាស ឆ្នាំណាមានភ្លៀងធ្លាក់ច្រើន ក៏ល្មមមានបាយបរិភោគគង់វជីវិត ឆ្នាំណាទេវតា មេឃ ដីមិនអំណោយផល ក៏អត់ឃ្លាន ត្រូវទៅខ្ចីបុលគេយកមកចិញ្ចឹមកូនប្រពន្ធត្រូវអត់ឃ្លានស្គមរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីជួយកម្លាំងកាយឲ្យបានស្រួលសុខឲ្យដល់អ្នកដទៃ អាចនឹងពោលបានថា គេមានជីវិតរស់នៅដើម្បីសេចក្ដីសុខរបស់អ្នកដទៃពិតៗ សូម្បីនឹងធ្វើការញើសក្លាយទៅជាទឹកមកតាំងតែពីបុព្វបុរសមក ក៏មិនដែលមានបាន មានតែធ្លាក់ចុះក្នុងពេលដែលម្ចាស់ស្រែនិងអ្នកជំនួញ ឈ្មួញកណ្ដាលទៅជាមានបានជានិច្ច អ្នកស្រែទាំងអស់នេះគឺជាពលរដ្ឋមួយ

ផ្នែកដ៏ធំរបស់ថៃ ចំណែកមួយផ្នែកធំរបស់ជាតិ គឺមកពីពួកគាត់នេះឯងមិនបានដោយត្រង់ ក៏បានដោយវាង នៅពេលដែលមានសង្គ្រាម ពួកគេទាំងនេះត្រូវចេញជួរមុខតស៊ូជាមួយពួកសត្រូវ នៅពេលស្ងប់ក៏មកតស៊ូក្នុងការអត់ឃ្លាន រោគា ព្យាធិ គ្រុន ឈឺចាប់ ទាំងនោះយ៉ាងវេទនា ៗ

នៅពេលដែលអាត្មា កំពុងតែអង្គុយគិតនោះឯង ត្រចៀកបានឮសម្លេងមនុស្សប្រកែកគ្នា ចេញមកអំពីផ្ទះជិតខាង ដោយការចង់ដឹងទើបក្រោកឡើង ហើយដើរទៅសង្កេតមើលហេតុការណ៍នោះ ៗ ស្ត្រីអាយុចំណាស់ម្នាក់កំពុងនៅលើគ្រែខាងមុខខ្ទមប្រក់ស្បូវឈើករយោគមួយខ្នង មានប្រុសជាតិចិន ២ ឬ ៣ នាក់ឈរច្រត់ចង្កេះ ស្រែកឡូងៗនៅជិតៗហ្នឹង ៗ ទាំងអស់គ្នាឈប់ប្រកែកគ្នា ហើយងាកមកសម្លឹងមើលអាត្មាមិនដាក់ភ្នែក មិនមាននរណាស្គាល់អាត្មា គេគិតថាអាត្មា គ្រាន់តែប្រុសកម្លោះក្រៅប្រទេសម្នាក់ ឬក៏គ្រាន់តែជាអ្នកជំនួសក្រុមហ៊ុន ដែលនឹងមកឃោសនាលក់របស់ជាមួយអ្នកស្រែ ដែលមានមកជានិច្ចជាកាល ទើបងាកទៅប្រកែកគ្នាដូចមុន ដោយមិនបានយកចិត្តទុកដាក់ជាមួយអាត្មាពេកទេ

- អ្នកពន្យារពេលឲ្យលើមកច្រើនដងហើយ! បុរសចិនមាឌធំឆាត់ពោលឡើងដោយសម្លេងតិចៗ, លឺគួរតែយល់ចិត្តអ្នកខ្លះផង

- យល់ចិត្តនោះវាយល់ហើយ! ស្រីម្ចាស់ផ្ទះឆ្លើយឡើងដោយទឹកភ្នែកពោរពេញដោយសេចក្តីទុក្ខ, តែវាមិន

ទាន់មាន តើនឹងឲ្យខ្ញុំធ្វើយ៉ាងណា ចៅកែក៏បាននឹងហើយ ថាឆ្នាំមុននេះខ្ញុំមិនបានផលស្រូវទេ គាលពីខែ ៣ ផុតទៅនេះ ណា ប្តីខ្ញុំគាត់ក៏ស្លាប់ចោលខ្ញុំទៅ ខ្ញុំរស់នៅតែ ២ នាក់ម៉ែកូន ដូចបានឃើញស្រាប់ហើយ មិនដឹងទៅរកប្រាក់រកមាសពី ណាមកសងខ្ញុំសុំពន្យារទៅមួយឆ្នាំទៀតទៅ ជួនកាលឆ្នាំនេះ អាចនឹងបានធ្វើស្រែខ្លះ នៅពេលដែលខ្ញុំលក់ស្រូវបានប្រាក់ ហើយ ខ្ញុំនឹងយកទៅសង តែឥឡូវនេះពិតជាមិនមានមែន

- ក៏លីនិយាយតែដដែលៗថា មិនមាន ! មិនមាន ! បុរសចិនម្ចាស់បំណុល និយាយហើយព្រមទាំងគ្រវីក្បាល ទាំងតូចចិត្តតូចថ្លើម

- អើ ! វាមិនមានមែនៗនេះ នឹងឲ្យខ្ញុំប្រាប់ថាមានបាន យ៉ាងណាទៅ ! ម្ចាស់ផ្ទះប្រកែក, បើមានខ្ញុំក៏ឲ្យចៅកែទៅ ហើយ នរណាខ្លះនឹងចង់ជំពាក់គេ វាសប្បាយស្អី

- គិតយ៉ាងនេះចុះ ! បុរសចិននិយាយឡើង គ្រោក ឈរត្រិះរិះគិតមួយសន្ទុះ, លីទៅខ្ចីនរណាយកមកឲ្យអ៊ូ ១០០ បាតសិនក៏បានសម្រាប់ខែនេះ អ៊ូព្រមឲ្យលីសងបន្តយមួយ ខែមួយបាតលុះត្រាតែអស់ ព្រមឬទេ ?

- កុំថាឡើយមួយរយបាត, ស្រីម្ចាស់ផ្ទះពោលឡើង ដោយអស់សង្ឃឹម, សូម្បីតែ ៥ បាត ក៏ខ្ញុំមិនមានដែរ ខ្ញុំមិន ហ៊ានទៅខ្ចីនរណាទៀតទេឥឡូវនេះ ដែលនៅបានពីព្រោះ ទៅរកខ្ចីអ្នកជិតខាងយកមកទិញ អង្ករផង គាពិផង ទឹកត្រី ផង ទៅខ្ចីគេទាំងអស់ ជួនកាលសូមយកគ្រង់ៗ ទាល់តែគេ ស្អប់ខ្ញុំទាំងភូមិទៅហើយ

- អ្នមិនអាចពន្យារបន្តទៅទៀតបានទេ!, ប្រុសចិននិយាយ, នរណាៗក៏សូមពន្យារ ៤ ឆ្នាំនេះ អ្នទុកពេលឲ្យលី ៣ ថ្ងៃទៀត បើលីរកប្រាក់ ១០០ បាតឲ្យអ្នមិនបានទេក្នុងពេល ៣ ថ្ងៃអ្នកនឹងហៅប៉ូលិសមកចាប់លី

- ល្អហើយចុះ ខ្ញុំនឹងសាកទៅរក បើរកមិនបាន បើឯងនឹងចាប់ខ្ញុំទៅចូលគុក ចូលច្រវាក់ណាក៏ព្រមទាំងអស់

បុរសចិនហើយនិងកូនចៅបែរខ្នងចេញទៅ តែមិនអស់ចិត្ត រាគមកបញ្ហោយ៉ាងដាច់ខាតថា៖

- កុំភ្លេចណា៎ ៣ ថ្ងៃណា៎ ខានស្អែកមួយនេះ អ្នកនឹងមកទទួលប្រាក់

- ឈប់សិនចៅកែ! អាត្មានិយាយឡើង ធ្វើឲ្យបុរសចិនទាំងពីរនោះឈប់ងឹក, ត្រឡប់មកនិយាយជាមួយគ្នាសិន

ប្រុសចិនទាំងពីរ ឈប់ហើយឈរខ្សឹបខ្សៀវគ្នាមួយរយៈ ហើយក៏ត្រឡប់មកឈរទល់មុខអាត្មាយ៉ាងប្រយ័ត្នប្រយែង

- គេនៅជំពាក់លីប៉ុន្មាន? អាត្មាសួរឡើង

- ទាំងដើមទាំងការ វាត្រូវជាមួយពាន់ពីររយបាត, ចៅកែនោះឆ្លើយដោយងឿងឆ្ងល់

- ពុទ្ធោអើយ! នឹកស្មានថាជាម៉ឺនសែនទៅហើយ, អាត្មាភ្លេចខ្លួនពោលចេញមក ហើយក៏លូកការបូបប្រាក់ចេញមករាប់សន្លឹកប្រាក់មួយរយចំនួន ១២ សន្លឹកហុចឲ្យបុរសចិននោះ ៤ ចិនទាំងពីរឈរមើលមុខគ្នាបែបភ្ញាក់មិនហ៊ានទទួលប្រាក់ពីដៃអាត្មា ហើយមិននិយាយថាយ៉ាង

ណា, ទទួលយកទៅ! អាត្មាគឿន ប្រាក់ពិតប្រាកដមិនមែន ក្លែងក្លាយទេ ខ្ញុំទទួលខុសត្រូវ

- លីជាអ្នកណា? បុរសចិនសួរដោយឆ្ងល់, លីនឹង សងប្រាក់ជំពាក់ជំនួសអាយ៉ែមឬ?

- អូជាអ្នកណាកុំខ្វល់! អាត្មានិយាយ អូមានប្រាក់សង ថ្លៃជំពាក់ជំនួសម្ចាស់ផ្ទះនេះហើយ ក៏រូបគ្នាទទួលយកទៅ

បុរសចិននោះ ហុចដៃចេញមកទទួលប្រាក់ដោយ យឺតៗ ភ្នែកសម្លឹងមើលអាត្មាផ្ទឹង ញីក្រដាសចេញរាប់ យ៉ាងប្រុងប្រយ័ត្ន ដូចជាខ្លាចថាជាក្រដាសប្រាក់ក្លែងក្លាយ ។

- លីនឹងទៅណាក៏ទៅៗ! អាត្មាចេញជាពាក្យបញ្ជា, ហើយហាមកុំមករកកូនផ្ទះនេះទៀតជាដាច់ខាត

ប្រុសចិនម្ចាស់បំណុលនោះ យកប្រាក់ដាក់ហោប៉ៅ ហើយក៏ដើរចេញទៅ ព្រមទាំងងាកក្រឡេកមកមើលអាត្មា ម្ដងៗ ។ មើលទៅខាងក្នុងខ្ទម អាត្មាបានឃើញស្រីម្ចាស់ផ្ទះ និងស្រីក្រមុំម្នាក់ទៀត ដែលយល់ថាជាកូនក្រមុំ ឈរសម្លឹង អាត្មានៅក្នុងលក្ខណៈស្ញៀមស្ញាត់ដូចជារូបចម្លាក់ ។ អាត្មា ឈរសម្លឹងមើលគេមួយសន្ទុះជាគារសងទៅវិញ ហើយក៏ ងាកក្រោយ ហៀបនឹងចេញទៅអង្គុយសម្រាកនៅកន្លែង ដើម

- ឈប់សិនលោកម្ចាស់! មានសម្លេងស្រែកតាមមក ពីក្រោយ នៅពេលងាកទៅមើល ឃើញស្រីម្ចាស់ផ្ទះនិង កូនស្រីរត់ត្របោបត្របាបតម្រង់មករកអាត្មាទាំងពីរនាក់មក ដាក់គូទអង្គុយចុះលុតជង្គង់នៅពីមុខអាត្មា លើកដៃសំពះ

ងាក់ត្រឹមដើមទ្រូងប្រហែលនឹងព្រះសង្ឃ ហើយនិយាយទាក់ទាក់ថា៖

- លោកម្ចាស់អើយ! លោកជានរណា មកពីណា ដូចម្ដេចបានជាមានទឹកចិត្តដ៏សប្បុរសយ៉ាងនេះ លោកជាមនុស្ស ឬទេវតា និម្មិតខ្លួនមកជួយយើងនៅពេលមានអាសន្នអន់ក្រ?

នៅពេលសង្កេតឃើញទឹកភ្នែក ដែលហូរធ្លាក់ចុះជាផ្លូវកាត់ផែនថ្ពាល់ស្រីចាស់ជាម្ចាស់ផ្ទះ អាត្មាដូចជារស់រវើកនឹងចិត្ត ដោយសេចក្ដីអាណិត លុះត្រាមិនអាចនិយាយអ្វីចេញមកបាន ៗ

- លោកម្ចាស់អើយ! ស្រីម្ចាស់ផ្ទះបានពោលឡើងដោយសម្លេងញ័រៗ យកដៃទាំងពីរត្រដុះគ្នា, ប្រាប់ខ្ញុំផងថា លោកជានរណា មកពីណា ថាហើយក៏ឱនចុះក្រាបជិតជើងរបស់អាត្មា ចំណែកកូនស្រី ក៏ឱនចុះក្រាបអាត្មាតាមម្ដាយដែរ

- ក្រោកឡើងអ៊ំ! អាត្មានិយាយព្រមទាំងចាប់ដៃអ៊ំយ៉ែមឲ្យក្រោកឡើង, ខ្ញុំមិនមែនជាទេវតា ឥន្ទ្រព្រហ្មពីណាទេ ជាមនុស្សធម្មតាយើងនេះឯង

នៅពេលអ៊ំយ៉ែមមិនព្រមក្រោក ទើបអាត្មាអង្គុយចោងហោងជិតទើតនៅពីមុខគាត់ ៗ

- បើដូច្នេះលោកជាអ្នកណាទៅ?

- កុំអាលចង់ដឹងអីអ៊ំ មិនចាំបាច់ទេ តទៅអ៊ំគង់តែនឹងដឹងដោយខ្លួនឯងទេ

- ចុះមានចិត្តល្អអ្វីម្ល៉េះព្រះអង្គអើយ ! អាំម៉ែប៉ាមពោល
រៀបរាប់បណ្តើរ រួចទាញដៃយអាវស្បៃឡើងជូតទឹកភ្នែក
បណ្តើរ, ខ្ញុំមិនដែលបាននឹកគិតយល់សប្តិឡើយថានឹងមាន
ទេវតាមកជួយយ៉ាងនេះ បុណ្យគាលពីមុនមក តាមមកទាន់
ពិតៗតែម្តង ខ្ញុំភ្ញាក់ផ្អើលលុះត្រាមិនដឹងនឹងអរព្រះគុណ
យ៉ាងដូចម្តេចឲ្យសមទេ, អាំម៉ែប៉ាមងាកទៅកូនស្រី ហើយ
ពោលថា នេះយើងនឹងតបស្នងសងគុណចំពោះលោក
យ៉ាងណាល្អកូន ឋានៈរបស់យើងក៏ក្រលោមរហាមយ៉ាង
នេះ ?

- កុំគិតថាដាបុណ្យដាគុណអ្វីឡើយអាំ ! អាត្មាល្មង
លោមគាត់, តរពិតអាំទេដែលមានគុណលើខ្ញុំ

- ហ្អុំ ! អាំមានគុណចំពោះលោកយ៉ាងណាដែរចាស់
អាំមិនដែលឃើញមុខមាត់លោកគាលពីមុនមកសោះ, អាំ
ម៉ែប៉ាមសួរដោយបូកពាសង្ស័យ

- ខ្ញុំចង់ដឹងថាតើអាំជួលស្រែគេធ្វើមកប៉ុន្មានឆ្នាំហើយ?

- ធ្វើមកតាំងតែពីមីតូចគើតម្ល៉េះលោកម្ចាស់ ដប់ប្រាំបួ
ដប់ប្រាំមួយឆ្នាំមកម្ល៉េះ

- យូរណាស់មកហើយៗតាំងតែពី ១៦ ឆ្នាំមក ដែលអាំ
ធ្វើស្រែមកនេះ តើអាំមានបានធូរធារឡើងខ្លះឬទេ ?

- មិនដែលមានបានសោះលោកម្ចាស់ ល្មមរស់នៅ
ស៊ីចុកទៅក្នុងមួយឆ្នាំៗតែប៉ុណ្ណោះឯង ជួនគាលក៏មិនគ្រប់
ស៊ី ត្រូវទៅខ្ចីបុលរបស់របរយកមកទទួលទាន ដូចដាពីរឆ្នាំ
កន្លងមកនេះ ពិបាកខ្លាំងត្រូវខ្ចីប្រាក់គេយកមកទិញអង្ករ

ម្ហូបលុះដល់ជំពាក់ចៅកែសេងដល់ទៅមួយពាន់ពីររយ ដូចជាលោកឃើញនោះឯង ថែមពីលើនេះទៅទៀត ឪពុករបស់មីនាងក៏គាត់ចែកឋានចោលទៅទៀត, ពោលហើយក៏យំអណ្តឺតអណ្តកគ្នារឲ្យអាណិតស្រណោះ

- អ៊ំធ្វើស្រែតាំងពី ១៦ ឆ្នាំមកនេះ តែមិនដែលមានសោះ ហើយអ៊ំនឹងឬទេថា ម្ចាស់ស្រែគេក្រីក្រចុះដូចជាអ៊ំដែរឬទេ? អាត្មាសួរ

- ប្រហែលមិនក្រទេដឹង! ពីព្រោះលោកមិនបាច់ចុះដើមទុន ចុះកម្លាំងស្អីផង ឆ្នាំណា អ្នកស្រែមិនបានធ្វើស្រែ លោកក៏អាចនឹងមានចំណូលបានតិច តែដីស្រែក៏នៅជារបស់លោកដដែល មិនមានការខាតដើម

- បើដូច្នេះក៏បង្ហាញឲ្យឃើញថា អ៊ំមានគុណទៅលើម្ចាស់របស់ស្រែនេះ ពីព្រោះអ៊ំធ្វើស្រែឲ្យគេ ធ្វើស្រែមានប្រយោជន៍ ធ្វើឲ្យគេមានកម្រៃពិសេសអំពីស្រែ អ៊ំធ្វើឲ្យគេមានបាន អ៊ំព្រមនឿយហត់ ព្រមក្រលំបាកដើម្បីឲ្យម្ចាស់ស្រែមានបានយ៉ាងនេះ អ៊ំទើបជាអ្នកមានគុណដល់គេយ៉ាងច្រើនតែម្តង

- ហ្អឺ អ៊ំមិនដែលគិត, អ៊ំយ៉ែមពោលចេញមកដោយការរិះគិតយ៉ាងខ្លាំង គាត់នៅស្ងៀមមួយស្របក់ហើយសួរថា តែខ្ញុំមិនទាន់យល់នៅឡើយថា ដូចម្តេចបានជាលោកត្រូវមកសងគុណអ៊ំជំនួសម្ចាស់ដីស្រែនេះទៅវិញ?

- ជួនកាលលោកអាចនឹងជាម្ចាស់របស់ស្រែទេដឹងប៉ែ! កូនស្រីគាត់និយាយឡើង

- *អើមែនហើយ! អាំម៉ែមនិយាយសម្លេងសោចក្តី យល់ស្របជាមួយកូនស្រី ព្រមទាំងសម្លឹងមករកអាត្មាយ៉ាង ពិនិត្យពិច័យ, អាំបានឮអ្នកផ្ទះជិតខាងគេនិយាយគ្នាថា លោកតួចកូនប្រុសពៅគេរបស់លោកម្ចាស់ បានទទួល មរតកទីស្រែ លោកគឺលោកតួចកូនប្រុសពៅរបស់លោក ម្ចាស់មែនឬទេ?*

- *ប្រហែលមែន! អាត្មាឆ្លើយតប ព្រមទាំងសើចតិចៗ*

*អាំម៉ែមឱនក្រាបជិតជើងរបស់អាត្មាម្តងទៀត ទឹក ភ្នែកគាត់ចាប់ផ្តើមហូររហៀលគាត់ជែនថ្ពាល់ហើយនិយាយ ឡើងដោយសម្លេងញ័រៗ ហើយដាច់ៗជាឃ្លាៗ, ដូច្នេះ ហើយបានជាមានចិត្តបុណ្យដូចលោកម្ចាស់ និយាយដល់ លោកម្ចាស់ហើយ អត់គិតនឹកដល់លោកមិនបានទេ សូម ឲ្យវិញ្ញាណក្ខន្ធរបស់លោក សោយសុខក្នុងឋានសួគ៌ចុះព្រះ គុណ, អាំម៉ែមលើកដៃដាក់ទូលលើក្បាលហើយនិយាយ បន្តទៅទៀតថា ម្ចាស់របស់ស្រែដែលមានសន្តានចិត្តល្អដូច លោកម្ចាស់រកមិនបានទៀតទេ នៅពេលលោកមានជីវិត នៅឡើយ លោកចេញមកមើលសួរសុខទុក្ខអ្នកធ្វើស្រែ គ្រប់ៗគ្នា សួរពីជំងឺសុខទុក្ខអ្នកនេះ អ្នកនោះ នរណា មានសេចក្តីក្តៅក្រហាយស្អីពិបាកផ្សេងៗ លោកតែងតែ ជួយដោយមិនគិតយកថ្លៃឈ្នួលស្រែនោះឡើយ ចង់ឲ្យ ប៉ុណ្ណារយកប៉ុណ្ណឹង បើអ្នកណាធ្វើស្រែបានតិច លោកមិន គិតយកថ្លៃឈ្នួលស្រែទេ គួរឲ្យស្តាយដែលលោកឆាប់លា ចាកលោកនេះទៅ តែក៏គិតថាជាបុណ្យរបស់ពួកយើងចុះ*

ដែលបានលោកគ្រូចមកជាម្ចាស់ស្រែជំនួស ប៉ុន្តែតែខ្ញុំបានដំណើងថាលោកគ្រូចនឹងលក់ដីស្រែឲ្យគេសង់រោងចក្រ តើមែនឬទេ?

- អាំបានដំណើងមកអំពីណា? អាត្មាសួរ

- បានឮអ្នកស្រុកគេនិយាយគ្នាមកជាច្រើនថ្ងៃហើយ មែនឬទេចាស៎?

- ពិតឬមិនពិត អាំក៏នឹងបានដឹងនៅក្នុងថ្ងៃនេះឯងនៅពេលរសៀលម៉ោង ៤ ថ្ងៃនេះ ឲ្យអាំទៅប្រជុំគ្នានៅវត្តក៏នឹងបានដឹងច្បាស់ទាំងអស់គ្នា!

នៅពេលសន្ទនាគ្នាជាមួយអាំយ៉េមល្មមសមគួរដល់ពេលហើយ អាត្មាក៏លាគាត់ចេញទៅ ។

រសៀលម៉ោង ៣ ជាងថ្ងៃនេះ អាត្មានិងនាយតើមបានទៅជួបលោកឪបុណ្យ ដែលជាលោកគ្រូធំប្រចាំក្នុងវត្តនៃភូមិនេះ ។

- ញោមមកក៏ល្អហើយ! លោកឪបុណ្យទទួលរាក់ទាក់ប្រញាប់រកទឹកតែមកទទួល, អ្នកស្រុកនាំគ្នាភ័យព្រួយ ក្តៅក្រហាយមកជាច្រើនថ្ងៃណាស់ហើយ ពីព្រោះមានមនុស្សមកប្រាប់ថា ម្ចាស់ស្រែនឹងលក់ដីស្រែឲ្យគេសង់រោងចក្រ អ្នកស្រុកមករកគ្រូនអាត្មា ឲ្យនាំទៅជួបនឹងម្ចាស់ស្រែនៅឯបាងកក តែអាត្មាមានអាពាធ គ្រុនផ្តាសាយ ទើបទៅមិនបាន លោកមកក៏ល្អហើយនឹងបានសាកសួរឲ្យដឹងការពិតតែម្តង

- លោកម្ចាស់មិនបាច់ខ្វល់ទេទាន! អាត្មាឆ្លើយតបទៅ

លោកឱ្យបុណ្យ, លក់ឬមិនលក់ក៏គង់នឹងដឹងគ្នាក្នុងថ្ងៃនេះឯង បន្តិចទៀតខ្ញុំនឹងប្រកាសឲ្យអ្នកស្រុកដឹង

- បើញោមតាំងចិត្តនឹងលក់មែន អាត្មាចង់សុំបិណ្ឌបាតទុក កុំទាន់អាលលក់ ៗ បើញោមលក់ អ្នកធ្វើស្រែកន្លែងនេះ ក៏គង់អស់ទីពឹង មិនដឹងនឹងទៅធ្វើស្អីទេដើម្បីចិញ្ចឹមជីវិតនោះ ចំណេះចេះដឹងអ្វីក៏គ្មាន ពីព្រោះធ្វើស្រែចិញ្ចឹមជីវិតតាំងតែអំពីដូនតាមក បើញោមលក់ដីស្រែ គេក៏គង់នឹងបែកខ្ញែកព្រាត់ប្រាសគ្នា ទៅម្នាក់មួយផ្លូវផ្ទះម្ដុំនេះក៏គង់ក្លាយទៅជាផ្ទះរហោស្ថានស្ងាត់ ពីព្រោះផ្ទះនិងវត្តត្រូវអាស្រ័យគ្នា បើមិនយល់ដល់ញាតិញោម ក៏សូមឲ្យយល់ដល់អ្នកបួសក្នុងព្រះពុទ្ធសាសនានេះផងចុះញោម!

នៅទីបំផុត អ្នកស្រុកប្រហែលជា ៤០ នាក់បានមកប្រជុំគ្នាពេញសាលាវត្ត ៗ ទោះបីជាមានមនុស្សច្រើននៅជាមួយគ្នា តែក៏ដឹងថាបរិយាកាសស្ងាត់ស្ងៀមខុសធម្មតា អ្នកស្រុកងាករកគ្នាសួរជាក្រុមៗ ពិភាក្សាគ្នាដោយសម្លេងតិចៗ គ្រប់ៗគ្នាសុទ្ធតែមានទឹកមុខបង្ហាញឲ្យឃើញនូវសេចក្ដីព្រួយបារម្ភ ស្រងូតស្រងាត់ ៗ

ក្រោយពីនាយភើមពោលណែនាំឲ្យស្គាល់រួចហើយ អាត្មាក៏ថ្វាយបង្គំលោកគ្រូចៅអធិការ ក្រោកឡើងដើរទៅប្រាស្រ័យដល់អ្នកស្រុកដែលអង្គុយស្ងៀមស្ងាត់ សម្លឹងមើលមកអាត្មាក្នុងក្រសែភ្នែកតែមួយ

- បងប្អូនទាំងឡាយ ! ខ្ញុំមានសេចក្ដីរីករាយណាស់ដែលមានឱកាសបានមកជួបនឹងបងប្អូនទាំងអស់ក្នុងថ្ងៃនេះ

គឺជាថ្ងៃដំបូងក្នុងជីវិតខ្ញុំ ដែលបានមកឃើញដីស្រែដែលលោកឪពុកលើកមកឲ្យជាមរតកដល់ខ្ញុំ ហើយបានមកឃើញស្ថានភាព ការរស់នៅដ៏ពិតប្រាកដរបស់អ្នកជួលដីស្រែ ។ នៅពេលខ្ញុំមកដល់ម្តុំផ្ទះខ្លះៗនៅពេលព្រឹកមិញនេះ ខ្ញុំក៏បានដឹងថាបងប្អូនទាំងអស់កំពុងភ័យ ខ្លាចថាខ្ញុំនឹងលក់ដីស្រែឲ្យគេធ្វើរោងចក្រឧស្សាហកម្ម ពីព្រោះមានមនុស្សជាច្រើនផ្សព្វផ្សាយដំណឹងដូច្នេះជាមុន ច្រើនថ្ងៃមកហើយ ។ អ្នកទាំងឡាយនាំគ្នាចង់ដឹងថា ខ្ញុំនឹងលក់មែនឬមិនមែន ? ការពិតកន្លែងដីមួយដុំនេះ កំពុងឡើងតម្លៃយ៉ាងឆាប់រហ័សណាស់ បើខ្ញុំលក់នៅពេលនេះនឹងបានជាប្រាក់ដប់លានបាតតែម្តង ប៉ុន្តែខ្ញុំសូមប្រកាសចំពោះបងប្អូនទាំងអស់ឲ្យបានជ្រាបឲ្យហើយនៅក្នុងពេលនេះថា ខ្ញុំមិនលក់ដីស្រែ ៣០០ រ៉ៃនេះជាដាច់ខាត !

នៅពេលចប់សម្លេងអាត្មា អ្នកស្រុកជិតទាំងអស់គ្នាដកដង្ហើមចេញព្រមគ្នាទាំងអស់ដោយសេចក្តីធូរចិត្ត គ្រប់គ្នាមានទឹកមុខស្រស់ស្រាយឡើងមកភ្លាម ហើយងាកទៅញញឹមញញែមរាក់ទាក់រកគ្នាឯង ៗ មានឮសម្លេងអ៊ូរអែពេញតែម្តង ៗ

- បងប្អូនទាំងឡាយ ! អាត្មាពោលបន្តធ្វើឲ្យអ្នកស្រុកស្ងាត់សម្លេងភ្លាមមួយរំពេច, ខ្ញុំជាមនុស្សមិនចូលចិត្តសេចក្តីមានបាន ពីព្រោះបានពិចារណាឃើញហើយថាមនុស្សយើងនេះ សូម្បីនឹងមានបានប៉ុណ្ណា ក៏បរិភោគនូវអាហារល្មមពេញពោះមួយថ្ងៃ ៣ ពេលប៉ុណ្ណោះ សូម្បីនឹង

*មានជាមហាសេដ្ឋីដែលមានច្រើនយ៉ាងណាក៏ដោយ នៅពេលប្រើប្រាស់ពិតៗ ក៏ប្រើចំពោះតែល្មមដាក់ខ្លួនដេកដាក់គូទអង្គុយចុះតែប៉ុណ្ណោះ ។ យើងកើតមក យើងមិនបានស្ពាយសម្បត្តិផ្សេងៗមកជាមួយផងទេ នៅពេលស្លាប់ទៅក៏មិនមានអ្នកណាស្ពាយយកសម្បត្តិទ្រព្យ មាសប្រាក់ទៅបរលោកបានដែរ របស់ដែលអាចនឹងយកជាប់ខ្លួនទៅបាននោះគឺមានតែល្អនិងអាក្រក់ប៉ុណ្ណោះ ដោយសារដីស្រែនេះខ្ញុំយកទៅជាមួយខ្លួនមិនបាន ដូច្នេះខ្ញុំនឹងប្តូរដីស្រែនេះឲ្យទៅជាស្រែបុណ្យ គឺខ្ញុំសូមប្រគល់ដីស្រែនេះឲ្យទៅជាសម្បត្តិរបស់អ្នកណាធ្វើស្រែនោះ ហើយជាសាច់ដីប៉ុន្មានៗខ្ញុំក៏សូមប្រគល់ឲ្យអ្នកនោះ ឬគ្រួសារនោះជាចំនួនប៉ុណ្ណោះ*

*អ្នកស្រុកគ្រប់គ្នាអង្គុយស្ងៀមហាមាត់ចន្ត្រង ដូចជាត្រូវមន្តសណ្តំ ភ្នែកទាំងគូរសម្លឹងមើលមករកអាត្មាដោយសេចក្តីងឿងឆ្ងល់ ដូចជាមិនចង់ជឿត្រចៀកខ្លួនឯង...*

# ហ៊ានលះ

**» បើចង់ធ្វើទានត្រូវហ៊ានលះធន**

**បើចង់បានបុណ្យត្រូវមានមេត្តា**

**ធ្វើបុណ្យដោយទឹកចិត្តបរិសុទ្ធថ្លា**

**មិនបានប្រាថ្នាយកផលតបវិញ ។**

ដោយឧបាសក មុិញ សារ៉ាង

# ៤០. សេចក្ដីស្រឡាញ់ និងសេចក្ដីអាណិត

ថ្ងៃបន្តបន្ទាប់មក អាត្មាក៏នាំអ្នកស្រុកដែលធ្វើស្រែទាំងអស់ ទៅឯគ្រួសារសុរិយោទី ចាត់ការបែងចំណែកហើយធ្វើកិច្ចប្រគល់ឲ្យដល់អ្នកស្រែគ្រប់ៗគ្នា យ៉ាងត្រឹមត្រូវទៅតាមច្បាប់ ។ សេចក្ដីរីករាយពេញចិត្តគ្រប់ៗគ្នា តែអ្នកខុសបំណងជាងគេបំផុតគឺបងប្រុសទាំងពីរ ។ គាត់មកតវ៉ាតឿងសួរអាត្មាយ៉ាងខ្លាំង រកឿងអាត្មាថាជាអ្នកបំផ្លាញកេរមរតករបស់បិតាខ្លះ ហើយថាអាត្មាឆ្កួតខ្លះ ។

- ឯងនេះឆ្កួតហើយ ! ឆ្កួតយ៉ាងច្បាស់តែម្ដង ! បងប្រុសធំស្រែកចេញមកយ៉ាងក្ដៅក្រហាយ, ឯងបំផ្លាញមរតកដែលលោកឪពុកប្រគល់ឲ្យ ធ្វើឲ្យគ្រួសារចុះឱនថយតែម្ដងបងៗមាននៅទាំងអស់ ឯងមិនគិតដល់សោះ ឯងត្រឡប់ជាលើកស្រែឲ្យទៅពួកអ្នកជួលស្រែទទេៗ ឯងឃើញពួកអ្នកស្រែនោះវាល្អជាងបងហើយឬហ្ន៎ា ? បងប្រុសឱនមុខមកសួរ

- ប្អូនមិនបានឃើញថា អ្នកស្រែល្អជាងបងនោះទេ, អាត្មាឆ្លើយដោយព្យាយាមរំងាប់ចិត្តឲ្យជាប្រក្រតី, តែឃើញថាគេក្រីក្រជាងបង អាណិតគេក៏ឲ្យទានគេទៅ

- បងក៏ក្រដូចគេដែរហើយ ! បងប្រុសប្រកែកបែបចូលខាងខ្លួនឯង

- តែក្ររបស់បង នៅគ្រាន់បើជាងក្ររបស់អ្នកស្រែ

ទាំងអស់នោះមួយរយនិងមួយពាន់ផង បងនៅមានដី របស់ខ្លួនឯងច្រើនកន្លែង តែអ្នកស្រែទាំងនោះ មិនមានអ្វី សោះ បងមានផ្ទះថ្មនៅយ៉ាងស្អឹមស្អែ តែអ្នកស្រែអស់នោះ នៅក្នុងខ្ទមប្រក់ស្លឹក បងមានសំពត់អាវមិនដឹងជាប៉ុន្មាន ឈុត តែអ្នកស្រែទាំងនោះមានសំពត់អាវចាស់ៗហែក គ្រាន់តែឱណ្ដាប់កាយ កូនៗរបស់បងបានចូលរៀនថ្នាក់ខ្ពស់ តែកូនអ្នកស្រែទាំងអស់នោះអានសៀវភៅមិនដាច់ បង ពិសារម្ហូបបរិបូណ៌ឆ្ងាញ់ពិសាគ្រប់ពេល តែអ្នកស្រែទាំង នោះត្រូវអត់ឃ្លានបានព្រឹកខ្វះល្ងាច

- ឯងកុំមកសម្ដែងធម៌ឲ្យបងស្ដាប់នោះ! បងប្រុសធំ ឆ្លើយកាត់ឡើងក្នុងពេលអាត្មាកំពុងនិយាយ, អើ! គេចង់ កើតមកជាអ្នកស្រែធ្វើអីហ្នឹ? កើតមកយ៉ាងនេះក៏ត្រូវរស់ នៅយ៉ាងនោះទៅ ដូច្នេះហើយកម្មរបស់អ្នកណា អ្នកនោះ ទទួល ឯងក៏ដឹងហើយថែរតើ កើតមកមានកម្មក៏ត្រូវទទួល កម្មនោះទៅ

- គិតយ៉ាងនេះដូចជាចិត្តចង្អៀតពេកហើយ យើងគួរ តែនឹកអាណិតអាសូរមិត្តមនុស្ស ជាអ្នកមានគ្រោះកាច អាក្រក់ ហើយជួយសង្គ្រោះគេទៅតាមកម្លាំងដែលអាច ជួយបានទើបជាការត្រឹមត្រូវ

- ជួយនោះបងមិនថាអ្វីទេ តែគួរនឹងជួយក្នុងផ្លូវដែល សមគួរ ដូចជាចែកប្រាក់ម្នាក់ ១០០ ឬ ២០០ ក៏ជាការល្មម សមគួរហើយ នេះឯងត្រឡប់ទៅធ្វើបែបក្លួតៗ លើកទី ដីស្រែដែលមានតម្លៃបួនដប់លានឲ្យទៅគេទទេៗ មានតែ

មនុស្សភ្លួតទេដែលនឹងធ្វើហួសហេតុបែបនេះ

- បើឲ្យប្រាក់គេម្នាក់ ១០០ ឬ ២០០ យ៉ាងហោចណាស់ក៏ជួយឲ្យគេរួចអំពីការជំពាក់គេពីមុន គឺបំណុលចាស់បានខ្លះប៉ុណ្ណោះ ឆ្នាំណាមិនបានធ្វើស្រែក៏ត្រូវជំពាក់គេទៀត វាមិនមែនការជួយថ្នាក់មូលដ្ឋាន, បងណាក់! ការដែលប្អូនលើកដីស្រែឲ្យគេតែម្តងនេះក៏ដើម្បីជួយឲ្យគេរួចអំពីសេចក្តីក្រីក្រពិតៗ ប្អូនមិនបានធ្វើហួសហេតុស្អីផងសោះ !

- កុំទៅតពាក្យតសម្តីប្រកែកជាមួយនឹងវាអីបង ! បងប្រុសបន្ទាប់ពោលកាត់ឡើង, មិនមានប្រយោជន៍ទេ វារៀនខាងក្រៅ រៀនខាងក្នុងមកច្រើនជ្រៅជ្រះ វាគង់តែមានហេតុផល ប្រកែកប្រជែងនឹងយើងពីថ្ងៃដល់យប់ មិនមានផ្លូវណាៗទៀតទេ ដែលយើងនឹងយកមរតកមួយនេះត្រឡប់មកវិញ

បងប្រុសធំនៅស្ងៀម គិតមួយសន្ទុះ ហើយពោលថា៖

- មានដូចគ្នា តែបងមិនចង់ធ្វើឲ្យវាខកចិត្ត ហើយខ្មាសពួកអ្នកស្រុកទទេៗ

- បងនឹងគិតធ្វើយ៉ាងណា ? បងប្រុសបន្ទាប់សួរយ៉ាងពេញចិត្ត

- ជួនកាលយើងនឹងអាចត្រូវខាត បងកុំភ្លេចណាំ៎ ស្រែទាំង ៣០០ រ៉ៃនេះ យើងនឹងបណ្តោយឲ្យរបូតពីដៃទៅទទេៗមិនបានទេណើយ !

- មានតែអ្នកម៉ែប៉ុណ្ណោះដែលអាចនឹងធ្វើបាន ! បង

ប្រុសធំនិយាយឡើងដោយការរិះគិត, អ្នកមិនអាចទៅប្ដឹងសាលាក្ដី ឲ្យសាលាក្ដីថា កូនតូចពៅនេះវាជាមនុស្សទុច្ចរិត ការដែលនាំយកស្រែទៅឲ្យអ្នកស្រុក ក៏ធ្វើទៅដោយសេចក្ដីទុច្ចរិត

- បានការហើយបង! បងប្រុសបន្ទាប់និយាយឡើងយ៉ាងរីករាយរំភើបចិត្ត, ចាត់ការតែម្ដងទៅល្អឬទេ? ខ្ញុំគិតថា សាលាច្បាប់ត្រូវតែជឿយ៉ាងពិតប្រាកដ មិនមានមនុស្សជាៗ សតិល្អណាហ៊ាន គេនឹងយកដីតម្លៃទាំងរយលានៗ ទៅចែកឲ្យអ្នកស្រុកលេងៗអញ្ចឹងនោះ

- អ្នកណាឃើញមនុស្សល្អៗ ទៅជាឆ្កួត មនុស្សនោះឯងហើយគឺជាមនុស្សឆ្កួតពិតៗ, អាត្មានិយាយបណ្ដើរសើចតិចៗ ពីព្រោះនឹកអស់សំណើចចំពោះហេតុការណ៍របស់បងៗទាំងពីរ, បើប្អូនធ្វើយ៉ាងនេះថាឆ្កួត ព្រះអង្គម្ចាស់សិទ្ធត្ថដែលលះបង់រាជសម្បត្តិ ទ្រង់យាងចេញសាងព្រះផ្នួសក៏ឆ្កួត នរណាដែលលះបង់ទ្រព្យសម្បត្តិធ្វើបុណ្យធ្វើទាន ម្នាក់ៗច្រើនៗ ក៏សុទ្ធតែឆ្កួតទាំងអស់នោះហើយ កុំគិតខ្វល់ខ្វាយនូវការបៀតបៀនគ្នាឡើយបងអើយ វេគបាប វេគកម្មពៀរមកដាក់ខ្លួនឯងទទេៗ ក្រៅអំពីបានបាបកម្មហើយ នៅមានការបំផ្លាញកេរ្តិ៍ឈ្មោះ កិត្តិយសរបស់វង្សត្រកូលទៀតផង

- ហើយអាដែលឯងយកមរតក ទៅចែកឲ្យពួកអ្នកស្រែទទេៗ នេះមិនជាការបំផ្លាញវង្សត្រកូលទេឬ ? បងប្រុសរងស្បូរឡើងទាំងកំហឹង

- ប្អូនមិនឃើញថាហ្នឹង ជាការបំផ្លាញកិត្តិយសរបស់

វង្សត្រកូលណា ពីព្រោះទីដីស្រែមួយនេះជាសម្បត្តិផ្ទាល់ខ្លួនរបស់ប្អូន បើជាការបង់ខាត ក៏វាជារឿងរបស់ខ្ញុំតែម្នាក់ឯង ក៏មិនទង្គិចទង្គើដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃៗក្នុងគ្រួសាររបស់យើងឡើយ ផ្ទុយទៅវិញត្រឡប់ទៅជាការកសាងកេរ្តិ៍ឈ្មោះប្រវត្តិដ៏ល្អប្រសើរ ឲ្យដល់ត្រកូលរបស់យើងទៀតផង ដំណើរនេះផ្សាយទៅដល់ទីណា មនុស្សគេនឹងអនុមោទនាសាធុការទៅដល់ទីនោះ ប្អូនយល់ឃើញថាបងគួរតែអនុមោទនា ជាមួយបុណ្យកុសលរបស់ប្អូនទៅល្អជាង កុំជំទាស់ឃាត់ឃាំងនៅបុណ្យកុសលរបស់ខ្ញុំឡើយ

- ខ្ញុំទទួលអនុមោទនាមិនរួចទេ! បងប្រុសទីពីរគាត់និយាយឡើងដោយសម្លេងកញ្ឆក់, នាំគ្នាទៅជួបម៉ែល្អជាងបង! បើនៅតែតវ៉ាប្រកែកទៅនាំឲ្យខូចពេលវេលាទទេៗ

នៅទីបំផុតបងទាំងពីរបានចាកចេញទៅ ។ អាត្មាគ្មានភ័យព្រួយខ្វល់អ្វីសោះ ពីព្រោះមុនពេលនឹងចែកដីឲ្យអ្នកស្រែ ខ្ញុំក៏បានពិភាក្សាជាមួយម៉ែរួចហើយ លោកក៏យល់ព្រមឃើញថាល្អដែរ ហើយលោកក៏បានអនុមោទនារួចហើយគ្រប់ប្រការ មិនជឿថាលោកនឹងត្រឡប់ប្រែប្រួលចិត្តដោយការញុះញង់បន្ថែមរបស់បងទាំងពីរនោះទេ ។

ការស្មានទាយទុករបស់អាត្មាត្រូវមែន ពីព្រោះប្រហែលកន្លះម៉ោងក្រោយមក ឃើញបងទាំងពីរដើរគាត់មុខអាត្មាចេញទៅដោយមិននិយាយមិនស្តី ។

នៅពេលទំលាក់ភារកិច្ចផ្សេងៗ ជ្រះស្រឡះហើយ អាត្មាក៏បាន ប្រគល់ខ្លួនសុំឧបសម្បទា ទៅជាព្រះភិក្ខុក្នុង

ព្រះពុទ្ធសាសនាដូចប្រាថ្នា ៗ នៅថ្ងៃបួសនោះ មានអ្នកស្រែមកអំពីភូមិអូររស្សេសិតទាំងស្រីទាំងប្រុស គ្រប់វ័យជាច្រើនរយនាក់ មកជួយកិច្ចការគ្រប់យ៉ាង តាំងតែពីជួយរៀបចំរបស់របរជញ្ជូនអីវ៉ាន់ រហូតដល់ទៅលើកអាត្មាមកឲ្យជិះកសែហទៅជុំវិញព្រះវិហារ ធ្វើឲ្យរីករាយបីតិកើតមានដល់មាតាលុះគ្រាទឹកភ្នែកហូរ ៗ ក្រោយអំពីបានបួសយូរបន្តិចមកហើយ លោកគ្រូក៏នាំអាត្មាចេញដើរធុតង្គទៅ ដើម្បីបដិបត្តិធម៌តាមព្រៃភ្នំ ក្រោមម្លប់ដើមឈើតទៅ ៗ ក្រោយពីដើរតាមលោកអាចារ្យទៅអស់រយៈពេលច្រើនឆ្នាំ នៅពេលលោកគ្រូឃើញថា អាត្មាមានភូមិធម៌ល្មមនឹងការពារខ្លួនឯងបានហើយ លោកក៏អនុញ្ញាតឲ្យអាត្មាចេញដើរធុតង្គទៅដោយបែកផ្សេងគ្នា ៗ អាត្មាក៏ចេញធុតង្គបដិបត្តិធម៌និងបង្រៀនប្រជាជនជារឿយៗ លុះមកដល់ពេលនេះអស់ថេរៈផលា ៨ ឆ្នាំហើយ

- គួរឲ្យអនុមោទនាខ្លាំងណាស់ព្រះតេជគុណ ! អ្នកម៉ែពោលឡើង ក្រោយពីបានស្តាប់ពាក្យបរិយាយរបស់អាត្មាមកអស់រយៈយ៉ាងយូរ, ស្តាប់ទៅដូចជាប្រហែលៗនឹងរឿងព្រះវេស្សន្តរ មានអ្វីៗលះបង់ទាំងអស់ អ្នកស្រែទាំងអស់នេះក៏មានសំណាងល្អសម្បើមហើយ ប្រហែលគេសប្បាយចិត្តដូចជាព្រះមាល័យយាងមកប្រោស

- ចុះដីស្រែនិងផ្ទះឈ្នួលនៅឯបន្ទាត់មាស នៅឡើយទេឬ? ប៉ុណ្ណារិម៉ាសួរឡើង, បើសិនជានៅ លោកម្ចាស់គិតនឹងលះបង់ធ្វើបុណ្យទៀតឬ? នឹងសុំទទួលចំណែកខ្លះផង

មែនណា! ដួងកែវសួរគាត់ឡើងទំនងលលេង

- បើសិនជាព្រះអង្គប្រទានឲ្យក៏យក! ប៉ុណ្ណាម៉ាតបព្រម ទាំងសើច ធ្វើឲ្យអ្នកប៉េងកមកហាមឲ្យស្ងប់ស្ងាត់

- អាត្មាលើកឲ្យមាតាទៅហើយ! អាត្មាស្លើយ, មាតា យកផលប្រយោជន៍សងជំពាក់រដ្ឋជំនួសអាត្មា នៅពេលនេះ សងរួចហើយ អ្នកម្ដាយក៏យកកម្រៃនៃប្រាក់ដួលផ្ទះនោះ ប្រើប្រាស់ចាយវាយតទៅ

- ចុះគូដណ្ដឹងរបស់ព្រះអង្គនោះ តើនៅលីវរហូតសព្វ ថ្ងៃនេះឬ ក៏រៀបការទៅហើយ? ដួងកែវសួរអាត្មា

- គេនៅលីវដដែលទេ, អាត្មាស្លើយ

- ព្រះគុណម្ចាស់លោកមិនអាណិតគេខ្លះទេឬ? ប៉ុណ្ណា-ម៉ាសួរខ្លះ

- អាណិតដែរ, អាត្មាស្លើយ

- បើដូច្នេះមានន័យថា លោកម្ចាស់នៅតែស្រឡាញ់គេ ដែរ, ប៉ុណ្ណាម៉ានិយាយញឹមៗ

- មិនស្រឡាញ់ទេ គ្រាន់តែអាណិត!

- ស្រឡាញ់ និងអាណិត មិនមែនដូចគ្នាទេឬ? ដួង កែវសួរ

- មិនមែនទេញោម សេចក្ដីស្រឡាញ់វាងគេទនោះ ក៏គឺត្រូវការសេចក្ដីប្រាថ្នា សេចក្ដីចង់បាននោះឯង, សេចក្ដី ស្រឡាញ់បែបនេះ តែងកើតឡើងនៅពេលដែលបានជួប ជាមួយអារម្មណ៍ដែលគួរឲ្យស្រឡាញ់ គួរឲ្យពេញចិត្តដូចជា បុរសកំលោះឃើញស្រីក្រមុំ ស្រីក្រមុំឃើញបុរសកំលោះ

ជាដើម ។ ចំណែកសេចក្ដីអាណិតនោះកើតឡើងនៅពេលឃើញអ្នកដទៃបានទទួលនូវសេចក្ដីទុក្ខ មិនថាជាប្រុសឬជាស្រី ឬសូម្បីតែសត្វតិរច្ឆាន បើយើងឃើញគេធ្លាក់ទឹកនៅក្នុងសេចក្ដីទុក្ខ យើងនឹងកើតសេចក្ដីអាណិត សេចក្ដីស្រឡាញ់រវាងភេទជាសេចក្ដីចង់បាន តែសេចក្ដីអាណិតមិនមានសេចក្ដីចង់បាន មានតែចង់ឲ្យចង់ជួយ អាត្មាអាណិតគូដណ្ដឹងពីព្រោះគេមានសេចក្ដីទុក្ខ ប៉ុន្តែមិនមានសេចក្ដីស្រឡាញ់

- យល់ឃើញថាព្រះគុណម្ចាស់ នឹងយកសេចក្ដីស្រឡាញ់ ទៅជារបស់ដូចគ្នាជាមួយសេចក្ដីស្រណោះទៅហើយនឹង, ខណៈនោះដួងតែវប្រជែងពោលឡើង ដូចជាអ្នកមានបញ្ហាដូចមុនៗ, ខ្ញុំម្ចាស់យល់ឃើញថាស្រឡាញ់និងអាណិតជាមនុស្សផ្សេងគ្នា ពីព្រោះអ្នកខ្លះអាចនឹងកើតសេចក្ដីអាណិត ដោយមិនមានសេចក្ដីស្រឡាញ់

- សេចក្ដីស្រឡាញ់និងអាណិត ក៏គឺសេចក្ដីត្រូវការដូចគ្នា ខុសគ្នាតែត្រង់ជាអារម្មណ៍ដែលត្រូវការ សេចក្ដីស្រឡាញ់ជាសេចក្ដីត្រូវការផ្លូវភេទតែម្យ៉ាង ។ មនុស្សអាចនឹងកើតសេចក្ដីអាណិតបាន ដោយមិនមានសេចក្ដីស្រឡាញ់ដូចញោមថា ចំណែកសេចក្ដីស្រឡាញ់នោះ ជាសេចក្ដីត្រូវការអារម្មណ៍ច្រើនៗព្រមៗគ្នា ដូចជាត្រូវការជាម្ចាស់របស់ ត្រូវការសេចក្ដីស្រឡាញ់តបពីអ្នកស្រឡាញ់ត្រូវការសេចក្ដីសុខ ភាពកក់ក្ដៅអំពីសេចក្ដីស្រឡាញ់រួមទាំងត្រូវការសេចក្ដីសម្រេចនូវការអាណិតផង ព្រោះដូច្នោះ

សេចក្តីស្រឡាញ់ ទើបត្រូវមានសេចក្តីអាណិតផងដែរនិច្ច តែសេចក្តីអាណិតអាចនឹងមិនមានសេចក្តីស្រឡាញ់ក៏បាន បើនឹងនិយាយឲ្យច្បាស់ទៅទៀត សេចក្តីស្រឡាញ់មានព្រំដែនធំជាង ផ្នែកសេចក្តីអាណិតមានព្រំដែនចង្អៀតញោមល្មមនឹងចូលចិត្តហើយឬនៅ?

- ចូលចិត្តហើយ តែនៅសង្ស័យដែលលោកម្ចាស់ថា សេចក្តីស្រឡាញ់គឺសេចក្តីត្រូវការ សេចក្តីចង់ ស្តាប់ៗទៅដូចជាថា សេចក្តីស្រឡាញ់ជាសេចក្តីឃើញផ្ទាល់ខ្លួន ជាការមើលសេចក្តីស្រឡាញ់ក្នុងចំណុចទាបទៅវិញ ដ្បិនគាលសេចក្តីស្រឡាញ់បែបនោះ អាចនឹងមិនមែនស្រឡាញ់ពិតពីព្រោះគេថាស្រឡាញ់ពិត គឺសេចក្តីលះបង់ មិនមែនទេឬ?

- អាត្មាមិនបានមើលការស្រឡាញ់ក្នុងផ្នែកខ្ពស់ឬទាប តែព្យាយាមមើលតាមការពិត អាត្មានៅតែយល់ឃើញថា ការស្រឡាញ់រវាងភេទ ជាសេចក្តីស្រឡាញ់ត្រូវការ ចង់បានការប្រាថ្នានោះក៏អាចឃើញជាប្រយោជន៍ផ្ទាល់ខ្លួនច្រើនជាងពីព្រោះយកខ្លួនយើងជាគោល យើងចង់បានរបស់ដែលយើងស្រឡាញ់មក ដើម្បីផ្តល់នូវសេចក្តីស្រឡាញ់របស់យើង ។ ការស្រឡាញ់គ្រប់យ៉ាង តែងតែមានសេចក្តីសន្ដឹមល្អដែលនៅជាមួយ សេចក្តីសន្ដឹមល្អនោះឯង ជាហេតុឲ្យយើងប្រាថ្នាឲ្យអ្នកដែលយើងស្រឡាញ់មានសេចក្តីសុខ ហើយនៅពេលខ្លះយើងក៏ធ្វើការលះបង់ ដើម្បីឲ្យអ្នកដែលស្រឡាញ់មានសេចក្តីសុខ នៅពេលឃើញអ្នកដែលខ្លួនស្រឡាញ់មានសេចក្តីសុខ យើងក៏ដូចជាមានសេចក្តី

សុខជាមួយដែរ ពីព្រោះមានសេចក្តីប្រកាន់ថា គេជារបស់យើង តែបើគេមិនព្រមប្រគល់នូវសេចក្តីស្រឡាញ់ដល់យើង គេទៅស្រឡាញ់អ្នកផ្សេង យើងនឹងខុសបំណងយ៉ាងខ្លាំង មានសេចក្តីទុក្ខព្រួយយ៉ាងធ្ងន់ធ្ងរហើយអាចនឹងមានការគ្រោះថ្នាក់ផង ។ អាត្មាមិនដែលឃើញអ្នកណាមានសេចក្តីស្ងប់ចិត្ត យ៉ាងពិតប្រាកដនៅឡើយទេ នៅពេលដែលឃើញមនុស្សជាទីស្រឡាញ់របស់ខ្លួន ក្លាយទៅជារបស់អ្នកដទៃ សូម្បីនឹងនិយាយថា ស្រឡាញ់ដែលពិតប្រាកដ គឺការចេះលះបង់ ពាក្យនេះនិយាយកែខ្លួនឲ្យតែផុតពីមាត់ប៉ុណ្ណោះទេ

ដូងកែវអ្នកមានបញ្ហា អង្គុយស្ងៀមគិតមួយសន្ទុះ ហើយនិយាយខ្សាវៗថា ៖

- បើយ៉ាងនេះ បានយល់ថា សេចក្តីស្រឡាញ់មិនមែនប្រសើរ មិនមែនសុខ ដូចជាគេនាំគ្នានិយាយនោះទេ

- មិនខ្ពស់ មិនទាប ជារបស់ធម្មតាសម្រាប់សត្វលោកយ៉ាងនោះឯង

- ហើយចុះសេចក្តីផ្សេងៗទៀតនោះ ដូចជាសេចក្តីស្រឡាញ់រវាងឪពុក ម្តាយ កូន ?

- សេចក្តីស្រឡាញ់រវាងឪពុក ម្តាយ កូន មិនទាក់ទងជាមួយសេចក្តីអាណិត មិនទាក់ទងនឹងសេចក្តីឃើញប្រយោជន៍ផ្ទាល់ខ្លួនដោយត្រង់ តែទាក់ទងជាមួយឧបាទានការប្រកាន់ថាជាកូនរបស់ខ្លួន ជាសាច់ឈាមរបស់ខ្លួន ។ សេចក្តីប្រាថ្នាល្អ សេចក្តីហួងហែង និងសេចក្តីភ័យព្រួយ

ទាំងអស់កើតមកពីឪពុកម្ដាយ ។ ការស្រឡាញ់កូន ច្រើន ពីព្រោះយើងស្គាល់ថាជាកូនរបស់យើង បើជាកូនរបស់អ្នកដទៃ យើងក៏ស្រឡាញ់តិច ឬមិនស្រឡាញ់សោះ

- ពួកឯងចេះតែនាំលោកម្ចាស់និយាយពីរឿងជ្រៅទៅ ហួសពេកហើយ នួងកែវ ប៉ុណ្ណិម៉ា ! ម្ចាស់ប៉ែពោលឡើង, ខ្ញុំកំពុងតែពិរោះរឿងរបស់គូដណ្ដឹងរបស់លោក ខ្ញុំករុណាសូមសួរទានបន្តិចទៀតចុះណាំទាន ការដែលគូដណ្ដឹងរបស់ព្រះតេជគុណមិនព្រមរៀបការនោះ មានន័យថា គេនៅរង់ចាំលោកម្ចាស់មែនទេទាន ?

- តាមដែលអាត្មាយល់ក៏ប្រហែលដូច្នេះដែរមើលទៅ!

- គេប្រហែលសង្ឃឹមថាលោកនឹងសឹកវិញ ទើបទ្រាំនៅចាំមកដល់ពេលនេះអស់រយៈពេលប្រាំបីឆ្នាំហើយ តើព្រះគុណម្ចាស់ដែលបានជួបគេឬទេ ?

- បានជួបខ្លះដែរ តាំងតែពីអាត្មាបានបែកចេញអំពីលោកគ្រូ ដូចជាបានជួប ៣ ដង រាល់ពេលអាត្មាទៅមើលញោមប៉ែ ញោមប៉ែតែងទូរស័ព្ទហៅគេមកជួបរាល់ពេល

- បើព្រះតេជគុណមិនសឹកទេ ដូចម្ដេចលោកមិនប្រាប់នាងឲ្យរៀបការទៅ, ប៉ុណ្ណិម៉ាសួរ

- អាត្មាបានប្រាប់គេជាច្រើនដងហើយ ដូចជានៅពេលដំបូងដែលអាត្មាបានជួបនឹងគេ ។ ក្រោយអំពីបានដើរធុតង្គអស់រយៈមួយឆ្នាំពេញ គេសួរអាត្មាថា ៖

- លោកម្ចាស់ដូចជាស្គមទៅៗច្រើនណាស់ លោកដើរធុតង្គទៅតាមព្រៃភ្នំ លោកនៅបែបណា ឆាន់យ៉ាងណា

ប្រាប់ "ជិន្ត" ផង "ជិន្ត" គិតបារម្ភលោកណាស់

- ឆាន់មួយថ្ងៃម្ដងនៅពេលព្រឹក ម្ហូបអាហារបានមកពីការបិណ្ឌបាត អ្នកស្រុកដាក់ស្អីឲ្យឆាន់ ក៏ឆាន់យ៉ាងនោះ ពេលខ្លះមិនមានម្ហូប មានតែបាយទទេ ក៏ឆាន់បាយទទេ ៗ ការរស់នៅ ក៏នៅទៅតាមគល់ដើមឈើ យប់នៅកន្លែងណាក៏ដាក់ក្រូតសម្រាកនៅទីនោះ

- ពុទ្ធោអើយ ! គួរឲ្យអាណិតណាស់, ជិន្តណាពោលឡើងយ៉ាងមុខស្រងូត ពោរពេញទៅដោយសេចក្ដីខ្វល់ខ្វាយគិតច្រើន, ហើយលោកម្ចាស់សុខសប្បាយជាទេឬគិតថាជីវិតជារបស់សំខាន់ណាស់

- ក៏សុខសប្បាយ សូម្បីអាហារតិចឬច្រើន តែល្មមដើម្បីឲ្យជីវិតរស់នៅបាន ពីព្រោះមិនបានទៅធ្វើការលើសែងអ្វី ការរស់នៅទៅតាមព្រៃតាមភ្នំ ក៏សប្បាយល្អម៉្យាងស្ងប់ស្ងាត់ចិត្តបានល្អ

- មិនមានអន្តរាយអំពីសត្វព្រៃខ្លះទេឬ ?

- មិនដែលមានសត្វកាចផ្សេងៗទេ បើយើងគិតថាវាជាមិត្តរួមលោក ផ្សាយមេត្តាចិត្តដល់វា វាក៏ដូចជាយល់ចិត្តរបស់យើង បណ្ដោយឲ្យយើងនៅយ៉ាងស្ងប់សុខ ម្នាក់ៗនៅរៀងៗខ្លួន បានសុខផុតភ័យ ហើយសប្បាយចិត្តជាងនៅផ្ទះក្នុងស្រុកទៅទៀត

ជិន្តណាដកដង្ហើមធំយ៉ាងវែង អង្គុយឱនមុខគិតមួយរយៈហើយក៏ពោលឡើងថា ៖

- ព្រះគុណម្ចាស់ ! "ជិន្ត" នឹកលោកបងណាស់ តាំងតែពី

លោកបងចាកចេញទៅ "ជិន្ត" មិនដែលមានសេចក្ដីសុខសោះឡើយ លោកបងនឹកមកជិន្តខ្លះដែរឬទេ?

- ការគិតដល់ស្ត្រីភេទ គឺខុសវិស័យរបស់សមណៈ ទើបអាត្មាព្យាយាមហាមឃាត់ចិត្ត នៅពេលបួសថ្មីៗ យល់ថាការហាមចិត្តក៏ពិបាកដូចគ្នាដែរ ពីព្រោះចិត្តថ្មើមមួយចំណែកព្យាយាមទាក់ទាញរកអតីត អាត្មាចង់ឲ្យញោមព្យាយាមចិត្តដូចគ្នាដែរ

- ជិន្តបានព្យាយាមហើយតែមិនសម្រេច ជិន្តមិនអាចបំភ្លេចលោកបងបានទេ រាល់ពេលដែលមកទីនេះ ជិន្តនឹកដល់លោកបងគ្រប់ពេល ពេលដែលឃើញព្រះសង្ឃសាមណេរ ជិន្តនឹកដល់លោកបង សូម្បីឃើញស្លឹមានពណ៌លឿងៗ ក៏នឹកដល់លោកបងដែរ ជិន្តយល់ច្បាស់ថា សេចក្ដីអាល័យនឹកជាសេចក្ដីទុក្ខ បើជិន្តមិនមានទុក្ខមួយនេះទេ ជិន្តប្រហែលជាសប្បាយចិត្តច្រើន តែវាមិនអាចនឹងឃាត់ឃាំងឬលើកយកចេញបានងាយៗ លោកបងមិនអាណិតជិន្តខ្លះទេឬ?

- អាត្មាអាណិតគ្រប់មនុស្សសត្វដែលមានទុក្ខ បើអាចធ្វើបាន ក៏ចង់ជួយឲ្យរួចអំពីទុក្ខ

ជិន្តណា សម្លឹងមើលមកអាត្មា ដោយទឹកមុខមានស្នាមរីករាយបន្តិច ហើយពោលថា៖

- បើដូច្នេះក៏ជួយ "ជិន្ត" ផងខ្លះទៅលោកបង?

- ទុក្ខរបស់ញោមជាទុក្ខផ្លូវចិត្ត ដែលកើតអំពីការព្យាយាម ទាញយកមកភ្ជាប់ជាមួយអារម្មណ៍ចាស់ទុក មិន

ព្រមស្រាយឲ្យវាចេញទៅ ព្រមទាំងវាក៏ក្លាយទៅជាចំណងយ៉ាងខ្លាំងពេញទីនោះផងដែរ ជីវិតរបស់យើង ប្រៀបដូចជាទូកដែលអណ្តែតបញ្ច្រាស់ទឹកទៅតាមទន្លេ នៅពេលដែលអង្គុយនៅក្នុងទូក យើងបានឃើញរបស់ផ្សេងៗអណ្តែតតាមទឹកហួសយើងទៅ មានរបស់ខ្លះជារបស់ល្អគួរជាទីពេញចិត្ត របស់ខ្លះមិនល្អ មិនគួរឲ្យពេញចិត្ត នៅពេលជួបនូវរបស់ដែលល្អ យើងក៏យកខ្សែចងវាទុកនឹងទូក ធ្វើឲ្យទូកនោះធ្ងន់ បើកបរទៅយឺតឡើងៗ ហើយយើងក៏ពោលថាទូកវាធ្ងន់ តែមិនព្រមស្រាយខ្សែ បណ្តោយឲ្យរបស់ធ្ងន់នោះឲ្យវាអណ្តែតទៅតាមក្រសែទឹកតាមធម្មតារបស់វា ។ យ៉ាងណាមិញ ពេលមួយ នៅពេលដែលទូកគឺជីវិតរបស់ញោមបើកបរមកតាមក្រសែទឹក ញោមបានមកជួបប្រទះនឹងប្រុសកំលោះម្នាក់ ហើយញោមក៏យកខ្សែគឺចិត្តមកចងគេទុក ធ្វើឲ្យទូករបស់ញោមធ្ងន់ ធ្វើឲ្យញោមកើតទុក្ខ ។ វិធីកែច្នៃមានតែមួយទេគឺ ស្រាយខ្សែឲ្យគេអណ្តែតទៅតាមក្រសែទឹកនោះទៅ កុំគិតដល់គេ កុំមើលទៅខាងក្រោយទូក ឲ្យមើលទៅខាងក្បាលទូក ដើម្បីនឹងបានឃើញនូវរបស់ប្លែកៗថ្មីៗ ដែលអណ្តែតមកមិនឈប់មិនឈរសោះនោះ បើញោមធ្វើដូច្នេះបាន ញោមនឹងសប្បាយចិត្ត

- របស់គ្រប់យ៉ាងជិនអាចបំភ្លេចបាន តែលោកបងជិនមិនអាចបំភ្លេចបានទេ ជិនបានព្យាយាមហើយព្យាយាមទៀតតែមិនសម្រេច ជិននៅតែពោលពាក្យដដែលៗដូចមុន

បរិយាកាសមានភាពតានតឹងមួយសន្ទុះ ហើយ

ជិន្តណាពោលឡើងថា៖

- លោកបង! នៅពេលនេះ មានប្រុសកំលោះមួយរូប មកទាក់ទងនឹងជិន្ត គេប្រាប់ថា គេស្រឡាញ់ជិន្ត ហើយសូមរៀបការជាមួយជិន្ត តើលោកបងឲ្យជិន្តធ្វើយ៉ាងណាទើបល្អ?

- បើគេស្រឡាញ់ពិត ហើយគេជាមនុស្សល្អ ក៏គួរនឹងរៀបការជាមួយគេទៅ!

ជិន្តណា សម្លឹងមកអាត្មាសម្តែងនូវអាការៈមិនពេញចិត្តមួយស្របក់ ឈ្ងោកមុខចុះ ឃាំអណ្តឺតអណ្តក យកកន្សែងមកជូតទឹកភ្នែក ក្រាបថ្វាយបង្គំ ហើយក៏ក្រោកដើរចេញទៅទាំងក្តីអស់សង្ឃឹម មុខគួរឲ្យស្រណោះណាស់...

**ចប់ដោយបរិបូណ៌...**

ក្រុងប៉ុងពេអាល, ថ្ងៃទី២០ ខែមករា គ.ស.២០១៧

**ដូនជី ចារូន**

**មុិញ សាវ៉ាន / ហុិម ឆាន់ / វ៉ាត តិរក្ស / ធឹម អរុណី**

# កោរសក់សាងផ្នួស

បទពាក្យ៧

កោសក់សាងផ្នួសបួសជាសង្ឃ ប្រព្រឹត្តត្រឹមត្រូវតាមពុទ្ធដីកា
ជ្រកម្លប់ព្រះធម៌បវរថ្លា កាយចិត្តវាចាប្រាថ្នាស្ងប់ ។
លះបង់អ្វីៗដែលធ្លាប់មាន ជំពាក់ស្រែកឃ្លានមានមិនចប់
តណ្ហាប្រាថ្នាពុំដែលស្ងប់ ខ្វះខាតទាំងសព្វទោះយប់ថ្ងៃ ។
លះសម្បត្តិដីចំការស្រែ លាតូចស្រីស្នេហ៍ធ្លាប់កិសម័យ
លាញាតិមិត្រកក្តីស្មក្រមេត្រី វិទ្យាស្ពឹមស្តែសូមលះលា ។
លាបងលាប្អូនស្ងួនពិសី លាមាតាថ្លៃគុណមហិមា
កូនសូមក្រាបទៀបនៃបាទា ចូលឧបសម្បទាភេទជាសង្ឃ ។
គ្រងស្បង់ចីពរល្អពិសិដ្ឋ បដិបត្តិកាយចិត្តពិតត្រឹមត្រូវ
កាន់វត្តប្រព្រឹត្តអង្គធុតង្គ ប្រាថ្នាធម៌ក្នុងបរិសុទ្ធថ្លា ។
ព្យាយាមលះកាត់អាសវៈ ផម្រុះទម្លាក់នូវកាមា
កាត់បង់ចិត្តដាមហិច្ឆតា បរិភោគអាហារតាមសមគួរ ។
ត្រេចចរទៅតាមស្រុកនិគម ព្រឹក្សាញកភ្នំជ្រោះដងអួរ
កាយចិត្តពិតពឹងលើព្រះធម៌ ជាពំនឹងល្អសម្រាប់ជីវិត ។
ឥតជាប់ជំពាក់ទីកន្លែង ចិត្តឥតហួងហែងព្រួយភ័យគិត
ម្រឹគាបក្សីជាញាតិមិត្រ អធិដ្ឋានតាំងចិត្តផ្ចិតធម្មា ។
ជីវិតពឹងលើពុទ្ធបរិស័ទ ព្យាយាមផុសខាត់ហាត់ចិន្តា
គឺសីលសមាធិបញ្ញា ផ្សាយធម៌មេត្តាដល់សព្វសត្វ ។
គ្មានឱសថអ្វីស្មើព្រះធម៌ កំចាត់បានល្អទុក្ខវិបត្តិ
ជាធម្មយានចម្លងសត្វ សំដៅឆ្លងកាត់វដ្តបាន ៕

ដោយឧបាសក ម៉ិញ សារ៉ាន

# ទី៣ សូមលា...បើមានវាសនាជួបគ្នាជាថ្មី !

បទពាក្យ៨

| | | |
|---|---|---|
| ជូនជីបកប្រែសរសេរស្មេរតែង | ក្រុមអ្នកចាត់ចែងជំនួយកិច្ចការ | |
| និងជនសប្បុរសចិត្តស្មោះជ្រះថ្លា | បង្អោនសិរសា វាចាសូមលា | ។ |
| កិច្ចពនេចរភាគទី ៣ | កាយចិត្តរចីសិរសីវន្ទា | |
| លាធម្មមិត្តឆ្ងាយជិតគ្រប់គ្នា | ចប់ហើយឃ្លាតឃ្លាលាទាំងសោកស្តាយ | ។ |
| សូមវីមង្សា[១] ថែមសុឆន្ទៈ[២] | បូកនិងវីរិយៈ[៣] និងគុណទាំងឡាយ | |
| កើតបុណ្យជូនញាតិសន្តានជិតឆ្ងាយ | រីករាយសប្បាយផុតឆ្ងាយកង្វល់ | ។ |
| សូមអ្នកស្តាប់អាន បានសម្រាន្តសុខ | ចៀសចាកផុតទុក្ខអស់ស្មុគស្មាញខ្វល់ | |
| កកើតបញ្ញាផាសុក[៤] និមល | ជីវិតជួបយល់មង្គលសិរី | ។ |
| សង្ឃឹមថ្ងៃជាវេលាបវរ | មានរឿងមួយល្អកំដរជាថ្មី | |
| ជូនព្រះគុណម្ចាស់ធម្មមិត្តប្រុសស្រី | កំសាន្តហឫទ័យដោយក្តីស្មោះស្ម័គ្រ | ។ |
| ជូនជី ចាន់រួន និង ម៉ិញ សារ៉ាន | ព្រមទាំង ហ៊ិម ឆាន់ និង ខ៉ាត តិរត្យ | |
| ឆឹម អរុណី សូមលាលោកអ្នក | សូមសុខត្រជាក់ក្សាន្តក្រោមម្លប់ធម៌ | ៕ |

ដោយឧបាសក ហ៊ិម ឆាន់

---

(១) វីមង្សា ការពិចារណាដោយល្អិត

(២) សុឆន្ទៈ បំណងល្អ

(៣) វីរយៈ ការព្យាយាម

(៤) ផាសុក សេចក្តីសុខ

សូមរង់ចាំអាន...

# ច្បាប់នៃកម្ម

*** បកប្រែជាខេមរភាសាដោយ**

**ដូនជី សុភចម ចំរើន ចារូន (ចារុវណ្ណា)**



@ សូមពុទ្ធបរិស័ទដែលមានសទ្ធាជ្រះថ្លា ចូលរួមក្នុងការបោះពុម្ពនៃសៀវភៅ « **រឿងព្រះភិក្ខុពនេចរ ភាគ ៣** » និងទូរទ្រង់ « គេហដ្ឋានអភិរក្សមរតកព្រះពុទ្ធសាសនា » យើងខ្ញុំនេះ បានប្រកបតែនឹងសិរីសួស្តី ជោគជតា រាសីជ័យមង្គលវិបុលសុខ និងបានប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមសព្វសត្តនិករ អនុមោទនាត្រេកអរ ទទួលយក នូវចំណែកបុណ្យកុសលដែលយើងខ្ញុំបានសាងសន្សំ ទទួលយកនូវចំណែកសន្តិភាពក្នុងចិត្តរបស់យើងខ្ញុំ ទទួលយកនូវចំណែកនៃព្រះធម៌របស់យើងខ្ញុំ ។

សូមសព្វសត្តនិករ បានរួចរំដោះចាកផុតទុក្ខទាំងពួង ។

សូមអនុមោទនា !

សូមអនុមោទនាបុណ្យ !

សូមអនុមោទនាធម្មទាន !

# ទានបុណ្យបរិស័ទ...

## មានសទ្ធាជ្រះថ្លាបានបរិច្ចាគប្រាក់ដើម្បីបោះពុម្ព សៀវភៅ « *ព្រះភិក្ខុពនេចរ ភាគ ៣* » ជាធម្មទាន

. បច្ច័យនៅសល់ពីសៀវភៅលើកមុន ........................................................ ១០០០ ដុល្លារ
. ព្រះភិក្ខុ **មហា យិន ឡើន** ........................................................ ១០០ ដុល្លារ
. ព្រះភិក្ខុ **ធឹង ធីម** ( **ចន្ទត្ថេរ** ) ចៅអធិការវត្ត **ធម្មិការាម** ........... ២០០ ដុល្លារ
. ព្រះភិក្ខុ **សុំ ប៊ុនធឿម** ( **សុវណ្ណត្ថេរោ** ) វត្ត **ពុទ្ធសុទ្ធារាម** ...... ២០០ ដុល្លារ
. ព្រះភិក្ខុ **តិក្ខមុនី អ៊ុំ ឆេង** វត្ត **ពោធិការាម** ( Ottawa ) ................. ៥៥ ដុល្លារ
. ព្រះភិក្ខុ **ស៊ឹម ផាន់ណា** វត្ត **ខ្មែរភាណាដា** ................................ ១០០ ដុល្លារ
. ព្រះភិក្ខុ **ប៉ាវ សែន** វត្ត **ខេមរារាម** ( Anjou ) ............................. ៧០ ដុល្លារ
. ដូនជី **សុភចម ចារ៉ូន** (France) .......................................... ៥០ ដុល្លារ U.S
. លោក **ជា ផលនិស្ស័យ** និងគ្រួសារ ................................. ១៨០ ដុល្លារ
. ឧបាសក **នុន ស្បៃ** និងឧបាសិកា **នុន ណាន់ថា** ..................... ១៧៥ ដុល្លារ
. ឧបាសក **លិម ហ៊ុយគាង** និងឧបាសិកា **លិម ឡេង**(ONT) ........... ១៦០ ដុល្លារ
. ឧបាសិកា **ជា ស្រីយុទ្ធថូ** ........................................................ ១៥០ ដុល្លារ
. លោក **នូ ស៊ីយឿន** និងអ្នកស្រី **លី សុតី** ............................ ១៣០ ដុល្លារ
. ឧបាសក **ខាយ ប៊ុនគិម** និងឧបាសិកា **ស ឆេង** ............................ ១៣០ ដុល្លារ
. ឧបាសិកា **ទូច ណាំ** ........................................................................ ១០០ ដុល្លារ
. អ្នកស្រី **នួន សាយណ្ណា** ........................................................ ១០០ ដុល្លារ
. លោកយាយ **ម៉ឿន ហេង** និងកូនចៅ ............................................ ១០០ ដុល្លារ
. លោក **លី សុខផុន** និងអ្នកស្រី **ម៉ែន ចន្ធូ** ព្រមទាំងបុត្រ ....... ១០០ ដុល្លារ
. ឧបាសក **ម៉ិញ សាវ៉ាន** និងឧបាសិកា **សិម ចាន់ធូរ៉ា** ................ ១០០ ដុល្លារ
. ឧបាសិកា **ស៊ុម យ៉ាង** ព្រមទាំងបុត្រ ................................................ ១០០ ដុល្លារ
. ឧបាសក **អ៊ឹម សាមៃ** និងឧបាសិកា **ភូង ឡើន** ........................... ៨០ ដុល្លារ

. ឧបាសក **គិម សាក់ឆ្វាង** និងឧបាសិកា **ត្រាំ ធីខេម** និងបុត្រ ........... ៧០ ដុល្លារ
. លោក **វ៉ាត អិរក្សេ** និងអ្នកស្រី **ម៉ៀច វណ្ណា** ........................... ៧០ ដុល្លារ
. ឧបាសក **ពេជ្រ សារឿម** និងឧបាសិកា **សិម ចាន់តារា** .................... ៦០ ដុល្លារ
. លោក **ឆឿង រី** ........................................................................ ៦០ ដុល្លារ
. លោក Lam Duc Quang ........................................................ ៦០ ដុល្លារ
. ឧបាសិកា **ជា ឆាង** ................................................................. ៦០ ដុល្លារ
. លោក **យុត រឿង** និងអ្នកស្រី **សយ គុំ** ....................................... ៦០ ដុល្លារ
. ឧបាសិកា **ណាងវ៉ាន់នី** ............................................................... ៦០ ដុល្លារ
. ឧបាសិកា **រ៉ុន** និងលោក **ឈុំ ឆារ៉ុង** .................................................... ៦០ ដុល្លារ
. ឧបាសក **យន់ សាវុធ** និងឧបាសិកា **ណាម នី** ព្រមទាំងបុត្រ ........... ៥៥ ដុល្លារ
. លោក **តាន់ ម៉ុនតឹក** និងអ្នកស្រី **តាន់ ថានី** .............................. ៥០ ដុល្លារ
. ឧបាសិកា **ឡេង អម** ................................................................. ៥០ ដុល្លារ
. ឧបាសិកា **ហ៊ុន ហៀង** ................................................................ ៥០ ដុល្លារ
. ឧបាសក **យិត ឆេង** .................................................................. ៥០ ដុល្លារ
. លោក **មាយ ចន្ទកក្កដា** និងអ្នកស្រី **មាយ ហេឡែន** ............. ៥០ ដុល្លារ
. លោក **ផាត់ សុខឡឹត** និងអ្នកស្រី **ឆៃ សុភិន** ............................. ៥០ ដុល្លារ
. ឧបាសក **ខូច សែម** និងឧបាសិកា **លីម មុយគីម** ....................... ៥០ ដុល្លារ
. លោក **សក្តិ ផល្លា** និងអ្នកស្រី **ចាន់ សុម៉ាលី** ............................. ៥០ ដុល្លារ
. អ្នកស្រី **ផាន សាវុទ្ធ** ................................................................ ៥០ ដុល្លារ
. ឧបាសក **ម៉េង ណាំ** និងឧបាសិកា **សក់ សានី** ................................ ៥០ ដុល្លារ
. ឧបាសក **តែ មេងលី** និងឧបាសិកា **លិម សួងអ៊ីម** ...................... ៥០ ដុល្លារ
. អ្នកស្រី **ហ៊ុន មរណី** ................................................................ ៥០ ដុល្លារ
. អ្នកស្រី **ជួប ស៊ីមន** ................................................................ ៥០ ដុល្លារ
. ឧបាសិកា **ប្លែក អ៊ាម** ................................................................ ៥០ ដុល្លារ
. លោក **លិម ភិរុន** និងអ្នកស្រី **ចាន់ សុគន្ធារី** ព្រមទាំងបុត្រ ............ ៥០ ដុល្លារ
. ឧបាសក **អ៊ូ សុផុន** និងឧបាសិកា **អ៊ូ សុខន** ............................... ៥០ ដុល្លារ
. លោក **ស៊ន់ គេង** និងអ្នកស្រី **ស៊ិត ស៊ុយ** .................................. ៤០ ដុល្លារ
. ឧបាសិកា **ស៊ីវ គិមសឺន** ............................................................ ៤០ ដុល្លារ
. អ្នកស្រី **អ៊ុង ស៊ូណៃ** និងបុត្រ (Kévin) ......................................... ៤០ ដុល្លារ

. ឧបាសក **ហ៊ីន ហេង** និងឧបាសិកា **ឆាង ម៉ែ** ................................ ៤០ ដុល្លារ
. លោក **ឃួត គិមគាវ** និងអ្នកស្រី **តិច ស៊ីន្ធួន** ......................... ៤០ ដុល្លារ
. អ្នកស្រី **គ្រុយ គីមដា** ................................................................. ៤០ ដុល្លារ
. ឧបាសក **ឈិន ធុន** និងឧបាសិកា **ខត្យ មួយ** ............................. ៤០ ដុល្លារ
. ឧបាសិកា **តែ ធឹងអ៊ី** ..................................................................... ៤០ ដុល្លារ
. លោក **ភី គីឡាំ** និងអ្នកស្រី **តាន់ វ៉ាន់នី** ............................. ៤០ ដុល្លារ
. ឧបាសក **ស្រី អូន** និងឧបាសិកា **ខែ៉ត សុខុខម** ព្រមទាំងបុត្រ ......... ៤០ ដុល្លារ
. លោកយាយ **អៀង ឡេងជុន** ............................................................. ៣៥ ដុល្លារ
. ឧបាសក **ស្រី សារិន** និងឧបាសិកា **តូ អេងលី** ............................. ៣០ ដុល្លារ
. ឧបាសក **ហ៊ិម ឆាន់** និងឧបាសិកា **សាមិត សុភ័ណ** ....................... ៣០ ដុល្លារ
. ឧបាសិកា **ហេង គិមធី** .................................................................. ៣០ ដុល្លារ
. ឧបាសិកា **លី ហៃស៊ីម** .................................................................. ៣០ ដុល្លារ
. លោក **អ៊ឹង ជីទី** និងអ្នកស្រី ........................................................ ៣០ ដុល្លារ
. ឧបាសិកា **អៀន ទេង** ព្រមទាំងបុត្រ .................................................. ៣០ ដុល្លារ
. ឧបាសិកា **សួរ ហ៊ុច** ...................................................................... ២៥ ដុល្លារ
. ឧបាសក **អ៊ួង ហ៊ាង** និងឧបាសិកា **វ៉ែន យិម** ............................. ២៥ ដុល្លារ
. លោក **សួស ប៉ុណ្ណាវុធ** និងអ្នកស្រី **សិម វិច្ឆិកា** ....................... ២៥ ដុល្លារ
. លោក **ម៉ែន សុផាន់នី** និងគ្រួសារ ...................................................... ២០ ដុល្លារ
. លោក **យិល ណៃត** និងអ្នកស្រី ........................................................ ២០ ដុល្លារ
. ឧបាសក **ស៊ាង ធី** និងឧបាសិកា **អ៊ុន យូឡេង** ............................ ២០ ដុល្លារ
. ឧបាសក **រស់ សុផុន** និងឧបាសិកា **ហ៊ីន ហឿប** ........................... ២០ ដុល្លារ
. ឧបាសិកា **សេង ស៊ីត** .................................................................... ២០ ដុល្លារ
. ឧបាសក **ប៉ែន សារឿន** និងឧបាសិកា **ឈួម ឡាំ** ........................... ២០ ដុល្លារ
. លោក **លី គិមហ៊ុយ** និងអ្នកស្រី ....................................................... ២០ ដុល្លារ
. លោក **ឈុំ ថន** និងអ្នកស្រី **មុយ គាំ** និងបុត្រ ........................... ២០ ដុល្លារ
. លោក **ស៊ឺ នរ៉ា** និងអ្នកស្រី **ឥន្ទ វិសាល** ....................................... ២០ ដុល្លារ
. អ្នកស្រី **ជី ចិន្តាមុនី** ................................................................... ២០ ដុល្លារ
. លោក **ប៉េង ថុងហេង** ..................................................................... ២០ ដុល្លារ
. លោកយាយ **តាំង ហ្គេចឡៀង** .......................................................... ២០ ដុល្លារ

. ឧបាសិកា **សេង សុផានី** ........................................ ២០ ដុល្លារ
. ឧបាសិកា **ម៉ុង ចាន់ថា** ........................................ ២០ ដុល្លារ
. ឧបាសក **តាំង សៀង** ........................................ ៤០ ដុល្លារ
. ឧបាសិកា **សេង ស៊ីត** ........................................ ២០ ដុល្លារ
. ឧបាសិកា **ស៊ុយ ដាលី** ........................................ ២០ ដុល្លារ
. ឧបាសក **ម៉ែន សារ៉ាវ៉េ** និងឧបាសិកា **អ៊ឹម គីមរ៉ុង** .................. ២០ ដុល្លារ
. M. Normand Aubin ........................................ ២០ ដុល្លារ
. M. Chhang Ravann ........................................ ២០ ដុល្លារ
. ឧបាសក **អ៊ុន សឿន** និងឧបាសិកា **អ៊ុន យូសេង** .................. ២០ ដុល្លារ
. ឧបាសិកា **លិម បាក់អៀវ** ........................................ ២០ ដុល្លារ
. ឧបាសិកា **ចាន់ ទ្រី** ........................................ ២០ ដុល្លារ
. ឧបាសិកា **ម៉ែន ផន** ........................................ ២០ ដុល្លារ
. អ្នកស្រី **ម៉ម ស៊ីយ៉ារិន** ........................................ ២០ ដុល្លារ
. ឧបាសិកា **មាយ ឡាញ់** ........................................ ២០ ដុល្លារ
. ឧបាសិកា **ស៊ុយ ដាលី** ........................................ ២០ ដុល្លារ
. លោក **លិម ប៉ាង** ........................................ ២០ ដុល្លារ
. ឧបាសិកា **ហង្ស វណ្ណារី** ........................................ ២០ ដុល្លារ
. ឧបាសិកា **ចឹក វរុន** ........................................ ២០ ដុល្លារ
. ឧបាសក **ផ្លុង ព្រឿន** និងឧបាសិកា **អ៊ុន គិមប៊ន** .................. ២០ ដុល្លារ
. លោក **អ៊ុំ អ៊ន** និងអ្នកស្រី ........................................ ២០ ដុល្លារ
. លោក **មាន សួន** ........................................ ២០ ដុល្លារ
. លោក **ថាយ ចាន់ថា** ........................................ ២០ ដុល្លារ
. ឧបាសិកា **ហៀង ខេង** ........................................ ២០ ដុល្លារ
. ម្តាយដុកទ័រ**អ៊ិត** ........................................ ២០ ដុល្លារ
. ឧបាសិកា **មាស សាវី** ........................................ ២០ ដុល្លារ
. **អានី** ........................................ ២០ ដុល្លារ
. លោក **ឆែម ព្រិច** និងគ្រួសារ ........................................ ២០ ដុល្លារ
. ឧបាសិកា **សឹន សារីបុប្ផាស៊ី** ........................................ ២០ ដុល្លារ
. លោក **គុណា ហេង** ព្រមទាំងកូនចៅ ........................................ ២០ ដុល្លារ

. ឧបាសិកា **ម៉ុន** និងឧបាសក **ឡុង** ........................................ ២០ ដុល្លារ
. លោក **សាំង ហួរ** និងភរិយា ........................................ ២០ ដុល្លារ
. លោក **ថៃ ឃុនហៃ** និងអ្នកស្រី **សិម ចាន់ធូរ៉ា** ព្រមទាំងបុត្រ .... ២០ ដុល្លារ
. ឧបាសក **ឈិត ឈាង** និងគ្រួសារ ........................................ ១៥ ដុល្លារ
. លោក **វិបុល សុខា យៀន** ........................................ ១៥ ដុល្លារ
. អ្នកស្រី **លី វត** ........................................ ១០ ដុល្លារ
. ឧបាសក **ចាន់ អឿន** និងឧបាសិកា **សឿ សុខុម** ........................................ ១០ ដុល្លារ
. លោក **ចឹម រឹមរ៉ុម** និងអ្នកស្រី **ឱក ចន្ទក្រិស្នា** ........................................ ១០ ដុល្លារ
. អ្នកស្រី **សិម ចាន់នី** ព្រមទាំងបុត្រ ........................................ ១០ ដុល្លារ
. កញ្ញា **ផាវ ហ្សូលីយ៉ា** Phao Julia ........................................ ១០ ដុល្លារ
. អ្នកស្រី **ឱក ផ្កាបូរី** ........................................ ១០ ដុល្លារ
. អ្នកស្រី **ប៉ាន់ នរិន្ទឌី** ........................................ ១០ ដុល្លារ
. លោកយាយ **វិច គិន** ........................................ ១០ ដុល្លារ
. អ្នកស្រី **ឈួន វាសនា** ........................................ ១០ ដុល្លារ
. បង **ឡា** ........................................ ១០ ដុល្លារ
. ឧបាសិកា **ពេញ** ........................................ ១០ ដុល្លារ
. ឧបាសិកា **ហ៊ាង** ........................................ ១០ ដុល្លារ
. អ្នកស្រី **ឈួន ធីតា** ........................................ ១០ ដុល្លារ
. ឧបាសិកា **ឌី ភាយ៉ាន** ........................................ ១០ ដុល្លារ
. លោក **អ៊ុក ចាប** និងអ្នកស្រី **ហ៊ុន ផលរ័ត្ន** ........................................ ១០ ដុល្លារ
. ឧបាសិកា **យ៉ង់ បុរី** និងកូនចៅ ........................................ ១០ ដុល្លារ
. ឧបាសិកា **ខាំផូ ណាយ** និងគ្រួសារ ........................................ ១០ ដុល្លារ
. ឧបាសិកា **ហាឡៃ វណ្ណារី** ........................................ ១០ ដុល្លារ
. ឧបាសិកា **ចាន់ ទ្រី** ........................................ ១០ ដុល្លារ
. លោក **អ៊ុត សុខា** ........................................ ១០ ដុល្លារ
. ឧបាសិកា **ភឿក វណ្ណៈ** និងគ្រួសារ ........................................ ១០ ដុល្លារ
. ឧបាសិកា **នាង ខេង** ព្រមទាំងបុត្រ ........................................ ១០ ដុល្លារ
. ឧបាសិកា **ហាម សុវណ្ណា** ព្រមទាំងបុត្រ ........................................ ១០ ដុល្លារ
. ឧបាសិកា **សៀង ម៉ៃ** ........................................ ១០ ដុល្លារ
. ឧបាសិកា **មេង គិមណាំ** ........................................ ១០ ដុល្លារ

. លោក **យ៉ង់ ម៉ិច** និងអ្នកស្រី **ហែម សាឡុន** ................................ ១០ ដុល្លារ
. ឧបាសក **ស្វរ ស៊ីម** .............................................................. ១០ ដុល្លារ
. ឧបាសិកា **ស សុឆេង** និងគ្រួសារ ................................................ ១០ ដុល្លារ
. ឧបាសិកា **មេឃសុវណ្ណា ស៊ីលួនថង** ............................................. ១០ ដុល្លារ
. លោក **លី សុជាតិ** និងអ្នកស្រី **ខង្សេ ដាលី** ................................. ១០ ដុល្លារ
. អ្នកស្រី **ព្រុំ មុនី** ......................................................................... ៥ ដុល្លារ
. អ្នកស្រី **យិន សារ៉ុម** .................................................................... ៥ ដុល្លារ
. ឧបាសិកា **ឈីវ ហៀក** ..................................................................... ៥ ដុល្លារ
. ឧបាសិកា **សម្បត្តិ** ........................................................................... ៥ ដុល្លារ
. ឧបាសិកា **យូ យៀង** ....................................................................... ៥ ដុល្លារ
. កុមារី **សាប ភានីកា** ...................................................................... ៥ ដុល្លារ
. កុមារី **សាប លីស្សា** ....................................................................... ៥ ដុល្លារ
. អ្នកស្រី **ជា ដាដាណេ** ...................................................................... ៥ ដុល្លារ
. ឧបាសិកា **ប៊ី គិមឡាយ** .................................................................... ៥ ដុល្លារ
. ឧបាសក **ស៊ុន លី** ............................................................................ ៥ ដុល្លារ
. ឧបាសិកា **លឿង** .............................................................................. ៥ ដុល្លារ
. ឧបាសិកា **កែ** ................................................................................... ៥ ដុល្លារ
. ឧបាសិកា **តាំង មួយផាង** .................................................................. ៥ ដុល្លារ
. លោក **គុន លី** ................................................................................ ៥ ដុល្លារ
. បង **រិត** .......................................................................................... ៥ ដុល្លារ
. លោក **សី សាម៉ន** និងគ្រួសារ .......................................................... ៥ ដុល្លារ
. អ្នកស្រី **ម៉ារីយ៉ាន** ........................................................................... ៥ ដុល្លារ
. ឧបាសិកា **ទូច គ្រី** និងគ្រួសារ ........................................................... ៥ ដុល្លារ
. ឧបាសិកា **យៀង** .............................................................................. ២ ដុល្លារ

## * *ពុទ្ធបរិស័ទនៅប្រទេសផ្សេងៗ*

. ឧបាសក **អ៊ុំច ណាត** និងឧបាសិកា **អ៊ុំច គឹមលាត** - **USA** ...... ៧៥ ដុល្លារ US
. ឧបាសិកា **ជា ស៊ុយហ៊ាង** និងឧបាសិកា **អ៊ាវ ហាក់លេង** - **USA** ១០០ដុល្លារ US

. អ្នកស្រី **អ៊ុច សុជាលីន** (Germany) .................................................. ១០០ €
. លោក **សិម ទី** និងអ្នកស្រី **សិម ចិន្តា** ព្រមទាំងបុត្រ (France) ..... ៥០ ដុល្លារ
. ឧបាសក **លឹម ជុំខអេង** និងឧបាសិកា **ជួង សីហា** (Cambodia) ១០០ ដុល្លារ US
. ឧបាសិកា **ម៉ែន នារីឧត្តរី** និងស្វាមីព្រមទាំងកូនចៅ (Cambodia) . ១០០ ដុល្លារ CA
. កញ្ញា **លឹម សុខលៀង** (Cambodia) .................................... ៥០ ដុល្លារ US
. អ្នកស្រី **ហួត ណារី** (Cambodia) ....................................... ៥០ ដុល្លារ US
. ឧបាសិកា **ចេង សាយចិម** និងអ្នកស្រី **ស៊ឺន ម៉ុនរ័ត្ន** (Cambodia)
ព្រមទាំងគ្រួសារនិងបុត្រ .......................................... ៥០ ដុល្លារ US
. អ្នកស្រី **ស៊ុន ហ៊ី** និងស្វាមី (Cambodia) ................................ ៣០ ដុល្លារ US
. អ្នកស្រី Nuphea Zenith (Cambodia) ................................ ៣០ ដុល្លារ US
. អ្នកស្រី **ឡូន សុវិរិយ៍** (Cambodia) ................................. ៣០ ដុល្លារ US
.ឧបាសិកា **អ៊ុង ខ៉ែតនិងឧបាសក ធឹម ហុន**(Cambodia) ............. ២០ ដុល្លារ US
. អ្នកស្រី **ណៅ សុគន្ធ** និងស្វាមីព្រមទាំងបុត្រ (Cambodia) ......... ២០ ដុល្លារ US
. លោក **សារុំម សុទ្ធិ** និងអ្នកស្រីព្រមទាំងបុត្រ (Cambodia) .......... ២០ ដុល្លារ US
. លោក Nao Rithy និងអ្នកស្រី (Cambodia) ....................... ២០ ដុល្លារ US
. លោក **សែម ពិសិដ្ឋ** និងអ្នកស្រី **គ្រឿន មុន្នា** (Cambodia) .... ១០ ដុល្លារ US
. លោក **ម៉ប់ ធីរិទ្ធ** និងអ្នកស្រី **ថាំង សុភា** (Cambodia) ........ ១០ ដុល្លារ US
. អ្នកស្រី **ធឹម អរុណី** (Cambodia) ........................................ ១០ ដុល្លារ US
. លោក **ឈើន គាន** និងអ្នកស្រី **ហ៊ិម ឆេង** (Cambodia) .......... ១០ ដុល្លារ US
. ឧបាសិកា **ថាំង សុខហៀង** និងស្វាមីព្រមទាំងបុត្រ (Cambodia) ..... ១០ ដុល្លារ US
. អ្នកស្រី **ធឹម នីរ័ត្ន**និងស្វាមី (Cambodia) .................................. ១០ ដុល្លារ US
. អ្នកស្រី **ធឹម នីរីម**(Ababa Nirim Lotus)និងស្វាមី(Cambodia) ... ១០ ដុល្លារ US
. កញ្ញា **ពៅ ពន្លឺពណ៌** (Cambodia) ....................................... ៥ ដុល្លារ US

***សូមពុទ្ធបរិស័ទដែលបានចូលរួមបោះពុម្ពសៀវភៅ***
***ជាធម្មទាន បានសម្រេចនូវសម្មាទិដ្ឋិគ្រប់ៗជាតិ***
***និងបានឧបនិស្ស័យរួចផុតចាកទុក្ខទាំងពួង***
***កុំបីឃ្លៀងឃ្លាតឡើយ !***

**សូមអនុមោទនាធម្មទាន** !!!

**គេហដ្ឋាន**
**អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ**
ក្រុងម៉ុងរេអាល - កេបិក - កាណាដា

## ❖ សៀវភៅដែលផ្សព្វផ្សាយហើយ ៖

១. ស្នាព្រះហស្តក្រោយបង្អស់នៃសម្តេចព្រះមហាសុមេធាធិបតី **ជួន ណាត**
២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្តារ - សង្ខេប
៣. ប្រស្នា គិហិប្រតិបត្តិពិស្តារ ( ឈឹម ទូច, សុង ស៊ីវ )
៤. ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )
៥. អានាបាណស្សតិកម្មដ្ឋាន វិបស្សនាបញ្ញាធម្មបរិយាយ ( គង់ ឌឹប )
៦. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, ភិក្ខុ សាន សុជា )
៧. ជីវិតកថា ( ម៉ិញ សាវ៉ាន ) ថ្មី
៨. ធម្មប្រទីប ( ប្រជុំកងធម៌ យិន វន់ )
៩. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )
១០. រឿង នគរកាយ ( ចាប ពិន )
១១. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )
១២. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )
១៣. ត្រៃកូដធម៌ ( សុង ស៊ីវ )
១៤. ឱវាទបាតិមោក្ខ ( ចាប ពិន )
១៥. កម្រងកំណាព្យ ( ហ៊ុម ឆាន់ ) ថ្មី
១៦. ឧបនីយតិសូត្រ ( ព្រះមហាវិរិយបណ្ឌិតោ ប៉ាង ខាត់ )
១៧. ធម្មទ្វេស ៤ យ៉ាង ( ម៉ិញ សាវ៉ាន ) ថ្មី

១៨. ធម៌នមស្ការសង្ខេបសម្រាប់យុវវ័យ Khmère-Français ( វ៉ាត ភិរក្ស ) ថ្មី
១៩. ធម៌នមស្ការសង្ខេបសម្រាប់យុវវ័យ Khmère-Anglais ( វ៉ាត ភិរក្ស ) ថ្មី
២០. លោកនីតិបករណ៍ ( អ៊ុក ជា )
២១. មង្គលសូត្រ ៣៨ ប្រការ ( ព្រះវិន័យធរអនុគណ ឯក ញឹម ធម្មិស្សរោ )
២២. កម្រងកំណាព្យ ភាគ ២ ( ហ៊ិម ឆាន់ ) ថ្មី
២៣. ព្រះបាទឡាត់ឃោសនាគ ហែម ចៀវ វីរបុរស ( គង់ សម្ការ )
២៤. ចំណងដៃឆ្នាំថ្មី ( ម៉ិញ សាវ៉ាន ) ថ្មី
២៥. ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាសង្ខេប (សម្តេចព្រះពោធិវ័ង្ស ហួត តាត)
២៦. ឱវាទ ៤ «ខ» របស់លោក **លៀម ហ្វាន**(បកប្រែដោយលោកយាយ ចំរើន ចារុន)
២៧. គុណមាតាបិតា ( ម៉ិញ សាវ៉ាន ) ថ្មី
២៨. ទស្សនៈសម្តេចព្រះសង្ឃរាជ ជួន ណាត (គង់ សម្ការ )
២៩. អភិធម្មបរមត្ថសង្ខេប (ព្រះគ្រូ. យ៉ាង ផាន់ និង ព្រះមហា. អ៊ុម ប៉ុណ្ណ)
៣០. កម្រងកំណាព្យ ភាគទី ៣( ហ៊ិម ឆាន់ ) ថ្មី
៣១. រឿង ព្រះភិក្ខុពនេចរ ភាគ ២ ( ធម្មឃោស - ចំរើន ចារុន )
៣២. អ្នករូតរាំងនននសង្គម ( បណ្ឌិត កែម ឡី )

## ❖ ថាស CD, DVD, MP3 ដែលផ្សព្វផ្សាយហើយ ៖

១. ព្រះត្រៃបិដក ភាគទី ១ ដល់ភាគទី ១១០ ( PDF )
២. ព្រះវិន័យបិដក ភាគទី ១ ដល់ភាគទី ១៣ ( MP3 )
៣. ព្រះសុត្តន្តបិដក ភាគទី ១៤ ដល់ភាគទី ៣៧ ( MP3 )
៤. ព្រះសុត្តន្តបិដក ភាគទី ៣៨ ដល់ភាគទី ៦២ ( MP3 )
៥. ព្រះគុណម៉ែ ( MP3 )
៦. ព្រះភិក្ខុពនេចរ ( MP3 )
៧. វិធីសាស្ត្រចំរើនអានាបាណស្សតិកម្មដ្ឋាន ( MP3 )
៨. ព្រះពុទ្ធដីកា ( MP3 )
៩. ព្រះសុត្តន្តបិដក ភាគទី ៦៣ ដល់ភាគទី ៧៧ ( MP3 )
១០. អាមិសទាន និង ធម្មទាន ( MP3 )
១១. ៤៨ ធម្មទស្សន៍ ព្រះពុទ្ធសាសនា (ខ្លឹមសារគួរយល់ដឹង) ( MP3 )
១២. ព្រះអភិធម្ម ភាគទី ៧៨ ដល់ភាគទី ១១០ ( MP3 )

១៣. ប្រវត្តិមហាឧបាសិកា **វិសាខា** ( DVD )
១៤. ព្រះវេស្សន្តជាតក ( DVD )
១៥. ទុក្ខសច្ចៈ( DVD ) ៖ ភិក្ខុ **នៅ សាខន**
១៦. សមថវិបស្សនា (MP3) វគ្គទី ១ និងវគ្គទី ២ : មហាវិមលធម្ម **ពិន សែម**
១៧. ភាពយន្តឯកសារ ( DVD ) Angkor Land Of The Gods
១៨. វិធីសាស្ត្រចំរើនអាការៈ ៣២ (MP3) ព្រះមហាវិមលធម្ម **ពិន សែម**
១៩. ព្រះធម្មទេសនានានា (MP3) ព្រះភិក្ខុ **ធឹង ធីម ចន្ទត្ថេរ**
២០. កំណាព្យរូបភាព ភាគទី ១ ( DVD ) ៖ **ហ៊ិម ឆាន់**
២១. ព្រះធម្មទេសនា១០ ថ្ងៃ ( MP3 ) ជាភាសាខ្មែរ និងភាសាបារាំង ៖ លោកអាចារ្យប្រមុខ GOENKA
២២. សម្លេងកំណាព្យរូបភាព ភាគទី២ (DVD)៖ ភិក្ខុវណ្ណគុត្តោ **ស្វាត សារឿម** និង **ហ៊ិម ឆាន់**
២៣. ឱវាទ ៤ «ខ» របស់លោក លៀវ ហ្វាន ៖ **ហ៊ិម ឆាន់**
២៤. សម្លេងព្រះអដ្ឋកថា
២៥. កំណាព្យរូបភាព ភាគទី ៣, ៤, ៥
២៦. គុណមាតាបិតា
២៧. ព្រះភិក្ខុពនេចរ ភាគ ២ ( MP3 )
២៨. សំនៀងកេរ សំណេរខ្ញុំ

សូមប្រគេន និងជំរាប ដល់ព្រះតេជព្រះគុណព្រមទាំងបងប្អូនពុទ្ធបរិស័ទជាសទ្ធាសម្បន្ន និងសទ្ធាសម្បន្នាទាំងអស់ដែលចង់អាន ឬចង់ស្តាប់នូវព្រះធម៌ណាមួយ ឬក៏មានសទ្ធាជ្រះថ្លាចូលរួមក្នុងការបោះពុម្ពសៀវភៅ និងធ្វើ CD DVD MP3 សម្រាប់ចែកជាធម្មទាន សូមនិមន្ត និងអញ្ជើញទំនាក់ទំនងតាមរយៈ ៖

**គេហដ្ឋាន**
**អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ**
ក្រុងម៉ុងរេអាល - កេបិក - កាណាដា

គេហដ្ឋាន **អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ**

---

- ឧបាសក **ម៉ិញ សាវ៉ាន** ៥១៤ - ៧៣៥ - ៥៩៧៥
- ឧបាសក **ហ៊ិម ឆាន់** ៥១៤ - ២៧៧ - ៤១២៩
  ( chhann@live.ca )
- ឧបាសក **វ៉ាត ភិរក្ស** ៥១៤ - ៥០៩ - ៥០២៥
  ( phireak.vat@gmail.com )

ម្យ៉ាងទៀតសៀវភៅចាស់ៗ ដែលបានចម្លងថ្មី មានចុះផ្សាយនៅក្នុង

https://www.facebook.com/groups/KhmerBuddhistBookClub

និង http://www.5000-years.org ផងដែរ ។

សូមអស់លោកពុទ្ធបរិស័ទអញ្ជើញអានដោយមេត្រី...